ទស្សនាវដ្តី

# វិទ្យាស្ថានភាសាជាតិ

នៃរាជបណ្ឌិត្យសភាកម្ពុជា

Journal of Institute of National Language

Royal Academy of Cambodia

ឆ្នាំទី១៧ លេខ១០
ខែមាឃ ឆ្នាំរកា នព្វស័ក
ព.ស.២៥៦១

Vol. 17 No. 10,
January 2018

មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ 12406

ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ : ឆ្នាំទី១៧ លេខ១០ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
Journal of Institute of National Language: Vol.17 No.10 January 2018

ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិគឺជាផ្នែកមួយនៃការផ្សព្វផ្សាយរបស់វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជាក្នុងការលើកកម្ពស់ការសិក្សាស្រាវជ្រាវភាសានិងអក្សរសាស្ត្រ ខ្មែរឱ្យមានលក្ខណៈស្តង់ដានិងឈានទៅរកការរីកចម្រើនដូចអរិយភាសាក្នុងលោក។

**និពន្ធនាយក**
បណ្ឌិត **ជួរ គារី**

**និពន្ធនាយករង**
បណ្ឌិត **ខឿង មេង**

**ក្រុមការងារ**
មន្ត្រីវិទ្យាស្ថានភាសាជាតិ

**ទំនាក់ទំនងទូទៅ**
លោក **ផង់ គិរុណា**
លោកស្រីបណ្ឌិត **គាដ ណាង**
លោក **កែវ លីណែត**
លោកស្រី **អ៊ឹង ម៉ាល័យ**

**ទីប្រឹក្សាបច្ចេកទេស**
បណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់**
បណ្ឌិតសភាចារ្យ **ច័ន្ទ សំណព្វ**
បណ្ឌិតសភាចារ្យ **ខ្លូត ធីតា**
បណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន**
បណ្ឌិតសភាចារ្យ **សោម សុមុនី**

**ទីប្រឹក្សារដ្ឋបាល**
ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច**
ឯកឧត្តមបណ្ឌិត **យង់ ពៅ**
ឯកឧត្តម **លី សុធីរ័ត្ន**
ឯកឧត្តមបណ្ឌិត **ជូ ច័ន្ទដារី**
បណ្ឌិត **សន ពៅ**

**រចនានិងរៀបចំទំព័រ**
បណ្ឌិត **ជុំ ស៊ុនណាង**

ព័ត៌មានទស្សនាវដ្ដី
វិទ្យាស្ថានភាសាជាតិ, ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ ឆ្នាំទី១៧ លេខ១០, ខែមករា គ.ស.២០១៨, ភ្នំពេញ : រាជបណ្ឌិត្យសភាកម្ពុជា។

ចេញផ្សាយដោយ : វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា
អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
: ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ 12406
អ៊ីមែល : inlrac.languages@gmail.com
ទូរសព្ទ : ០១១ ៧១៧ ០១១

មាតិកា
ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ : ឆ្នាំទី១៧ លេខ១០ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
Journal of Institute of National Language: Vol.17 No.10 January 2018

ទំព័រ

អារម្ភកថា ..... ក
ជីវប្រវត្តិសង្ខេបរបស់បណ្ឌិត នៅ ស៊ុន ..... គ
សេចក្ដីផ្ដើម
បណ្ឌិត វង្ស មេង ..... ១
វិធីកម្លាយក្នុងភាសាខ្មែរ : បញ្ហាកង្វះផ្នត់សម្រាប់ធ្វើវិធីកម្លាយឱ្យមានសម្បូរណ៍បែប, បញ្ហាវិសាលភាពតូចចង្អៀតនៃផ្នត់មួយចំនួន និង បញ្ហាសទិសសូរវេយ្យាករណ៍វិស័យ
បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ ..... ៣
អន្តេបទ/-អំម.ណា-/ឬ/-អ៊ំម.ន-/
បណ្ឌិត វង្ស មេង ..... ១៤
កម្រងគំនិតគួរពិចារណា
លោក គុយ រិន (ស្រង់ពីបណ្ដាញសង្គម) ..... ៣៤
វិភាគសំណេរ ណ និង ន ក្នុងភាសាខ្មែរទំនើប
លោក ឡុង ធវង្ស ..... ៣៩
ពិចារណាអំពីលទ្ធភាពភាសាខ្មែរ
បណ្ឌិត ជុំ ស៊ុនណាង ..... ៦៨
ន័យ អត្ថន័យ បំណកស្រាយន័យក្នុងទិដ្ឋភាពអក្សរសាស្ត្រនូវសុភាសិតបុរាណខ្មែរ «កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប»
បណ្ឌិត ជួរ គារី ..... ៨១
ការគ្រប់គ្រងដីធ្លីនៅប្រទេសកម្ពុជាសម័យបុរាណ
លោក កែវ លីណែត ..... ៨៧
លោកគ្រូ នៅ ស៊ុន និងជីវិតសិល្បៈ
លោក ផង់ ភិរុណ ..... ១១៣
ស្ដាយបញ្ញវន្តខេត្តយើង (បទពាក្យ៧)
លោក សេស សារ៉ាត់ ..... ១១៧
បាត់ដំបងបណ្ដូលចិត្ត (បទកាកគតិ)
លោក អ៊ឹម គួយ ..... ១២០

# អារម្ភកថា

គំនិតទស្សនៈរបស់អ្នកសិក្សាស្រាវជ្រាវដែលទើបរកឃើញថ្មីគឺសុទ្ធតែមានសារៈសំខាន់នៅក្នុងការរួមចំណែកអភិវឌ្ឍសង្គមជាតិផ្នែកបញ្ញាញាណ។ ថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានភាសាជាតិ(វ.ភ.ជ.) នៃរាជបណ្ឌិត្យសភាកម្ពុជាក៏បានខិតខំសិក្សាស្រាវជ្រាវ វិភាគ ប្រមូលចងក្រងជាឯកសារមួយចំនួនដែលចុះផ្សាយតាមរយៈទស្សនាវដ្ដីរបស់ខ្លួនចំនួន១០លេខនិងលេខពិសេសចំនួន០១លេខរួចមកហើយ។

ពិសេសជាងលេខមុនៗ ទស្សនាវដ្ដីលេខ១១នេះ គឺជាអត្ថបទសិក្សាស្រាវជ្រាវវិភាគទាក់ទងទៅនឹងភាសានិងអក្សរសាស្ត្រ ដើម្បីចូលរួមបុណ្យគម្រប់ខួប១០០ថ្ងៃនៃសពបណ្ឌិត នៅ ស៊ុន ដែលបានទទួលមរណភាពកាលពីថ្ងៃព្រហស្បតិ៍ ទី១៩ ខែតុលា ឆ្នាំ២០១៧កន្លងទៅ។ ថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានភាសាជាតិនិងក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជា រួមជាមួយនឹងបណ្ឌិតសភាចារ្យ បណ្ឌិត សាស្ត្រាចារ្យ និស្សិត ដែលជាមិត្តភក្ដិ សហសេវិក សហការី សិស្សគណរបស់បណ្ឌិត នៅ ស៊ុន ទាំងអស់ ចូលរួមសរសេរអត្ថបទដើម្បីសម្ដែងនូវសមានចិត្តស្ដាយស្រណោះ អាឡោះអាល័យ និង គោរពចំពោះវិញ្ញាណក្ខន្ធរបស់លោកបណ្ឌិតនៅក្នុងពិធីបុណ្យ គម្រប់ខួប១០០ថ្ងៃដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨នេះ។

ទស្សនាវដ្ដីចុះផ្សាយនៅឆ្នាំទី១៧ លេខ១១ ឆ្នាំ២០១៨នេះ មានអត្ថបទចម្រុះ ដែលក្នុងនោះមានអត្ថបទវិភាគ បែបភាសាវិទ្យានិងអក្សរសាស្ត្រ, អត្ថបទមួយចំនួនរបស់លោកបណ្ឌិត នៅ ស៊ុន ដែលលោកបានសរសេរបង្ហោះតាមបណ្ដាញសង្គមឬហ្វេសប៊ុក ហើយត្រូវបានសិស្សគណលោកស្រាវជ្រាវប្រមូលមកចុះផ្សាយនិងអត្ថបទកំណាព្យរបស់សហការី សិស្សគណរបស់លោកនិពន្ធសម្ដែងនូវមនោសញ្ចេតនារបស់ខ្លួនដែលមានចំពោះលោក បណ្ឌិត។ល។

គណៈកម្មការទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា នឹងទទួលចុះផ្សាយនូវរាល់អត្ថបទរបស់អ្នកស្រាវជ្រាវទាំងឡាយដែលមានគោលបំណងអភិរក្សនិងអភិវឌ្ឍភាសានិងអក្សរខ្មែរ ដើម្បីធ្វើយ៉ាងណាឱ្យភាសានិងអក្សរសាស្ត្រជាតិរបស់យើងមានឯកភាពនិងរីកចម្រើនជឿនលឿនដូចអរិយភាសាក្នុងលោកដែរ។

ក្នុងឱកាសនេះផងដែរ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាជាកូនចៅ ចៅទួត ជាថ្នាក់ដឹកនាំ មន្ត្រីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា សូមក្រាបថ្វាយបង្គំឧទ្ទិសស្នាដៃនេះថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រខ្មែរគ្រប់ជំនាន់ និង ព្រះវិញ្ញាណក្ខន្ធព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ ព្រះវិញ្ញាណក្ខន្ធអតីតព្រះសង្ឃរាជនិងព្រះសង្ឃស្នេហាជាតិនិងអក្សរសាស្ត្រខ្មែរគ្រប់ជំនាន់។

យើងខ្ញុំទាំងអស់គ្នាដែលជា មិត្តភក្តិ ថ្នាក់ដឹកនាំ និង មន្ត្រី វ.ភ.ជ. ទាំងអស់ក៏សូមឧទ្ទិសទស្សនាវដ្ដី លេខ១១នេះ ជូនចំពោះវិញ្ញាណក្ខន្ធឯកឧត្តមបណ្ឌិតសភាចារ្យ **ឡុង សៀម**, ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុំ ច័ន** ឯកឧត្តមបណ្ឌិត **នៅ ស៊ុន** ជាពិសេស និង វរជនអក្សរសាស្ត្រជាតិដទៃទៀត ដែលមានគុណបំណាច់ក្នុងការលើកស្ទួយភាសានិងវប្បធម៌ជាតិខ្មែរឱ្យគង់វង្សរៀងរហូតមក។

សូមឱ្យព្រះវិញ្ញាណក្ខន្ធ ព្រះមហាវីរក្សត្រ សម្ដេចព្រះសង្ឃរាជ ព្រះសង្ឃគ្រប់ព្រះអង្គ និង វិញ្ញាណក្ខន្ធ កវីនិពន្ធខ្មែរគ្រប់ជំនាន់និងសម័យកាលទាំងអស់ ឆ្ពោះទៅសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូមវិញ្ញាណក្ខន្ធឯកឧត្តមបណ្ឌិតសភាចារ្យ **ឡុង សៀម**, ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុំ ច័ន** និង ឯកឧត្តមបណ្ឌិត **នៅ ស៊ុន** ឆ្ពោះទៅសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

**និពន្ធនាយក**
បណ្ឌិត **ជួរ គារី**

# ជីវប្រវត្តិសង្ខេបរបស់លោកបណ្ឌិត នៅ ស៊ុន

មន្ត្រីវិទ្យាស្ថានភាសាជាតិ



**ក- ព័ត៌មានផ្ទាល់ខ្លួន**

- នាមត្រកូលនិងនាមខ្លួន នៅ ស៊ុន អក្សរពុម្ពឡាតាំង NEOU SUN ភេទ ប្រុស
- កើតថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៥៤ សញ្ជាតិ ខ្មែរ នៅភូមិវាលប្រីយ៍ ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ។

**ខ- ព័ត៌មានគ្រួសារ**

រៀបការរួច មានកូន២នាក់។

**គ- អាសយដ្ឋានបច្ចុប្បន្ន**

ភូមិវាលប្រីយ៍ ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ។

**ឃ- ភាសាបរទេស**

បារាំង អង់គ្លេស រុស្ស៊ី

**ង- ប្រវត្តិនៃការសិក្សា**

១- សាលាបឋមសិក្សាអង្គសិង្ហ

២- អនុវិទ្យាល័យចំបក់ សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (១៩៦៩)

៣- វិទ្យាល័យជម្ពូវ័ន មធ្យមសិក្សាបត្រភាគ១ (១៩៧១)

៤- វិទ្យាល័យតាខ្មៅ មធ្យមសិក្សាបត្រភាគ២ (១៩៧២)

៥- មហាវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច (ផ្នែកតុលាការ) នៃសកលវិទ្យាល័យភ្នំពេញ (១៩៧៣-១៩៧៥)

៦- សកលវិទ្យាល័យរដ្ឋស៊ីមហ្វេរ៉ូប៉ូល សាធារណរដ្ឋអ៊ុយក្រែន (១៩៨១-១៩៨៦) សញ្ញាបត្រ Master of Arts en Philologie។

៧- វិទ្យាស្ថានបូព៌ាសាស្ត្រនៃបណ្ឌិត្យសភាវិទ្យាសាស្ត្រសហព័ន្ធរុស្ស៊ី (១៩៨៩-១៩៩២) សញ្ញាបត្រ Doctor of Philosophy (Ph.D) in Philology)។

**ច- ប្រវត្តិការងារ**

- ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ។
- ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៨៦ ដល់ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៤ បម្រើការនៅនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្រសួងអប់រំ។
- ខែកញ្ញា ឆ្នាំ២០១១ ជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ។
- ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ អនុប្រធានប្រចាំការនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ។
- ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ ត្រូវបានតែងតាំងជា សមាជិកបម្រុងនៃរាជបណ្ឌិត្យសភាកម្ពុជា។

**ឆ- ស្នាដៃស្រាវជ្រាវនិងនិពន្ធ**

១- ទីតាំងភាសាខ្មែរក្នុងចំណោមភាសាអ៊ីសូឡង់និងមិនមែនអ៊ីសូឡង់ (សៀវភៅខេមរវិទ្យាបោះពុម្ពផ្សាយដោយរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០២)

២- តើព្យាង្គក្នុងភាសាខ្មែរមានទម្រង់«ស»និង«សព»ឬទេ ? បាឋកថានៅរាជបណ្ឌិត្យសភា (២០០៨)

៣- ដំណើរការកម្លាយពាក្យខ្មែរមួយចំនួន បាឋកថា នៅរាជបណ្ឌិត្យសភាកម្ពុជា (២០០៩)

៤- វេយ្យាករណ៍ខ្មែរសម្រាប់មធ្យមសិក្សា(២០១៣) បោះពុម្ពដោយគ្រឹះស្ថានបោះពុម្ពផ្សាយរបស់ក្រសួងអប់រំ យុវជន និង កីឡា

៥- សទ្ទានុក្រមបឋមសិក្សាភាគ១ រៀបចំបោះពុម្ពដោយគ្រឹះស្ថានបោះពុម្ពផ្សាយរបស់ក្រសួងអប់រំ (២០១៦)

៦- ពាក្យមាន«រ»រៀបចំបោះពុម្ពដោយគ្រឹះស្ថានបោះផ្សាយរបស់ក្រសួងអប់រំ(២០១៦)

៧- ពាក្យងាយច្រឡំរៀបចំបោះពុម្ពដោយគ្រឹះស្ថានបោះផ្សាយរបស់ក្រសួងអប់រំ(២០១៦)

៨- អំបូរភាសានិងនានាភាពនៃភាសា(សំណៅដៃ)

៩- សញ្ញាណទូទៅនៃសូរវិទ្យានិងសទ្ទតាវិទ្យា(សំណៅដៃ)

១០- សូរវិទ្យាខ្មែរនិងបញ្ហា (សំណៅដៃ)

១១- លក្ខណៈភាសាខ្មែរ(សំណៅដៃ)

**ជ-ការលើកសរសើរ ជូនរង្វាន់ និងផ្ដល់គ្រឿងឥស្សរិយយស**

មេដាយការងារ(ប្រាក់)

## ឈ- អវសាននៃជីវិត

ព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូនៃយើង បានសម្ដែងថា ជីវិតសត្វលោកមិនទៀងទាត់ឡើយ មិនដឹងវេលាណាដែលត្រូវស្លាប់នោះទេ យ៉ាងណាមិញ លោកបណ្ឌិត **នៅ ស៊ុន** ក៏ដូច្នោះដែរ នៅថ្ងៃព្រហស្បតិ៍ ទី១៩ ខែតុលា ឆ្នាំ២០១៧ តាំងពេលព្រឹកម៉ោង៨ ដល់វេលាថ្ងៃត្រង់ លោកនៅធ្វើការងារជាមួយពួកយើងនៅឡើយ យើងបែកគ្នានៅម៉ោង១២.៣០ ពេលបរិភោគអាហារថ្ងៃត្រង់។ តែអនិច្ចា សង្ខារមិនទៀង វេលាម៉ោង៥ល្ងាចថ្ងៃដដែល ពួកយើងបានទទួលដំណឹងមរណភាពពីក្រុមគ្រួសាររបស់លោក។

# សេចក្ដីផ្ដើម

ទស្សនាវដ្ដីរបស់វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជានេះ គឺជាទស្សនាវដ្ដីដែលមានអាយុកាលដប់ប្រាំពីរឆ្នាំហើយៗ ទស្សនាវដ្ដីនេះគឺបានបង្កើតឡើងពីស្ថាបនិកបណ្ឌិតសភាចារ្យ ឡុង សៀម និង បណ្ឌិតសភាចារ្យ អ៊ីវ ច័ន។ បច្ចុប្បន្ន បណ្ឌិត ជួរ គារី និងសហសេវិក កំពុងតែបន្តការងារនេះយ៉ាងសកម្ម ដើម្បីឱ្យមាននិរន្តរភាព។ ក្នុងលេខនេះ យើងមានស្នាដៃចំនួន១០ ដោយចែកចេញជាបួនផ្នែក ដូចមានអត្ថាធិប្បាយដូចខាងក្រោម។

ផ្នែកទីមួយ មានបរិយាយអំពីការបង្កើតពាក្យ។ ផ្នែកទីមួយនេះ មានអ្នកនិពន្ធពីររូប ទីមួយ បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ និង បណ្ឌិត វង្ស មេង បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ បានលើកឡើងអំពី«វិធីកម្លាយក្នុងភាសាខ្មែរ» ដោយ បណ្ឌិតសភាចារ្យ បានបង្ហាញបញ្ហាកង្វះផ្នត់សម្រាប់ធ្វើវិធីកម្លាយឱ្យមានសម្បូរណ៍បែប បញ្ហាវិសាលភាពតូចចង្អៀតនិងផ្នត់មួយចំនួន និង បញ្ហាសទិសសូរវេយ្យាករណ៍វិស័យ។ ទាក់ទងនឹងវិធីកម្លាយនេះ បណ្ឌិតសភាចារ្យបានលើកឡើងអំពីបញ្ហាផ្នត់ដែលមានមតិឯកភាពគ្នា និង ផ្នត់ដែលមិនមានមតិឯកភាពក្នុងការបង្កើតពាក្យក្នុងភាសាខ្មែរ។ ជាមួយគ្នានេះផងដែរ លោក បានបង្ហាញផ្នត់មួយចំនួនក្នុងភាសាខ្មែរដែលមានការគ្រួតស៊ីគ្នា មិនត្រឹមតែប៉ុណ្ណោះ អ្នកនិពន្ធបានផ្ដល់ជាយោបល់សម្រាប់ការបង្កើតពាក្យខ្មែរឱ្យមានឯកភាព និង គោរពទៅតាមក្បួនខ្នាត នៃវិធីកម្លាយដែលមានពីមុនមក។ ទន្ទឹមគ្នានេះ បណ្ឌិត វង្ស មេង បានបរិយាយអំពីផ្នត់ដែក/-អំម.ណ-/ឬ/-អ៊ំម.ន-/ ដោយស្នេរ បានលើកឡើងសម្មតិកម្មពីរផ្សេង គ្នាទាក់ទងនឹងផ្នត់នេះ។ សម្មតិកម្មទីមួយ ស្នេរបានលើកឡើងថា ផ្នត់ដែកនេះ មានតាំងពីបុរាណមករហូតមកដល់បច្ចុប្បន្ន។ សម្មតិកម្មទីពីរ ស្នេរបានបង្ហាញថា ផ្នត់ដែក/-អំម.ណ-/ឬ/-អ៊ំម.ន-/គឺជាប្រភេទផ្នត់ដែក ដែលកើតមកអំពីផ្នត់ដែក/-អំម-/ឬ/-ម-/ និងទំនាក់ទំនងរវាងផ្នត់ដែក/-ម-/និង/-ន-/ប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ស្នេរបានបង្ហាញអំពីមុខងារ វេយ្យាករណ៍របស់ផ្នត់ដែក/-អំម.ណ-/ឬ/-អ៊ំម.ន-/ ដោយមាននាមសម្គាល់លទ្ធផល នាមសម្គាល់អំពើ គុណនាម កិរិយាសព្ទ និងនិបាតសព្ទ ក្នុងនោះ ផ្នត់នេះមានទិន្នន័យចំនួន១៥៩ពាក្យ។

ផ្នែកទីពីរទាក់ទងនឹងសូរវិទ្យានិងសទ្ទតាវិទ្យា។ ផ្នែកនេះ យើងឃើញមានស្នេរចំនួនពីររូប ទីមួយ បណ្ឌិត នៅ ស៊ុន ស្រង់ចេញពីបណ្ដាញសង្គមដោយ លោក គុយ រិន និង បណ្ឌិត ជុំ ស៊ុនណាង។ ក្នុងកម្រងគំនិតនេះ យើងសង្កេតឃើញមានមួយផ្នែកទាក់ទងនឹងអក្ខរាវិរុទ្ធ និង មួយផ្នែកទៀតទាក់ទងនឹងសូរវិទ្យានិងសទ្ទតាវិទ្យាក្នុងភាសាខ្មែរ ដែលមានមូលភេទ អនិងអ៊ ជារឿងសំខាន់។ ផ្នែកអក្ខរាវិរុទ្ធ ស្នេរ បានលើកឡើងអំពី មូលហេតុដែលម្ដងបានសរសេរនឹង ណ និង ម្ដងសរសេរនឹង ន។ គំនិតចុងក្រោយ ស្នេរបានវិភាគអំពី មូលហេតុដែលបណ្ដាលឱ្យភាសាខ្មែរមានមូលភេទ អ ផង និង អ៊ ផង។ ស្របគ្នានេះផងដែរ បណ្ឌិត ជុំ ស៊ុនណាង បានលើកឡើងអំពី«ពិចារណាអំពីលទ្ធភាពភាសាខ្មែរ»

ដោយស្នេរ បានបង្ហាញគំនិតពីរសំខាន់។ ទីមួយទាក់ទងនឹងបាតុភូតបម្រែបម្រួលនិងបន្លែកក្នុងភាសា ដែលស្នេរបានធ្វើការសិក្សាប្រៀបធៀបទៅលើទម្រង់សទ្ទតានិងទម្រង់សូរវិទ្យាភាសាខ្មែរក្រោមនិងខ្មែរកណ្តាល។ និងទីពីរ កម្ទីភាសា ដោយស្នេរបានបង្ហាញគោលគំនិតសំខាន់បី រួមមាន កម្ទីពាក្យទាំងដុល កម្ទីបន្សំ និងកម្ទីប្រែ។

ផ្នែកទីបី ទាក់ទងនឹងអក្ខរាវិរុទ្ធ ក្នុងផ្នែកនេះ មានស្នេរចំនួនពីររូប បានលើកឡើង។ ស្នេរទីមួយ សាស្ត្រាចារ្យបណ្ឌិត នៅ ស៊ុន ដូចបានបង្ហាញជូនខាងលើស្រាប់ និង ស្នេរទីពីរ លោក ឡុង ធវង្ស។ លោក ឡុង ធវង្ស បានពិពណ៌នាអំពី«វិភាគសំណេរ ណ និង ន ក្នុងភាសាខ្មែរទំនើប»។ ក្នុងការវិភាគរបស់លោក ស្នេររូបនេះ បានបង្ហាញអំពីរឿងពីរសំខាន់។ ទីមួយគឺសំណេរ ណ និង ន ទាក់ទងនឹងពាក្យកម្ទីបរទេសដែលមានបាលីនិងសំស្ក្រឹត សៀម បារាំង យួន និងទីពីរការវិភាគសំណេរ ណ និង ន ទាក់ទងនឹងវិធីកម្លាយក្នុងភាសាខ្មែរ។

ផ្នែកទីបួន គឺជាផ្នែកផ្សេងៗ ហើយ ផ្នែកនេះមានអ្នកនិពន្ធចំនួនប្រាំរូប។ អ្នកនិពន្ធទីមួយ គឺ បណ្ឌិត ជួរ គារី ដែលបានបរិយាយអំពី«ន័យ អត្ថន័យ បំណកស្រាយន័យក្នុងទិដ្ឋភាពអក្សរសាស្ត្រនូវសុភាសិតបុរាណខ្មែរ«កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប»។ អ្នកនិពន្ធទីពីរ លោក កែវ លីណែត ដែលបានបរិយាយអំពី«ការគ្រប់គ្រងដីធ្លីនៅប្រទេសកម្ពុជាសម័យបុរាណ»។ ក្នុងសំណេររបស់ស្នេរ លោកបានរៀបរាប់អំពីបញ្ហាបីសំខាន់គឺ ទីមួយទាក់ទងនឹងការគ្រប់គ្រងដីធ្លីសម័យនគរភ្នំ សម័យចេនឡា និងសម័យអង្គរ។ ទីពីរទាក់ទងនឹងគោលនយោបាយដីធ្លីនៅសម័យទាំងបីខាងលើ និងបញ្ហាសំខាន់ទីបី ស្នេរបានលើកឡើងអំពីវង្វាស់វង្វាល់មួយចំនួនទាក់ទងនឹងរឿងដីធ្លីសម័យនោះផងដែរ។ អ្នកនិពន្ធទីបី លោក ផង់ ភិរុណ ដែលបានលើកឡើងអំពី«លោកគ្រូ នៅ ស៊ុន និង ជីវិតសិល្បៈ» ដោយស្នេរ បានបង្ហាញអំពីការណែនាំរបស់សាស្ត្រាចារ្យបណ្ឌិត នៅ ស៊ុន ផ្តល់ការណែនាំក្នុងការស្រាវជ្រាវអំពីបទចំនួន ៣៤ ដើម្បីយកទៅប្រគុំជាតន្ត្រីអ័កកាដង់។ អ្នកនិពន្ធទីបួន គឺលោក សេស សារ៉ាត់ ស្នេរបានសរសេរអំពី«ស្តាយបញ្ញវន្តខេត្តយើង» ដោយចង់បញ្ជាក់ថា ស្តាយសាស្ត្រាចារ្យ បណ្ឌិត នៅ ស៊ុន មកពីខេត្តតាកែវ បានទទួលមរណភាព។ អ្នកនិពន្ធទីប្រាំចុងក្រោយ គឺលោក អ៊ឹម គួយ ដែលបានសរសេរអំពី«បាត់ដំបងបណ្តូលចិត្ត»។

**និពន្ធនាយករង**
បណ្ឌិត **វង្ស មេង**

# វិធីកម្លាយក្នុងភាសាខ្មែរ បញ្ហាកង្វះផ្នត់សម្រាប់ធ្វើវិធីកម្លាយឱ្យមានសម្បូរណ៍បែប, បញ្ហាវិសាលភាពតូចចង្អៀតនៃផ្នត់មួយចំនួន និង បញ្ហាសទិសសូរវេយ្យាករណ៍វិស័យ[1] [2]

បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់
ទីប្រឹក្សារាជរដ្ឋាភិបាល

<u>កំណត់សម្គាល់</u> : ខ្ញុំប្រើពាក្យ'សទិសសូរវេយ្យាករណ៍វិស័យ'ដែលជាបម្រែនៃពាក្យបារាំង'homonymie grammaticale'ដែលអ្នកភាសាវិទ្យាបារាំងស្គាល់ជាទូទៅ ហើយ ដែលសម្គាល់បាតុភូតដែលមានក្នុងភាសាជាច្រើនៗ ដើម្បីប្រែ'homonymie grammaticale'មកជា'សទិសសូរវេយ្យាករណ៍វិស័យ' ខ្ញុំបានយកលំនាំតាមលោក តិប យក់ & ថាវ គន្ធ ដែលបានប្រែគុណនាមបារាំង'subjectif'ថា'អត្តវិស័យ' នាម'subjectivité'ថា'អត្តវិស័យភាព' និង នាម'objectivité'ថា'វត្ថុវិស័យភាព' ក្នុងវចនានុក្រមបារាំង-ខ្មែររបស់គាត់ៗ

## <u>សេចក្ដីផ្ដើម</u>

ខ្ញុំបានសង្កេតឃើញថា ភាសាខ្លះបង្កើតពាក្យបានតែតាមវិធីបន្សំ និង ភាសាខ្លះទៀតអាចបង្កើតពាក្យបានតាមវិធីបន្សំផងនិងតាមវិធីកម្លាយផង[3]។

ភាសាដែលអាចបង្កើតពាក្យបានតែតាមវិធីបន្សំ មានដូចជាភាសាបាអ៊ូឡេ (baoulé), ភាសាសេ-នូផូ (sénoufo) នៅប្រទេសកូឌីវ័រ (Côte d'Ivoire) ជាដើម។ ភាសាខ្មែរជាភាសាដែលនៅក្នុងក្រុមទី២ គឺអាចបង្កើតពាក្យបានតាមវិធីបន្សំផងនិងតាមវិធីកម្លាយផង។ ប៉ុន្តែវិធីកម្លាយនៃភាសាខ្មែរមិនសូវសម្បូរណ៍បែបទេ។ ក្នុងចំណោមភាសាដែលស្ថិតនៅក្នុងក្រុមទី២ ភាសាបារាំងជាភាសាមួយដែលមានផ្នត់យ៉ាងសម្បូរណ៍ ដែលគេប្រើសម្រាប់ទាញនាមចេញពីនាមគ្នាឯង ចេញពីកិរិយាសព្ទ និងចេញពីគុណនាម, ទាញកិរិយាសព្ទចេញពីនាមនិងចេញពីគុណនាម, ទាញគុណនាមចេញពីនាម, ទាញគុណកិរិយាចេញពីគុណនាម,... ឧទាហរណ៍ :

១- ផ្នត់ប្រើសម្រាប់បង្កើតពាក្យកម្លាយចេញពីកិរិយាសព្ទ :

Former, កិរិយាសព្ទ
- formation[4] (នាមសម្គាល់អំពើ/លទ្ធផល)
- formateur (នាមសម្គាល់ភ្នាក់ងារ)
- formatif (គុណនាម)

[1] បាឋកថា របស់បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ សម្រាប់ឆ្នាំ២០១៧ ថ្លែងនៅថ្ងៃអង្គារ ទី៣១-១០-២០១៧ ម៉ោង ៩:០០ នៅសាលរំដួលនៃរាជបណ្ឌិត្យសភាកម្ពុជា

[2] តាមរយៈប្រធានបទនេះ ខ្ញុំនឹងលើកឡើងនូវកង្វះខាតមួយចំនួនក្នុងភាសាខ្មែរ ប៉ុន្តែភាសាណាក៏មានកង្វះខាតដែរ ហើយភាសាខ្មែរពិតជាមិនចាញ់ភាសាជាច្រើនក្នុងលោកឡើយ។

[3] ក្រៅពីវិធីទាំងពីរនេះដែលភាសាជាច្រើនក្នុងលោកបានស្គាល់ជាយូរលង់មកហើយ គេមានវិធីបង្កើតពាក្យមួយបែបទៀតដែលមានឈ្មោះក្នុងភាសាបារាំងថា 'procédés morphophonologiques' ហើយ ដែលយើងបកប្រែថា 'វិធីរូប-សទ្ទតា', ឧ. Villes capitales > capitales (រដ្ឋ/រាជធានី), e(lectronic) mail > email, ការិយា(ល័យ) + (អ)ធិបតេយ្យ > ការិយាធិបតេយ្យ,...។

[4] ចំណែកក្នុងពាក្យនីមួយៗដែលមានគំនូសពីក្រោម គឺជាផ្នត់។

២- ផ្នត់សម្រាប់បង្កើតពាក្យកម្លាយចេញពីនាម :

Forme, នាម
- former ( កិរិយាសព្ទ )
- informer ( កិរិយាសព្ទ )
- déformer ( កិរិយាសព្ទ )

Jardin, នាម
- jardiner ( កិរិយាសព្ទ )
- jardinage ( នាមសម្គាល់អំពើ )
- jardinier ( នាមសម្គាល់ភ្នាក់ងារ )

៣- ផ្នត់សម្រាប់បង្កើតពាក្យកម្លាយចេញពីគុណនាម :

Blanche, គុណនាម
- blancheur ( នាម )
- blanchâtre ( គុណនាម )
- blanchir ( កិរិយាសព្ទ )

Lent, គុណនាម
- lenteur ( នាម )
- lentement ( គុណកិរិយា )

៤- ផ្នត់ប្រើដើម្បីធ្វើកម្លាយពាក្យជាបន្តបន្ទាប់ ចេញជាប្រភេទពាក្យផ្សេងៗគ្នា :

Marge( នាម ) → marginal( គុណនាម ) → marginaliser( កិរិយាសព្ទ ) → marginalisation ( នាម ).

បញ្ជាក់ : ឧទាហរណ៍ខាងលើមិនគ្របដណ្ដប់លើវិធីកម្លាយនៃភាសាបារាំងទាំងអស់ទេ : ខ្ញុំគ្រាន់តែផ្ដល់វត្ថុតាងដែលបង្ហាញឱ្យឃើញថា វិធីកម្លាយក្នុងភាសាបារាំងមានភាពសម្បូរណ៍បែបៗ

## សេចក្ដីអត្ថាធិប្បាយ

**០- បុព្វយោគ**

**០១- តម្រូវការ**'Alphabet Phonétique International' ( API ) **ដើម្បីកត់ត្រាភាសាផ្សេងៗក្នុងការស្រាវជ្រាវ**

ជាទូទៅ អ្នកភាសាវិទ្យាតែងតែប្រើ'API'ដែលមានប្រភពចេញពីអក្សរឡាតាំងសម្រាប់កត់ត្រាភាសាដែលគេសិក្សា ដើម្បីឱ្យអ្នកភាសាវិទ្យាឯទៀតអាចអានបាន ពីព្រោះភាសាមួយចំនួនប្រើអក្សរផ្សេងៗគ្នា ហើយ ទោះបីចំពោះភាសាដែលប្រើអក្សរឡាតាំងក៏អក្ខរាវិរុទ្ធមានអំណាននមិនដូចគ្នាពីភាសាមួយទៅភាសាមួយទៀតដែរ : ដូច្នេះខ្ញុំក៏មានការចាំបាច់ប្រើ 'API' ដើម្បីកត់ត្រាផ្នត់ឬពាក្យខ្មែរដែលខ្ញុំផ្ដល់ជាឧទាហរណ៍ផងដែរ។

**០២- បម្រែពាក្យ**'Alphabet Phonétique International'**មកជាពាក្យខ្មែរ**

ខ្ញុំបានប្រែ'Alphabet Phonétique International'ថា 'អក្ខរក្រមសូរវិស័យអន្តរជាតិ' ដោយពឹងផ្អែកលើវចនានុក្រមបារាំង-ខ្មែរ របស់លោក តិប យក់ & ថាវ គន្ធ តាំងពីខ្ញុំចាប់សរសេរអត្ថបទជាភាសាខ្មែរ។ ក្នុងវចនានុក្រមបារាំង-ខ្មែរនោះ អ្នករៀបរៀងបានប្រែ'alphabet' ថា 'អក្ខរក្រម'។ ចំពោះពាក្យ'សូរវិស័យ' ខ្ញុំបានយកលំនាំតាមពាក្យ 'អត្តវិស័យ'( =subjectif ), 'អត្តវិស័យភាព'( =subjectivité ) និង 'វត្ថុវិស័យភាព'( =objectivité ) របស់ពួកគាត់( អ្នករៀបរៀងវចនានុក្រមបារាំង-ខ្មែរនោះបានប្រើពាក្យ'វិស័យ' ដើម្បីបង្កើតគុណនាមចេញពីធាតុ'អត្ត'ឬពីនាម'វត្ថុ' )។

'អក្ខរក្រមសូរវិស័យអន្តរជាតិ'អាច ជាអក្សរកាត់ ចេញជា'អ.ស.អ.' ប៉ុន្តែ ក្នុងបាឋកថានេះ ខ្ញុំសុំប្រើអក្សរកាត់បារាំង 'API' តាមទម្លាប់ចាស់របស់ខ្ញុំវិញសិន ពីព្រោះ ក្រោយមក បម្រែផ្សេងមួយទៀតត្រូវបានប្រើផងដែរ ដែលជាហេតុនាំឱ្យមានបញ្ហាចម្រូងចម្រាស។

**១- ការរំលឹកជាគោលៗ[5]អំពីបែបផ្សេងៗនៃវិធីកម្លាយពាក្យក្នុងភាសាខ្មែរ**

**១.១- ចំណុចដែលលើនោះអ្នកអក្សរសាស្ត្រខ្មែរមូលមតិគ្នា**

គួររំលឹកថា អ្នកអក្សរសាស្ត្រខ្មែរបានស្រុះស្រួលមូលមតិគ្នា ទទួលស្គាល់ថា ភាសាខ្មែរសុទ្ធសាធ មានផ្នត់ដើមនិងផ្នត់ដែក។

(១)- ផ្នត់ដើម

(១.១)- ផ្នត់ដើមសម្រាប់បង្កើតកិរិយាហេតុ មានដូចជា :

- [p-/ph-], ឧ. [p-] + dœŋ( ដឹង ) > pdœŋ( ប្ដឹង ), [p-] + juo( យួរ ) > pjuo( ព្យួរ ), [ph-] + sœk( សឹក ) > phsœk( ផ្សឹក ), [ph-] + cɔap( ជាប់ ) > phcɔap( ភ្ជាប់ );
- [bɑŋ-], [bɑṇ-], [bɑn-], [bɑm-][6], ឧ. [bɑŋ-] + khaŋ( ខាំង ) > bɑŋkhaŋ( បង្ខាំង ), [bɑṇ-] + co:l( ចូល ) > bɑṇco:l( បញ្ចូល ), [bɑn-] + si( ស៊ី ) > bɑnsi( បន្ស៊ី ), [bɑm-] + buos( បួស ) > bɑmbuos( បំបួស );
- [rum-] + kœl( កិល ) > rumkœl( រំកិល ),...។

(១.២)- ផ្នត់ដើម[lum-]សម្រាប់បង្កើតនាមសម្គាល់លទ្ធផល, ឧ. [lum-] + nɯŋ( នឹង ) > lumnɯŋ ( លំនឹង ), [lum-] + hat( ហាត់ ) > lumhat ( លំហាត់ ),...។

(២)- ផ្នត់ដែកមាន : [-m-], [-n-], [-b-], [-ɑmn-/-ɔmn-], [-ɑm-/-ɔm-]។

(២.១)- ផ្នត់ដែក [-m-] ប្រើសម្រាប់បង្កើតពាក្យកម្លាយសម្គាល់ភ្នាក់ងារ, ឧ. cam( ចាំ ) + [-m-] > cmam > chmam( ឆ្មាំ ), cuoṇ( ជួញ ) + [-m-] > cmuoṇ > chmuoṇ ( ឈ្មួញ ),...។

(២.២)- ផ្នត់ដែក [-n-] ប្រើសម្រាប់បង្កើតពាក្យកម្លាយសម្គាល់ឧបករណ៍, ឧ. kaos[7]( កោស ) + [-n-] > knaos > khnaos( ខ្នោស ),...។

(២.៣)- ផ្នត់ដែក [-b-] សម្រាប់បង្កើតពាក្យកម្លាយសម្គាល់លទ្ធផល : jɔl( យល់ ) + [-b-] > jbɔl > jbɑl( យ្បល់ ) > jobɑl( យោបល់ ), riep( រៀប ) + [-b-] > rbiep > rɔ:biep( របៀប ), lɔas( លាស់ ) + [-b-] > lbɔas > lbas( ល្បាស់ ),...។

(២.៤)- ផ្នត់ដែក [-ɑmn-/-ɔmn-] ប្រើសម្រាប់បង្កើតពាក្យកម្លាយសម្គាល់លទ្ធផល, ឧ. co:l( ចូល ) + [-ɑmn-] > cɑmno:l( ចំណូល ), ku:s( គូស ) + [-ɔmn-] > kɔmnu:s( គំនូស )។

[5] ចំពោះសម្រង់លំអិតនៃផ្នត់ទាំងប៉ុន្មាន សូមមើលក្នុង'វេយ្យាករណ៍ទម្រង់និយម'ភាគទី២ ដែលមានក្នុងគន្លនិទ្ទេសនិងដែលមានចុះផ្សាយតាម Facebook របស់បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់។

[6] សមាជិកនៃគណៈកម្មការភាសាវិទ្យានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ បានស្រុះស្រួលគ្នាចាត់ទុក [bɑŋ-], [bɑṇ-], [bɑn-], [bɑm-] ថាជាកាឡា-រូបរបស់ផ្នត់ដើម/p-/។ គួរកត់សម្គាល់ថា ក្នុងករណីខ្លះ គេអនុវត្តការសម្របសូរ ជាពិសេសជាមួយពាក្យដើមកើតចេញពីព្យញ្ជនៈ យ, រ, ល, វ ដូចជា យារ > ពន្យារ, រាយ > ពង្រាយ, លូត > ពន្លូត, វាង > ពង្វាង,...។

[7] អ្នកសូរវិទ្យានិយមប្រើ [h] ដើម្បីកត់ត្រាព្យញ្ជនៈ'ស'ដែលយើងប្រើក្នុងភាសាខ្មែរ : ពាក្យ'កោស' ត្រូវគេសរសេរជា API ដូចនេះ : [kaoh] ប៉ុន្តែខ្ញុំសុំប្រើ [s] សម្រាប់កត់ត្រាព្យញ្ជនៈ'ស'ខ្មែរ ដើម្បីឱ្យសាធារណជនខ្មែរងាយយល់ គឺ [kaos]។

(២.៥)- ផ្នត់ដែក [-ɑm-/-ɔm-] ប្រើសម្រាប់បង្កើតនាមកម្លាយសម្គាល់លទ្ធផលផង, នាមកម្លាយសម្គាល់ឧបករណ៍ផង និង កិរិយាហេតុសម្គាល់ន័យថា«ធ្វើឱ្យ»ផង :

(២.៥.១)- ការប្រើផ្នត់ [-ɑm-/-ɔm-] សម្រាប់បង្កើតនាមកម្លាយសម្គាល់លទ្ធផល មានដូចជា : chŋa:j(ឆ្ងាយ) + [-ɑm-] > chɑmŋa:j > cɑmŋa:j(ចម្ងាយ), chea:n(ឈាន) + [-ɔm-] > chɔmhea:n > cɔmhea:n(ជំហាន), khlea:t(ឃ្លាត) + [-ɔm-] > khɔmlea:t > kɔmlea:t(គម្លាត)។

(២.៥.២)- ការប្រើផ្នត់ដែក [-ɑm-/-ɔm-] សម្រាប់បង្កើតនាមកម្លាយសម្គាល់ឧបករណ៍ មានដូចជា : trɑ:ŋ(ត្រង) + [-ɑm-] > tɑmrɑ:ŋ(តម្រង), krɔ:p(គ្រប) + [-ɔm-] > kɔmrɔ:p(គម្រប)។

(២.៥.៣)- ការប្រើផ្នត់ដែក [-ɑm-/-ɔm-] សម្រាប់បង្កើតកិរិយាហេតុកម្លាយសម្គាល់ន័យថា«ធ្វើឱ្យ» មានដូចជា : trov(ត្រូវ) + [-ɑm-] > tɑmrov(តម្រូវ), krɔp(គ្រប់) + [-ɔm-] > kɔmrɔp(គម្រប់)។

### ១.២- <u>ចំណុចដែលលើនោះអ្នកអក្សរសាស្ត្រខ្មែរមិន/មិនទាន់មូលមតិគ្នា</u>

អ្នកអក្សរសាស្ត្រខ្មែរមិន/មិនទាន់មូលមតិគ្នាលើផ្នត់ចុង/បច្ឆិមបទនៅឡើយ។ អ្នកខ្លះយល់ថា ភាសា-ខ្មែរឥតមានផ្នត់ចុង/បច្ឆិមបទទេ។ ពាក្យដែលខាងចុងមានធាតុ[8]'សាស្ត្រ'(វិទ្យាសាស្ត្រ, វេជ្ជសាស្ត្រ), 'វិទ្យា'(ភាសាវិទ្យា), 'វិទូ'(ភាសាវិទូ), 'ករ'(ពលករ),... ត្រូវបានអ្នកអក្សរសាស្ត្រទាំងនោះចាត់ទុកថាជាពាក្យបន្សំ/ពាក្យសមាស[9] : ដូច្នេះពួកគាត់មិនទទួលស្គាល់ថាធាតុខាងចុងនៃពាក្យទាំងប៉ុន្មានដែលទើបត្រូវបានបង្ហាញមកនេះ ជាផ្នត់ចុង/បច្ឆិមបទនោះឡើយ។

អ្នកអក្សរសាស្ត្រខ្មែរខ្លះទៀត យល់ថា ភាសាខ្មែរបច្ចុប្បន្នមានផ្នត់ចុង/បច្ឆិមបទ ដោយគេផ្អែកលើនិយមន័យនៃផ្នត់/អព្ភាសបទ ដូចនេះ : «ផ្នត់/អព្ភាសបទជាកន្ទេចពាក្យដែលមានន័យនឹងនរនិងរូបនឹងនរ លើកលែងតែក្នុងករណីកម្រដែលមានការវិវត្តឬក្នុងករណីកាឡារូប»។ ពាក្យ'កន្ទេចពាក្យ' ជាពាក្យខ្ចីពីលោក អៀវ កើស[10] ក្នុងន័យថា «ធាតុដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសាខ្មែរឬភាសាណាមួយ» : ដូច្នេះ ចំពោះក្រុមទី២នេះ ធាតុ'សាស្ត្រ', 'វិទ្យា'[11], 'វិទូ', 'ករ',... (ដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសាខ្មែរបច្ចុប្បន្ន) គឺជាផ្នត់ចុង/បច្ឆិមបទ។

---

[8] ខ្ញុំប្រើ`ធាតុ´សម្រាប់សម្គាល់កម្ទេចពាក្យដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសាខ្មែរបច្ចុប្បន្ន។

[9] ក្នុងគម្រោងវេយ្យាករណ៍ភាសាខ្មែរ(កម្រិតមធ្យមសម្រាប់ការប្រើប្រាស់ទូទៅ)ដែលគណៈកម្មការភាសាវិទ្យានៃក្រុមប្រឹក្សាជាតិភាសាខ្មែរបានរៀបរៀង សមាជិកបានមូលមតិគ្នាហៅកន្សោមពាក្យផ្សារជាប់ កើតចេញពីការផ្គុំពាក្យខ្មែរនិងពាក្យខ្មែរ, ពាក្យខ្មែរនិងពាក្យបាលី/សំស្ក្រឹតដែលចូលស៊ុបក្នុងភាសាខ្មែរ ឬ ពាក្យបាលី/សំស្ក្រឹតនិងពាក្យបាលី/សំស្ក្រឹតដែលចូលស៊ុបក្នុងភាសាខ្មែរ ហើយ ដែលមានសម្ព័ន្ធបែបខ្មែរ ថាជា`ពាក្យបន្សំ´, ឧ. ស្បែកជើង, ខ្មៅដៃ, អ្នកប្រាជ្ញ, ប្រវត្តិរូប, ទោសឧក្រិដ្ឋ,...។ ចំពោះ`ពាក្យសមាស´វិញ សមាជិកនៃគណៈកម្មការដដែល បានមូលមតិគ្នាប្រើសម្រាប់សម្គាល់បណ្តុំដែលកើតចេញពីការផ្គុំពាក្យឬធាតុបាលី/សំស្ក្រឹតនិងពាក្យឬធាតុបាលី/សំស្ក្រឹត ហើយដែលមានសម្ព័ន្ធបែបបាលី/សំស្ក្រឹត , ឧ. រដ្ឋសភា, ធនាគារ, សាស្ត្រាចារ្យ, វិទ្យាល័យ,...។

[10] អៀវ កើស, ភាសាខ្មែរ បណ្ណាគារមិត្តសេរី ភ្នំពេញ ឆ្នាំ១៩៦៧ ទំព័រ១៦៨។

[11] ភាសាខ្មែរប្រើ`វិទ្យា´ជាធាតុចុងពាក្យក្នុងពាក្យជាច្រើន ដូចជាគណិតវិទ្យា, ភូមិវិទ្យា, ភាសាវិទ្យា,...។ ក្រៅពីនេះ គេសង្កេតឃើញមានប្រើនៅដើមពាក្យដែរ ដូចជា វិទ្យាល័យ, វិទ្យាស្ថាន,... ប៉ុន្តែទោះយ៉ាងណាក៏គេមិនដែលប្រទះឃើញធាតុ`វិទ្យា´នេះ ប្រើជាពាក្យឯករាជ្យដូច`វិជ្ជា´នោះឡើយ។

ម្យ៉ាងទៀត បើយើងផ្អែកលើពាក្យឡាតាំង'mente' ដែលបានក្លាយមកជាបច្ឆិមបទបារាំង'-ment'[12](ដោយបានបន្សល់ទុកនូវពាក្យកម្លាយ mental និង mentalité) យើងអាចគិតថា នៅពេលអនាគតណាមួយ ពាក្យខ្លះក្នុងចំណោមពាក្យ ដូចជា 'និយម', 'កម្ម', 'ភាព',... ដែលគេប្រើជាញ៉ឹកញាប់សម្រាប់ដាក់ខាងចុងនៃពាក្យសមាស(ដូចជា សង្គមនិយម, សេរីនិយម,... ទំនើបកម្ម, ពលកម្ម,... មិត្តភាព, សុខភាព,...) អាចក្លាយទៅជាផ្នត់ចុង/បច្ឆិមបទក៏មិនដឹង។

<u>កំណត់សម្គាល់</u> : ការខ្វែងគំនិតគ្នាលើបញ្ហាផ្នត់ចុង/បច្ឆិមបទគ្រាន់តែជាការបកស្រាយផ្សេងគ្នាតែប៉ុណ្ណោះ។ ក្នុងភាពជាក់ស្ដែង ការបង្កើតពាក្យដោយប្រើធាតុ 'សាស្ត្រ', 'វិទ្យា', 'វិទូ', 'ករ',... អាចធ្វើទៅបានជាច្រើន ដោយងាយ តាមសេចក្ដីត្រូវការ(ទោះមានការខ្វែងគំនិតគ្នាលើបញ្ហាផ្នត់ចុង/បច្ឆិមបទរវាងអ្នកអក្សរសាស្ត្រខ្មែរក៏ដោយ)។

## ២- បញ្ហាកង្វះផ្នត់ដើម្បីធ្វើវិធីកម្លាយឱ្យបានសម្បូរណ៍បែប

### ២.១- កង្វះផ្នត់សម្រាប់បង្កើតកិរិយាសព្ទចេញពីនាម

កង្វះផ្នត់សម្រាប់បង្កើតកិរិយាសព្ទចេញពីនាម ជាកង្វះដែលបានបណ្ដាលឱ្យប្រភេទពាក្យមានភាព-ច្របូកច្របល់, ឧទាហរណ៍ :

- ពាក្យ'ឯកភាព'ដែលជានាម (ដូចមាន'ភាព'ខាងចុងជាស្លាកស្នាមស្រាប់) ក្រោយមកត្រូវបានប្រើជាកិរិយាសព្ទ[13] ហើយ បើគេចង់បាននាមគេត្រូវដាក់'ការ-'នៅខាងដើម គឺ'ការឯកភាព' ប៉ុន្តែគួរកត់សម្គាល់ថា ក្នុងបរិបទខ្លះ គេនៅប្រើពាក្យ'ឯកភាព'ជានាមនៅឡើយ។

  ជាទូទៅ ពាក្យដែលមាន'ភាព'នៅខាងចុងជានាម ដូចជា : សេរីភាព, សមភាព, ភាតរ-ភាព, មេត្រីភាព, សាមគ្គីភាព, មិត្តភាព, សហគ្រិនភាព,...។ ការដែលនាម'ឯកភាព'បានប្រែក្លាយទៅជាកិរិយាសព្ទ'ឯកភាព'ដោយឥតមានរូបសាស្ត្រអ្វីជាគ្រឿងសម្គាល់ បានធ្វើឱ្យប្រព័ន្ធរបស់នាមដែលមាន'ភាព'នៅខាងចុងឈប់ជាប្រព័ន្ធទាំងស្រុង (ពីព្រោះកិរិយាសព្ទ'ឯកភាព'ក៏មាន'ភាព'នៅខាងចុងដែរ)។

- ពាក្យ'ទំនាក់ទំនង'ជានាមកើតចេញពីកិរិយាសព្ទ'ទាក់ទង'តាមរយៈផ្នត់ដែក [-ɔmn-] : teak (ទាក់) + [-ɔmn-] > tɔmneak (ទំនាក់) និង tɔːŋ (ទង) + [-ɔmn-] > tɔmnɔːŋ (ទំនង) ; (ទំនាក់ + ទំនង > ទំនាក់ទំនង)។ នាម'ទំនាក់ទំនង'ត្រូវបានគេប្រើជាកិរិយាសព្ទ'ទំនាក់ទំនង'ជំនួសកិរិយាសព្ទ'ទាក់ទង' ហើយ គេបានបង្កើតនាមថ្មី'ការទំនាក់ទំនង'ដើម្បីជំនួសនាម'ទំនាក់ទំនង'(ដែលត្រូវបានគេយកទៅប្រើជាកិរិយាសព្ទទៅហើយ)។

<u>កំណត់សម្គាល់</u> : ផ្ទុយពីពាក្យ'ឯកភាព'ដែលត្រូវបានប្រើជាកិរិយាសព្ទស្ទើរតែទាំងស្រុងទៅហើយ ចំពោះពាក្យ'ទំនាក់ទំនង'វិញ ការប្រើប្រាស់ជានាមក៏នៅមានគេប្រើជាញឹកញាប់នៅឡើយ។

---

[12] ខ្ញុំបានគំនិតនេះពីលោក Walther V. Wartburg, Problèmes et Méthodes de la linguistique, PUF 1963, p.95។

[13] ថ្វីបើគ្មានរូបសាស្ត្រអ្វីជាគ្រឿងសម្គាល់ គេអាចដឹងបានថាពាក្យ'ឯកភាព'ត្រូវគេប្រើជានាមឬជាកិរិយាសព្ទ គឺដោយសារ សម្ព័ន្ធ(ក្នុងល្បះ) :
(១)- ប្រើជានាម : រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរនៅឆ្នាំ២០០៧ ដើម្បីឱ្យរកឯកភាពជូនភាសាជាតិ;
(២)- ប្រើជាកិរិយាសព្ទ : អ្នកនយោបាយខ្មែរគួរឯកភាពគ្នាលើបញ្ហាជាតិចម្បងៗ។

- ពាក្យ‘ចំណាក’(ស្រុក) ជានាមកើតចេញពីកិរិយាសព្ទ‘ចាក’(ស្រុក)ត្រូវបានបង្កើតឡើងក្រោមតម្រូវការ។ ពាក្យនេះត្រូវបានគេប្រើស្របតាមប្រភេទរបស់វា, ឧ. ប្រជាពលរដ្ឋខ្មែរជាច្រើនបានធ្វើចំណាកស្រុកទៅប្រទេសក្រៅ មានប្រទេសថៃ, ប្រទេសម៉ាលេស៊ី ជាដើម។ ប៉ុន្តែសាធារណជនយកគំរូតាម ‘ទំនាក់ទំនង’ បានប្រើ‘ចំណាក’ជាកិរិយាសព្ទ, ឧ. ប្រជាពលរដ្ឋខ្មែរជាច្រើនបានចំណាក ស្រុក[14]។

កង្វះផ្នត់សម្រាប់បង្កើតកិរិយាសព្ទចេញពីនាម តម្រូវឱ្យខ្មែរយើងយកនាមមកប្រើជាកិរិយាសព្ទដោយឥតមានរូបសាស្ត្រអ្វីជាគ្រឿងសម្គាល់តាំងពីយូរយារណាស់មកហើយ។ ក្រៅពីបីករណីដែលខ្ញុំបានលើកឡើង មានករណីជាច្រើនសន្ធឹកសន្ធាប់ទៀត ដូចមានក្នុងឧទាហរណ៍នេះ ជាដើម : ខ្ញុំបានទូរសព្ទទៅមិត្តខ្ញុំ; តើឯងបាយហើយឬនៅ?...

**<u>សង្កេត</u> : លទ្ធភាពដែលគេអាចយកនាមទៅប្រើជាកិរិយាសព្ទ ដោយឥតមានរូបសាស្ត្រអ្វីជាគ្រឿងសម្គាល់នោះ អនុញ្ញាតឱ្យសាធារណជនប្រើនាមណាមួយដែលកើតចេញពីកិរិយាសព្ទណាមួយ ទៅជំនួសកិរិយាសព្ទនោះឯង ដូចនាម‘ទំនាក់ទំនង’ប្រើជាកិរិយាសព្ទជំនួសកិរិយាសព្ទ‘ទាក់ទង’(ដែលជាប្រភពនៃ‘ទំនាក់ទំនង’) : ការប្រើបែបនេះ នាំឱ្យមានភាពច្របូកច្របល់ៗ**

<u>សំណូមពរ</u> : បើអ្នកអក្សរសាស្ត្រណាយល់ថា ករណីដែលខ្ញុំបានលើកឡើងនេះជាបញ្ហាពិតមែន សូមអស់លោកជួយរកដំណោះស្រាយនិងធ្វើសំណើជាសាធារណៈ ដើម្បីឱ្យអ្នកអក្សរសាស្ត្រឯទៀតពិចារណានិងធ្វើការទិតៀនស្ថាបនា(គាំទ្រឬច្រានចោល)។

**២.២- <u>កង្វះផ្នត់សម្រាប់បង្កើតគុណនាមចេញពីនាម</u>**

កង្វះផ្នត់សម្រាប់បង្កើតគុណនាមចេញពីនាម មិនបានបណ្ដាលឱ្យមានភាពច្របូកច្របល់ដូចកង្វះផ្នត់សម្រាប់បង្កើតកិរិយាសព្ទចេញពីនាមទេ : ភាសាខ្មែរប្រើនាមក្នុងមុខងារជាកម្ម/កម្មបទសម្រាប់ផ្ដល់លក្ខណៈឱ្យនាមមួយទៀត, ឧទាហរណ៍ :

- ‘ក្រុមប្រឹក្សាធម្មនុញ្ញ’ដែលក្នុងនោះ‘ក្រុមប្រឹក្សា’និង‘ធម្មនុញ្ញ’ជានាមទាំងពីរ ហើយ មួយជាពាក្យគោល មួយទៀតជាកម្ម/កម្មបទ;
- ‘សុវត្ថិភាពស្បៀង’ដែលក្នុងនោះ‘សុវត្ថិភាព’ជានាមគោលនិង‘ស្បៀង’ជានាមដែរ ដែលមានមុខងារជាកម្ម/កម្មបទ;
- ‘សមាជជាតិ’ដែលក្នុងនោះ‘សមាជ’និង‘ជាតិ’ជានាមទាំងពីរ ហើយ មួយជាពាក្យគោល មួយទៀតជាកម្ម/កម្មបទ។

ប៉ុន្តែ លោក តិប យក់ និង ថាវ គន្ធ អ្នកដែលតាក់តែងវចនានុក្រមបារាំង-ខ្មែរ បានប្រែគុណនាមបារាំង‘subjectif’ថា‘អត្តវិស័យ’, នាម‘subjectivité’ថា‘អត្តវិស័យភាព’ និង នាម‘objectivité’ថា

[14] កិរិយាសព្ទ‘ឯកភាព’ដែលបានកើតចេញពីនាម‘ឯកភាព’ មិនបានយកកន្លែងកិរិយាសព្ទណាមួយដែលជាប្រភពនៃនាម‘ឯកភាព’នោះទេ : ផ្ទុយពីនេះ កិរិយាសព្ទ‘ទំនាក់ទំនង’ និង កិរិយាសព្ទ‘ចំណាក(ស្រុក)’,... បាន ជាលំដាប់លំដោយ យកកន្លែងនៃកិរិយាសព្ទ‘ទាក់ទង’ និង កិរិយាសព្ទ‘ចាក(ស្រុក)’។

'វត្ថុវិស័យ-ភាព'។ តាមរយៈពាក្យទាំងនេះ យើងអាចវិភាគឃើញថា អ្នកវចនានុក្រមយើង បានប្រើពាក្យ'វិស័យ'ដើម្បីបង្កើតគុណនាមចេញពីជាតុ'អត្ថ'និងនាម'វត្ថុ'។

កំណត់សម្គាល់ : ក្នុងប្រធានបទនៃបាឋកថារបស់ខ្ញុំ ខ្ញុំបានប្រើបណ្ដុំពាក្យ[15] 'សទិសសូរវេយ្យាករណ៍វិស័យ' ពីព្រោះខ្ញុំចង់ប្រើគុណនាម 'វេយ្យា-ករណ៍វិស័យ'វិញម្ដង ដោយយកលំនាំតាមអត្ថវិស័យ, អត្ថវិស័យភាព, វត្ថុវិស័យភាព របស់លោក តិប យក់ & ថាវ គន្ធ (បើខ្ញុំប្រើ'សទិសសូរវេយ្យាករណ៍'ដែលមាន'វេយ្យាករណ៍'ជាកម្មបទនោះ ក៏បានដែរ)។

**២.៣- កង្វះផ្នត់សម្រាប់បង្កើតនាមចេញពីគុណនាម ដើម្បីសម្គាល់គុណភាព**

ដូចកង្វះផ្នត់សម្រាប់បង្កើតគុណនាមចេញពីនាមដែរ(មើលចំណុច២.២) កង្វះផ្នត់សម្រាប់បង្កើតនាមចេញពីគុណនាម មិនបានបណ្ដាលឱ្យមានភាពច្របូកច្របល់ដូចកង្វះផ្នត់សម្រាប់បង្កើតកិរិយាសព្ទចេញពីនាមទេ(មើលចំណុច២.១) ប៉ុន្តែកន្សោមពាក្យ ដូចជា ពណ៌ខ្មៅ, ពណ៌ក្រហម,... ជាតុត្រជាក់, ជាតុក្ដៅ,... ដែលក្នុងនោះ សព្ទខាងដើមនៃកន្សោមពាក្យ ជាសព្ទផ្សេងគ្នាតាមករណី ហើយ ដែលគួរតែជាសព្ទអរូបីតែមួយដែលធ្វើគុណនាមឱ្យទៅជានាមសម្គាល់គុណភាព។ ឧទាហរណ៍ទាំងនេះ បង្ហាញឱ្យឃើញថា ភាសាខ្មែរនៅមានកង្វះខាតក្នុងការបង្កើតនាមចេញពីគុណនាមដើម្បីសម្គាល់គុណភាពនៅឡើយ ពីព្រោះមិនទាន់មានសព្ទអរូបីតែមួយណាមួយសម្រាប់បង្កើតនាមចេញពីគុណនាមដើម្បីសម្គាល់គុណភាពទេ។

បញ្ជាក់ : ការលើកឡើងនូវចំណុចខ្វះខាតមួយចំនួនក្នុងភាសាខ្មែរ ឥតមានន័យថា ភាសានេះជាភាសាខ្សត់ខ្សោយនោះឡើយ : ភាសាណាក៏មានកង្វះខាតដែរ។ ដោយភាសាខ្មែរបានរីកចម្រើនជាច្រើន ជាពិសេសចាប់ពីប្រទេសខ្មែរមានឯករាជ្យ[16]មក ខ្ញុំសង្ឃឹមថាភាសានេះនឹងបន្តការរីកចម្រើន ហើយ កង្វះខាតនឹងត្រូវបានកាត់បន្ថយបន្តិចម្ដងៗជាលំដាប់។

**៣- បញ្ហាវិសាលភាពតូចចង្អៀតនៃផ្នត់មួយចំនួន**

**៣.១- សក្តិភាព**

ផ្នត់ទាំងប៉ុន្មាន ដែលយើងបានឃើញក្នុងឧទាហរណ៍នៅចំណុច១.១ ប្រើបានតែជាមួយពាក្យដើម(ពាក្យដែលជាប្រភពនៃពាក្យកម្លាយ) ដែលកើតចេញពីព្យញ្ជនៈទោល(លើកលែងតែផ្នត់[-αm-/-ɔm-])។

កាលណាពាក្យដើមកើតចេញពីកន្សោមព្យញ្ជនៈ(ព្យញ្ជនៈ + ព្យញ្ជនៈ)ផ្នត់ដែក[-αmn-/-ɔmn-]សម្រាប់បង្កើតនាមកម្លាយសម្គាល់លទ្ធផល, ផ្នត់ដែក[-n-]សម្រាប់បង្កើតនាមកម្លាយសម្គាល់

[15] ខ្ញុំប្រើ'បណ្ដុំពាក្យ' ក្នុងន័យទូលាយជាង'កន្សោមពាក្យ'('កន្សោមពាក្យ'ក៏ជា'បណ្ដុំពាក្យ'ដែរ)។ ខ្ញុំគិតថា ក្នុងបណ្ដុំ'សទិសសូរវេយ្យា-ករណ៍វិស័យ' 'វិស័យ'ដែលបានធ្វើឱ្យបណ្ដុំ'វេយ្យាករណ៍វិស័យ'មានលក្ខណៈជាគុណនាមនោះ ដើរតួជាបច្ច័យបទមួយបែប (យកលំនាំតាមអត្ថវិស័យ, អត្ថវិស័យភាព, វត្ថុវិស័យភាព នៃវចនានុក្រមបារាំង-ខ្មែររបស់លោក តិប យក់ & ថាវ គន្ធ)។

[16] នៅថ្ងៃពុធ ២១-០៥-២០១៤ ក្រុមប្រឹក្សាជាតិភាសាខ្មែរបានអនុម័តទទួលយកពាក្យ'អធិបតេយ្យភាព' ដោយអនុលោមតាមទំនោរនៃភាសាខ្មែរបច្ចុប្បន្ន (ដោយមិនយកតាមក្បួនវេយ្យាករណ៍បាលីនិងន័យដើមទាំងស្រុងទេ)។ ពិតមែនហើយ តាមវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត 'អធិបតេយ្យភាព' មានន័យថា «ភាពនៃភាពនៃ...ជាអធិបតី» ប៉ុន្តែពាក្យ'តម្លាភាព'ក៏មានន័យត្រួតដូចនេះដែរ គឺ«ភាពនៃភាពថ្លា»។ សព្វថ្ងៃ មានគេប្រើជាញឹកញយនូវ ពាក្យ'អធិបតេយ្យភាព'ជំនួសនាម'អធិបតេយ្យ', 'ភាពជោគជ័យ'ជំនួសនាម'ជោគជ័យ', 'ឯករាជ្យភាព'ជំនួសនាម'ឯករាជ្យ',... ពីព្រោះភាសាខ្មែរកំពុងវិវត្តឆ្ពោះទៅរកទម្រង់បែបខ្មែរ។

ឧបករណ៍និងផ្នត់ដើមទាំងប៉ុន្មានសម្រាប់បង្កើតកិរិយាហេតុ ត្រូវបានជំនួសដោយផ្នត់ដែក[-ɑm-/-ɔm-]តែមួយ។

<u>កំណត់សម្គាល់</u> : ផ្នត់ដែក[-m-]ឥតត្រូវបានជំនួសដោយផ្នត់ណាមួយទេ ប៉ុន្តែ តាមភាពជាក់ស្តែង គេបានប្រើវាតែក្នុងពាក្យមួយចំនួនតូចប៉ុណ្ណោះ។

### ៣.២- <u>លទ្ធភាពពង្រីកវិសាលភាព</u>

យើងទើបបានឃើញថា កាលណាពាក្យដើមកើតចេញពីកន្សោមព្យញ្ជនៈ ផ្នត់ដែក[-ɑmn-/-ɔmn-]សម្រាប់បង្កើតនាមកម្លាយសម្គាល់លទ្ធផល, ផ្នត់ដែក[-n-]សម្រាប់បង្កើតនាមកម្លាយសម្គាល់ឧបករណ៍ និង ផ្នត់ដើមទាំងប៉ុន្មានសម្រាប់បង្កើតកិរិយាហេតុសម្គាល់ន័យថា«ធ្វើឱ្យ» ត្រូវបានជំនួសដោយផ្នត់ដែក[-ɑm-/-ɔm-]តែមួយ។

ប៉ុន្តែ ទោះបីក្នុងករណីនៃពាក្យដើមដែលកើតចេញពីកន្សោមព្យញ្ជនៈក៏ដោយ ក៏បុព្វបុរសយើងបានបន្សល់ទុកនូវពាក្យខ្លះៗដែរ ដែលក្នុងនោះផ្នត់ដែក[-n-]សម្រាប់បង្កើតនាមកម្លាយសម្គាល់ឧបករណ៍និងផ្នត់ដើមនានាសម្រាប់បង្កើតកិរិយាកម្លាយសម្គាល់ន័យថា«ធ្វើឱ្យ»(កិរិយាហេតុ) មិនត្រូវបានជំនួសដោយផ្នត់ដែក[-ɑm-/-ɔm-]ទេ គឺ :

- ក្នុងនាមកម្លាយសម្គាល់ឧបករណ៍ : ទ្រាប់ > ទ្រនាប់(មានផ្នត់[-n-]) ;
- ក្នុងកិរិយាកម្លាយសម្គាល់ន័យថា«ធ្វើឱ្យ» : គ្រប់ > បង្គ្រប់(មានផ្នត់[bɑŋ-], ជ្រាប > បញ្ជ្រាប(មានផ្នត់[bɑɲ-]), ភ្លឺ > បំភ្លឺ(មានផ្នត់[bɑm-]),...។

ឧទាហរណ៍ខាងលើអនុញ្ញាតឱ្យយើងពង្រីកវិសាលភាពនៃផ្នត់ដែក[-n-]និងផ្នត់ដើមនានាសម្រាប់បង្កើតកិរិយាហេតុ តាមរយៈពាក្យថ្មីៗដែលសេចក្តីត្រូវការតម្រូវឱ្យយើងបង្កើតឡើង។

ម្យ៉ាងទៀត យើងក៏បានសង្កេតឃើញថា តាមរយៈពាក្យផ្គុំ[17] វិសាលភាពនៃផ្នត់មួយចំនួនត្រូវបានពង្រីកបណ្តើរៗ, ឧទាហរណ៍ :

- ផ្នត់[-ɑmn-/-ɔmn-]តាមរយៈពាក្យ‘ទាក់ទង’បង្កើតបានពាក្យ‘ទំនាក់ទំនង’...;
- ផ្នត់[-ɑm-/-ɔm-]តាមរយៈពាក្យ‘ប្រែប្រួល’បង្កើតបានពាក្យ‘បម្រែបម្រួល’[18]...;
- ផ្នត់ចំរុះ[-b-]និង[-ɑm-/-ɔm-]តាមរយៈពាក្យ‘រកឃើញ’បង្កើតបានពាក្យ‘របកគំហើញ’...។

## ៤- <u>បញ្ហាសទិសសូរវេយ្យាករណ៍វិស័យ</u>

### ៤.១- <u>និយមន័យនិងបម្រើបម្រាស់នៃ‘សទិសសូរវេយ្យាករណ៍វិស័យ’</u>

សទិសសូរវេយ្យាករណ៍វិស័យ គឺជាការប្រើផ្នត់ដូចគ្នា(សទិសសូរ)[19] ឬ បើនិយាយឱ្យងាយយល់ គឺផ្នត់ដដែល/តែមួយសម្រាប់បង្កើតពាក្យកម្លាយដែលសម្គាល់បញ្ញត្តិផ្សេងគ្នា ហើយ ជួនកាល

[17] ខ្ញុំគិតថា ពាក្យដូចជា ទាក់ទង, ប្រែប្រួល, រកឃើញ,... មិនមែនជាពាក្យបន្សំទេ : ខ្ញុំសុំប្រើបណ្តោះអាសន្ននូវ«ពាក្យផ្គុំ»នេះ។

[18] ក្រៅពីការធ្វើកម្លាយទៅលើព្យាង្គទាំងពីរដូចមានក្នុងឧទាហរណ៍ខាងលើ យើងក៏សង្កេតឃើញមានការធ្វើកម្លាយតែទៅលើព្យាង្គទី១ដែរ ដូចជា ដោះស្រាយ > ដំណោះស្រាយ, ខ្វះខាត > កង្វះខាត ជាដើម។

[19] និយមន័យនេះ ផ្តោតលើ‘សទិសសូរវេយ្យាករណ៍វិស័យ’ទាំងមូល មិនសង្កត់តែលើ‘សទិសសូរ’ដែលគេបានស្គាល់ជាទូទៅនោះទេ។

សម្គាល់ប្រភេទពាក្យផ្សេងគ្នាផងទៀត។ សទិសសូរវេយ្យាករណ៍វិស័យដែលខ្ញុំនឹងលើកមកបង្ហាញនៅពេលនេះ គឺសទិស-សូរវេយ្យាករណ៍វិស័យ[-ɑm-/-ɔm-]ដែលមានការប្រើជាន់គ្នាដូចខាងក្រោម :

(១)- ប្រើសម្រាប់បង្កើតនាមសម្គាល់លទ្ធផល : krɑ:ŋ(ក្រង) + [-ɑm-] > kɑmra:ŋ(កម្រង), krọŋ (គ្រោង) + [-ɔm-] > kɔmrọŋ(គម្រោង);

(២)- ប្រើសម្រាប់បង្កើតនាមសម្គាល់ឧបករណ៍ : trɑ:ŋ(ត្រង) + [-ɑm-] > tɑmrɑ:ŋ(តម្រង), krɔ:p (គ្រប) + [-ɔm-] > kɔmrɔ:p(គម្រប);

(៣)- ប្រើសម្រាប់បង្កើតកិរិយាហេតុសម្គាល់ន័យថា«ធ្វើឱ្យ» : trœm(ត្រឹម) + [-ɑm-] > tɑmrœm (តម្រឹម), thlus(ធ្លុះ) + [-ɔm-] > thɔmlus > tɔmlus(ទម្លុះ)។

<u>សង្កេត</u> :

(១)- ក្រៅពីការប្រើផ្នត់ដែក[-ɑm-/-ɔm-]ដើម្បីបង្កើតកិរិយាហេតុដូចខ្ញុំទើបបានលើកឡើងខាងលើ(ដែលជាហេតុនាំឱ្យមានសទិសសូរវេយ្យាករណ៍វិស័យ) បុព្វបុរសខ្មែរក៏បានប្រើផ្នត់ដើម[bɑŋ-], [bɑṇ-], [bɑm-],... ដើម្បីបង្កើតកិរិយាហេតុចេញពីពាក្យដើមដែលមានទម្រង់ជាកន្សោមព្យញ្ជនៈ(ព្យញ្ជនៈ + ព្យញ្ជនៈ)ដែរ, ឧ. គ្រប់ > បង្គ្រប់, ជ្រាប > បញ្ជ្រាប, ភ្លឺ > បំភ្លឺ,...។ វិធីកម្លាយបែបនេះអាចបញ្ចៀសការប្រើផ្នត់ដែក[-ɑm-/-ɔm-] ដើម្បីបង្កើតកិរិយាហេតុ។

(២)- ចំពោះពាក្យកម្លាយសម្គាល់ឧបករណ៍ បុព្វបុរសយើងក៏បានបន្សល់ទុកនូវពាក្យ‘ទ្រនាប់’(កើតចេញពី‘ទ្រាប់’)ផងដែរ។ តាមរយៈពាក្យ‘ទ្រនាប់’នេះ យើងអាចបង្កើតពាក្យកម្លាយសម្គាល់ឧបករណ៍ដោយមិនប្រើផ្នត់ដែក[-ɑm-/-ɔm-][20](ដើម្បីចៀស‘សទិសសូរវេយ្យាករណ៍វិស័យ’)។

<u>កំណត់សម្គាល់</u> : ក្រៅពីផ្នត់ដែក[-ɑɑm-/-ɔm-] យើងក៏សង្កេតឃើញមានសទិសសូរវេយ្យាករណ៍វិស័យតាមរយៈផ្នត់ដើម[រ-] ផងដែរ។ ផ្នត់ដើម [រ-] នេះ ប្រើសម្រាប់បង្កើតពាក្យកម្លាយសម្គាល់ឧបករណ៍ផង និង សម្រាប់បង្កើតកិរិយាសព្ទអកម្មអត្តផល[21]ចេញពីកិរិយាសព្ទសកម្មផង, ឧទាហរណ៍ :

- ឧបករណ៍ : [រ-] + បុក > របុក[22] (ប្រដាប់សម្រាប់បុក, សម្រាប់រុកក្នុងរណ្ដៅ,...), (វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត)។
- កិរិយាសព្ទអកម្មអត្តផល : [រ-] + បើក > របើក។

ប៉ុន្តែសទិសសូរវេយ្យាករណ៍វិស័យតាមរយៈផ្នត់ដើម[រ-] នេះ មិនបានបណ្ដាលឱ្យមានបញ្ហាស្មុកស្មាញដូចសទិសសូរវេយ្យាករណ៍វិស័យ តាមរយៈផ្នត់ដែក[-ɑɑm-/-ɔm-] នោះទេ។

---

[20] ក្នុងករណីដែលអាចធ្វើបានដោយឥតមានបញ្ហាបែបណាមួយ។

[21] ខ្ញុំប្រើពាក្យ‘អត្តផល’នេះសម្រាប់សម្គាល់កិរិយាសព្ទអកម្មមួយប្រភេទដែលកើតចេញពីកិរិយាសព្ទសកម្ម តាមរយៈផ្នត់ដើម[រ-]នេះឯង ដូច-ជា [រ-] + បើក(កិរិយាសព្ទសកម្ម) > របើក(កិរិយាសព្ទអកម្ម) ជាដើម។ កម្មបទផ្ទាល់របស់កិរិយាសព្ទសកម្មដែលរងអំពើត្រូវក្លាយជាប្រធាននៃកិរិយាសព្ទអកម្ម ហើយ ធ្វើអំពើខ្លួនឯងម្ដង, ឧ. គេបើកគម្របផ្ទាំង > គម្របផ្ទាំងរបើក(ខ្លួនឯង)។

[22] តាមធម្មតា ខ្ញុំកត់ត្រាពាក្យខ្មែរដោយប្រើAPI ដោយដាក់ពាក្យខ្មែរជាអក្សរខ្មែរក្នុងវង់ក្រចក ប៉ុន្តែ ក្នុងករណីនេះ(ដូចករណីមួយចំនួនទៀត) ខ្ញុំប្រើតែអក្សរខ្មែរ ពីព្រោះការប្រើតែអក្សរខ្មែរជាការគ្រប់គ្រាន់និងឱ្យផលល្អ។

### ៤.២- ការវិភាគ

យើងសង្កេតឃើញថា :

- ផ្នត់[-ɑm-/-ɔm-] ក្នុងពាក្យកម្លាយ(១)និង(២) សម្គាល់បញ្ញត្តិប្លែកគ្នា តែប្រភេទពាក្យដូចគ្នា (នាមដូចគ្នា);
- ក្នុង(៣) ផ្នត់ដដែលនេះសម្គាល់បញ្ញត្តិប្លែកពីបញ្ញត្តិដែលមានក្នុង(១)និង(២)ផង និង សម្គាល់ប្រភេទពាក្យប្លែកពីប្រភេទពាក្យដែលមានក្នុង(១)និង(២)ផង : (៣)សម្គាល់កិរិយាហេតុ ផ្ទុយពី(១)និង(២)ដែលសម្គាល់នាម។

## សេចក្តីសន្និដ្ឋាន

យើងមិនអាចមិនទទួលស្គាល់ថា ភាសាខ្មែរមានការរីកចម្រើនជាច្រើននោះឡើយ។ ប៉ុន្តែខ្ញុំគ្រាន់តែលើកឡើងនូវចំណុចខ្វះខាតមួយចំនួនដើម្បីទាញអារម្មណ៍សាធារណជនទាំងឡាយលើកង្វះខាតទាំងនោះ ក្រែងអស់លោកយល់ដូចខ្ញុំដែរ ហើយ ព្យាយាមដោះស្រាយនិងធ្វើបែបណាឱ្យភាសាខ្មែរយើងកាន់តែប្រសើរឡើង។

ក្នុងចំណោមកង្វះផ្នត់សម្រាប់ធ្វើវិធីកម្លាយក្នុងភាសាខ្មែរឱ្យមានសម្បូរណ៍បែបនោះ កង្វះផ្នត់សម្រាប់ធ្វើឱ្យកិរិយាសព្ទកម្លាយមានរូបសាស្ត្រប្លែកពីពាក្យដើមដែលជានាមនោះ ជាបញ្ហាចម្បង ហើយខ្ញុំឥតបានឃើញតម្រុយអ្វីដើម្បីលើកឡើងជាសំណើទេ : សូមសាធារណជនជួយពិចារណារកដំណោះស្រាយផង បើអស់លោកគិតថា កង្វះខាតនេះជាបញ្ហាពិតប្រាកដមែន។

ចំពោះវិសាលភាពតូចចង្អៀតនៃផ្នត់មួយចំនួន ខ្ញុំគិតថា បើយើងពង្រីកវាឬបន្តពង្រីក គឺជាការល្អ ដោយយកលំនាំតាម បង្គ្រប់, បញ្ច្រាប, ទ្រនាប់, របកគំហើញ, បម្រើបម្រាស់, ដំណោះស្រាយ, ទំនុកចិត្ត ជាដើម។

ចំពោះបញ្ហាសទិសសូរវេយ្យាករណ៍វិស័យ យើងអាចមានដំណោះស្រាយ បើសាធារណជនទាំងឡាយព្រមទទួលយកសំណើដូចតទៅនេះ[23] :

- ឈប់ប្រើផ្នត់ដែក[-ɑm-/-ɔm-]សម្រាប់បង្កើតនាមកម្លាយសម្គាល់ឧបករណ៍ចេញពីពាក្យដើមដែលកើតឡើងពីកន្សោមព្យញ្ជនៈ គឺឈប់យកលំនាំតាម ‘គ្រប > គម្រប’ ហើយ បែរទៅយកលំនាំតាម ‘ទ្រាប់ > ទ្រនាប់’វិញ;
- ឈប់ប្រើផ្នត់ដែក[-ɑm-/-ɔm-]សម្រាប់បង្កើតកិរិយាសព្ទកម្លាយសម្គាល់ន័យថា«ធ្វើឱ្យ» គឺកិរិយាហេតុ ចេញពីពាក្យដើមដែលកើតឡើងពីកន្សោមព្យញ្ជនៈ គឺឈប់យកលំនាំតាម ‘គ្រប់ > គម្រប់’ ហើយ បែរទៅយកលំនាំតាម ‘គ្រប់ > បង្គ្រប់’, ‘ជ្រាប > បញ្ច្រាប’, ‘ភ្លឺ > បំភ្លឺ’,... វិញ។

ដូច្នេះផ្នត់ដែក[-ɑm-/-ɔm-]ត្រូវប្រើតែសម្រាប់បង្កើតនាមកម្លាយកើតចេញពីពាក្យដើមដែលមានទម្រង់ជាកន្សោមព្យញ្ជនៈ សម្គាល់លទ្ធផល ដូចជា ក្តៅ > កំដៅ, គ្រោង > គម្រោង,...។

---

[23] សំណើទាំងប៉ុន្មានទាក់ទងតែនឹងពាក្យដែលត្រូវបង្កើតថ្មីទេ(យើងមិនត្រូវប៉ះពាល់ដល់ពាក្យដែលមានរួចមកហើយនោះឡើយ)។

កំណត់សម្គាល់ : សំណើខាងលើផ្អែកលើគំរូដ៏រឹងមាំដែលមានក្នុងភាសាខ្មែរៗ រីឯបណ្តុំដូចជា អត្តវិស័យ, អត្តវិស័យភាព, វត្ថុវិស័យភាព ដែលក្នុងនោះ 'វិស័យ' បានធ្វើ 'អត្ត' និង 'វត្ថុ' ឱ្យមានលក្ខណៈជាគុណនាមនោះ វាគ្រាន់តែជាបម្រើបម្រាស់របស់អ្នករៀបរៀងវចនានុក្រមបារាំង-ខ្មែរពីរនាក់ប៉ុណ្ណោះៗ ខ្ញុំបានយកលំនាំតាមពួកគាត់ ដោយបានប្រើបណ្តុំ 'វេយ្យាករណ៍វិស័យ' និង 'សូរវិស័យ' : បើអ្នកអក្សរសាស្ត្រឯទៀតសម្រេចបែបណាៗនោះ ស្រេចតែពួកគាត់ទៅចុះៗ

ខ្ញុំសង្ឃឹមថា ការពិចារណាខាងលើ អាចជាតម្រុយឬជាចលករដែលអាចជំរុញអ្នកអក្សរសាស្ត្រឯ-ទៀតឱ្យចង់សិក្សាឡើងវិញឬសិក្សាបន្តអំពីបម្រើបម្រាស់នៃផ្នត់ក្នុងភាសាខ្មែរ។ បើមានការភាន់ច្រឡំនិង/ឬកង្វះខាតក្នុងការពិចារណានេះ សូមអ្នកអក្សរសាស្ត្រខ្មែរទាំងឡាយជួយកែតម្រូវនិង/ឬបន្ថែមបង្គ្រប់ផង។

## <u>គន្ថនិទ្ទេស</u>


- កេង វ៉ាន់សាក់, មូលភាពនៃការបង្កើតពាក្យថ្មី ភាគទី១ ទ្រឹស្តី បណ្ណាគារស្មើកម្ពុជា ១៩៦៤ ;
- គណៈកម្មការភាសាវិទ្យានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ, គម្រោងវេយ្យាករណ៍ភាសាខ្មែរ កម្រិតមធ្យមសម្រាប់ការប្រើប្រាស់ទូទៅ(មិនទាន់បោះពុម្ពនៅឡើយ) ;
- ច័ន្ទ សំណព្វ, បង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ, រាជបណ្ឌិត្យសភាកម្ពុជា ២០១០ ;
- ពូវ អ៊ុម, វេយ្យាករណ៍ខ្មែរ, បណ្ណាគារ គឹម សេង ភ្នំពេញ ១៩៥៨ ;
- ព្រុំ ម៉ល់, វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប ភាគទី២ : អំពីសព្ទនិងពាក្យ (មានកិច្ច-សហការពី កែវ លីណែត, វ៉ាន់ ម៉ូន, ក. អ៊ឹង ម៉ាល័យ) ផ្សព្វផ្សាយដោយអ្នកនិពន្ធ ២០០៦ ;
- ព្រុំ ម៉ល់, «លទ្ធភាពបង្កើតពាក្យនិងការបង្កើតពាក្យ ក្នុងភាសាខ្មែរ», បទអន្តរាគមន៍ក្នុងសមាជជាតិ ស្តីពីការស្រាវជ្រាវក្នុងភាសាខ្មែរ រៀបចំដោយវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលបានប្រព្រឹត្តទៅ នៅភ្នំពេញ ពីថ្ងៃទី៧ ដល់ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០០, ចុះផ្សាយក្នុងទស្សនាវដ្តីលេខ២ ខែមិថុនា ឆ្នាំ២០០១ របស់វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ;
- ព្រុំ ម៉ល់, «វិភាគសង្ខេប អំពីទម្រង់ភាសាខ្មែរ» កែសម្រួលបន្ថែមបង្គ្រប់ និង ចុះផ្សាយឡើងវិញក្នុងទស្សនាវដ្តី លេខ១ នៃវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០០ ;
- អៀវ កើស, ភាសាខ្មែរ ការល្បងពិនិត្យដោយរកហេតុផល, បណ្ណាគារមូលមិត្ត ភ្នំពេញ ១៩៦៧។

# អន្តែបទ/-អំម.ណា-/ឬ/-អ៊ំម.ន-/

បណ្ឌិត វង្ស មេង
អនុប្រធានវិទ្យាស្ថានភាសាជាតិ

## សេចក្ដីផ្ដើម

អន្តែបទ /-អំម.ណា-/ ឬ /-អ៊ំម.ន-/នៅក្នុងពេលបច្ចុប្បន្នក្លាយជាប្រធានបទមួយយ៉ាងសំខាន់នៃភាសាខ្មែរសម័យទំនើប ពីព្រោះ អន្តែបទនេះមានការសិក្សានិងសម្មតិកម្មពីរផ្សេងគ្នា។ សម្មតិកម្មទីមួយបានលើកឡើងថា អន្តែបទនេះមានតាំងពីសម័យបុរាណកាលមកម្ល៉េះ ហេតុដូច្នេះ ទម្រង់/-អំម.ណា-/ ឬ /-អ៊ំម.ន-/គឺជាទម្រង់មួយដែលមានលក្ខណៈជាអន្តែបទនៅក្នុងភាសាខ្មែរ ដោយរក្សាលក្ខណៈរបស់ខ្លួនតាំងពីបុរាណកាលមក ដូចមាន លោក សាស្ត្រាចារ្យ ឡុង សៀម បានអះអាងបញ្ជាក់ជាភស្តុតាងថា៖ «*តាមសិលាចារឹកមួយចំនួននាសតវត្សទី៧ ផ្នត់ដែក /-អំម.ណា-/ ឬ /-អ៊ំម.ន-/មិនប្រើជាពាក្យកម្លាយធម្មតាទេ គេប្រើវាសម្រាប់សំដែងអំពើ ទម្រង់អកម្មនៃកិរិយាស័ព្ទ(le passif)។ ផ្នត់ដែកនេះទទួលន័យជាផ្នត់ដែក សម្រាប់បង្កើតនាមអរូបីនិងនាមតាងរូបធាតុដោយសារលទ្ធផលដែលទទួលបានពីបម្លែងន័យនៃភាពអកម្ម។*»[១] ជាមួយគ្នានេះ សាស្ត្រាចារ្យ ច័ន្ទ សំណព្វ បានលើកឡើងផងដែរថា៖ «*ផ្នត់ដែក[-អំម.ណា-] ឬ [-អ៊ំម.ន-] អាចកម្លាយពាក្យឫសខ្លះឲ្យកើតបានតែជានាមសព្ទ ហើយក៏អាចកម្លាយពាក្យឫសខ្លះទៀតឲ្យកើតបានទៅជាកិរិយាសព្ទផងនិងនាមសព្ទផង។ ជាក់ស្ដែងផ្នត់ដែក[-អំម.ណា-] កម្លាយពាក្យឫស* ***កើត*** *ឲ្យបានទៅជានាមសព្ទ* ***កំណើត*** *ដែលជានាមសព្ទ។ ផ្នត់ដែកដដែលនេះអាច កម្លាយកិរិយាសព្ទ* ***ចាយ*** *ឲ្យបានទៅជា* ***ចំណាយ*** *ដែលអាចប្រើជាកិរិយាសព្ទក៏បាន។*»[២]

សម្មតិកម្មទីមួយខាងលើសបញ្ជាក់ឲ្យឃើញថា អន្តែបទ*/-អំម.ណា-/ ឬ /-អ៊ំម.ន-/* មានការប្រើប្រាស់តាំងពីសម័យបុរាណរហូតមកដល់សម័យបច្ចុប្បន្ន ដោយមានភស្តុតាងនិងអំណះអំណាងដូចបានពិពណ៌នាដូចខាងលើមកស្រាប់។

សម្មតិកម្មទីពីរបានអះអាងថា ភាសាខ្មែរពុំមានអន្តែបទ*/-អំម.ណា-/ ឬ /-អ៊ំម.ន-/* នោះទេ ដូចសាស្ត្រាចារ្យ នៅ ស៊ុន បានពិពណ៌នាថា[៣]៖ «*...បើយោលតាមទស្សនៈទីពីរ ឃើញថាគ្មាន ផ្នត់ដែក /-អំម.ណា-/ ឬ /-អ៊ំម.ន-/ នោះទេ គឺមានតែផ្នត់ដែក /-អំម-/ ឬ /-ម-/ ប៉ុណ្ណោះនៅក្នុងភាសាខ្មែរ។*» ទាក់ទងទៅនឹងគំនិតនៃការបង្ហាញថា មានទស្សនៈពីរនៅក្នុងការសិក្សានៃអន្តែបទ/-អំម.ណា-/ ឬ /-អ៊ំម.ន-/

---

[១] ឡុង សៀម «ការស្រាវជ្រាវទាក់ទងនឹងកំណកំណើតវាក្យស័ព្ទតាមបម្រើបម្រាស់ផ្នត់នីយកម្ម» ដ.ឯ.ម. ទំព័រ១៦-១៧។

[២] ច័ន្ទ សំណព្វ ***បង្កើតពាក្យ កម្លីពាក្យ បម្រើបម្រាស់ពាក្យ*** រាជបណ្ឌិត្យសភាកម្ពុជា ២០១០ ទំព័រ១១៣។

[៣] នៅ ស៊ុន «ដំណើរការកំលាយពាក្យខ្មែរ» អត្ថបទសិក្ខាសាលា ធ្វើឡើងនៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ទំព័រ៣។

លោកសាស្ត្រាចារ្យ ក៏បានគូសបញ្ជាក់ផងដែរថា៖ «*ដោយសារតែមានការនិយមប្រើប្រាស់សម្រាប់បង្កើតពាក្យថ្មីក៏ដោយ ហើយមានស្នាដៃជាច្រើនទាំងជនជាតិខ្មែរ និង បរទេសបង្ហាញថាការប្រើប្រាស់ផ្នត់ ក្នុងការបង្កើតពាក្យថ្មីជាមធ្យោបាយមួយពេញនិយមក៏ដោយ ក៏បើយោលទៅតាមទស្សនៈយើងផ្ទាល់ឃើញថា អ្នកសិក្សាស្រាវជ្រាវទាំងនោះមិនបានចាប់អារម្មណ៍ខ្លាំងទៅលើដំណើរការកំលាយពាក្យក្នុងភាសាខ្មែរនោះទេ ដែលជាហេតុនាំឲ្យមានការយល់ច្រឡំ ឬ បណ្ដាលឲ្យមានភាពមិនច្បាស់លាស់ ក្នុងការរកមូលដ្ឋាន ឬ ពាក្យគ្រឹះដែលពាក្យថ្មីបានក្លាយចេញ ដូចជាពាក្យ «កំណើត» អ្នកសិក្សាស្រាវជ្រាវមួយក្រុមថា ពាក្យនេះក្លាយចេញពាក្យមូលដ្ឋានឬពាក្យគ្រឹះ«កើត» ដោយប្រើផ្នត់ដែក(អន្តបទ)* /-មន-/ *ចំណែកឯអ្នកសិក្សាស្រាវជ្រាវមួយក្រុមទៀតថាពាក្យនេះក្លាយចេញពាក្យមូលដ្ឋាន ឬពាក្យគ្រឹះ«ក្នើត» (ខ្នើត) ដោយប្រើផ្នត់ដែក* /-អំម-/... *។*»[៤]

ទស្សនៈលើកឡើងរបស់លោក សាស្ត្រាចារ្យ នៅ ស៊ុន ខាងលើចង់បង្ហាញថា នៅក្នុងភាសាខ្មែរ អាចមានដំណើរការបង្កើតពាក្យ តាមរយៈទំនាក់ទំនង ពាក្យមូលដ្ឋានឬពាក្យគ្រឹះ>កម្លាយទីមួយ> កម្លាយទីពីរ។[៥] ការបង្ហាញសម្មតិកម្មនេះឡើង គឺក្នុងបំណងអះអាងថា ភាសាខ្មែរមិនមានអន្តបទ/-អំម.ណ-/ ឬ /-អ៉ំម.ន-/នោះទេ។ ដូចលោក បានលើកឡើងថា៖ « *យើងយល់ថាប្រភេទផ្នត់ក្នុងពាក្យមួយចំនួនដូចជា អំណោយ, អំណាន, អំណួត ជាដើម មិនមែនជាផ្នត់ដែក* /-អំម.ណ-/ ឬ /-អ៉ំម.ន-/ *ដូចដែលអ្នកសិក្សាស្រាវជ្រាវតែងតែនិយមយល់នោះទេ គឺជាផ្នត់ដើម* /-ម.ណ-/ *(ដូចជា វែក-អំវែក, រស់-អំរស់, រក(រក៏)-អំរ, ចាស់-អំចាស់(អម្ចាស់) និងផ្នត់ដែក -ភ- ដាក់ញែកផ្នត់ដើម និងពាក្យមូលដ្ឋានឬពាក្យគ្រឹះ។*»[៦]

សម្មតិកម្មដែលបានលើកឡើងរបស់សាស្ត្រាចារ្យ នៅ ស៊ុន ស្រប គ្នាទៅនឹងគំនិតរបស់សាស្ត្រាចារ្យ ធីធីម៉ា សុធីវណ្ណ[៧] ដោយលោកស្រីបានអះអាងថា ដំណើរការកម្លាយពាក្យនៃអន្តបទ/-អំម.ណ-/ ឬ /-អ៉ំម.ន-/គឺកើតមកដោយសារទំនាក់ទំនងនៃអន្តបទ/-ម-/និង/-ន-/ ដោយលោកស្រីបានពិពណ៌នាថា អន្តបទ /-អំម.ណ-/ ឬ /-អ៉ំម.ន-/ កើតមកអំពីពាក្យឫស ដោយប្រើវិធីកម្លាយទីមួយនៃអន្តបទ/-ន-/ ហើយប្រើអន្តបទ/-ម-/លើអន្តបទ/-ន-/ សម្រាប់បង្កើតអន្តបទ/-អំម.ណ-/ ឬ /-អ៉ំម.ន-/។ ការណ៍នេះលោកស្រី បានលើកអំណះអំណាងបង្ហាញថា៖

---

[៤] ដដែល ទំព័រ២-៣។

[៥] ដដែល ទំព័រ៤។

[៦] នៅ ស៊ុន «ដំណើរការកំលាយពាក្យខ្មែរ» អត្ថបទទសិក្ខាសាលា ធ្វើឡើងនៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ទំព័រ១៥។

[៧] សាស្ត្រាចារ្យ ធីធីម៉ា សុធីវណ្ណ ជាសាស្ត្រាចារ្យបង្រៀនភាសាថៃ នៅមហាវិទ្យាល័យសិល្បៈនិងសង្គមសាស្ត្រ សាកលវិទ្យាល័យជាតិសិង្ហបុរី ( National University of Singapore, NUS )។ ការលើកឡើងនេះជាការផ្ដល់យោបល់លើការដឹកនាំនិក្ខេបបទរបស់ស្មេរ នៃថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨ នៅសាកលវិទ្យាល័យជាតិសិង្ហបុរី។

កើត + /-ន-/> ខ្នើត + /-ម-/> កំណើត

កួច + /-ន-/> ឃ្នួច + /-ម-/> កំណួច

គាប + /-ន-/> ឃ្នាប + /-ម-/> គំនាប

កប់ + /-ន-/> ខ្នប់ + /-ម-/> កំណប់

ជាន់ + /-ន-/> ឈ្នាន់ + /-ម-/> ជំនាន់

បន្ថែមពីលើនេះទៀត លោកស្រីសាស្ត្រាចារ្យ បានបង្ហើបឲ្យដឹងទៀតថា ពាក្យកម្លាយដែលប្រើប្រាស់អន្តែបទ/-ន-/មិនមាន មានត្រឹមតែ /-ម-/ ដោយសារថា ដំណាក់កាលទីមួយដែលប្រើប្រាស់អន្តែបទ /-ន-/បានបាត់បង់ ហើយមានត្រឹមតែ/-ម-/ ដូចជា៖

កាត់+ /-ន-/> ខ្នាត់ ? + /-ម-/> កំណាត់

តែង + /-ន-/> ត្នែង ? + /-ម-/> តំណែង

ចាយ + /-ន-/> ច្នាយ ? + /-ម-/> ចំណាយ

ជន់ + /-ន-/> ឈ្នន់ ? + /-ម-/> ជំនន់

ទុក + /-ន-/> ធ្នុក ? + /-ម-/> ទំនុក

ការបាត់បង់អន្តែបទ /-ន-/ នៅក្នុងពាក្យកម្លាយដែលមានបុច្ឆនសញ្ញាខាងលើ ទំនងជាអាចរកឃើញឬអាចមាននៅក្នុងពាក្យខ្មែរបុរាណ។

ទោះបីជាយ៉ាងណាក៏ដោយ អ្វីដែលលោកស្រីសាស្ត្រាចារ្យបានលើកឡើងគឺជាសម្មតិកម្មមួយដែលមានលក្ខណៈសមហេតុសមផល និង អាចជាគំនិតពិចារណាសម្រាប់ការសិក្សាអំពីដំណើរការនៃពាក្យកម្លាយនៅក្នុងភាសាខ្មែរ។

លោក ហ្វីលីប ជេនន័រក៏បានពិពណ៌នាផងដែរអំពីទម្រង់នៃអន្តែបទ/-អំម.ណ-/ ឬ /-អ៉ំម.ន-/។ លោកបានបង្ហាញថា[៨]៖ *«ភាសាខ្មែរទំនើបមានព្យាង្គអន្តែបទទោល។ អន្តែបទនេះបង្ហាញទម្រង់ពីរដែលជាវិភាគទានយ៉ាងសំខាន់បំផុត /-Vmn-/ ដែលកើតឡើងជាមួយទម្រង់មូលដ្ឋានទីមួយយ៉ាងច្បាស់លាស់ ហើយ /-Vn-/កើតឡើងនៅក្នុងទម្រង់ទីពីរ។ ទម្រង់ទាំងពីរនេះ V តំណាង «អឬអ៊» ចំណែកឯ N តំណាង /ម, ន, ង/។ ទម្រង់/-Vmn-/មានកាឡូរូបCចំណែកឯទម្រង់ /-Vn-/ មានកាឡូរូប /-អ៉ំម-, -អ៉ំន-, -អ៉ំង-/និង /-អំម-, -អំន-, -អំង-/។ កាឡូរូប /-អ៉ំន-, -អាំន-/មានលក្ខណៈផ្សេងៗពីគ្នា។ ព្យាង្គអន្តែបទត្រូវគេបញ្ចូល ដូចនៅក្នុងអព្យាង្គអន្តែបទដែរ គេបញ្ចូលទៅក្នុងពាក្យដោយផ្ទាល់បន្ទាប់ពីព្យញ្ជនៈដើមព្យាង្គ។ ពាក្យកម្លាយជាលទ្ធផលបានក្លាយទៅជាទ្វេព្យាង្គដែលព្យញ្ជនៈដើមព្យាង្គគឺជាបុព្វ ទ្វេព្យាង្គ។ ពាក្យកម្លាយនៃទម្រង់មូលដ្ឋានទីមួយមានព្យាង្គដើម/-n-/ បួល(to utter, talk)> ពំនោល (talking), ចាយ> ចំណាយ។ ពាក្យកម្លាយទម្រង់ទីពីរមានពាក្យឫសជាព្យាង្គបន្ទាប់ពីព្យាង្គសំខាន់ ជ្រៅ>ជម្រៅ, ផ្អាត់>បង្អាត់។»*

---

[៨] Philip N. Jenner, *Affixation in Modern Khmer*, op.cit., p.165.

ទម្រង់បែបនេះមាន/-Vmn-/ ដែលកើតពីពាក្យឫសទីមួយដែលគេហៅថា ពាក្យកម្លាយទីមួយ។ ទម្រង់/-Vn-/អាចបង្កើតពាក្យជាមួយពាក្យឫសទីពីរដែលគេហៅថាពាក្យកម្លាយទីពីរ។

លោក ហ្សក ម៉ាស្ប៉េរ៉ូ មិនបានកត់សម្គាល់សមានកម្មនៃអន្តែបទ/-VN-/ នោះទេ។[៩] ដោយមើលឃើញភាសាខ្មែរពីសំណេរជាដំបូង គាត់បានបែងចែកអសមានកម្មនៃ /-Vm-/ ពីសមានកម្មនៃ /(V)N-/.

លោក ស្រី ជូឌីត ចាកុប[១០] ធ្វើការកត់សម្គាល់ទាំងទម្រង់ /-Vmn-/ និង /-VN-/ ដោយលោកស្រីបានអះអាងថា ទម្រង់នេះបង្កើតពាក្យនៅក្នុងភាសាខ្មែរគឺមានមុខងារសម្រាប់បង្កើតនាមនីយកម្ម ហើយទម្រង់/-VN-/ សម្រាប់បង្កើតនាមឧបករណ៍និងនាមភ្នាក់ងារ។

ដូចបានរៀបរាប់ខាងលើ យើងអាចធ្វើការកត់សម្គាល់ថា ទម្រង់ /-អំម.ណា-/ឬ/-អុំម.ន-/ស្ថិតនៅលើ ការពិចារណានៅឡើយថាតើ ទម្រង់បែបនេះគ្រាន់តែជាទម្រង់កើតមាន នៅក្នុងភាសាខ្មែរបុរាណឬយ៉ាងណាឬមួយអាចជាអន្តែបទនៅក្នុងភាសាខ្មែរទំនើបផង។ គំនិតនិងទស្សនៈចំពោះទម្រង់ខាងលើ យើងសង្កេតឃើញថា យោបល់អ្នកស្រាវជ្រាវខាងបស្ចិមប្រទេសបង្ហាញថា ទម្រង់/-អំម.ណា-/ឬ/-អុំម.ន-/គឺជាដំណើរការឬជាទំនាក់ទំនងរវាងអន្តែបទ /-ម-/ឬ/-ន-/តែប៉ុណ្ណោះ ដោយហេតុថា ស្រៈ«អ»ខាងមុខគឺគ្រាន់តែជាអាគមសម្រាប់សម្រួលអំណាននៅក្នុងភាសាខ្មែរ។ គំនិតបែបនេះ យើងមិនទាត់ចោលទាំងស្រុងនៅក្នុងការសិក្សារបស់យើងនោះទេ តែយើងនឹងធ្វើការពិចារណា រកហេតុផលនិងតក្កភាពនៅក្នុងភាសាខ្មែរ ដោយសម្អាងទៅលើទិន្នន័យដែលយើងប្រមូលបានថាតើ ទម្រង់នោះជាអន្តែបទឬមិនមែន។ ទិន្នន័យដែលយើងមានអំពីទម្រង់/-អំម.ណា-/ឬ/-អុំម.ន-/និងការពន្យល់ពាក្យនោះបានបង្ហាញថា ពាក្យទាំងឡាយនោះកើតមកអំពីពាក្យឫសដូចមាននៅក្នុងការពន្យល់នៅក្នុងវចនានុក្រមបោះពុម្ពឆ្នាំ១៩៦៧ជាភស្តុតាងស្រាប់។ ផ្តើមចេញអំពី នោះទិន្នន័យទាំង១៥៩ពាក្យបានបង្ហាញថាពាក្យទាំងនោះមានប្រភពមកអំពី ពាក្យឫស ហើយមុខងារវេយ្យាករណ៍មាន***នាមលទ្ធផលឬអំពើ កិរិយាសព្ទ គុណនាម និងនិបាតសព្ទ***។

## ៤.១. ការវិភាគទម្រង់/-អំម.ណា-/ឬ/-អុំម.ន-/

ដោយសម្មតិកម្មពីរបានលើកឡើងខាងលើ យើងនឹងធ្វើការវិភាគថាតើទម្រង់ /-អំម.ណា-/ឬ/-អុំម.ន-/ជាអន្តែបទដើមឬមួយជាទម្រង់កម្លាយពីរជាន់។ ដូចយើងបានបង្ហាញជូននៅក្នុងសេចក្ដីផ្តើមខាងលើស្រាប់ថា ទម្រង់នេះមានសម្មតិកម្មពីរ។ សម្មតិកម្មទីមួយយល់ថាមិនមានអន្តែបទ /-អំម.ណា-/ឬ/-អុំម.ន-/នោះទេ ដោយមតិនេះបានអះអាងថា ទម្រង់ /-អំម.ណា-/ឬ/-អុំម.ន-/ គឺកើតឡើងតាមវិធី

[៩] Georges, Maspero, ***Grammaire de la langue khmère*** (cambodgien), op.cit., p.211-115.

[១០] Judith M. Jacob, ***Introduction to Cambodian***, op.cit., p.66-69.

កម្លាយទីមួយនឹងទីពីរ ពាក្យកម្លាយទីមួយកើតមកអំពី អន្តេបទ/-ន-/ ចំណែកឯពាក្យកម្លាយទីពីរកើតមកអំពីអន្តេបទ/-ន-/ជាមួយនឹងអន្តេបទ/-អំម-/ ដើម្បីបង្កើតទម្រង់/-អំម.ណ-/ឬ/-អ៊ំម.ន-/ ដូចមាននៅក្នុងតារាងខាងក្រោម៖

| **ពាក្យមូលដ្ឋានឬពាក្យគ្រឹះ** | **កម្លាយទីមួយ** | **កម្លាយទីពីរ** |
|---|---|---|
| កប់ | ក្នុប់ (ខ្នប់) | កំណប់ |
| កើត | ខ្នើត | កំណើត |
| កួច | ក្នួច (ខ្នួច) | កំនួច |
| កៀរ | ក្នៀរ (ខ្នៀរ) | កំណៀរ |
| កៀស | ក្នៀស(ខ្នៀស) | កំណៀស |
| គាប | គ្នាប (ឃ្នាប) | គំនាប |
| គូស | គ្នូស (ឃ្នូស) | គំនូស |
| ចាប់ | ច្នាប់ (ឆ្នាប់) | ចំណាប់ (អារម្មណ៍) |
| ជាប់ | ជ្នាប់ (ឈ្នាប់) | ជំនាប់ |
| ជូត | ជ្នូត (ឈ្នូត) | ជំនូត |
| ដង | ត្នង (ថ្នង) | ដំណង |
| ដូរ | ត្នូរ (ថ្នូរ) | ដំណូរ |
| ដាក់ | ត្នាក់ (ថ្នាក់) | (តំ) ដំណាក់ |
| ដេរ | ត្នេរ (ថ្នេរ) | ដំណេរ |
| ទាក់ | ទ្នាក់ (ធ្នាក់) | ទំនាក់ |
| ទើរ | (ទ្នើរ) ធ្នើរ | ទំនើប |
| បែក | ប្នែក (ផ្នែក) | បំណែក |
| ពាក់ | ព្នាក់ (ភ្នាក់) | ពំនាក់ |

*តារាងទីមួយ[១១]៖ ទម្រង់ដំណើរការកម្លាយពាក្យមូលដ្ឋានឬពាក្យគ្រឹះ ទៅកម្លាយទីមួយ ដោយ*

[១១] នៅ ស៊ុន ***ដំណើរការកម្លាយពាក្យខ្មែរ*** ដ.ឯ.ម. ទំព័រ៨-៩។

*ប្រើផ្នត់ដែកជាព្យញ្ជនៈសូរទោល -n- និងពីកម្លាយទីមួយទៅកម្លាយទីពីរដោយប្រើផ្នត់ដែកជាបន្សំសូរ ស្រៈផ្សំនិងព្យញ្ជនៈ/-អំម-/និង/-ម.ណ-/*

ការបកស្រាយខាងលើគឺចង់បង្ហាញថា អន្តេបទ /-អំម.ណ-/ឬ/-អឹម់.ន-/ជាទម្រង់អន្តេបទដែលកើតឡើងដោយសារ ទំនាក់ទំនង ពាក្យមូលដ្ឋានឬពាក្យគ្រឹះ> កម្លាយទីមួយ> កម្លាយទីពីរ។ នេះបានន័យថា អន្តេបទ/-អំម.ណ-/ឬ/-អឹម់.ន-/កើតមកអំពីអន្តេបទ/-ន-/ ដោយប្រើអន្តេបទ/-អំម-/។ ដូចគ្នានេះផងដែរ លោក ហ្វីលីប ជែនន័រក៏បានបង្ហាញផងដែរថា៖« *ការបកស្រាយមួយបែបទៀតគឺថា /-អំម.ណ-/គឺ ជាសមាសដែលរួមមាន/-អំន-/ជាមួយនឹងCCVF ពាក្យឫសដែល ព២គឺអន្តេបទ/-ន-/៖ បួស> ផ្នួស>បំណួស; ដាំ>ថ្នាំ>ដំណាំ។ លទ្ធភាពពាក្យកម្លាយ/-អំម.ណ-/មួយចំនួនអាចត្រូវគេយកមកធ្វើការប្រៀបធៀបផ្ទាល់ពីពាក្យឫស(មានន័យថា គ្មានការសម្របសម្រួលទៅនឹងឫសនៃCCVF) ដែលគ្មានទិដ្ឋភាពផ្លាស់ប្តូរនៃមធ្យោបាយមិនសមស្របនោះទេ។*»[១២]

ទស្សនៈទីមួយនេះគឺជាលើកឡើង ដោយគ្រាន់តែជាអំណះអំណាងតែមួយប៉ុណ្ណោះហើយ យើងយល់ថាមិនទាន់មានលក្ខណៈរឹងមាំនៅឡើយ ពីព្រោះថា ដំណើរការនៃកម្លាយពាក្យ ពីពាក្យឫសទៅកម្លាយទីមួយនិងពីកម្លាយទីពីរមិនមានលក្ខណៈប្រត្យក្សភាព។ នៅក្នុងភាសាខ្មែរបច្ចុប្បន្ន វាក្យស័ព្ទខ្លះមានដំណើរការកម្លាយពាក្យត្រឹមតែពីពាក្យឫសទៅកម្លាយទីពីរ ចំណែកឯវាក្យស័ព្ទខ្លះទៀតមានត្រឹមតែពាក្យឫសទៅកម្លាយទីមួយតែម្តង ដោយយើងមិនឃើញមាននៅក្នុងកម្លាយទីពីរ ដូចមានតារាងបង្ហាញជូនខាងក្រោម៖

| **ពាក្យមូលដ្ឋានឬពាក្យគ្រឹះ** | **កម្លាយទីមួយ** | **កម្លាយទីពីរ** |
|---|---|---|
| ក | - | កំណ |
| កត់ | - | កំណត់ |
| គរ | - | គំនរ |
| គួរ | - | គំនួរ |
| គិត | - | គំនិត |
| ជួញ | - | ជំនួញ |
| ទិញ | - | ទំនិញ |
| ចូល | - | ចំណូល |

[១២] Philip N. Jenner, ***A Dictionary of pre-Angkorian Khmer***, Doug Cooper (ed.), Pacific Linguistics: Research school of Pacific and Asian Studies, Australian National University, 2009, p.xvii.
*<< Another interpretation is that /-amn-/ is compound, consisting of /-am-/ with a CCVF wordbase in which $C_2$ is infix /-n-/: pvas / ' to enter holy orders', > phnvas 'holy orders', > pamnvas 'one in holy orders'; tāṃ 'to plant',>*thnāṃ (cf. Modern thnāṃ) /tʰnam/ 'plant', > taṃnāṃ 'plantation, land under crops'. The liklihood that some /-amn-/ derivatives may have ben minted analogicallly direct from primary wordbases. (i.e., with no mediating CCVF base) in no way invalidates this alternative view.>>*

*តារាងទីពីរ ពាក្យមួយចំនួនដែលក្នុងការកម្លាយមិនដើរតាមលំដាប់លំដោយៈ ពាក្យមូលដ្ឋានឬពាក្យគ្រឹះ> កម្លាយទីមួយ>កម្លាយទីពីរគឺ ក្លាយពីពាក្យមូលដ្ឋាន> កម្លាយទីពីរ*[១៣]

ការពន្យល់ខាងលើ គឺក្នុងគោលបំណងបង្ហាញថាភាសាខ្មែរទាក់ទងទៅនឹងទម្រង់/-អំម.ណ-/ហាក់ដូចជាមិនមាននោះផងទេ ដោយហេតុថា ភាសាខ្មែរអាចមានដំណើរការកម្លាយពាក្យពីពាក្យឫស > កម្លាយទីមួយ> កម្លាយទីពីរ។ សម្មតិកម្មនេះមានលក្ខណៈសមរម្យនឹងមានតក្កភាពអាចទទួលយកបាន ក៏ប៉ុន្តែសំណើនេះហាក់ដូចជា ស្រពិចស្រពិលមិនមានលក្ខណៈទូទៅនិងមិនសមស្របនៅក្នុងភាសាខ្មែរ។ ពីព្រោះ យើងសង្កេតឃើញថា ដំណើរការនេះមានតិចតួចនៅក្នុងភាសាខ្មែរ លក្ខណៈស្ដួចស្ដើងបែបនេះមិនអាចធ្វើជាឧបភាសកម្មបានឡើយ ក៏ប៉ុន្តែ យើងអាចយកចំណុចឬលក្ខណៈទាំងនោះមកធ្វើការពិចារណា។

សម្មតិកម្មទីពីរយល់ថា ទម្រង់/-អំម.ណ-/ឬ/-អំម.ន-/គឺជាអន្តែបទដែលមានមុខងារសំខាន់សម្រាប់បង្កើតនាមសម្គាល់លទ្ធផលនិងអំពើ ព្រមទាំងទម្រង់ទាំងនេះមានកំណើតមកអំពី ពាក្យឫសជាមូលដ្ឋានផងដែរ។ តួយ៉ាងដូចជា សាស្ត្រាចារ្យ ព្រុំ ម៉ល់ បានលើកឡើងថា អន្តែបទ/-អំម.ណ-/ឬ/-អំម.ន-/អាចប្រើដើម្បីបង្កើតពាក្យកម្លាយ សម្រាប់នាមលទ្ធផលឬអំពើ។[១៤] លោក សាស្ត្រាចារ្យ ហ្វីលីប ជេនន័របានគូសបញ្ជាក់ផងដែរថា អន្តែបទ/-អំម.ណ-/ឬ/-អំម.ន-/ គឺជាអន្តែបទបុរាណ ដែលកើតឡើងដោយផ្ទាល់បន្ទាប់ពីពាក្យឫស។[១៥]

## ៤.២. មុខងារវេយ្យាករណ៍ទម្រង់/-អំម.ណ-/ឬ/-អំម.ន-/

លោក សាស្ត្រាចារ្យ ព្រុំ ម៉ល់ បានលើកបង្ហាញថា អន្តែបទ/-អំម.ណ-/ឬ/-អំម.ន-/អាចជាអន្តែបទដែលប្រើប្រាស់ ដើម្បីបង្កើតពាក្យកម្លាយសម្គាល់លទ្ធផលឬអំពើ។[១៦] ដូចមាននៅក្នុងឧទាហរណ៍[១៧]៖

កាត់ + /-អំម.ណ-/ > កំណាត់
គួរ + /-អំម.ន-/ > គំនួរ

---

[១៣] នៅ ស៊ុន ***ដំណើរការកម្លាយពាក្យខ្មែរ*** ដ.ឯ.ម. ទំព័រ១២។

[១៤] ព្រុំ ម៉ល់ ***ភាសាវិទ្យាអនុវត្តន៍៖ វេយ្យាករណ៍ទម្រង់និយនៃភាសាខ្មែរទំនើប*** ដ.ឯ.ម. ទំព័រ៦-១១។

[១៥] Philip N. Jenner, Dictionary of pre-Angkorian Khmer, op.cit., p.xvii <<*The infixes of Old Khmer include /-b-, -m-, -n-/ and /-əN-~əmn-/, which occur directly after the wordbase initial.*>>

[១៦] ព្រុំ ម៉ល់ ***ភាសាវិទ្យាអនុវត្តន៍៖ វេយ្យាករណ៍ទម្រង់និយនៃភាសាខ្មែរទំនើប*** ដ.ឯ.ម. ទំព័រ៦-៧។

[១៧] ឧទាហរណ៍ទាំងនេះគឺជាឧទាហរណ៍ដែលលោកសាស្ត្រាចារ្យបានយកមកពន្យល់ ហើយយើងលើកយកបង្ហាញនិងពិចារណា។

ចាស់ + /-អំម.ណ-/ > ចំណាស់

ចាំ + /-អំម.ណ-/ > ចំណាំ

ធី + /-អំម.ណ-/ > ចំណី

ជិះ + /-អុំម.ន-/ > ជំនិះ

ដឹង + /-អំម.ណ-/ > ដំណឹង

តាង + /-អំម.ណ-/ > តំណាង

ទាប + /-អុំម.ន-/ > ទំនាប

នាំ + /-អុំម.ន-/ > នម្នាំ>លំនាំ

បិទ + /-អំម.ណ-/ > បំណិទ

ពិត + /-អុំម.ន-/ > ពំនិត

សូក + /-អំម.ណ-/ > សំណូក

អរ + /-អំម.ណ-/ > អំណរ

លោក សាស្ត្រាចារ្យ ហ្វីលីប ជែននើរ បានបែងចែកប្រភេទវេយ្យាករណ៍នៃទម្រង់នេះជា៤ប្រភេទ គឺ នាមដំណើរការ, នាមលទ្ធផល, នាមភ្នាក់ងារ-ឧបករណ៍-ទីកន្លែង, និង នាមសមូហភាព។[១៨] ប្រភេទដូចបានរៀបរាប់ខាងលើគឺចង់បង្ហាញថា គំនិតរបស់លោកគឺ ផ្អែកទៅលើន័យនៃពាក្យរបស់ពាក្យកម្លាយ។

ចំពោះយើងវិញ ទិន្នន័យដែលយើងបានវិភាគនិងរកប្រភេទវេយ្យាករណ៍របស់ពាក្យកម្លាយទម្រង់/-អំម.ណ-/ឬ/-អុំម.ន-/នេះគឺផ្អែកទៅលើទិន្នន័យចំនួន១៥៩ ពាក្យ ដោយយើងបានបែងចែកទៅជា នាមសម្គាល់លទ្ធផលឬអំពើ គុណនាម កិរិយាសព្ទ និងនិបាតសព្ទ។

### ៤.២.១. ទម្រង់/-អំម.ណ-/ឬ/-អុំម.ន-/ បង្កើតនាមសព្ទ

នាមសព្ទនេះអាចមានប្រភពមកអំពីពាក្យឫសជា កិរិយាសព្ទ គុណនាម កិរិយាវិសេសន៍ នាមសព្ទ ជាដើម។

| | | | | |
|---|---|---|---|---|
| កក | + | /-អំម.ណ-/ | > | កំណក |
| កត់ | + | /-អំម.ណ-/ | > | កំណត់ |
| កប់ | + | /-អំម.ណ-/ | > | កំណប់ |
| កល់ | + | /-អំម.ណ-/ | > | កំណល់ |
| កាច | + | /-អំម.ណ-/ | > | កំណាច |
| កាច់ | + | /-អំម.ណ-/ | > | កំណាច់ |

[១៨] Philip N. Jenner, ***Affixation in Modern Khmer***, op.cit., p.169-172.

| | | | | |
|---|---|---|---|---|
| កាញ់ | + | /-អ់ម.ណ-/ | > | កំណាញ់ |
| កាត់ | + | /-អ់ម.ណ-/ | > | កំណាត់ |
| កាព្យ | + | /-អ់ម.ណ-/ | > | កំណាព្យ |
| កិន | + | /-អ់ម.ណ-/ | > | កំណិន |
| កួច | + | /-អ់ម.ណ-/ | > | កំណួច |
| កើត | + | /-អ់ម.ណ-/ | > | កំណើត |
| កើន | + | /-អ់ម.ណ-/ | > | កំណើន |
| កើល | + | /-អ់ម.ណ-/ | > | កំណើល |
| កៀង | + | /-អ់ម.ណ-/ | > | កំណៀង |
| កៀច | + | /-អ់ម.ណ-/ | > | កំណៀច |
| កៀរ | + | /-អ់ម.ណ-/ | > | កំណៀរ |
| កៀវ | + | /-អ់ម.ណ-/ | > | កំណៀវ |
| កៀស | + | /-អ់ម.ណ-/ | > | កំណៀស |
| កេះ | + | /-អ់ម.ណ-/ | > | កំណេះ |
| កែ | + | /-អ់ម.ណ-/ | > | កំណែ |
| កែន | + | /-អ់ម.ណ-/ | > | កំណែន |
| កោង | + | /-អ់ម.ណ-/ | > | កំណោង |
| កោត | + | /-អ់ម.ណ-/ | > | កំណោត |
| កោន | + | /-អ់ម.ណ-/ | > | កំណោន |
| កោរ | + | /-អ់ម.ណ-/ | > | កំណោរ |
| កោស | + | /-អ់ម.ណ-/ | > | កំណោស |
| កោះ | + | /-អ់ម.ណ-/ | > | កំណោះ |
| គង | + | /-អ៉់ម.ន-/ | > | គំនង |
| គម | + | /-អ៉់ម.ន-/ | > | គំនម |
| គាក់ | + | /-អ៉់ម.ន-/ | > | គំនាក់ |
| គាត | + | /-អ៉់ម.ន-/ | > | គំនាត |
| គាប | + | /-អ៉់ម.ន-/ | > | គំនាប |
| គាប់ | + | /-អ៉់ម.ន-/ | > | គំនាប់ |
| គាល់ | + | /-អ៉់ម.ន-/ | > | គំនាល់ |
| គិត | + | /-អ៉់ម.ន-/ | > | គំនិត |
| គូរ | + | /-អ៉់ម.ន-/ | > | គំនូរ |

| | | | |
|---|---|---|---|
| គូស | + | /-អ៊់ម.ន-/ | > គំនូស |
| គួប | + | /-អ៊់ម.ន-/ | > គំនួប |
| គួរ | + | /-អ៊់ម.ន-/ | > គំនួរ |
| គោះ | + | /-អ៊់ម.ន-/ | > គំនោះ |
| គុំ | + | /-អ៊់ម.ន-/ | > គំនុំ |
| ចង | + | /-អ់ម.ណ-/ | > ចំណង |
| ចង់ | + | /-អ់ម.ណ-/ | > ចំណង់ |
| ចត | + | /-អ់ម.ណ-/ | > ចំណត |
| ចត់ | + | /-អ់ម.ណ-/ | > ចំណត់ |
| ចាក់ | + | /-អ់ម.ណ-/ | > ចំណាក់ |
| ចាប់ | + | /-អ់ម.ណ-/ | > ចំណាប់ |
| ចាយ | + | /-អ់ម.ណ-/ | > ចំណាយ |
| ចារ | + | /-អ់ម.ណ-/ | > ចំណារ |
| ចាល់ | + | /-អ់ម.ណ-/ | > ចំណាល់ |
| ចាស់ | + | /-អ់ម.ណ-/ | > ចំណាស់ |
| ចិត | + | /-អ់ម.ណ-/ | > ចំណិត |
| ចី | + | /-អ់ម.ណ-/ | > ចំណី |
| ចុច | + | /-អ់ម.ណ-/ | > ចំណុច |
| ចុះ | + | /-អ់ម.ណ-/ | > ចំណុះ |
| ចង | + | /-អ់ម.ណ-/ | > ចំណង |
| ចូក | + | /-អ់ម.ណ-/ | > ចំណូក |
| ចូរ | + | /-អ់ម.ណ-/ | > ចំណូរ |
| ចូល | + | /-អ់ម.ណ-/ | > ចំណូល |
| ចេញ | + | /-អ់ម.ណ-/ | > ចំណេញ |
| ចិរឬចីរ | + | /-អ់ម.ណ-/ | > ចំណេរ |
| ចេះ | + | /-អ់ម.ណ-/ | > ចំណេះ |
| ចែក | + | /-អ់ម.ណ-/ | > ចំណែក |
| ចោត | + | /-អ់ម.ណ-/ | > ចំណោត |
| ចោទ | + | /-អ់ម.ណ-/ | > ចំណោទ |
| ចោម | + | /-អ់ម.ណ-/ | > ចំណោម |
| ចោះ | + | /-អ់ម.ណ-/ | > ចំណោះ |

| | | | | |
|---|---|---|---|---|
| ចាំ | + | /-អ់ម.ណ-/ | > | ចំណាំ |
| ចាំង | + | /-អ់ម.ណ-/ | > | ចំណាំង |
| ចួប | + | /-អ់ម.ណ-/ | > | ចំនួប |
| ចៀរ | + | /-អ់ម.ណ-/ | > | ចំនៀរ |
| ជន់ | + | /-អ៊់ម.ន-/ | > | ជំនន់ |
| ជា | + | /-អ៊់ម.ន-/ | > | ជំនា |
| ជាង | + | /-អ៊់ម.ន-/ | > | ជំនាង |
| ជាន់ | + | /-អ៊់ម.ន-/ | > | ជំនាន់ |
| ជាប់ | + | /-អ៊់ម.ន-/ | > | ជំនាប់ |
| ជិះ | + | /-អ៊់ម.ន-/ | > | ជំនិះ |
| ជីក | + | /-អ៊់ម.ន-/ | > | ជំនីក |
| ជូន | + | /-អ៊់ម.ន-/ | > | ជំនូន |
| ជួញ | + | /-អ៊់ម.ន-/ | > | ជំនួញ |
| ជួយ | + | /-អ៊់ម.ន-/ | > | ជំនួយ |
| ជួស | + | /-អ៊់ម.ន-/ | > | ជំនួស |
| ជឿ | + | /-អ៊់ម.ន-/ | > | ជំនឿ |
| ជឿន | + | /-អ៊់ម.ន-/ | > | ជំនឿន |
| ជោរ | + | /-អ៊់ម.ន-/ | > | ជំនោរ |
| ជុំ | + | /-អ៊់ម.ន-/ | > | ជំនុំ |
| ឈប់ | + | /-អ៊់ម.ន-/ | > | ជំហប់ |
| ឈរ | + | /-អ៊់ម.ន-/ | > | ជំហរ |
| ឈាន | + | /-អ៊់ម.ន-/ | > | ជំហាន |
| ឈូស | + | /-អ៊់ម.ន-/ | > | ជំហូស |
| ឈោង | + | /-អ៊់ម.ន-/ | > | ជំហោង |
| ដឹង | + | /-អ់ម.ណ-/ | > | ដំណឹង |
| ដក | + | /-អ់ម.ណ-/ | > | ដំណក |
| ដក់ | + | /-អ់ម.ណ-/ | > | ដំណក់ |
| ដាក់ | + | /-អ់ម.ណ-/ | > | ដំណាក់ |
| ដាច់ | + | /-អ់ម.ណ-/ | > | ដំណាច់ |
| ដឹង | + | /-អ់ម.ណ-/ | > | ដំណឹង |
| ដាប់ | + | /-អ់ម.ណ-/ | > | ដំណាប់ |

| | | | | |
|---|---|---|---|---|
| ដុស | + | /-អំម.ណ-/ | > | ដំណុស |
| ដួច | + | /-អំម.ណ-/ | > | ដំណួច |
| ដួច | + | /-អំម.ណ-/ | > | ដំណួច |
| ដួល | + | /-អំម.ណ-/ | > | ដំណួល |
| ដើរ | + | /-អំម.ណ-/ | > | ដំណើរ |
| ដៀល | + | /-អំម.ណ-/ | > | ដំណៀល |
| ដេក | + | /-អំម.ណ-/ | > | ដំណេក |
| ដេញ | + | /-អំម.ណ-/ | > | ដំណេញ |
| ដែល | + | /-អំម.ណ-/ | > | ដំណែល |
| ដោះ | + | /-អំម.ណ-/ | > | ដំណោះ |
| ដំ | + | /-អំម.ណ-/ | > | ដំណំ |
| ដាំ | + | /-អំម.ណ-/ | > | ដំណាំ |
| ត | + | /-អំម.ណ-/ | > | តំណ |
| តក់ | + | /-អំម.ណ-/ | > | តំណក់ |
| តាង | + | /-អំម.ណ-/ | > | តំណាង |
| តិះ | + | /-អំម.ណ-/ | > | តំណិះ |
| តូច | + | /-អំម.ណ-/ | > | តំណូច |
| តែង | + | /-អំម.ណ-/ | > | តំណែង |
| តាំង | + | /-អំម.ណ-/ | > | តំណាំង |
| ទង | + | /-អុំម.ន-/ | > | ទំនង |
| ទប់ | + | /-អុំម.ន-/ | > | ទំនប់ |
| ទាក់ | + | /-អុំម.ន-/ | > | ទំនាក់ |
| ទាញ | + | /-អុំម.ន-/ | > | ទំនាញ |
| ទាន់ | + | /-អុំម.ន-/ | > | ទំនាន់ |
| ទាប | + | /-អុំម.ន-/ | > | ទំនាប |
| ទាយ | + | /-អុំម.ន-/ | > | ទំនាយ |
| ទាស់ | + | /-អុំម.ន-/ | > | ទំនាស់ |
| ទិញ | + | /-អុំម.ន-/ | > | ទំនិញ |
| ទុក | + | /-អុំម.ន-/ | > | ទំនុក |
| ទូល | + | /-អុំម.ន-/ | > | ទំនូល |
| ទួញ | + | /-អុំម.ន-/ | > | ទំនួញ |

| | | | | |
|---|---|---|---|---|
| ទូល | + | /-អិ់ម.ន-/ | > | ទំនួល |
| ទើង | + | /-អិ់ម.ន-/ | > | ទំនើង |
| ទើប | + | /-អិ់ម.ន-/ | > | ទំនើប |
| ប៉ង | + | /-អ់ម.ណ-/ | > | បំណង |
| បន់ | + | /-អ់ម.ណ-/ | > | បំណន់ |
| បុល | + | /-អ់ម.ណ-/ | > | បំណុល |
| ប៉ែក | + | /-អ់ម.ណ-/ | > | បំណែក |
| ប៉ះ | + | /-អ់ម.ណ-/ | > | បំណះ |
| ពូត | + | /-អិ់ម.ន-/ | > | ពំនូត |
| ពោល | + | /-អិ់ម.ន-/ | > | ពំនោល |
| សើម | + | /-អ់ម.ណ-/ | > | សំណើម |
| ស្ទាក់ | + | /-អ់ម.ណ-/ | > | សម្ទាក់ |
| ស្ទាដៃ | + | /-អ់ម.ណ-/ | > | សម្ទាដៃ |
| ស្ទាម | + | /-អ់ម.ណ-/ | > | សម្ទាម |
| សក | + | /-អ់ម.ណ-/ | > | សំណក |
| សង | + | /-អ់ម.ណ-/ | > | សំណង |
| សង់ | + | /-អ់ម.ណ-/ | > | សំណង់ |
| សល់ | + | /-អ់ម.ណ-/ | > | សំណល់ |
| សាក | + | /-អ់ម.ណ-/ | > | សំណាក |
| សាង | + | /-អ់ម.ណ-/ | > | សំណាង |
| សាញ | + | /-អ់ម.ណ-/ | > | សំណាញ |
| សាប | + | /-អ់ម.ណ-/ | > | សំណាប |
| សឹក | + | /-អ់ម.ណ-/ | > | សំណឹក |
| សូក | + | /-អ់ម.ណ-/ | > | សំណូក |
| សូម | + | /-អ់ម.ណ-/ | > | សំណូម |
| សួរ | + | /-អ់ម.ណ-/ | > | សំណួរ |
| សើច | + | /-អ់ម.ណ-/ | > | សំណើច |
| សើ | + | /-អ់ម.ណ-/ | > | សំណើ |
| សែន | + | /-អ់ម.ណ-/ | > | សំណែន |
| សោក | + | /-អ់ម.ណ-/ | > | សំណោក |
| ដុំ | + | /-អ់ម.ណ-/ | > | សំណុំ |

| | | | | |
|---|---|---|---|---|
| អត់ | + | /-អំម.ណ-/ | > | អំណត់ |
| អរ | + | /-អំម.ណ-/ | > | អំណរ |
| អាច | + | /-អំម.ណ-/ | > | អំណាច |
| ឲ្យ | + | /-អំម.ណ-/ | > | អំណោយ |
| អួត | + | /-អំម.ណ-/ | > | អំនួត |

## ៤.២.២.ទម្រង់/-អំម.ណ-/ឬ/-អ៊ំម.ន-/បង្កើតគុណនាម

ពាក្យកម្លាយជាគុណនាមបែបនេះ អាចកើតមកអំពីពាក្យឫសជាកិរិយាសព្ទ គុណនាម

| | | | | |
|---|---|---|---|---|
| កាច | + | /-អំម.ណ-/ | > | កំណាច |
| កាញ់ | + | /-អំម.ណ-/ | > | កំណាញ់ |
| ចាប់ | + | /-អំម.ណ-/ | > | ចំណាប់ |
| ចាយ | + | /-អំម.ណ-/ | > | ចំណាយ |
| ចុះ | + | /-អំម.ណ-/ | > | ចំណុះ |
| ចូក | + | /-អំម.ណ-/ | > | ចំណូក |
| ចូល | + | /-អំម.ណ-/ | > | ចំណូល |
| ជាញ | + | /-អ៊ំម.ន-/ | > | ជំនាញ |
| ជិត | + | /-អ៊ំម.ន-/ | > | ជំនិត |
| ជួយ | + | /-អ៊ំម.ន-/ | > | ជំនួយ |
| ឈរ | + | /-អ៊ំម.ន-/ | > | ជំហរ |
| ទើប | + | /-អ៊ំម.ន-/ | > | ទំនើប |
| ទេ | + | /-អ៊ំម.ន-/ | > | ទំនេរ |
| សល់ | + | /-អំម.ណ-/ | > | សំណល់ |
| សាក | + | /-អំម.ណ-/ | > | សំណាក |
| សួរ | + | /-អំម.ណ-/ | > | សំណួរ |
| សែន | + | /-អំម.ណ-/ | > | សំណែន |
| អត់ | + | /-អំម.ណ-/ | > | អំណត់ |

## ៤.២.៣.ទម្រង់/-អំម.ណ-/ឬ/-អ៊ំម.ន-/បង្កើតកិរិយាសព្ទ

ពាក្យកម្លាយជាគុណនាមបែបនេះ អាចកើតមកអំពីពាក្យឫសជាកិរិយាសព្ទ គុណនាម

| | | | | |
|---|---|---|---|---|
| កត់ | + | /-អំម.ណ-/ | > | កំណត់ |
| គាប់ | + | /-អ៊ម.ន-/ | > | គំនាប់ |

| | | | | |
|---|---|---|---|---|
| ចាយ | + | /-អំម.ណា-/ | > | ចំណាយ |
| ឈម | + | /-អឹម.ន-/ | > | ជំហម |
| តែង | + | /-អំម.ណា-/ | > | តំណែង |
| ស្នាក់ | + | /-អំម.ណា-/ | > | សម្នាក់ |
| សឹក | + | /-អំម.ណា-/ | > | សំណឹក |

### ៤.២.៤.ទម្រង់/-អំម.ណា-/ឬ/-អឹម.ន-/បង្កើតនិបាតសព្ទ

ពាក្យកម្លាយជាគុណនាមបែបនេះ អាចកើតមកអំពីពាក្យឫសជាកិរិយាសព្ទ

| | | | | |
|---|---|---|---|---|
| ជុំ | + | /-អឹម.ន-/ | > | ជំនុំ |
| សឹក | + | /-អំម.ណា-/ | > | សំណឹក |

## សន្និដ្ឋាន

ទិដ្ឋភាពអន្តេបទនេះនៅក្នុងភាសាខ្មែរ ក៏ដូចជាទិដ្ឋភាពមួយចំនួនផ្សេងទៀតនៅក្នុងភាសាខ្មែរផងដែរ ពីព្រោះទិដ្ឋភាពនោះបានចោទជាបញ្ហានិងសម្មតិកម្មដោយឡែកៗសម្រាប់ការសិក្សាអន្តេបទក៏ដូចជាអព្ភាសបទដទៃទៀត។ អន្តេបទ/-អំម.ណា-/បានក្លាយជាចំណោទផងនិងប្រធានបទនៃការសិក្សាផង។

ទម្រង់អន្តេបទ /-អំម.ណា-/ឬ/-អឹម.ន-/ បានក្លាយជាប្រធានបទយ៉ាងសំខាន់សម្រាប់ការស្រាវជ្រាវសម័យទំនើប។ អន្តេបទនេះ អ្នកសិក្សាស្រាវជ្រាវសម័យថ្មីបានបង្កើតសម្មតិកម្មប្លែក ដោយយល់ឃើញថា ទម្រង់អន្តេបទនេះមិនមែនអន្តេបទ ក៏ប៉ុន្តែ ការយល់ឃើញបែបនេះគឺប្រាសចាកសម្មតិកម្មបុរាណ ពីព្រោះថា ទម្រង់នេះមានការប្រើប្រាស់តាំងពីសម័យបុរាណមកម្ល៉េះ។ អាស្រ័យហេតុនេះ ការសិក្សារបស់យើងគឺផ្អែកលើមិនត្រឹមតែសម្មតិកម្មនិងភស្តុតាងពីបុរាណនោះទេ ហើយការសិក្សានេះថែមទាំងផ្អែកលើទិន្នន័យនិងន័យនៃពាក្យកម្លាយជាមួយពាក្យឫសដែលមានការជាប់ទាក់ទងគ្នាជាប្រព័ន្ធថែមទៀតផង។ ដូច្នេះ លទ្ធផលបានបង្ហាញថា ទម្រង់/-អំម.ណា-/ឬ/-អឹម.ន-/ជាអន្តេបទដែលមានមុខងារវេយ្យាករណ៍សំខាន់ជាច្រើននៅក្នុងការបង្កើតពាក្យថ្មី ពោលគឺអន្តេបទនេះសម្រាប់បង្កើតនាមសព្ទសម្គាល់អំពើឬលទ្ធផល កិរិយាសព្ទ គុណនាម កិរិយាវិសេសន៍ និងនិបាតសព្ទ។ ទិន្នន័យទាំងមូលនៃពាក្យកម្លាយ ដោយប្រើប្រាស់អន្តេបទនេះមានទំនោរទៅរកការបង្កើតពាក្យថ្មីដែលមានប្រភេទពាក្យជានាមសព្ទ សម្រាប់សម្គាល់អំពើឬលទ្ធផលជាងប្រភេទផ្សេងៗ។

អន្តេបទនេះ បើទោះបីមានទិន្នន័យនិងមានឫសគល់ច្បាស់លាស់នៅក្នុងភាសាខ្មែរទំនើបផងនិងបុរាណផងក៏ដោយ ក៏អន្តេបទទាំងមូលនៅក្នុងភាសាខ្មែរឬពាក្យកម្លាយនៅក្នុងភាសាខ្មែរនៅតែចោទជាបញ្ហា ដោយសារតែបញ្ហាដែលចោទឡើងបានផ្តល់ជាអំណះអំណាងថាអន្តេបទនីយកម្មនៅ

ក្នុងភាសាខ្មែរមិនរស់រាននោះទេ។[១៩] គំនិតនេះអាចមិនពិត ចំពោះអ្នកប្រើប្រាស់ភាសាខ្មែរ ពីព្រោះបើទោះបីជាពាក្យកម្លាយហាក់មិនមានការរីកចម្រើននៅក្នុងផ្នែកបច្ចេកសព្ទក៏ពិតមែន។ ម្យ៉ាងការប្រើប្រាស់សម័យបច្ចុប្បន្ន អ្នកប្រើប្រាស់និយមប្រើពាក្យ« អ្នកឬការ» សម្រាប់ជំនួសពាក្យកម្លាយទៅវិញ ដូចមានការប្រើប្រាស់«អ្នកសរសេរ» ជំនួសឲ្យពាក្យ«ស្មេរ» ប្រើពាក្យ«អ្នកដើរ» ជំនួសឲ្យពាក្យ«ថ្មើរ» ។ផ្ទុយទៅវិញ យើងក៏សង្កេតឃើញមានការប្រើប្រាស់ពាក្យកម្លាយនៅក្នុងអត្ថបទព័ត៌មានួករណ៍ មួយចំនួនផងដែរដូចជា «បំផ្ទុះគ្រាប់បែក» ជាដើម។ ម្យ៉ាងវិញទៀត គណៈកម្មាធិការខេមរយានកម្មបានធ្វើឲ្យរស់រានឡើងវិញបន្ទាប់ពីមានការអាក់ខានប្រើពាក្យកម្លាយមួយរយៈមក។ បច្ចុប្បន្ន ការប្រើប្រាស់ គឺនៅមានការលាយឡំគ្នា ទាំងពាក្យកម្លាយនិងពាក្យដែលមាន«អ្នកឬការ»នាំមុខ ដោយពេលខ្លះការប្រើប្រាស់ធ្វើឲ្យមានការភាន់ច្រឡំថែមទៀតផង។

## គន្ថនិទ្ទេស


### ១.ស្នាដៃភាសាវិទ្យា
### ១.១. ស្នាដៃភាសាខ្មែរ

ច័ន្ទ សំណព្វ «ពាក្យកម្លាយនិងពាក្យក្លាយ» នៅក្នុង៖ *ទស្សនាវដ្ដីរាជបណ្ឌិតសភាកម្ពុជា* លេខ១ ឆមាសទី១ ឆ្នាំ២០០៩ ទំព័រ៤៧-៥៥។

ច័ន្ទ សំណព្វ«ការបង្កើតពាក្យនិងកម្ទីពាក្យ» នៅក្នុង៖ *ទស្សនាវដ្ដីសង្គមសាស្ត្រ-មនុស្សសាស្ត្រ* ឆ្នាំទី៣៨ លេខ៦៣ ខែមេសា ឧសភា មិថុនា ឆ្នាំ២០០៨ ទំព័រ៦-១២។

ច័ន្ទ សំណព្វ «ការកំណត់ប្រភេទពាក្យក្នុងភាសាខ្មែរ៖ តួនាទីនៃបុរបទ ការនិងផ្នត់ដែក[-អំម/ណ-]/[-អំម/ន-]» នៅក្នុង៖ *ទស្សនាវដ្ដីសង្គមសាស្ត្រ-មនុស្សសាស្ត្រ* ឆ្នាំទី៣៧ លេខ៥៩ ខែមេសា ឧសភា មិថុនា ឆ្នាំ២០០៧ ទំព័រ៤-១០។

ឌឹក គាម «ភាសាសាស្ត្រនឹងអក្សរសាស្ត្រ» នៅក្នុង៖ *ទស្សនាវដ្ដីកម្ពុជសុរិយា*ឆ្នាំទី៣៤ លេខ៥ ខែឧសភា ឆ្នាំ១៩៦២ ទំព័រ៥៥៥-៥៦៥។

ថោង ធែល «កម្មវាចកៈក្នុងភាសាខ្មែរ» នៅក្នុង៖ *ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា* ឆ្នាំទី២ លេខ២ ខែមិថុនា ឆ្នាំ២០០១ ទំព័រ២៥-៣៨។

នៅ ស៊ុន «ភាសានិងការបែងចែកជាអំបូរភាសា» នៅក្នុង៖ *ទស្សនាវដ្ដីរាជបណ្ឌិតសភាកម្ពុជា* លេខ១ ឆមាសទី១ ឆ្នាំ២០០៩ ទំព័រ៣៣-៤៦។

នៅ ស៊ុន «ភាសាខ្មែរនៅក្នុងចំណោមភាសាអ៊ីសូឡង់និងភាសាមិនមែនអ៊ីសូឡង់» នៅក្នុង៖ *ស៊ិន*


[១៩] Marjory Ellen Meechan, ***Register in Khmer: The Laryngeal Specification of Pharyngeal Expansion***, op.cit., p.8.

*សំណាង(អ្នកបោះពុម្ពផ្សាយ) ខេមរវិទ្យា(ចំណេះដឹងអំពីអតីតកាលនិងការរួមវិភាគទានក្នុងការស្តារនិងស្ថាបនាប្រទេសកម្ពុជាឡើងវិញ)* ភាគទី២ ឆ្នាំ១៩៩៩ ទំព័រ៧៣៨-៧៤០។
នៅ ស៊ុន ***ដំណើរការកំលាយពាក្យខ្មែរ*** អត្ថបទសិក្ខាសាលានៅវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩។
ព្រុំ ម៉ល់ «លទ្ធភាពបង្កើតពាក្យនិងការបង្កើតពាក្យក្នុងភាសាខ្មែរ» នៅក្នុង៖ ***ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា*** ឆ្នាំទី២ លេខ២ ខែមិថុនា ឆ្នាំ២០០១ ទំព័រ៦៥-៨២។
ព្រុំ ម៉ល់ ៖ ***វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប*** ភាគទី១ ភាគទី២ ភ្នំពេញ៖ ការផ្សាយរបស់អ្នកនិពន្ធ ២០០៦។
ឡុង សៀម៖ ***បញ្ហាវចនស័ព្ទវិទ្យា (Problèmes de Lexicology Khmère)*** ភ្នំពេញ៖ ការផ្សាយរបស់អ្នកនិពន្ធ ១៩៩៩, ១១៣ទំព័រ។
ឡុង សៀម«ការស្រាវជ្រាវទាក់ទងនឹងកំណកំណើតវាក្យសព្ទតាមបម្រើបម្រាស់ផ្ទត់នីយកម្ម» នៅក្នុង៖ ***សន្និសីទជាតិស្តីពី ការស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ*** រៀបចំដោយ វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា ថ្ងៃទី៧-៩ ខែកញ្ញា ឆ្នាំ២០០០ ទំព័រ១១-២៩។

## ១.២. ឯកសារជាភាសាបរទេស

Blevins, Juliette. “Untangling Leti Infixation.” ***In Oceanic Linguistics, Vol. 38, No.2, (Dec., 1999)***, University of Hawaii, pp. 383-404.
Cambefort, Gaston. ***Introduction au Cambodgien***. Paris: Maisonneuve, 1950.
Diffloth, Gérard. “Khmer” in William Bright (ed.) ***International Encyclopedia of Linguistics*** Vol.2. Oxford University Press: New York and Oxford. 271-275. 1992.
Diffloth, Gérard. “History of the word Khmer” in Sorn Samnang (ed.) ***Khmer Studies: Knowledge of the Past and Its contributions to the Rehabilitations and Reconstructions of Cambodia*** Vol.2. Royal University Phnom Penh Press: Phnom Penh. 644-651. 1996.
Diffloth, Gérard. “The Lexical Evidence for Austric, So Far” in ***Oceanic Linguistics***, Vol. 33, No.2, December 1994, pp.309-321, University of Hawaii' I Press, http://www.jstor.org/stable/3623131. Accessed: 16/06/2008.
Haiman, John. “Possible origins of infixation in Khmer”. ***Studies in Language*** 22:597-617, 1998.
Haiman, John; and Ourn, Noeurng. “Nouns, Verbs and Syntactic Backsliding in Khmer.” ***Studies in Language*** 27:3:, 505-528, John Benjamins Publishing Company, 2003.

Henderson, Eugénie J.A. “The Main Features of Cambodian Pronunciation”. In the ***Bulletin of the School of Oriental and African Studies***, University of London: Cambridge University Press, Vol.14, No.1, (1952), pp.149-174.
Hevesy, W.F. de. On W. Schmidt's Munda-Mon-Khmer Comparisons (Does an “Austric” Family of Languages?). ***Bulletin of the School of Oriental Studies, University of London***, Vol.6, No.1, 1930, pp.187-200, Cambridge University Press, http://www.jstor.org/stable607304, Accessed: 29/07/2008.
Horwood, Graham. ***Implications of Katu Nominalization for Infixation Typology***. Thammasat University, 2008, 21 pages.

Jacob, Judith M. ***Cambodian Linguistics, Literature and History.*** (collected articles), David A. Smyth (ed.), University of London, 1993.

Ourn, Noeurng; and Haiman, John. "Creative forces in Khmer." In Shoichi Iwasaki, Andrew Simpson, Karen Adams & Paul Sidwell, eds. ***SEALSXIII: papers from the 13th meeting of the Southeast Asian Linguistics Society (2003)***. Canberra, Pacific Linguistics, 2007, pp.157-164.

Payne, Thomas E. ***Exploring Language Structure: A Student's Guide***. Cambridge University Press, 2006, 367 pages.

Sebeok, Thomas A. "An Examination of the Austroasiatic Language Family". ***In Language, Vol. 18, No.3, (Jul.-Sep., 1942)***, Linguistic Society of America, pp. 206-217 <http://www.jstor.org/stable/409554>.

Schiller, Eric. "Khmer Nominalizing and Causativizing Infixes". ***SEALS II: papers from the 2nd meeting of the Southeast Asian Linguistics Society***. 1992, pp.309-326.

Schiller, Eric. "Khmer Writing" in Peter T. Daniels and William Bright (eds). ***The World's writing system***. New York: Oxford University Press, 1996. pp.467-473.

Sidwell, Paul (ed). ***SEALS XV: Papers from the 15th annual meeting of the Southeast Asian Linguistics Society***. Pacific Linguistics: Research School of Pacific and Asian Studies, Australian National University, 2005, 2004 pages.

Smalley, William A. "Multilingualism in the Northern Khmer Population of Thailand". ***In Language Sciences***, Volume 10, Number 2, pp.395-408, 1988, Great Britain: Pergamon Press plc, 1999.

Spencer, Andrew. ***Morphological Theory: An Introduction to Word Structure in Generative Grammar***, Cambridge University Press: Basil Blackwell, 1991, 512 pages.

Shorto, H.L. Three Mon-Khmer Word Families. ***Bulletin of the School of Oriental and African Studies***, University of London, Vol. 36, Cambridge University Press, 1973, pp. 374-381, http://www.jstor.org/stable/613515. Retrieved 13/05/2008.

Varasarin, Uraisi. ***Les Éléments Khmers dans La Formation de La Langue Siamoise***. Paris: SELAF, 1984.

Vong Meng, "The Evolution of Khmer Language in the Globalization Era." ***Paper presented at the International conference on Syncretism in South and Southeast Asia: Adoption and Adaptation***, The Institute of Language and Culture for Rural Development, Mahidol University, Thailand, 2007.

You sey. "Some old Khmer Affixation" in Kenneth J. Gregerson and David Thomas (ed.), ***Mon-Khmer Studies V***, Manila: the Summer Institute of Linguistics, 1976, pp. 85-95.

Yu, Alan C.L., ***A Natural History of Infixation***, Oxford University Press, 2007, 265 pages.

## ២. សារណានិងនិក្ខេបបទ

### ២.១. ស្នាដៃភាសាខ្មែរ

យៀង វីរបុត្រ៖ *ការបង្កើតពាក្យនៅក្នុងភាសាខ្មែរទំនើបតាមវិធីកម្លាយ* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី១សាកលវិទ្យាភូមិន្ទភ្នំពេញ ២០០៦។

វង្ស មេង៖ *ពាក្យផ្គួននៅក្នុងភាសាខ្មែរទំនើប* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ ជំនាន់ទី៧ ២០០២។

វង្ស មេង៖ *ពាក្យសមាសនៅក្នុងភាសាខ្មែរទំនើប* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី១ រាជបណ្ឌិតសភាកម្ពុជា ២០០២។

## ២.២. ស្នាដៃភាសាបរទេស

Adams, Karen Lee. ***System of Numeral Classification in the Mon-Khmer, Nicobarese and Aslian Subfamilies of Austroasiatic***. A Dissertation submitted in partial fulfillment of the requirements for the degree of Doctor o f Philosophy (Linguistics) in the University of Michigan, 1982, 495pp.

Huebner, Thomas G. ***On the Phonology of the Khmer Simple Monosyllable***. University of Pittsburgh, M.A. Thesis, 1971, 43 pages.

Huffman, Franklin E. ***An Outline of Cambodian Grammar***. Cornell University, Ph.D. thesis, 264 pages, 1967.

Jenner, Philip Norman. ***Affixation in Modern Khmer***. Ph.D. dissertation, University of Hawaii, 1969, 207 pages.

Meechan, Marjory. ***Register in Khmer: The Laryngeal Specification of Pharyngeal Expansion***. M.A. thesis, Canada: University of Ottawa, 1992.

Rhee, Seok-Chae. ***Aspect of Release and Nonrelease in Phonology***. University of Illinois, Ph.D. thesis, 1998.

Sak-Humphry, Chhany. ***Khmer Nouns and Nouns Phrases: A Dependency Grammar Analysis***, 353p. A Dissertation of Linguistics, University of Hawaii, UMI Company, 1996.

Thach, Ngoc Minh. ***A Descriptive Grammar of Khmer in the Mekong Delta-Vietnam***. M.A. thesis, National University of Singapore, 2002.

Wayland, Ratree P. ***Acoustic and Perceptual Investigation of Breathy and Clear Phonotation in Chanthaburi Khmer: Implications for the History of Khmer Phonology***. Cornell University. Doctoral dissertation. 1997.

## ៣. ស្នាដៃវេយ្យាករណ៍

## ៣.១. ស្នាដៃភាសាខ្មែរ

កេង វ៉ាន់សាក់៖ ***មូលភាពនៃការបង្កើតពាក្យថ្មី*** ភ្នំពេញ៖ រោងពុម្ពទេព ១៩៦៤។

ខៀវ ជុំ៖ ***វេយ្យាករណ៍យើង*** ភ្នំពេញ៖ ទៀន ហុងសេង ១៩៦៦, ១៧៤ទំព័រ។

គីម សែត៖ ***វេយ្យាករណ៍ទំនើបនិងវិធីសម្ព័ន្ធ (សម្រាប់ថ្នាក់ទី៤និងទី៣ទំនើប នៃវិទ្យាល័យនិងអនុវិទ្យាល័យ)*** ការផ្សាយរបស់ បណ្ណាគារ វង្ស រស្មី កំពង់ចាម ឆ្នាំ? ១០៩ទំព័រ។

ជួង ហេង៖ ***វេយ្យាករណ៍បារាំងពន្យល់ជាខ្មែរ (Grammaire Française Expliquée en Khmer)*** បោះពុម្ពលើកទី១ ភ្នំពេញ ១៩៧៣, ៣៣៤ទំព័រ។

ឃីន សុខ៖ ***វេយ្យាករណ៍ភាសាខ្មែរ*** ភ្នំពេញ៖ការផ្សាយរបស់រាជបណ្ឌិតសភាកម្ពុជា ២០០៧។

ពូរ អ៊ុម៖ ***វេយ្យាករណ៍ខ្មែរ*** ភ្នំពេញ៖ បណ្ណាគារគឹម សេង ១៩៥៤។

ប៉ាយ ប៊ុក៖ ***ខេមរវេយ្យាករណ៍*** សម្រាប់ថ្នាក់មធ្យមដ្ឋាននិងឧត្តមដ្ឋាននឹងថ្នាក់ទី៦ទំនើប ភ្នំពេញ៖ បណ្ណាគារ គីម គី ១៩៥៥ ១២៥ទំព័រ។

សៀន ខ័នឌី និង ព្រហ្ម ស៊ុនណារ៉េត៖ ***នវវេយ្យាករណ៍នឹងខេមរភាសា*** ( សម្រាប់ថ្នាក់ទី៤និងទី៣ទំនើប វិទ្យាល័យនិងអនុវិទ្យាល័យ ) ភ្នំពេញ៖ រោងពុម្ពវិរិយៈ ១៩៥៦, ៥១៩ទំព័រ។

អៀវ កើស៖ ***ភាសាខ្មែរ(ការល្បងពិនិត្យដោយរកហេតុផល)*** បោះពុម្ពផ្សាយឡើងវិញ ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ៖ រោងពុម្ពមិត្តភាពកម្ពុជា-ជប៉ុន ១៩៩៥, ៣៦៧ទំព័រ។

### ៣.២. ស្នាដៃភាសាបរទេស


Gorgoniyev, Ju.A. ***The Khmer Language***. (translated from the Russian by V. Korotky), Moscow: Nauka Publishing house, 1966, 134 pages.

Maspero, Georges. ***Grammaire de la langue Khmère***. Paris, Imprimerie Nationale, 1915, 486p.

Schiller, Eric. "Introduction to Autolexical Grammar." Ericschiller.com (2007). 12 May 2008< http://www.ericschiller.com/ling/papers/autolexical.htm>.


## ៤. វចនានុក្រម

### ៤.១. វចនានុក្រមភាសាខ្មែរ


ក្រសួងអប់រំជាតិ៖ ***សទ្ទានុក្រម បារាំង-ខ្មែរ ពាក្យបច្ចេកទេស*** ផ្សាយចេញពីគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ ភ្នំពេញ៖ រោងពុម្ពមានជ័យ ១៩៦៩ ៥០៦ទំព័រ។

ជូឌីត ចាកុប៖ ***វចនានុក្រមខ្មែរ-អង់គ្លេស*** ការផ្សាយរបស់សាកលវិទ្យាល័យឡុង ដុង, ១៩៧៤, ២៤២ ទំព័រ។

នួន ប៊ុត៖ ***អក្ខរានុក្រមខ្មែរ ពី ក ដល់ អ នឹងពាក្យរាយ*** ការផ្សាយរបស់បណ្ណាគារ ប៊ុតនាង ១៩៥៤, ១៩០៦ទំព័រ។

ឃឹម លីអេង៖ ***វចនានុក្រមសទិសសព្ទខ្មែរ*** សម្រាប់មធ្យមសិក្សានិងបឋមសិក្សា អ្នកសិក្សាភាសាខ្មែរ ការផ្សាយរបស់អ្នកនិពន្ធ ១៩៧៣, ៦៤០ទំព័រ។

រ គោវិទ៖ ***ពាក្យវប្បធម៌ខ្មែរ*** ឆ្នាំ? ៤៤០ទំព័រ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ***វចនានុក្រមខ្មែរ ភាគទី១ ភាគទី២*** ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ រោងពុម្ព កម្ពុជា ១៩៦៧-៦៨, ១៨៥៨ទំព័រ។

ហាហ្វមែន ហ្វ្រែងលីន និង ព្រំ អ៊ឹម ***អក្សរសាស្ត្រខ្មែរ*** ការផ្សាយរបស់សាកលវិទ្យាល័យ យេល ១៩៧០, ៥៦ទំព័រ។


### ៤.២. វចនានុក្រមភាសាបរទេស


Bernard, Jean Baptiste. *Dictionnaire Cambodgien-Français* Hong Kong: Imprimerie de la Société des Missions Etrangères, 1902, 386 pages.

Bussmann, Hadumod. ***Routledge Dictionary of Language and Linguistics***. (translated and edited by Gregory P. Trauth and Kerstin Kazzazi), London and New York: Solidus (Bristol) Ltd, Bristol, 2006, 530 pages.

Carr, Philip. ***A Glossary of Phonology***. Scotland: Edinburgh Univesity Press Ltd. 2008, 206 pages.

Chrystal, David. ***A Dictionary of Linguistics and Phonetics***. UK: Blackwell Publisher, 1991, 389 pages.

Jenner, Philip N. and Saveros Pou, ***A Lexicon of Khmer Morphology***, MKS 9-10:1-517, 1981, 517 pages.

Jenner, Philip N., A dictionary of Pre-Angkorian Khmer, Doug Cooper (ed.), Canberra: Pacific Linguistics, 2009, 620 pages.

Jenner, Philip N., A dictionary of Angkorian Khmer, Doug Cooper (ed.), Canberra: Pacific Linguistics, 2009, 778 pages.

Guesdon, Joseph. ***Dictionnaire Cambogien-Français***. Paris: Libairie Plon, 1930.

# កម្រងគំនិតគួរពិចារណា
# សូមជួយពិចារណានិងផ្តល់យោបល់តាមការគួរ!!!

(ដោយបណ្ឌិតនៅ ស៊ុន)

លោក គុយ រិន (ស្រង់ពីបណ្តាញសង្គម)
មន្ត្រីវិទ្យាស្ថានភាសាជាតិ

មើលក្នុងវចនានុក្រមខ្មែរមួយត្រួស ឃើញថាស្រៈ « ួ » « ឿ » « ៀ » ជាមួយនឹង «ណ» និង «ន» ម្តងសរសេរនឹង«ណ» ដូចជា កំណួច (ក្នុងនេះលោកស្នើមិនឲ្យសរសេរនឹង«ន» ជា«កំនួច» ដូចនេះ) **កំណៀង កំណៀច កំណៀរ កំណៀវ ដំណួច ដំណៀល សំណួរ** តែចំនួន **ចំនួប ចំនៀរ តំនឿ តំនឿន សំនឹក សំនួន អំនួត** លោកសរសេរនឹង «ន» នេះបើគិតតាមអក្សរព្យញ្ជនៈដើមព្យាង្គស្ថិតក្នុង ព្យញ្ជនៈពួក«អ»ដែលក្នុងនេះមាន «ក» «ច» «ដ» «ត» «ស»និងតួស្រៈពេញតួ «អ»។ ក្នុងនេះ គេឃើញថា មិនដឹងមូលហេតុអ្វី ជាមួយព្យញ្ជនៈ «ច» សរសេរនឹង«ន» ទាំងអស់, ជាមួយ«ស» សរសេរនឹង«ន» លើកលែងតែ «សំណួរ» មួយចេញជាមួយស្រៈដើមព្យាង្គ«អ» សរសេរនឹង«ន»។ ចំពោះអក្សរព្យញ្ជនៈដើមព្យាង្គស្ថិតក្នុងពួក«អ៊» ដូចជា «គ» «ជ» «ទ» ដូចជា «គំនួប» «ជំនួញ» «ជំនឿ» «ទំនួញ» «ទំនៀម» ជាដើមសរសេរនឹង«ន»ទាំងអស់(មិនដែលប្រទះសរសេរនឹង «ណ»ទេ)។ តាមអ្វីដែលបានលើកខាងលើឃើញថា ទាំងតួព្យញ្ជនៈដើមព្យាង្គពួក«អ» (ដូចដែលបាននិយាយខាងដើមមកហើយ) ទាំងតួស្រៈពេញតួដើមព្យាង្គ «អ» ជាមួយស្រៈ «ួ» «ឿ» «ៀ» មានការច្របល់ក្នុងការប្រើ«ន»និង«ណ» ដែលអាចជាបញ្ហាដល់អ្នកសរសេរថា ពេលណាប្រើ«ន» ពេលណាប្រើ«ណ»។ ឬក៏ក្នុងការសរសេរម្តងៗទាល់តែរត់រកវចនានុក្រម?!!!

តើយើងគួរកំណត់ថាជាមួយព្យញ្ជនៈដើមព្យាង្គពួក«អ»និងជាមួយតួស្រៈពេញតួ«អ» ថាត្រូវសរសេរនឹង«ណ» ទាំងអស់ ដូចជា «ចំនួន» ទៅជា«ចំណួន» «តំនឿ» ទៅជា«តំណឿ» «សំនៀង» ទៅជា«សំណៀង» «អំនួត» ទៅជា«អំណួត»វិញបានឬទេ??!!!

បើការណ៍នេះអាចទៅរួចនោះ អ្នកសរសេរមិនបាច់ខ្វល់ច្រើនទេឲ្យតែក្រុម«អ» សរសេរនឹង «ណ» ក្រុម«អ៊» សរសេរនឹង«ន»ទាំងអស់។

សូមកុំប្រកាន់អីចំពោះគំនិតនេះ ជាគំនិតស្នើរភ្លើងទេ!!!!!!

## សប្បាយចិត្តបន្តិចហើយ ក៏បកស្រាយបន្តិចពីហេតុនាំឲ្យមានអ-អ៊ ក្នុងព្យញ្ជនៈខ្មែរ

គួរបញ្ជាក់ថា ពីដើមភាសាសំស្ក្រឹត ថ្វីត្បិតតែគ្មានអក្សរ មានឥទ្ធិពលច្រើនទៅលើប្រទេសនានានៅអាស៊ីចុងបូព៌ា អាស៊ីខាងត្បូង រហូតដល់អាស៊ីអាគ្នេយ៍។

អ្វីដែលមានឥទ្ធិពលខ្លាំងនោះ គឺការរៀបប្រព័ន្ធសូរព្យញ្ជនៈភាសាសំស្ក្រឹតរបស់អ្នកប្រាជ្ញឥណ្ឌាម្នាក់ឈ្មោះប៉ានិនី។ ប៉ានិនី ចែកជាសូរកណ្ឋជៈ (guttural) ក្រោយមកគេហៅថាសូររនាំងក្រអូមឬសូរ

ក្រអូមក្រោយ ដែលក្នុងនោះ មានសូរ[k] [kh] [g] [gh] និង [ṅ] មាន៥សូរ ដែលតាងដោយអក្សរព្រហ្មី ដែលខ្មែរកែក្នុងទម្រង់បច្ចុប្បន្ន (ទៅមុខទៀត យើងហៅថាអក្សរខ្មែរ) ក សម្រាប់សូរ [k], ខ សម្រាប់សូរ [kh], គ សម្រាប់សូរ [g], ឃ សម្រាប់សូរ [gh] និង ង សម្រាប់សូរ [ṅ] ។ក្នុងនេះ យើងឃើញមាន ៥សូរតាងដោយ៥តួអក្សរ។

បន្ទាប់ពីសូរទាំងក្រអូមមក ប៉ានិនីចែកជាសូរ តាលជៈ(palatal) សូរក្រអូម ក្នុងនោះមាន ៥ សូរ គឺ[c] [ch] [j] [jh] និង [ñ] ដែលតាងដោយអក្សរខ្មែរ ច ឆ ជ ឈ ញ (៥សូរតាងដោយ៥តួអក្សរ) ចែកជាសូរមុទ្ធជៈ (retroflex) ក្នុងនោះមាន៥សូរ គឺ [ṭ ] [ṭh] [ ḍ] [ḍh] និង[ṇ] (៥ សូរ ៥តួអក្សរ) តាងដោយ ដ ឋ ឌ ឍ ណ ចែកជាសូរទន្តជៈ(dental) សូរធ្មេញ ក្នុងនោះមានសូរ [t] [th] [d] [dh] និង [n] (៥សូរ ៥តួអក្សរ) តាងដោយ ត ថ ទ ធ ន ចែកជាសូរឱដ្ឋជៈ (labial) សូរបបូរមាត់ ដែលក្នុងនោះមាន[p] [ph] [b] [bh] [m] (៥សូរ) តាងដោយ ៥អក្សរ ប ផ ព ភ ម និងពួកសូរចម្រុះ ដែលគេនិយមហៅសេសវគ្គនោះ មាន យ [y] រ [r] ល [l] វ [w] ស [s] ស-គ[c] (អក្សរ c នេះមានកន្ទុយ តែគ្មានfont) ស-ប [ṡ] ហ [h] ឡ[ḷ] និង និគ្គហិត [ṃ] ។

ដល់ពេលសម្រាកហើយ រាត្រីសួស្ដី!!!! នឹងឆ្លៀតបន្តរឿងនេះទៀតនៅពេលក្រោយ។ សុខសប្បាយទាំងអស់គ្នា!!!

## សាកល្បងបកស្រាយទាំងប្រថុយពីមូលហេតុនាំឲ្យមានមូលភេទ អ-អ៊ ក្នុងភាសាខ្មែរ

រំលឹកបន្តិចពីរឿងអ-អ៊ក្នុងភាសាខ្មែរ។ លោក ហ្សក ម៉ាស្ពេរ៉ូ ក្នុងសៀវភៅ La grammaire de la langue Khmère(1919) លើកឡើងថា ព្យញ្ជនៈខ្មែរចែកជាពីរពួក គឺពួកអនិងពួកអ៊។ ពួកអគឺព្យញ្ជនៈណាដែលមាន ស្រៈអ កប់ក្នុងហ្នឹង (voyelle inhérent ២) ចំណែកពួកអ៊ គឺព្យញ្ជនៈ ដែលមានស្រៈអ៊កប់ក្នុងហ្នឹង(voyelle inhérent ១)។ ត្រង់ហេតុថា ហេតុដែលនាំឲ្យគេសន្មតថាមានស្រៈអឬស្រៈកប់ក្នុងតួព្យញ្ជនៈ គឺលោក ម៉ាស្ពេរ៉ូមិន បានលើកឡើយ។

លោក កេង វ៉ាន់សាក់ ក្នុងសៀវភៅ សូរសព្ទវិទ្យាខ្មែរ ថាព្យញ្ជនៈខ្មែរគ្មានឃោសៈ អឃោសៈទេ តែមានមូលភេទ អ-អ៊។ លោកថាតែប៉ុណ្ណឹងដោយមិនបានពន្យល់ថា ហេតុអ្វីបានជាមានមូលភេទអ-អ៊ នោះក៏ទេដែរ។

លោកយូរី អាឡិចសាន់ដ្រូវិច ហ្គោរហ្គោយ៉េវ ក្នុងសៀវភៅ Grammatika khmerskovo Yazyka លើកឡើង ពីការចែកស្រៈខ្មែរជាសេរី(série) ទី១និង សេរីទី២ ដោយសារតម្លង់កម្ម (អឃោសកម្ម) នៃសូរព្យញ្ជនៈដែលចម្លងតាមភាសាឥណ្ឌាបុរាណ (សំស្ក្រឹត )។ លោក ហ្គោរហ្គោញីយ៉េវ ក៏មិនបានពន្យល់ពីហេតុនាំឲ្យមានមូលភេទអ-អ៊ក្នុងព្យញ្ជនៈខ្មែរនោះដែរ។ មានអ្នកខ្លះទៀតថា អ-អ៊ ជាលក្ខណៈពិសេសនៃភាសាខ្មែរទៀតផង តែក៏មិនបាននិយាយពីហេតុនាំឲ្យមានអ-អ៊នោះឡើយ។ ដោយសារតែហេតុនេះ ខ្ញុំនឹងសាកល្បងពន្យល់ពីហេតុនាំឲ្យមានអ-អ៊ ក្នុងព្យញ្ជនៈខ្មែរ នៅពេលណាខ្ញុំសប្បាយចិត្ត៕

តរឿង អ-អ៊ បន្តិចចុះ!!!!!

ពេលខ្មែរយើងយកទម្រង់អក្សរព្រហ្មី(brahmi) មកកត់ត្រាសូរភាសាខ្លួន ក៏យកតាមចំណែកថ្នាក់សូរ ដែលលោកប៉ានិនីបានកំណត់ក្នុងភាសាសំស្ក្រឹតដែរ គឺខ្មែរយកទាំងអក្សរយកទាំងសូរ។ តឹកតាងជាក់ស្ដែង គេឃើញរឿងនេះនៅក្នុងវចនានុក្រមខ្មែរដែលយើងនិយមហៅវចនានុក្រម សម្ដេចជួន ណាត។ ការយកទាំងអក្សរទាំងសូរនេះហើយ ដែលធ្វើឲ្យអ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរយើងខ្វែងគំនិតគ្នាពីរឿងឃោសៈ អឃោសៈនិងរឿង អ-អ៊។

ក្រុមអ្នកប្រាជ្ញមួយក្រុមដែលគោរពតាមឥតខ្ចោះនូវចំណែកថ្នាក់សូររបស់លោកប៉ានិនី ចែកអក្សរទី១ និង ទី២ ជាអឃោសៈ ចំណែកអក្សរទី៣ ទី៤ ទី៥នៃវគ្គនីមួយៗជាអក្សរឃោសៈ (សូមអានរឿងនេះក្នុងវចនានុក្រម សៀវភៅវេយ្យាករណ៍ភាសាខ្មែរឬខេមរភាសារបស់លោកពូវ អ៊ុម លោក អ៊ុយ ជួន ក្រោយមកលោក ធន់ ហ៊ិន លោក សួន ឱសថ ជាដើមនិងវចនានុក្រមខ្មែរ)។ នេះជាការចែក ព្យញ្ជនៈឃោសៈនិងអឃោសៈក្នុងវចនានុក្រមខ្មែរ«ឃោសឬឃោសៈ *ន.* (បា.ឃោស "សូរ, សំឡេងគឹកកង") ឈ្មោះព្យញ្ជនៈ ដែលមានសំឡេងគឹកកងមាន ២១ តួ គឺ គឃង, ជឈញ, ឌឍណ, ទធន, ពភម; យរលវហឡ; និងស្រៈពេញតួទាំងអស់ ក៏រាប់បញ្ចូលក្នុងពួកអក្សរឃោសៈដែរ» ។ អឃោស អៈឃោសៈ ( គុ. ) បា. ដែលមិនគឹកកង, ដែលមានសូរសព្ទមិនកងរំពង ។ ន. អក្សរដែលមានសំឡេងមិនគឹកកង, មាន ១១ តួគឺ ក ខ, ច ឆ, ដ ឋ, ត ថ, ប ផ; ស, បើរាប់ ឝ, ឞ តាម សំ. ផ្សំផងជា ១៣ តួ(ព. វ.) ។ អឃោសសព្ទ សូរមិនគឹកកង»។ តាមអ្វីដែលវចនានុក្រមខ្មែរលើកឡើងនេះហាក់ដូចជាមានការច្រឡំរវាងសូរនិងអក្សរ ហើយពេទ្យខ្លះមើលទៅហាក់គោរពតាមចំណែកថ្នាក់សូររបស់ប៉ានិនី ពេលខ្លះទៀតហាក់ដូចជាមិនគោរពតាមចំណែកថ្នាក់សូរលោកប៉ានិនី បែរនិយាយពីអក្សរទៅវិញ។ តាមពិតកាលណាគេនិយាយពីរឿងឃោសៈអឃោសៈ គេនិយាយពីសូរដែលបន្លឺឡើងដោយមានការចូលរួមរបស់ខ្សែសំឡេង(ឃោសៈ)ឬមិនចូលរួមដោយខ្សែសំឡេង (អឃោសៈ) ទៅវិញទេ មិនមែនគឹកកងរំពងឬមិនគឹកកងរំពងនោះឡើយ។ ជាក់ស្ដែង សូរ[k] ដែលខ្មែរតាងដោយសញ្ញា «ក» បែបនេះនិងសូរ [g] ដែល ខ្មែរតាងដោយសញ្ញា«គ»បែបនេះ ឃើញថាសូរទាំងនេះគ្មានសូរណាមួយកងរំពងជាងសូរណាមួយផងទេ ខុសគ្នា ត្រង់បន្លឺសូរ[k] គ្មានការចូលរួមនៃខ្សែសំឡេងនិងពេលបន្លឺសូរ[g]មានការចូលរួមរបស់ខ្សែសំឡេងប៉ុណ្ណោះ។ ស្លេះ សិន។

តាំងតែពីបានស្រឡះខ្លួនពីជំងឺបន្តិចមក សតិខ្ញុំដូចជាត្រឡប់ត្រឡិនខុសធម្មតាយ៉ាងម៉េចមិនដឹងទេ។

បន្តិចគិតនេះ បន្តិចគិតនោះ។ សុខៗសោះ ទៅគិតពីរឿង«អ» «អ៊» ក្នុងភាសាខ្មែរឯណាតែផ្ដាសទៅ។ គិតថា តាំងពីលោកហ្សក ម៉ាស្ពេរ៉ូ មកអ្នកប្រាជ្ញផ្នែកអក្សរសាស្ត្រល្បីៗឈ្មោះខាងក្រោយមកទៀតថាលក្ខណៈពិសេសនៃភាសាខ្មែរកឺស្ថិតត្រង់ថាមានមូលភេទអ-អ៊នេះឯង។ ខ្ញុំស្វែងរកអានឯកសាររបស់អ្នកប្រាជ្ញទាំងនោះ មិនឃើញ លោកអ្នកប្រាជ្ញទាំងនោះប្រាប់ថា «ហេតុអ្វីបានជាភាសាខ្មែរមានមូលភេទអ-អ៊»ទាល់តែសោះ។ បើមិនប្រាប់ពីមូលហេតុអ៊ីចឹង បើមាននរណាមួយសួរខ្មែរលេងថា «ហេតុអ្វីបានជាអ្នកឯងហ៊ានអះអាងថា ភាសាអ្នកឯងមានមូលភេទអ-អ៊?

តើមូលភេទនេះគេសំដៅទៅលើសូរភាសាខ្មែរឬក៏សំដៅទៅលើការកត់ត្រាសូរភាសាខ្មែរដោយយកតាមលំនាំអក្សរព្រហ្មីមកប្រើ? តាមទម្លាប់មកគេចែកអក្សរខ្មែរជាវគ្គ ក ច ដ ត ប គេឃើញមានតួអក្សរ ដែលគេថាពួក«អ»នោះ គឺតួអក្សរទី១ និងទី២ក្នុងវគ្គ គឺ ក ខ ច ឆ ដ ឋ តថ ប ផ ចំណែកតួអក្សរទី៣និងទី៤ក្នុងវគ្គ ដូចជា គ ឃ ជ ឈ ឌ ឍ ទ ធ ព ភ។ ក្នុងសេសវគ្គពួក «អ» មាន ស ហ ឡ ពួក«អ៊» មាន យ រ ល វ។ បើរាប់ជាគូអ-អ៊ ភាគច្រើនអក្សរទី១ គូអ-អ៊នឹងអក្សរទី៣។ អក្សរទី២ភាគច្រើនមានគូអ-អ៊ ជាមួយអក្សរទី៤ ដូចជា ក គូនឹង គ ខ គូនឹង ឃ ផ គូនឹងភ ជាដើម។ ដោយឡែក «ប» ជាអក្សរទី១ក្នុងវគ្គប គ្មានគូអ-អ៊ ជាមួយតួអក្សរទី៣ ដូចគេដូចឯងទេ ឯតួអក្សរទី៣ «ព» ក៏គ្មានគូអ-អ៊ដែរ។ ហេតុអីបានជាអ៊ីចឹង? សូមអ្នកមាន ចំណេះដឹងខាងអក្សរសាស្ត្រ មេត្តាជួយបំភ្លឺឲ្យទានផង និងគួរមានដំណោះស្រាយយ៉ាណា។ សូមអរគុណទុកជាមុន។ យ៉ាប់មែនទែន ពេលដើរហាត់ប្រាណអំបាញ់មិញ ក្នុងក្បាលសុទ្ធតែអ-អ៊ ដឹងអ៊ីចឹងមិនលើករឿងនេះ នាំតែលំបាកខ្លួនទេ តែបានជាផុងគូទបេួតគំនិតនិយាយពីរឿងនេះទៅហើយ ក៏បន្តនិយាយទាំងទឹកភ្នែកទៅចុះ។ តែសរសេរខ្លីៗបានហើយ កុំឲ្យគេធុញនឹងអាន មិនពីរោះដូចបទចម្រៀងឬកំណាព្យឯកឧត្តម ចាប ពួក កំណាព្យព្រះរៀម ឈាឈៀន កំណាព្យដុកទ័រ ឌុក ហុកឈឿង ជាដើមឡើយនោះទេ។

តាមពិតទៅក្រុមអ្នកដែលថា ក[k] ខ[kh] ច[c] ឆ [ch] ដ[d] ឋ[th] ប[b] ផ [ph] ជាដើមជាអឃោសៈ មកពីគេអានតាមសូរសំស្ក្រឹតឬបាលីថា កាក់ ខាក់ ចាក់ ឆាក់ ដាក់(អានតាមខ្មែរ) ឋាក់ បាក់ (អានតាមខ្មែរ) ផាក់ជាដើម។ តែអ្វីដែលជាសូរឃោសៈតួយ៉ាង គ ឃ ជ ឈ ជាដើម គេអានគាក់សម្រាប់ តួ គ(តាមពិតមិនមែនគាក់ទេ តែ [ga]) ឃាក់ សម្រាប់តួ ឃ (សូរពិតគឺ [gha]) សម្រាប់តួ ជ គេអានថា ជាក់(សូរពិត[ja]) សម្រាប់តួ ឈ គេអានថា ឈាក់(សូរពិត[jha])។ តាមពិតនោះ មានតែសូរ[a] ទេដែលផ្សំប្រកបនឹងសូរព្យញ្ជនៈទាំងនោះ គឺគ្មានសូរ [ea]ឡើយ ព្រោះសូរស្រៈសំស្ក្រឹតគ្មានអ៊ា គ្មានអិ គ្មានអ៊ី ជាដើមនោះទេ(សូមមើលស្រៈសំស្ក្រឹត និងការបន្លឺសូរស្រៈទាំងនោះ)។ ការណ៍ដែលគេយកសូរ[a]មកដាក់ផ្សំ ប្រកបជាមួយសូរព្យញ្ជនៈទាំងនេះដោយសារ[a]នេះមានសូរខ្លីជាងគេក្នុងសូរស្រៈសំស្ក្រឹតនិងដើម្បីសម្រួលក្នុងការអានសូរព្យញ្ជនៈដែលត្រចៀកមនុស្សធម្មតាពិបាកចាប់ បើសូរពួកស្ទះ អឃោសៈវិញរឹតតែពិបាកចាប់ទៅទៀត សូម្បីតែម៉ាស៊ីនកត់ត្រាសូរក៏ដោយ (អ្នកសូរវិទ្យាក្រោយមកគេនិយមយក[ə]មកផ្សំទៅវិញ)។ ដល់ពេល ថាសូរ [ga] [gha [ja] [jha] ជាដើមបានត្រឹមតែ គាក់ ឃាក់ ជាក់ ឈាក់ អ្នកសូរវិទ្យាចាប់បានថា ខ្មែរ ថា គាក់ក៏ដូចជាថាកាក់ ព្រោះសូរព្យញ្ជនដើមព្យាង្គបន្លឺចេញសូរ[k] ដូចតែគ្នា ដូច្នេះបើ កាក់ [ka] តាងដោយតួ ក អឃោសៈនោះគាក់ [kea] តាងដោយតួ គ ក៏អឃោសៈដែរ ព្រោះខ្មែរមានថា [ga]ឯណា? បានន័យថាតួ ក និង គ សម្រាប់ភាសាខ្មែរមានសូរ[k] អឃោសៈស្ទះ រនាំងង ក្រអូម ជាព្យញ្ជនៈមាត់ (មុខជៈ) ដូចគ្នា។ ត្រង់ចំណុច នេះហើយដែលអ្នកប្រាជ្ញខាងអក្សរសាស្ត្រមួយក្រុមទៀតបដិសេធរឿងឃោសៈអឃោសៈក្នុងព្យញ្ជនៈខ្មែរ (សូមអាន កេង វ៉ាន់សាក់ សូរសទ្ទវិទ្យាខ្មែរ ភាគ២ ១៩៦៦)ថាមានតែអ-អ៊។ នេះជាកូន មូលហេតុដែលនាំឲ្យមានទស្សនៈក្នុងព្យញ្ជនៈខ្មែរ។ មិនទាន់ចប់ទេ!!

## សាកល្បងបកស្រាយទាំងប្រថុយពីមូលហេតុនាំឲ្យមានមូលភេទអ-អ៊ ក្នុងភាសាខ្មែរ

រំលឹកបន្តិចពីរឿងអ-អ៊ក្នុងភាសាខ្មែរ។ លោក ហ្សក ម៉ាស្ពេរ៉ូ ក្នុងសៀវភៅ La grammaire de la langue Khmère(1919)លើកឡើងថា ព្យញ្ជនៈខ្មែរចែកជាពីរពួក គឺពួកអនិងពួកអ៊។ ពួកអគឺព្យញ្ជនៈណាដែលមានស្រៈអ កប់ក្នុងហ្នឹង (voyelle inhérent ៦) ចំណែកពួកអ៊ គឺព្យញ្ជនៈ ដែលមានស្រៈអ៊ កប់ក្នុងហ្នឹង(voyelle inhérent ១)។ ត្រង់ហេតុថា ហេតុដែលនាំឲ្យគេសន្មតថាមានស្រៈអឬស្រៈកប់ក្នុងតួព្យញ្ជនៈ គឺលោកម៉ាស្ពេរ៉ូមិន បានលើកឡើយ។

លោកកេង វ៉ាន់សាក់ ក្នុងសៀវភៅ សូរសទ្ទវិទ្យាខ្មែរថាព្យញ្ជនៈខ្មែរគ្មាន ឃោសៈ អឃោសៈទេ តែមានមូលភេទ អ-អ៊។ លោកថាតែប៉ុណ្ណឹងដោយមិនបានពន្យល់ថា ហេតុអ្វីបានជាមានមូលភេទអ-អ៊ នោះក៏ ទេដែរ។

លោកយូរី អាឡិចសាន់ដ្រូវិច ហ្គោរហ្គោយ៉េវ ក្នុងសៀវភៅ Grammatika khmerskovo Yazyka លើកឡើងពីការចែកស្រៈខ្មែរជាសេរី(série)ទី១ និង សេរីទី២ ដោយសារតម្លង់កម្ម(អ-ឃោសកម្ម)នៃសូរព្យញ្ជនៈ ដែលចម្លងតាមភាសាឥណ្ឌាបុរាណ (សំស្ក្រឹត)។ លោកហ្គោរហ្គោញីយ៉េវ ក៏មិនបានពន្យល់ពីហេតុនាំឲ្យមានមូលភេទអ-អ៊ក្នុងព្យញ្ជនៈខ្មែរនោះដែរ។ មានអ្នកខ្លះទៀតថា អ-អ៊ ជាលក្ខណៈពិសេសនៃភាសាខ្មែរទៀតផង តែក៏មិនបាននិយាយពីហេតុនាំឲ្យមានអ-អ៊នោះឡើយ។ ដោយសារតែហេតុនេះ ខ្ញុំនឹងសាកល្បងពន្យល់ពីហេតុនាំឲ្យមានអ-អ៊ ។

# វិភាគសំណេរ ណ និង ន ក្នុងភាសាខ្មែរទំនើប

លោក ឡុង ឆវង្ស
និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យា
ទូរសព្ទ៖ ០៨៥ ៤៥១ ៤១១
អ៊ីម៉ែល៖ chh.vong411@gmail.com

## ឧទ្ទិសកថា

អត្ថបទនេះកើតមកពីការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទ ដែលព្យាយាមស្វែងយល់និងឆ្លើយចំពោះសំណួររបស់លោកគ្រូ នៅ ស៊ុន ដែលលោកគ្រូតែងតែបានលើកជាសំណួរឡើងនៅលើបណ្ដាញសង្គមហ្វេកប៊ុកកំឡុងពេលដែលលោកគ្រូនៅមានជន្មាយុនៅឡើយ។ ការបាត់បង់លោកគ្រូ នៅ ស៊ុន គឺជាការបាត់បង់ធនធានមនុស្សដ៏សំខាន់ម្នាក់របស់ជាតិខ្មែរ ជាពិសេសផ្នែកអក្សរសាស្ត្រ និងភាសាវិទ្យា។ ក្នុងនាមខ្ញុំបាទជាសិស្សម្នាក់ ខ្ញុំពិតជាមានការសោកស្ដាយយ៉ាងខ្លាំង ព្រោះមិននឹកស្មានថាលោកគ្រូចាកចេញពីពួកខ្ញុំយ៉ាងលឿនបែបនេះ ដោយមិនមានថ្ងៃត្រឡប់មកវិញបាន។ ស្នាដៃដ៏តូចមួយនេះ ខ្ញុំបាទសូមឧទ្ទិសចំពោះវិញ្ញាណក្ខន្ធលោកគ្រូ នៅ ស៊ុន និងសូមបួង សួងឱ្យវិញ្ញាណក្ខន្ធលោកគ្រូបានទៅកាន់សុគតិភពកុំបីខាន។

## សេចក្ដីផ្ដើម

បញ្ហាសំណេរក្នុងភាសាខ្មែរត្រូវបានអ្នកសិក្សានិងមហាជនទូទៅចាត់ទុកថាមិនទាន់មានឯកភាពគ្នានៅក្នុងការប្រើប្រាស់ឱ្យបានត្រឹមត្រូវតាមអក្ខរាវិរុទ្ធរបស់ពាក្យនៅឡើយទេ បើទោះបីជាគណៈកម្មាធិការជាតិភាសាខ្មែរ បានកំណត់ឱ្យយកវចនានុក្រមខ្មែរជាគោលចំពោះសំណេរពាក្យយ៉ាងណាក៏ដោយ ក៏ស្មេរមួយចំនួននៅតែសរសេរលែងវចនានុក្រមជារឿយៗដែរ។[1]

ស្មេរខ្លះនិយមសំណេរពាក្យរាយព្យាង្គ ស្មេរខ្លះនិយមសំណេរពាក្យពាក្យតម្រួតព្យាង្គ ចំណែកស្មេរមួយចំនួនទៀតនិយមសំណេរពាក្យតាមបែបទំនាញសូរ។ល។ ដោយមិនបានដឹងច្បាស់ពីប្រវត្តិនិងដំណាក់កាលនៃសំណេរទាំងនោះផងទេ។[2] ដោយសារតែអត្ថបទមួយនេះមាន លក្ខណៈជាអត្ថបទនិទស្សន៍ និងវិភាគតិចតួចទាក់ទងនឹង "វិភាគសំណេរ ណ និង ន ក្នុងភាសាខ្មែរទំនើប" ដូច្នេះនៅទីនេះ ស្មេរសូមលើកបង្ហាញដូចមានខាងក្រោមនេះ។

តាំងពីខ្មែរមានតួអក្សរសម្រាប់កត់ត្រាសូរសព្ទភាសារហូតមកទល់នឹងពេលនេះ យើងសង្កេតឃើញថាសំណេរពាក្យដែលទាក់ទងនឹង *ណ* ឬ *ន* នេះ ត្រូវបានប្រើប្រាស់មិនមានឯកភាពគ្នាទេ ម្ដងប្រើតួ *ណ* ម្ដងប្រើតួ *ន* ដូចជាពាក្យថា អំនោយ អំណោយ ឬអម្នោយ... នេះជាទិដ្ឋភាពពីមុនមកដ៏យូរអង្វែង។ ប៉ុន្តែក្រោយមកត្រូវបានដោះស្រាយបន្តិចម្ដងៗ ឆ្លងតាមសម័យកាលនីមួយៗ រហូតដល់សម័យដែលមានវចនានុក្រមប្រើប្រាស់

[1] ចំពោះស្មេរដែលសរសេរពាក្យខុស ឬប្រាសចាកពីពាក្យដែលមាននៅក្នុងវចនានុក្រមខ្មែរដែលបោះពុម្ពគ្រាទី៥នៅឆ្នាំ១៩៦៧ ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ត្រូវបានគេចាត់ទុកពាក្យនោះថា ខុសអក្ខរាវិរុទ្ធ។

[2] សំណេរពាក្យតាមទំនាញសូរមានទាំងសំណេររាយព្យាង្គផងនិងតម្រួតព្យាង្គផង។ ចំពោះភាសាខ្មែរ ករណីទំនាញសូរមាននៅក្នុងព្យាង្គ។ ប៉ុន្តែគេមិនអាចយកច្បាប់ទំនាញសូរមកធ្វើការកំណត់អក្ខរាវិរុទ្ធរបស់ពាក្យបានទាំងស្រុងឡើយ។

ដើម្បីកំណត់អក្ខរាវិរុទ្ធរបស់ពាក្យ។ បើទោះបីជាវចនានុក្រមបានព្យាយាមដោះស្រាយបញ្ហាអក្ខរាវិរុទ្ធរបស់ពាក្យ (តាមរយៈការបោះពុម្ពឡើងវិញលើកទី២ ទី៣ ទី៤ និងទី៥) ក៏ពិតមែន ក៏ប៉ុន្តែនៅមានបញ្ហាមួយចំនួនទៀតដែលនៅសេសសល់មិនទាន់ដោះស្រាយបានចប់សព្វគ្រប់នៅឡើយ។ តួយ៉ាងនៅសល់សំណេរពាក្យមួយចំនួនដែលវចនានុក្រមខ្មែរមិនទាន់បានរៀបចំឱ្យស្រួលស្របតាមក្បួន ឬគំរូជាធ្លុងមួយនៅឡើយដូចជាពាក្យ *កំនួច កំនៀរ ចំនួន ចំនួប ចំនៀរ តំនឿ តំនៀន សំនឹក សំនួន សំនៀង* និង *អំនួត*។ល។ ដែលក្បួនឬគំរូ គេត្រូវសរសេរពាក្យទាំងនេះជាមួយនឹងតួអក្សរ *ណ* តែនៅទីនេះគេបែរជាសរសេរជាមួយនឹងតួអក្សរ *ន* ទៅវិញ។

តាមពិតទៅបញ្ហាដែលទាក់ទងនឹង *សំណេរ ណ និង ន* វាមិនមែនជារឿងថ្មីដែលខ្ញុំទើបនឹងលើកឡើងនៅពេលនេះនោះទេ ពោលគឺមានការលើកឡើងជាយូរមកហើយ ដែលយើងឃើញមានដូចខាងក្រោម៖

លោក អៀវ កើស តាមរយៈសៀវភៅ ភាសាខ្មែរ(១៩៤៧) ទំព័រ៩០ លោកបានសរសេរថា *ក្នុងសម័យបូរាណ ព្យញ្ជនៈមុទ្ធជៈ (cérébrales) ដ ឋ ឌ ឍ ណ ឡ ហើយនិង ឞ គ ទុកសម្រាប់ប្រើតែចំពោះពាក្យដែលមកពីសំស្ក្រឹត ឬបាលី ក្នុងពាក្យខ្មែរសុទ្ធលោកមិនប្រើទេ*។ ប្រសិនយើងសង្កេតនូវអ្វីដែលលោកលើកឡើងនៅទីនេះ យើងអាចយល់បានថាក្នុងសម័យបុរាណ គេប្រើតួព្យញ្ជនៈ ណ ចំពោះតែពាក្យដែលមកពីសំស្ក្រឹត ឬ បាលី មិនប្រើចំពោះពាក្យខ្មែរសុទ្ធទេ។ សម័យបច្ចុប្បន្នដែលខ្មែរប្រើតួ ណ ដើម្បីកត់ពាក្យខ្មែរសុទ្ធ លោកមិនបានលើកលម្អិតឱ្យយើងបានដឹងពិតប្រាកដឡើយថា សមគួរប្រើឬមិនគួរប្រើ។

លោក កេង វ៉ាន់សាក់ តាមរយៈសៀវភៅ សូរសទ្ទខ្មែរ ទំព័រ៧០-៧១ លោកបានបង្ហាញស្របគ្នានឹងលោក អៀវ កើស ដែរថា *ឯការយកតួ ណ ឡ មកសរសេរខ្មែរសុទ្ធជាកំហុសទៅវិញ។ តួ ឌ ឍ ណ ឡ ទាំងនេះគេបានបង្កើតឡើងសម្រាប់តែពាក្យបាលី-សំស្ក្រឹតប៉ុណ្ណោះ គឺពុំមែនពាក្យខ្មែរទេ*។ តាមការលើកឡើងនេះតួ ណ បើកាលណាគេយកវាមកសរសេរឬកត់ត្រាពាក្យខ្មែរសុទ្ធ វាជាកំហុស ពោលគឺតួ ណ មិនត្រូវសរសេរចំពោះពាក្យខ្មែរសុទ្ធឡើយ។

វចនានុក្រមខ្មែររបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ(១៩៦៧) បោះពុម្ពគ្រាទី៥ ក៏បានធ្វើការកែប្រែសំណេរពាក្យជាច្រើន ក្នុងនោះសំណេរពាក្យដែលទាក់ទងនឹងតួព្យញ្ជនៈ ណ និង ន នេះ យើងឃើញមានជាតឹកតាងដូចជា៖ ទំព័រ-ញ- *ដំនៀល ន. ជា ដំណៀល* (ប្តូរពី ន>ណ)។ ទំព័រ៥៦ សំណេរមេពាក្យ *កំនួច* និង *កំនៀរ* វចនានុក្រមបានណែនាំឱ្យសរសេរជា *កំណួច* និង *កំណៀរ* បែបនេះ (ប្តូរពីតួ ន>ណ)។ ទំព័រ១៤១៩ ត្រង់មេពាក្យ សំណួរ វចនានុក្រមបញ្ជាក់ថា ... *ធ្លាប់សរសេរជា សំនួរ ខ្លះមកហើយ ប៉ុន្តែត្រូវសរសេរជា សំណួរវិញឱ្យដូចពាក្យឯទៀត*។ ទំព័រ១៤២១ សំណេរមេពាក្យ *សំនឹក* លោកឱ្យទៅមើលពាក្យ *សំណឹក*។ ដោយឡែកត្រង់សំណេរមេពាក្យនៅទំព័រដទៃទៀត វចនានុក្រមមិនបានណែនាំឱ្យប្តូរតួពី (ន>ណ) ឡើយ ដូចជាទំព័រ២១១ មានមេពាក្យ *ចំនួប ឬ ជំនួប, ចំនួន, ចំនៀរ*។ ទំព័រ៩៣៧ មានមេពាក្យ *តំនឿ, តំនៀន*។ ទំព័រ១៤២១ មានមេពាក្យ *សំនួន, សំនៀង*។ និងទំព័រ១៨៤៨ មេពាក្យ អំនួត។ល។

លោក លី សុវីរ៍[3] នៅក្នុងអត្ថបទស្តីពី ន ជំនួស ណ ល ជំនួស ឡ ហេតុអ្វីក្រសួងអប់រំយុវជននិងកីឡាសរសេរបែបនេះ?(២០០៤) ត្រង់ទំព័រ២៣ លោកបានសរសេរថា៖ *"ខ្ញុំសូមបញ្ជាក់ថា ក្រសួង មិនបានបំបាត់អ្វីទាំងអស់។ មានតែរៀបអក្សរតាមនាទីក្នុងពាក្យតែប៉ុននោះ"*។

[3] លោក លី សុវីរ៍ គឺជាអតីតគណៈកម្មការសរសេរសៀវភៅក្រសួងអប់រំ យុវជន និងកីឡា ម្នាក់ ដែលត្រូវបានក្រសួងបញ្ជាឱ្យក្រុមលោកសរសេរបន្តស្នាដៃរបស់ខេមរយានកម្ម។ ដោយមានការរិះគន់សំណេររបស់ក្រសួង ទើបលោកធ្វើគម្រោងបទសម្ភាសនៅប៉ុស្តិ៍អាស៊ីសេរី ពីថ្ងៃទី១ តុលា ២០០៤ ហើយបានចងក្រងជាកូនសៀវភៅនេះឡើង។

*ឧ. កោស > ខ្មោស > កំនោស (មិនប្រើ ណ តែប្រើ ន តាមរូបភាពកំលាយ)*

*សង > ស្នង > សំនង (មិនប្រើ ណ តែប្រើ ន តាមរូបភាពកំលាយ) ...*

*ដោយយោងតាមក្បួនវចនានុក្រមខ្មែរ*

*ស្ងាត់ > សំងាត់, ស្រស់ > សំរស់*

*ស្វែង > សំវែង, ស្ទេញ > សំទេញ ...។*

*តែបើទុកជាយកគោលការណ៍នេះមកធ្វើក៏ដោយ ក៏ក្នុងសៀវភៅក្រសួងអប់រំ នៅមានអក្សរ ណ និង ឡ ពេញសៀវភៅ។ .... បើព្យញ្ជនៈ ណ មានជើងអាចយកមកជំនួសជើង ន បាននោះ ចុះហេតុអ្វីបានជាសៀវភៅវចនានុក្រមទាំងមូល គ្មានធ្វើជើង ណ នៅពាក្យណាមួយឡើយ? ការបំបាត់អក្សរ ន៍ + ល៍ ត្រូវដូរលោយក្បួនវចនានុក្រមខ្មែរនិងឯកសារផ្សេងៗទៀតទាំងអស់។* ការបង្ហាញមកនេះនាំយើងឱ្យដឹងថា ពេលនោះមានការទិះតៀនសំណេររបស់ក្រសួង ដោយចោទប្រកាន់ថា ក្រសួងចង់លុបបំបាត់តួព្យញ្ជនៈ ន ប៉ុន្តែលោកបានបញ្ជាក់ថា មិនមានតួព្យញ្ជនៈណាមួយត្រូវបានលុបបំបាត់ទេ។

ក្រុមប្រឹក្សាជាតិភាសាខ្មែរ *សម្រង់ពាក្យដែលសរសេរជាមួយ «ណ» (មិនសរសេរជាមួយ «ន» ទេ) និងពាក្យដែលសរសេរជាមួយ «ឡ» ឬជាព្យាង្គតម្រួត (មិនសរសេរជាមួយ «ល» ទេ)* (២០០៨) ក៏បានស្រង់ពាក្យដែលមានសរសេរជាមួយនឹងតួ ណ និង ន នេះពីវចនានុក្រមខ្មែរ(បោះពុម្ពគ្រាទី៥)ដែរ ប៉ុន្តែសម្រង់ នៅក្នុងទិដ្ឋភាពជាពាក្យកម្លាយដែលមានជាប់ទាក់ទងទៅនឹងប្រកពពាក្យរឹសនិងផ្នត់កម្លាយតែ និងមិនមានការបកស្រាយឱ្យបានជាក់ច្បាស់ពីមូលហេតុដែលនាំឱ្យសរសេរជាមួយតួ ណ ឬ ន ឡើយ។

លោកសាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ ទាក់ទងនឹងសំណេរ ណ ឬ ន យើងអាចសង្ខេបបានបីចំណុចដូចតទៅ៖ ទី១ បើមានសូរអានជាពួក អ ត្រូវសរសេរនឹង ណ តែបើសូរអានជាពួក អ៊ ត្រូវសរសេរនឹង ន។ ឧទាហរណ៍ នាំ នាង នំ នាម នៅ។ល។ ណា ណាស់ ណោះ ណ្ហើយ។ល។ ទី២ លោកបានលើកឡើងទាក់ទងនឹងពាក្យខ្ចីពីបាលីមួយចំនួនមានសំណេរនិងសូរអានមិនស្របតាមការប្រកបសូរនៃភាសាខ្មែរដែលមានមូលគេទ អ-អ៊។ ពោលគឺសូរ អ តែកត់នឹង ន ហើយសូរ អ៊ បែរជាកត់នឹង ណ។ ឧទាហរណ៍ *សេនា* សាសនា(សូរ អ តែកត់នឹង ន) និង *ប្រពៃណី ប្រៃសណីយ៍ វេប្បវេណី*(សូរ អ៊ តែកត់នឹង ណ)។ និងទី៣ លោកបានលើកឡើងទាក់ទងនឹងបញ្ហា សំណេរ ណ ឬ ន (ក្នុងពាក្យកម្លាយ) តាមរយៈផ្នត់ដែក [-អ៉ម/ន-] ឬ [-អ៉ម/ណ-] ដោយបានផ្តល់ជាដំណោះស្រាយថា បើកម្លាយចេញពីពាក្យឫសដែលព្យញ្ជនៈដើមព្យាង្គមានសូរ អ ត្រូវប្រើផ្នត់[-អ៉ម/ណ-]។ ហើយបើឫសមានសូរ អ៊ គេត្រូវប្រើផ្នត់ដែក[-អ៉ម/ន-]។ (ច័ន្ទ សំណព្វ, ២០១២ : ២៤-២៦)។

ខាងក្រោមនេះគឺជាសេចក្តីខ្លះៗដែលខ្ញុំបានសង្កេតពិនិត្យលើបញ្ហា *សំណេរ ណ ឬ ន* ដែលសង្ខេបជារួមមានបីចំណុច។ បើទោះបីជាចំណុចណាមួយនោះមិនមែនជាបញ្ហាចោទខ្លាំងចំពោះសំណេរ *ណ* និង *ន* ក៏ដោយ ក៏ទាំងនេះជាអ្វីដែលយើងសង្កេតឃើញមាននៅក្នុងភាសាខ្មែរយើងដែរ។

## ១- សំណេរ ណ ឬ ន ជាធាតុក្នុងពាក្យដែលខ្មែរខ្ចីពីបរទេស

គ្រប់ភាសានៅក្នុងលោកមិនមានភាសាណាមួយសុទ្ធជាច់ដោយឡែកពីគេ ដែលមិនពាក់ព័ន្ធនឹងភាសាដទៃណាមួយនោះឡើយ ពោលគឺវាតែងមានទំនាក់ទំនងគ្នានៅក្នុងក្របខណ្ឌនៃកម្ចីពាក្យ វិធីបង្កើតពាក្យ ឬក្បួនវេយ្យាករណ៍។ល។ ដូច្នេះហើយ ទើបមានការបែងចែកភាសាជាអម្បូរ ក្រុម និងប្រភេទ ទៅតាមទំនាក់ទំនងដែលវាមានប្រហាក់ប្រហែលគ្នា។ លើសពីនេះបើទោះបីជាភាសាឋិតនៅក្នុងអម្បូរផ្សេងគ្នា ក៏វាអាចមានទំនាក់

ទំនងគ្នានៅក្នុងក្របខណ្ឌណាមួយដែរ។ តួយ៉ាងភាសាបាលី-សំស្ក្រឹត ជាភាសាបិតក្នុងអម្បូរឥណ្ឌូអឺរ៉ុប ចំណែកភាសាខ្មែរបិតក្នុងអម្បូរអូស្ត្រូអាស៊ីយ៉ាទិក តែក្នុងភាសាខ្មែរមានប្រើប្រាស់ក្បួនវេយ្យាករណ៍បែបបាលី-សំស្ក្រឹត-ខ្មែរ លាយឡំគ្នា និងមានខ្ចីពាក្យពីភាសាបាលី-សំស្ក្រឹតយ៉ាងច្រើន។ នៅក្នុងការខ្ចីពាក្យពីបាលី-សំស្ក្រឹត ខ្មែរមិនបានខ្ចីមកទាំងដុលនោះឡើយ ពោលគឺធ្វើខ្មែរនីយកម្មឱ្យមានលក្ខណៈជាខ្មែរ ឱ្យស្រួលស្របសម្រាប់ខ្មែរប្រើប្រាស់។ មិនថាតែចំពោះកម្ចីពាក្យពីភាសាបាលី-សំស្ក្រឹត ទិដ្ឋភាពខ្មែរនីយកម្មធំៗបីលើពាក្យកម្ចីពីបរទេស គឺ សំណេរនីយកម្ម សំណូរនីយកម្ម និងន័យនីយកម្ម។ សំណេរនីយកម្ម ខ្មែរមិនមានការកែប្រែឱ្យឃ្លាតឆ្ងាយពី និរុត្តិសាស្ត្ររបស់ភាសាដើមប៉ុន្មានឡើយ ទាំងប្រព័ន្ធសំណេរពាក្យ និងព្យញ្ជនៈឬស្រៈ ភាគច្រើនយើងរក្សាមិនកែប្រែ តែក៏មានមួយចំនួនដែលយើងមានថែមថយសំណេរខ្លះៗ(យើងប្រើវណ្ណយុត្តិមួយចំនួនដូចជា ៍ ័ និង ៈ ជាដើម) ឧទាហរណ៍ពាក្យ វេយ្យាករណ(បា.) វៃយាករណ(សំ.) ដល់មកខ្មែរជា វេយ្យាករណ៍ ពាក្យ ភយ (សំ.បា.) ដល់មកខ្មែរជា ភ័យ និងពាក្យ អាសន(សំ.បា.) ដល់មកខ្មែរជា អាសនៈ។ល។ សំណូរនីយកម្ម មានការកែប្រែស្ទើរតែទាំងស្រុងឱ្យមកជាខ្មែរ ដើម្បីស្រួលនិយាយឬស្រួលអាន ឧទាហរណ៍ពាក្យ សុវណ្ណ (បា.សំ. អាចអានថា សុវ៉ាន់ណៈ ខ្មែរអានថា សុវ៉ាន់) និង ជន(បាលីអាន ជៈនៈ ខ្មែរអានថា ជន់)។ល។
ចំណែកឯន័យនីយកម្ម មានប្រើឃ្លាតន័យតិចតួចបំផុតពីពាក្យដើមរបស់គេ ដូចជាខ្មែរប្រើ សាមញ្ញ(បា.) ឬ សាមាន្យ(សំ.) សំដៅន័យផ្សេងគ្នា និង សង្ខារ(បា.) ឬ សំសារ(សំ.) ឬ សង្សារ(សំ.បា.)។ល។

សំណេរ *ណ* ឬ *ន* ជាធាតុក្នុងពាក្យកម្ចីដែលខ្មែរខ្ចីពីបរទេស មានទាំងនៅដើមព្យាង្គ កណ្ដាលព្យាង្គ និងចុងព្យាង្គ ហើយមិនមែនមានតែកម្ចីពីបាលី-សំស្ក្រឹត ប៉ុណ្ណោះទេ ដែលឃើញមានដូចតទៅ៖

**ក- សំណេរ ណ ឬ ន ជាធាតុនៅដើមព្យាង្គនៃពាក្យកម្ចី**

- កម្ចីពីបាលី-សំស្ក្រឹត៖

ឧទាហរណ៍៖ នក្ខត្តឫក្ស នគរ នទី នព្វ នបុំសកលិង្គ នភា នរក នរនាថ នរបតី នាគ នានា នាម នាយក។ល។ នៅក្នុងវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧ ត្រង់មេពាក្យផ្ដើមដោយព្យញ្ជនៈ ណ ចាប់ពីទំព័រ៣២៨ដល់ទំព័រ៣៣១ យើងសង្កេតឃើញថាមិនមានពាក្យកម្ចីពីបាលី-សំស្ក្រឹត ដែលផ្ដើមដោយតួព្យញ្ជនៈ ណ ជាព្យញ្ជនៈដើមព្យាង្គ នៅក្នុងវចនានុក្រមឡើយ។

- កម្ចីពីសៀម៖

ឧទាហរណ៍៖ ណាមស្រង់ ណៃណន ណាំនួន ណាំង(ឬហ្នាំង)។ល។ នេន(ខ្ចីត្រឡប់មកវិញ)។ សៀមកត់ពាក្យទាំងនេះ នឹងតួ ន ទាំងអស់។

- កម្ចីពីបារាំង៖

ឧទាហរណ៍៖ នីឡុង។

- កម្ចីពីយួន៖

ឧទាហរណ៍៖ នឿក។

សរុបមក សំណេរ *ណ* ឬ *ន* ជាធាតុនៅដើមព្យាង្គនៃពាក្យកម្ចីពីបរទេសមកសរសេរនៅក្នុងភាសាខ្មែរ មានលេចឡើងនូវទិដ្ឋភាពពីរយ៉ាងយ៉ាងតិចគឺ ទី១រក្សាសំណេរនៅដដែល និងទី២គឺផ្លាស់ប្ដូរសំណេរពី ន>ណ ឬពី ណ>ន ដោយយើងមិនប្រើការកត់ត្រាជា ន៉ ឬ *ណ៊ា គឺដើម្បីរក្សាសំណូរដើមនៃពាក្យរបស់គេ។

**ខ- សំណេរ ណ ឬ ន ជាធាតុនៅកណ្ដាលព្យាង្គនៃពាក្យកម្ចី** [4]

[4] សូមមើលទិន្នន័យត្រង់ឧបសម្ពន្ធ១ ត្រង់ទំព័រ១០។

- កម្ចីពីបាលី-សំស្ក្រឹតៈ

ឧទាហរណ៍ៈ ចណ្ឌាល ជននី តន្ត្រី ធរណិន្ទ្រ និន្នាការ និន្នាទ បណ្ណាការ បណ្ណាល័យ។ល។ នៅទីនេះគឺយើងរក្សាសំណេរពាក្យដើមទាំងស្រុង។

### គ- សំណេរ ណ ឬ ន ជាធាតុឬព្យញ្ជនៈប្រកបចុងព្យាង្គនៃពាក្យកម្ចី

សញ្ញាណវេយ្យាករណ៍ប្រពៃណីបានឱ្យយើងដឹងថា ព្យញ្ជនៈប្រកប *ណ* ខាងចុងសម្គាល់ជាពាក្យកម្ចីពីភាសាបាលីនិងសំស្ក្រឹត ដូចជាពាក្យ *កសិណា កេណ្ឌ កោណ ក្សិណ ក្សីណ កិរុណ ប្រមាណ ប្រាណ* និង *ពិណ*។ល។ ការលើកឡើងនេះមិនមានអ្វីខុសនោះទេ ព្រោះបើយោងតាមទិន្នន័យសម្រង់ពាក្យប្រកបនឹង ណ នៅក្នុងភាសាខ្មែរ យើងឃើញថាវាជាពាក្យកម្ចីមកពីភាសាបាលី-សំស្ក្រឹត ទាំងអស់។ ចំណែកព្យញ្ជនៈប្រកប ន ខាងចុងមានទាំងចំពោះពាក្យខ្មែរសុទ្ធ ពាក្យកម្ចីពីបាលី-សំស្ក្រឹត កម្ចីពីសៀម កម្ចីពីលាវ កម្ចីពីចិន កម្ចីពីជ្វា កម្ចីពីបារាំង។ល។ [5] ដោយសារវាមិនមែនជាបញ្ហាចោទសំខាន់ ដូច្នេះខ្ញុំសូមមិនលម្អិតត្រង់ចំណុចនេះទេ។

## ២- សំណេរ ណ ឬ ន ជាធាតុមួយនៅក្នុងផ្នត់កម្លាយ

ការបង្កើតពាក្យដោយវិធីកម្លាយ ជាវិធីដ៏សំខាន់មួយសម្រាប់ភាសាក្នុងក្រុមមន-ខ្មែរ ហើយដែលនៅក្នុងភាសាខ្មែរយើងអាចបង្កើតពាក្យបានយ៉ាងច្រើនសម្បូរបែបផងដែរ។ កន្លងមកទល់នឹងពេលនេះ យើងបានប្រើប្រាស់ផ្នត់កម្លាយពីរគឺ ផ្នត់ដើម និងផ្នត់ដែក។ ផ្នត់ដើម និងផ្នត់ដែក មានច្រើនទម្រង់ និងមានបែងចែកជាផ្នត់ផ្សេងៗជាច្រើនទៀតទៅតាមទម្រង់នីមួយៗ ប៉ុន្តែដោយហេតុថានៅទីនេះ យើងនិយាយតែចំពោះតួ ណ និង ន ដូច្នេះខ្ញុំសូមលើកយកតែផ្នត់ណាដែលមានតួ ណ ឬ ន ជាចំណែកធាតុនៅក្នុងផ្នត់នោះមកបង្ហាញតែប៉ុណ្ណោះ។

### ២.១- សំណេរ ណ ឬ ន ជាធាតុមួយនៅក្នុងផ្នត់ដើម

សំណេរ ណ ឬ ន ក្នុងផ្នត់ដើមមួយចំនួនដូចជា /ក'ណ-; ក'ន- : kan-/, /គ'ន- : kun-/, /ច'ន- : can-/, /ជ'ន- : cun-/, /ដ'ណ- ; ដ'ន- : dan-/, /ទ'ន- : tan-/, /ប'ណ- ; ប'ន- : ban-/, /ព'ន- : pun-/, /រ'ណ- ; រ'ន- : run-/, /ល'ន- : lun-/, /ស'ណ- ; ស'ន- : san-/, /អ'ណ- ; អ'ន- : an-/ ... វាមិនមានរូបឯករាជ្យពេញលេញដោយខ្លួនវាឡើយប្រសិនវាឈរជាសំណេរផ្នត់បែបនេះ ព្រោះបរិបទសំណេរផ្នត់ក្នុងទីនេះវាមិនស្ដែងជាពាក្យ ប៉ុន្តែវានឹងក្លាយទៅជាសំណេរពេញលេញនៅក្នុងពាក្យកម្លាយ។ ជាការពិតទិដ្ឋភាពសំណេរ *ណ* ឬ *ន* នៅក្នុងផ្នត់ដើមទាំងឡាយនេះ ខ្ញុំមិនសូវឃើញ(ឬមិនឃើញ) គេចាប់អារម្មណ៍បកស្រាយឱ្យបានទូលាយទេ ច្រើនតែឃើញបកស្រាយក្នុងទិដ្ឋភាពផ្នត់ដែក។ ខាងក្រោមនេះ ខ្ញុំនឹងល្បងវិភាគបង្ហាញពីតួ *ណ* ឬ *ន* នៅក្នុងផ្នត់ដើមមួយចំនួនហើយដែលទាញជាគូធៀបលើតួ *ណ* និង *ន*ដូចតទៅនេះ៖

#### ២.១.ក- ផ្នត់ដើម /ក'ណ-; ក'ន- : kan-/

ក្នុងទិដ្ឋភាពនៃផ្នត់ដើមទាំងនេះគេច្រើនតែយល់ថា មូលហេតុសរសេរនឹង *ណ* ឬ *ន* គឺយោងទៅលើព្យញ្ជនៈដើមព្យាង្គនៃពាក្យរឹស។ ប្រសិនបើព្យញ្ជនៈដើមព្យាង្គនៃពាក្យរឹសជាពួក អ ត្រូវសរសេរពាក្យកម្លាយមានតួ ណ ដូចជា /ក'ណ-/ + ដក់(ដ ជាពួក អ) > កណ្ដក់។ ហើយប្រសិនបើព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសជាពួក អ៊ ត្រូវសរសេរពាក្យកម្លាយមានតួ ន ដូចជា /ក'ន-/ + ទ្រើង(ទ ជាពួក អ៊) > កន្ទ្រើង។ ប៉ុន្តែវាមិនមែនបែបនេះទាំងស្រុងទេ ព្រោះយើងច្បាស់ជាសង្កេតឃើញថា មានព្យញ្ជនៈដើមព្យាង្គនៃពាក្យរឹសមួយចំនួនជាពួក អ តែ

[5] សូមមើលទិន្នន័យត្រង់ឧបសម្ពន្ធ១ ត្រង់ទំព័រ១០។

សំណោរពាក្យកម្លាយមិនមែនសរសេរនឹងតួ ណ ឡើយ បែរជាមកសរសេរនឹងតួ ន វិញដូចជា /ក'ន-/ + តុញ > កន្តុញ, /ប'ន-/ + ត > បន្ត ...។ ត្រង់នេះមូលហេតុដែលសរសេរនឹងតួ ណ ឬ ន គឺមិនមែនមកពីគោរពតាមមូលភេទព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសឡើយ ប៉ុន្តែវាបែរជាអនុលោមទៅតាមព្យញ្ជនៈដែលបិតនៅក្នុងវគ្គជាមួយគ្នាទៅវិញទេ។[6] តួ ណ នៅក្នុងវគ្គជាមួយ ដ ឋ ឌ ឍ ដូច្នេះបើពាក្យឫសផ្តើមដោយព្យញ្ជនៈទាំងបួននេះ និងបិតក្នុងក្របខណ្ឌនៃផ្នត់ដែលយើងកំពុងនិយាយនៅពេលនេះ ពោលគឺគេកត់ផ្នត់ដោយមានជាតុឬតួ ណ ដូចជា /ក´ណ-/ + ដាច > កណ្តាច, /ក´ណ-/ + ដាច់ > កណ្តាច់។ល។ ដូចគ្នានេះដែរតួ ន នៅក្នុងវគ្គជាមួយ ត ថ ទ និង ធ គឺគេកត់ផ្នត់ដោយមានជាតុឬតួ ន ដូចជា /ក´ន-/ + ត្រង > កន្ត្រង, /ក´ន-/ + ធាត់ > កន្ធាត់។ល។

**២.១.៥- ផ្នត់ដើម /ប'ណ- ; ប'ន- : ban-/ , ផ្នត់ដើម /ស'ណ- ; ស'ន- : san-/ និងផ្នត់ដើម /អ´ណ- ; អ´ន- an : /**

ចំពោះសំណោរ *ណ* នៅក្នុងផ្នត់ដើម /ប'ណ-/, ផ្នត់ដើម /ស'ណ-/ និងផ្នត់ដើម /អ´ណ-/ បើពិនិត្យតាមទិន្នន័យពាក្យដែលស្រង់បាន[7] គឺមានមូលហេតុដូចទៅនឹងសំណោរ *ណ* នៅក្នុងផ្នត់ដើម /ក´ណ-/ ដែរ។ ដោយឡែកចំពោះសំណោរ *ន* នៅក្នុងផ្នត់ដើម /ប'ន-/, ផ្នត់ដើម /ស'ន-/ និងផ្នត់ដើម /អ´ន-/ ក្រៅពីប្រើជាមួយពាក្យឫសដែលមានព្យញ្ជនៈក្នុងវគ្គជាមួយគ្នា វាមានលទ្ធភាពអាចប្រើជាមួយព្យញ្ជនៈនៅក្នុងក្រុមសេសវគ្គបានថែមទៀតដូចជា /ប´ន-/ + លឺ > បន្លឺ, /ប´ន-/ + សល់ > បន្សល់។ល។ /ស´ន-/ + លាង > សន្លាង, ល។ /ស´ន-/ + លឹម > សន្លឹម, /ស´ន-/ + លឹម > សន្លឹម, /ស´ន-/ + សើម > សន្សើម។ល។ /អ´ន-/ + ត្រោក> អន្ត្រោក, /អ´ន-/ + ទាក់ > អន្ទាក់។ល។ យោងតាមវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ទំព័រ៤៩១ បានបញ្ជាក់ឱ្យដឹងថា៖ "*ន ... តម្រួតលើព្យញ្ជនៈទាំង៤តួក្នុងវគ្គរបស់ខ្លួនគឺ ត, ថ, ទ, ធ និងលើតួឯង ហើយនិងលើព្យញ្ជនៈសេសវគ្គ៦តួគឺ យ, រ, ល, វ, ស, ហ ទៀតផង តាមអក្ខរវិធីខ្មែរ*"។

## ២.២- សំណោរ ណ ឬ ន ជាជាតុមួយនៅក្នុងផ្នត់ដែក

ក្រៅពីសំណោរ ណ ឬ ន ដែលជាជាតុមួយនៅក្នុងផ្នត់ដើម យើងក៏ប្រើសំណោរ ណ ឬ ន ជាជាតុក្នុងផ្នត់ដែកមួយចំនួនដែរ ដូចជា /-អ'ណ- ; -អ'ន- : -an-/, /-អ'ម/ណ- ; -អ'ម/ន- : -am/n-/, /-អ៊'ម/ន- : -um/n-/, /-ន- : -n-/, /- អ៊ី/ន- : -ɔ/n-/, /-រ៍/ន- : -rɔ/n-/ ...។

**២.២.១- ផ្នត់ដែក /-អ'ណ-/ និង /-អ'ន-/ : /-an-/**

ចំពោះផ្នត់ /-អ'ណ-/ ឃើញប្រើសំណោរ ណ និងប្រើបានតែជាមួយព្យញ្ជនៈដើមព្យាង្គនៃពាក្យរើសដែលជាពួក អ ដូចជា : ក្តាប់ + /-អ'ណ-/ > កណ្តាប់, ផ្តុំ + /-អ'ណ-/ > បណ្តុំ...។ វាដូចគ្នាទៅនឹង សំណោរ ណ ដែលជាជាតុមួយនៅក្នុងផ្នត់ដើមដែរ ព្រោះវាប្រើបានតែជាមួយព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសដែលមានសូរ អ និងបិតនៅក្នុងវគ្គជាមួយវាតែប៉ុណ្ណោះ។[8]

ចំពោះផ្នត់ /-អ'ន-/ ឃើញមានទិដ្ឋភាពពីរលេចឡើងគឺ៖ ទី១ ព្យញ្ជនៈផ្សំដើមដើមព្យាង្គនៃពាក្យរើសជាពួក អ ដូចជា ផ្តក់ + /-អ'ន-/ > បន្តក់, ផ្សំ + /-អ'ន-/ > បន្សំ....។[9] យោងតាមឧទាហរណ៍នេះ បើយើងញែកព្យ

[6] សូមមើលទិន្នន័យក្នុងឧបសម្ពន្ធ២ ត្រង់ទំព័រ១៧។

[7] សូមមើលទិន្នន័យក្នុងឧបសម្ពន្ធ២ ត្រង់ទំព័រ១៧, ២០។

[8] សូមមើលទិន្នន័យក្នុងឧបសម្ពន្ធ២ ត្រង់ទំព័រ២១។

ញ្ជនៈផ្សំដើមព្យាង្គនៃពាក្យឫស វាលេចឡើងនូវទិដ្ឋភាពពីរទៀតគឺ ព្យញ្ជនៈផ្សំដើមព្យាង្គជាសូរ អ ទាំងពីរ ដោយមានព្យញ្ជនៈមួយឋិតនៅក្នុងក្រុមជាមួយ ន និងព្យញ្ជនៈមួយទៀតមិនឋិតនៅក្នុងក្រុមជាមួយ ន ឡើយ(វាអាចជាព្យញ្ជនៈនៅក្នុងវគ្គ ឬសេសវគ្គ)។ ទី២ ព្យញ្ជនៈផ្សំដើមព្យាង្គនៃពាក្យរឹសជាសូរពួក អ៊(អាចកើតឡើងតាមទំនាញសូរ(ក្នុងក្របខណ្ឌជាព្យាង្គ)នៃពាក្យឫស មុននឹងប្រើផ្នត់ដែកដើម្បីកម្លាយពាក្យ) ដូចជា : ផ្ទុក + /-អ'ន-/ > បន្ទុក, ស្ទុះ + /-អ'ន-/ > សន្ទុះ...។ ហើយកត្តាកំណត់សំណេរ ន ជាធាតុមួយនៃសំណេរផ្នត់ ឬលេចចេញច្បាស់ និងឯករាជ្យពេញលេញនៅក្នុងសំណេរនៃពាក្យកម្លាយដោយសារតែ ធាតុនៃព្យញ្ជនៈផ្សំនៃពាក្យឫស វាមានព្យញ្ជនៈណាមួយឋិតនៅក្នុងវគ្គជាមួយ ន។

**២.២.២- ផ្នត់ដែក /-អ'ម/ណ-/ និង /-អ'ម/ន-/ : /-am/n-/ និង /-អ៊'ម/ន-/**

ចំពោះផ្នត់ /-អ'ម/ណ-/ ឃើញថា សំណេរ ណ ក្នុងពាក្យកម្លាយអនុលោមតាមសូរ អ នៃព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសទាំងស្រុង។ ឧទាហរណ៍ កក + /-អ'ម/ណ-/ > កំណក, ដក + /-អ'ម/ណ-/ > ដំណក, តក់ + /-អ'ម/ណ-/ > តំណក់, ចង់ + /-អ'ម/ណ-/ > ចំណង់, បក + /-អ'ម/ណ-/ > បំណក, សូក + /-អ'ម/ណ-/ > សំណូក, អាច + /-អ'ម/ណ-/ > អំណាច...។ យើងសង្កេតឃើញមានទិដ្ឋភាពបីលេចឡើងគឺ ទី១ សំណេរ ណ ក្នុងបរិបទនេះវាអនុលោមតាមសូរ អ នៃពាក្យឫស ព្រោះ ណ ក៏មានសូរឬជាពួក អ ដូចគ្នា។ ទី២ ណ អាចមានលទ្ធភាពប្រើជាមួយពាក្យឫសដែលនៅក្រៅវគ្គខ្លួនបាន។ និងទី៣ ណ អាចប្រើជាសំណេរ(ជាតុមួយ)ដើម្បីកត់ត្រាពាក្យកម្លាយដែលព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសឋិតនៅក្នុងវគ្គ ន(មានតួ ត ជាដើម) ទីនេះដោយសារតែការកំណត់សំណេរ ណ ត្រូវអនុលោមតាមសូរ អ នៃពាក្យឫស ។

ចំពោះផ្នត់ /-អ'ម/ន-/ ឃើញថាសំណេរ ន ក្នុងពាក្យកម្លាយ ជាសំណេរដែលរត់ឬចាកពីមូលភេទរបស់ព្យញ្ជនៈដើមព្យាង្គនៃពាក្យរឹស ដែលតាមពិតគួរត្រូវសរសេរពាក្យកម្លាយដោយមានតួព្យញ្ជនៈ ណ ទើបត្រឹមត្រូវជាង បើទោះបីជាប្រើជាមួយស្រៈ ួ ឿ ៀ ដែលអាចមានសូរ អ៊ ឬទុកថាវាមានសូរដូចគ្នាក៏ដោយចុះ(ចំពោះខ្ញុំនិយាយឬអានចេញសូរតែមួយ តែចំពោះអ្នកដទៃប្រហែលជាគេនិយាយឬអានចេញសូរមិនដូចគ្នា ការនេះសម្រាប់សូរវិទូ ឬអ្នកចូលចិត្តផ្នែកសូរប្រាកដជាដឹងច្បាស់)។ ទិដ្ឋភាពនេះវាកើតមានចំពោះពាក្យមួយចំនួនដូចជា ចួន + /-អ'ម/ន-/ > ចំនួន, ចួប ឬ ជួប + /-អ'ម/ន-/ > ចំនួប ឬ ជំនួប, ចៀរ + /-អ'ម/ន-/ > ចំនៀរ, អួត + /-អ'ម/ន-/ > អំនួតល។ល។ ។ ត្រង់នេះដែរ ក៏ត្រូវពិនិត្យមើលលំណែនាំរបស់សម្ដេចសង្ឃ ជួន ណាត ត្រង់ទំព័រ-ញ- ទំព័រ៥៦ ទំព័រ១៤១៩ និងទំព័រ១៤២១ នៃវចនានុក្រមខ្មែរ ហើយដើម្បីឱ្យមានភាពត្រឹមត្រូវតាមក្បួននិងស្របតាមលំណែនាំនេះផង គួរត្រូវសរសេរនឹងតួ ណ វិញ។ សរុបមកចំពោះពាក្យកម្លាយមួយចំនួនក្នុងផ្នត់ /-អ'ម/ន-/ នេះ បើយកឱ្យត្រង់តាមមូលភេទនៃព្យញ្ជនៈដើមព្យាង្គរបស់ពាក្យឫសឃើញថានឹងកែប្រែពី ន ទៅ ណ ហើយបើប្រែទៅសរសេរនឹង ណ ដូច្នេះផ្នត់ /-អ'ម/ន-/ក៏អាចបាត់បង់ដែរ (ការកែប្រែសំណេរពី ន ទៅ ណ មិនមានការបាត់បង់ព្យញ្ជនៈណាមួយពីតារាងព្យញ្ជនៈខ្មែរដែរ)។ ការដែលសំខាន់ តើបន្តទុកបែបនេះ ឬកំណត់សរសេរ ឬជ្រើសរើសតែមួយ(សរសេរនឹង ច ជ ...ក៏ដូចគ្នាដែរ)។

**២.២.៣- ផ្នត់ដែក /-ន-/**

ចំពោះផ្នត់ដែក /-ន-/ ឃើញថាសំណេរ ន ដែលគេតាងតួសម្រាប់កត់សំណេរផ្នត់ វាបានក្លាយទៅជាជើង( ្ន )នៅក្នុងពាក្យកម្លាយ ហើយយើងមិនអាចផ្ទៀងផ្ទាត់ដូចម្ដេចបានជាមួយនឹងមូលភេទរបស់ព្យញ្ជនៈដើមព្យាង្គនៃពាក្យរឹស។ ឧទាហរណ៍៖ កោស + /-ន-/ > ខ្នោស(គេមិនសរសេរវាជា *ខ្ណោស), ជាន់ + /-ន-/ > ឈ្នាន់ (គេមិនអាចសរសេរវាជា *ឈ្ណាន់)។ល។ ការនេះព្រោះប្រហែលតាំងពីយូរមកហើយដែរ ដែលប្រើតួ ន នេះ ក្នុង

ទិដ្ឋភាពផ្នត់ដើម្បីបង្កើតពាក្យ (លោកមិនប្រើតួ ណ ដោយហេតុថាតួ ណ នេះប្រើចំពោះពាក្យបាលី-សំស្ក្រឹត តែបើសង្កេតតាមរយៈផ្នត់កម្លាយ ឃើញថាមានប្រើតួ ណ នេះយ៉ាងច្រើនចំពោះពាក្យខ្មែរ(មន-ខ្មែរ)។

## សន្និដ្ឋាន

ដូច្នេះសរុបជារួមមកវិញ ការដែលថាសរសេរនឹង ណ ឬ ន គឺយោងទៅតាមហេតុផលមួយចំនួនដូចដែលយើងបានលើកឡើង ហើយយើងអាចសង្ខេបមកមានដូចខាងក្រោម៖

- នៅដើមព្យាង្គលីសូរ អ សរសេរនឹង ណ លីសូរ អ៊ សរសេរនឹង ន។
- គោរពនិរុត្តិសព្ទពាក្យកម្ចី (តែសូរអោចមិនគោរពតាមមូលភេទក្នុងភាសាខ្មែរ)។
- ព្យញ្ជនៈប្រកបចុងព្យាង្គ ណ ប្រើចំពោះពាក្យកម្ចីពីភាសាបាលី-សំស្ក្រឹត។
- ព្យញ្ជនៈប្រកបចុងព្យាង្គ ន ប្រើទាំងចំពោះពាក្យខ្មែរ និងពាក្យកម្ចីពីភាសាបរទេស។
- ព្យញ្ជនៈ ណ អាចត្រួតបានតែលើតួ ណ ខ្លួនឯង(ពាក្យកម្ចីពីបាលី-សំស្ក្រឹត) និងតួ ហ តែប៉ុណ្ណោះ ហើយវានៅក្រោមតួព្យញ្ជនៈ ស។
- ព្យញ្ជនៈ ន អាចប្រើបានលើតួ ន ខ្លួនឯង លើតួ ម ហើយអាចនៅក្រោមតួព្យញ្ជនៈជាច្រើន។
- ករណីក្នុងពាក្យកម្លាយ សំណេរ ណ ឬ ន គឺវាអនុលោមតាមមូលភេទ អ-អ៊ នៃព្យញ្ជនៈដើមព្យាង្គនៃពាក្យឫស។ ចំពោះសំណេរ ណ ភាគច្រើនឬទាំងស្រុងគោរពតាមមូលភេទ(អ)របស់ព្យញ្ជនៈដើមព្យាង្គនៃពាក្យរឹស(ក្នុងទិដ្ឋភាពផ្នត់កម្លាយ)។ ចំពោះសំណេរ ន មានច្រើនគោរពតាមមូលភេទ(អ៊)របស់ព្យញ្ជនៈដើមព្យាង្គនៃពាក្យរឹស ហើយក៏មានច្រើនដែរដែលឃ្លាតពីមូលភេទនៃព្យញ្ជនៈដើមព្យាង្គនៃពាក្យរឹស។
- ករណីក្នុងពាក្យកម្លាយ សំណេរ ណ ឬ ន គឺវាអនុលោមតាមមូលភេទ អ-អ៊ នៃព្យញ្ជនៈដើមព្យាង្គនៃពាក្យឫស ព្រមទាំងកំណត់តាមវគ្គនៃព្យញ្ជនៈ ណ ឬ ន ផងដែរ។ ព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសឋិតក្នុងវគ្គ ណ គេកត់ពាក្យកម្លាយមានតួ ណ។ ព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសឋិតក្នុងវគ្គ ន គេកត់ពាក្យកម្លាយមានតួ ន។ ករណីនេះប្រសិនមានការសរសេរជាតម្រួតព្យាង្គ អាចនាំយើងឱ្យយល់បានមួយផ្នែកដែរ ទាក់ទងនឹងការប្រើជើងព្យញ្ជនៈ ពោលគឺនាំយើងឱ្យដឹងថា មួយណាជាជើង ដ(្ដ) និងមួយណាជាជើង ត(្ត)។
- ករណីក្នុងពាក្យកម្លាយ សំណេរ ណ គឺវាអនុលោមតាមមូលភេទ អ-អ៊ នៃព្យញ្ជនៈដើមព្យាង្គនៃពាក្យឫសហើយ ប៉ុន្តែវាអាចកត់ជាមួយព្យញ្ជនៈដែលនៅវគ្គ ន បានដែរដែលមានតួ ត នេះជាដើម៕

## ឧបសម្ព័ន្ធ

### ១- សំណេរ ណ និង ន ជាព្យញ្ជនៈប្រកប

| សទ្ទដើមព្យាង្គ | ប្រកប | ពាក្យ |
|---|---|---|
| ក | ណ | +បាលី-សំស្ក្រឹត៖ កសិណ កេណ្ឌ កោណ ក្សិណ ក្សីណ។ |
| គ | | +បាលី-សំស្ក្រឹត៖ គណ គុណ។ |
| ឆ | | +បាលី-សំស្ក្រឹត៖ ឆវិណ្ណ។ |
| ត | | +បាលី-សំស្ក្រឹត៖ ត្រាណ។ |

| | | |
|---|---|---|
| ទ | | +បាលី-សំស្ក្រឹតៈ ទារុណ។ |
| ប | | +បាលី-សំស្ក្រឹតៈ បរិមាណ(បា.) បរិវេណ បុណ្យ(សំ.បា.) បុត្រាធីន(សំ.) បុប្ផគន្ធ(បា.សំ.) បុរាណ បញ្ញាណ បដិភាណ បបរិកេសិណ(បា.) បទដ្ឋាន(បា.) បធាន(បា.) ប្រចណ្ឌ(សំ.) ប្រមាណ ប្រាណ(សំ.បា.)។ |
| ផ | | +បាលី-សំស្ក្រឹតៈ ផគ្គុណ(បា.សំ.) ផ្កាបិណ្ឌ(បា.)។ |
| ព | | +បាលី-សំស្ក្រឹតៈ ពិណ(សំ.បា.) ពិរុណ(សំ.)។ |
| ភ | | +បាលី-សំស្ក្រឹតៈ ភណ្ឌ(បា.សំ.) ភាណ(បា.)។ |
| រ | | +បាលី-សំស្ក្រឹតៈ រណ្ឌៅ រុណ្ណ(បា.) ឫណ(សំ.បា.)។ |
| ល | | +សំស្ក្រឹតៈ លាវណ្យ(សំ.)។ |
| វ | | +បាលី-សំស្ក្រឹតៈ វណ្ណ(សំ.បា.) វណ្ដ(សំ.បា.) វិចារណញ្ញាណ(បា.) វិញ្ញាណ(បា.សំ.)។ |
| ស | | +បាលី-សំស្ក្រឹតៈ សកុណណ្ឌ(បា.សំ.) សគុណ(បា.) សាណ(បា.សំ.) សាន់វណ្ដ(សំ.) សុបណ្ណ(បា.សំ.) សោភ័ណ(បា.សំ.) សោវណ្ណ(បា.សំ.) ស្វ័យត្រាណ(សំ.)។ |
| ហ | | +សំស្ក្រឹតៈ ហិរណ្យ(សំ.)។ |
| អ | | +បាលី-សំស្ក្រឹតៈ អធិគុណ(សំ.បា.) អនង្គណ(បា.សំ.) អបរិមាណ(សំ.បា.) អបេតវិញ្ញាណ(បា.) អបោគណ្ឌ(សំ.) អប្បមាណ(បា.សំ.) អភិញ្ញាណ(បា.សំ.) អរុណ(សំ.បា.) អានាប្រាណ(បា.សំ.) អានីតគណ្ឌ(បា.) ឰរាវណ(សំ.)។ |
| ក | ន | +ខ្មែរៈ កង្វែន កងព័ន្ធ កបិន កន កន្ទ្រោន កន្ទក់អង្កាន់ កន្ទុយថ្លែន កន្ទុយលឹន កណ្ដៀន កម្សាន្ត កាន់ ការដ្ឋាន កិន កីលែន កីឡដ្ឋាន កុន កូន កួន កើន កៀន កែន កោន កំញាន កំប្រោន កំភួន ក្វាន ក្ដន់ ក្ដាន់ ក្ដារឆ្នួន ក្លៀន ក្សាន ក្សិន ក្សួន ក្សួន ក្រញោន ក្រតើន ក្រពេន ក្រមួន ក្រយាសម្កាន់ ក្រវ៉ាន់ ក្រវើន ក្រវើនក្រតើន ក្រឡាន ក្រអួន ក្រាន ក្រិន ក្លួន ក្លាហាន ក្លិន ក្វែន ក្សាន្ត។<br>+សៀមៈ ក្ដារខៀន(ស.) ក្រសៀន(ស.) ក្លងយ៉ូន។ |
| ខ | ន | +ខ្មែរៈ ខន ខន់ ខាន ខ្ទន់ ខ្លួន ខ្វាន ខ្វាន់ ខ្សាន ខ្វិន ។<br>+បាលី-សំស្ក្រឹតៈ ខ័ន ខន្ធ ខាន់។<br>+សៀមៈ ខុន(ស.) ខឿន ខៀន ខេន(ស.) ខ្នាន(ស.)។ |
| គ | | +ខ្មែរៈ គគ្រន់ គឃ្លើន គង្កាន គង្គួន គន គន់ គុន គូលែន គំហឹន គ្នាន់ គ្មាន គ្រាន់ គ្រុន គ្រឿន។<br>+លាវៈ គែន(ល.)។<br>+បាលី-សំស្ក្រឹតៈ គជទន្ត គជេន្ទ្រ គាថាពន្ធ គេហជន គិលាន។ |
| ឃ | | +ខ្មែរៈ ឃ្លាន។<br>+សៀមៈ ឃុន។ |

| | | |
|---|---|---|
| ច | | +ខ្មែរ៖ ចង្រ្កាន ចាន ចិញ្ចៀន ចិន ចឹន ចួន ចៀន ចំណាន ប្រណែន ប្រមួន ប្រាន ច្រើន។ |
| | | +បាលី-សំស្ក្រឹត៖ ច័ក្កច័ន ច័ន ចន្ទ ចន្ទន៍ ចន្រ្ទ ចរន្ត ចូឡពន ចេលកជន ចៃជន់។ |
| | | +សៀម៖ ចុន(ស.)។ |
| ឆ | | +ខ្មែរ៖ ឆាន់ ឆ្នួន ឆ្ពិន ឆ្អិន។ |
| | | +បាលី-សំស្ក្រឹត៖ ឆទ្ទន្ត ឆន្ទ។ |
| ជ | | +ខ្មែរ៖ ជញ្ជូន ជន ជន់ ជន្លេន ជាន់ ជិន ជីដូន ជីតុន ជូន ជួន ជើងក្រាន ជើងទើន ជើងមាន់ ជឿន។ |
| | | +បាលី-សំស្ក្រឹត៖ ជន(២ សំ.បា.) ជន្ម ជម្ពូពាន ជីវិន ជីវ័ន ជីវន្ត ជុតិមន្ត ជើងពាន ជេតពន ជេតវន ជេន ។ |
| ឈ | | +បាលី-សំស្ក្រឹត៖ ឈាន (២ បា.សំ.)។ |
| ញ | | +ខ្មែរ៖ ញន ញ៉ឹន ញៀន។ |
| ដ | | +ខ្មែរ៖ ដង្គន់ ដង្វិន ដាន ដាស់តឿន ដុកដាន់ ដុន ដូន ដួន ដែន ដោះគន់ ដំបន់ ដំឡាន់ ។ |
| ឋ | | +បាលី-សំស្ក្រឹត៖ ឋាន ។ |
| ឌ | | +សៀម៖ ឌិន (ស.) ឌុដាន់(ស.) ឌុន(ស.)។ |
| | | +សំស្ក្រឹត៖ ឍាលិន(សំ.) ។ |
| ណ | | +សៀម៖ ណៃណន(ស.) ណាំនួន(ស.) ។ |
| | | +ខ្មែរ៖ ណែន ណែនណាន់។ |
| ត | | +ខ្មែរ៖ តន់ តន្ទើន តាន តាន់ តាប់តាន់ តុករង្វាន់ តឿន តៀន តេន តោន តំបន់ តាំណាន ត្រកួន ត្រពឹន ត្រលិន ត្រអៀន ត្រឱន ត្រុនៗ ។ |
| | | +ជ្វា៖ តួន(ជ្វា)។ |
| | | +សៀម៖ តើន(ស.)។ |
| | | +ចិន៖ តៅស៊ន(ចិន) ។ |
| | ន | +បាលី-សំស្ក្រឹត៖ តបោធន(សំ.បា.) តាលវ័ន(សំ.បា.) តិរច្ឆាន(បា.សំ.) តេជវន្ត(បា.)។ |
| | | +បារាំង-អង់គ្លេស៖ តុងទីន(បារ.) តូន(បារ.) តែនតឺ(អ. បារ.)។ |
| | | +សៀម៖ ថងមួន(ស.) ថងយន់(ស.)។ |
| ថ | | +បាលី-សំស្ក្រឹត៖ ថលយាន(បា.សំ.) ថាមវន្ត(បា.សំ.) ថូន(បា.) ទក្ខិណាទាន ទក្ខិណានុប្បទាន ទន់ ទន្ត(សំ.បា.) ទារាធីន(សំ.បា.) ទាហាន ទិតៀន ទិន(សំ.បា.) ទិនិកជន(សំ.) ទិវ័ន(សំ.) ទុរជន ទុរន់(បា.) ទុរេន ទុជ៌ន(សំ.បា.) ទេយ្យទាន(បា.) ទេវិន្ទ(បា.សំ.) ទោចក្រយាន(បា.សំ.) ទ្វន្ទ(សំ.បា.) ទ្វិទន្ត(សំ.បា.) ទ្វេស្សជន(សំ.) ធន(សំ.បា.) ធន់ ធនធាន(បា.សំ.)។ |

| | | |
|---|---|---|
| | | +ខ្មែរៈ ថួន ថ្កាន ថ្វាន់ ថ្កិន ថ្កឹន ថ្លាន់ ថ្លែន ។ |
| | | +ខ្មែរៈ ទទួលទាន ទន្លើន ទៈបាន ទាក់ទិន ទាន ទាន់ ទាន់ហន់ ទូរន់ ទួន ទៀន ទែន ទំពួន ទ្រយន ទ្រយាន ទ្រាន់។ |
| ទ | | +សៀមៈ ទំពុន(ស.)។ |
| ធ | | +បាលី-សំស្ក្រឹតៈ ធនិន ធរណិន្ទ(បា.សំ.) ធរមាន(បា.សំ.) ធាន ធុន ធួន ធ្វន់ ធ្យាន នគ្គជន(បា.) នរិន្ទ(បា.សំ.) នរេន្ទ្រ(សំ.) នវោត្បន្ន(សំ.បា.) នាគទន្ត(សំ.បា.) នាគព័ន្ធ(បា.) នាសន(បា.) និទាន(សំ.បា.) និពន្ធ និព្វាន(សំ.បា.) និមន្ត(បា.) និស្សយជន។ |
| | | +ខ្មែរៈ នាងនួន នួន នេន។ |
| | | +សៀមៈ នាម៉ឺន។ |
| ន | | +ខ្មែរៈ បង្គន់ បង្គាន បាកាន បាន បាពួន បាយខុន បាយម៉ាន បិទពួន បូកប៉ាន់ បួន បឿន បៀតបៀន បែន បោសលាន បំប៉ន ប៉ន់ ប៉ប៉ះប៉ប៉ុន ប៉ាន ប៉ាន់ ប៉ិន ប៉ិនប៉ាន់ ប៉ឺន ប៉ុកប៉ឺន ប៉ុន្មាន ប៉ែន ប៉ៃលិន ប្រគេន ប្រដាន់ ប្រថាន ប្រវិនប្រវាន់ ប្រិតប្រៀន ប្រិនប្រុន ប្រៀន ប្រាំធាន ប្រាំបួន ប្លន់ ប្លែន ប្អូន។ |
| ប | | |
| | | +សៀមៈ បារៀន(ស.) បែមន់(ស.)។ |
| | | +បាលី-សំស្ក្រឹតៈ បាយ័ន(សំ.បា.) បុរិន្ទ(បា.) បកតិទិន(បា.សំ.) បក្ខព័ន្ធ(បា.សំ.) បច្ចុប្បន្ន(បា.) បញ្ចក្ខន្ធ(បា.សំ.) បញ្ចវន្ត(បា.) បដិទាន(បា.) បដិទិន(បា.សំ.) បរមិន្ទ(បា.សំ.) បរិជន(បា.) បរិយោសាន(បា.សំ.) |
| | | ផល្គុន(បា.) បុថុជ្ជន(បា.សំ.) បេក្ខជន(បា.) បេសកជន(បា.) ប្រក្រតិទិន(សំ.បា.) ប្រឈួន(សំ.) ប្រណិធាន(សំ.បា.) ប្រតិទិន(សំ.) ប្រតិពន្ធ(សំ.បា.) ប្រថុជ្ជន ប្រទាន(សំ.បា.) ប្រធាន(សំ.បា.) ប្រពន្ធ(សំ.បា.) ប្រព័ន្ធ(សំ.បា.) ប្រហារទាន(សំ.បា.) ប្រាចិន(សំ.បា.) ប្រេតវ័ន(សំ.បា.)។ |
| | | +ខ្មែរៈ ផែន ផ្គុន ផ្គើន ផ្ជួន ផ្អោះក្រាន ផ្លាន ផ្លូន។ |
| ផ | | +ខ្មែរៈ ពន ពាន ពិបិន ពុន ពូន ពួន ពេន ពែន ពោន ពោះវៀន ព្រមាន ព្រហើន ព្រាន ព្រូន ព្រៀងលាន ព្រេន ព្រោន។ |
| ព | ន | +បាលី-សំស្ក្រឹតៈ ពន់(ស.) ពន្ធ ពន្ធ(សំ.បា.) ព័ន្ធ(សំ.បា.) ពលិទាន(សំ.បា.) ពាធជន្ម(សំ.) ពាន់ ពានរិន្ទ(បា.សំ.) ពានរេន្ទ្រ(សំ.) ពិតាន(សំ.) ពិមាន(សំ.បា.) ពុធជន(សំ.បា.) ពេទ្យស្ថាន(សំ.) ពេស្យាស្ថាន(សំ.) ព្រហាវន(បា.សំ.) ភគវន្ត(បា.) ភត្តាវសាន(បា.) ភទន្ត(បា.) ភ័ន្ត(បា.) |
| | | ភមរិន្ទ(បា.សំ.) ភាន ភាន់(បា.) ភាពយន្ត(បា.) ភិន(សំ.បា.) ព្រឹន្ទ(សំ.) ភុជិស្សជន(បា.សំ.) ភូធន(សំ.បា.) ភូមរិន្ទ(បា.) ភូមិន្ទ(បា.សំ.) ភោជន(សំ.បា.)។ |
| | | +បារាំងៈ ពព្រឺឡែន(បារ.)។ |
| | | +សៀមៈ ពិន(ស.) ពុំសែន(ស.)។ |

| | | |
|---|---|---|
| ភ | | ភីន(ស.) ភ្លើតភ្លើន(ស.) ភ្លន(ស.) ភ្លើន(ស.)។<br>+លាវ-សៀម៖ ភឿន(ល. ស.)<br>+ខ្មែរ៖ កុំភឿន ភ្ញីទៀន ភ្នាន ភ្នើន។ |
| ម | | +សំស្ក្រឹត៖ មករន្ទ(សំ.បា.) មការន្ត(បា.) មក្ខជន(បា.) មច្ចពន្ធ(បា.សំ.) មនុជិន្ទ(បា.សំ.) មន្ត(បា.សំ.) មន្ទលេនមហទ្ធន(សំ.បា.) មហន្ត(បា.សំ.) មានទណ្ឌ(សំ.បា.)មាសិកជន(សំ.បា.) ម៉ាស៊ីន(បារ.) មិគទាយពន(បា.សំ.) មិគព័ន្ធន៍(បា.សំ.) មិថុន(សំ.បា.) មីន(សំ.បា.) មុឺន(ស.) មុន មូសិកទន្ត(បា.សំ.) មេថុន(បា.សំ.) មោគ្គលាន(បា.សំ.) មោហន្ត(សំ.បា.)។<br>+ខ្មែរ៖ មន មាក់ប៉ែន មាក់សាន់ មាន មាន់ មាសស្ងួន មិន មឹន មួន មៀន មេន មែន មែនមាន ម្ហាន ម្លាន់ ។ |
| យ | | +បាលី-សំស្ក្រឹត៖ យថាឋាន(បា.សំ.) យន្ត(បា.សំ.) យ័ន្ត(បា.សំ.) យាន(សំ.បា) យោគិន(សំ.បា.) យោធិន(សំ.) យោន(បា.) យៅវ័ន។<br>+ខ្មែរ៖ យីហ៊ុន យួន។<br>+សៀម៖ យន់(ស.) យ៉ាប់យ៉ឺន(ស.) យីស៊ុន(ស.) យឺន(ស.) យោនយាន(ស.)។ |
| រ | | +ខ្មែរ៖ រខិន រងាន់ រង្វាន់ រដឺន រដៀន រត់យួន រន រន្ទាន់ រយាន រយោន រវាន រវាន់ រអឹករអឺន រហូន រាន រាន់ រានកាន រាប់អាន រុកកួន រុករាន រុន រូហាន រួសរាន់ រៀន។<br>+បាលី-សំស្ក្រឹត៖ រន្ធ(បា.សំ.) រវិន រវិន្ទ(សំ.) រហទដ្ឋាន(បា.សំ.) រហស្ថាន(សំ.បា.) រហោឋាន រឱសឋាន រាមចន្ទ្រ រោទន(សំ.បា.) រោធន(សំ.បា.) រោបន(បា.សំ.)។<br>+សៀម៖ រាយង៉ាន(ស.) រួន(ស រំខាន(ស.)។ |
| ល | ន | +សៀម៖ ល័ក្កចាន់(ស.) លូកយុន(ស.) ល្ហោន(ស.)។<br>+បាលី-សំស្ក្រឹត៖ លក្ខខណ្ឌ(បា.) លាសន(សំ.បា.)។<br>+ខ្មែរ៖ លង់ហិន ឬ លង្ហិន លន លន់ លាន លាន់ លីកលាន លឹន លីលាន់ លុន លូកលាន់ លូន លឿន លៀន លែនពែន លែនលន លំទោន លំបិន លំពាន់ លំពើន លំអិតលំអូន ល្ងេន ល្ងាន់ ល្ងន់ ល្ងាសល្ងន់ ល្អន់ ល្អាន ល្អិន ឮលាន់។ |
| វ | | +ខ្មែរ៖ វង្វាន់ វៀន វៀះវៀន វេះវៀន វែន វាំងនន។<br>+បាលី-សំស្ក្រឹត៖ វត្តមាន(បា.សំ.) វត្ថពន្ធ(បា.សំ.) វទ័ន(សំ.បា.) វធ្យស្ថាន(បា.សំ.) វន្ត(បា.) វន្ទន្ត(សំ.បា.) វរ្ម៉ែន(សំ.) វសនដ្ឋាន(បា.សំ.) វាគ្មិន(សំ.) វាន់(សំ.) វានរិន្ទ(បា.សំ.) វានរេន្ទ្រ(សំ.) វាសនដ្ឋាន(បា.សំ.) វិកប្បសន្ធាន(បា.) វិក្រាន្ត(សំ.បា.) វិចេយ្យទាន(បា.) វិចេស្តន(សំ.) វិជនដ្ឋាន(បា.សំ.) វិជយិន(សំ.បា.) វិជលដ្ឋាន(បា.សំ.) វិជ្ជមាន(បា.) វិធាន(សំ.បា.) វិន្ទ(សំ.បា.) វិប្របច្ចន្ន(សំ.) វិព្ភន្ត(បា.) វិភាគទាន(បា.) វិមាន(បា.សំ.) វីតាមីន(បារ.) |

| | | |
|---|---|---|
| ស | ន | រូបសន្ត(បា.) វេជយ័ន្ត(បា.សំ.) វេទាន្ត(សំ.បា.) វេន(បា.) វេស្ម័ន(សំ.បា.) វេឡុវ៉ែន(បា.សំ.)។<br>+សៀម-លាវ៖ វុន(ស.) វ៉ែក្វែន(ស.ល.)។<br>+បាលី-សំស្ក្រឹត៖ សក់ក័ន្ត សក្ការសម្មាន(បា.) សច្ចាធិដ្ឋាន(បា.សំ.) សច្ចាប្រណិធាន(បា.សំ.) សច្ចន្ទ(បា.សំ.) សជន(បា.សំ.) សញ្ជីវ៉ែន(សំ.បា.) សញ្ញោជន(បា.) សណ្ឋាន(បា.សំ.) សទាទាន(សំ.បា.)សន្តាន(សំ.បា.) សន្ធាន(សំ.បា.) សន្និដ្ឋាន(បា.សំ.) សន្និពន្ធន៍(បា.សំ.) សបត្តជន(បា.សំ.) សភាជន(សំ.បា.) សមាទាន(សំ.បា.) សមាធាន(សំ.បា.) សមិទ្ធន៍(សំ.បា.) សមុដ្ឋាន(បា.សំ.) សមោធាន(បា.សំ.) សម្បទាន(បា.សំ.) សម្បធាន(បា.សំ.) សម្ពន្ធ(សំ.បា.) សម្ពិន្ទ(សំ.បា.) សម្មជ្ជន(បា.សំ.) សម្មាន(សំ.បា.) សរីន្ទ្រ(សំ.បា.) សសិន(សំ.បា.) សាទិន(សំ.) សាទុភោជន(បា.សំ.) សាន្ត(សំ.បា.) សាបាន(បា.សំ.) សាមន្ត(សំ.បា.) សាមាន្យ(សំ.បា.) សាមីសម្ពន្ធ(បា.សំ.) សារព័ន(សំ.) សាសន(បា.សំ.) សិខណ្ឌិន(សំ.បា.) សិទ្ធ(បា.) សិទ្ធពអមរិន្ទ(បា.) សិខរិន(សំ.បា.) សិខិន (សំ.បា.) សុក័ន្ត សុគន្ធ(សំ.បា.) សុជន(សំ.បា.) សុទន្ត(បា.សំ.) សុទិន(សំ .បា.) សុទិន្ន(បា.) សុន្ទរ៍ទាន(សំ.បា.) សុបិន(បា.សំ.) សុភោជន(សំ.បា.) សុរសភោជន(សំ.បា.) សុរិន្ទ សុរិយ័ន(បា.សំ.) សុរេន្ទ្រ សុវណ្ណ(បា.សំ.) សុសាន(បា.សំ.) សុស្ន័ន(សំ.) សុស្និន(សំ.) សូន សូន្យ(សំ.បា.) សូរ្យកាន្ត(សំ.បា.) សេន្យ(សំ.ក្ល ឬ សំ.បា.) សោកាន្ត សោធន(បា.សំ.) សោបាន(សំ.បា.) សោមាន(សំ.) សៅគន្ធ(សំ.បា.) សៅរគន្ធ(សំ.បា.) សោក័ន្ត ស្កន្ធ(សំ.) ស្កន្ទ(សំ.) ស្តិន(សំ.បា.) ស្ថាន(សំ.បា.) ស្នាន(សំ.បា.) ស្នន្ធ ស្មសាន(សំ.បា.) ស្មាទាន(បា.សំ.) ស្រាន្ត(សំ.បា.) ស្វច្ឆន្ទ(សំ.បា.) ស្វជន(សំ.បា.) ស្វាធីន(សំ.បា.) ស្វាធ្យាយិន(សំ.បា.) ស្វាន(សំ.បា.)<br>+សៀម៖ សង្វៀន(ស.) សណ្ដាន់(ស.) ស៊ន(ស.) សប្បធន់(ស.) សួន (ស.) សៃយ៉ឺន(ស.) ស៊ាំស៊ន(ស.) ស្បៀន(ស.) ស្រលន(ស.)<br>+ខ្មែរ៖ សណ្ដូន សន្លិន សរសន់ សាន សាន់វ៉ាន់ សាយឺន សិន សិរមាន់ ស៊ីស្វផុន សុជន់ ស៊ុន សុនគ្រុន សើន សៀន សៀនមៀន សេរមាន់ សែន សំខាន់សំប៉ាន សំពិន ស្កុន ស្គន់ ស្ងួន ស្ទើន ស្ទៀន ស្ទន់ ស្នួន ស្បាន់ ស្បូន ស្តាន ស្តាន់ ស្តើន ស្ទន់ ស្នាន ស្នាន់ ស្នូវជន ស្រន់ ស្រពន់ ស្រពោន ស្រមៀន ស្រលូន ស្រវាក់ស្រវាន់ ស្រវើន ស្រឡូន ស្រែន្យ ស្លន់ ស្លាកំញាន ស្លាតាឱន ស្វៃរិន ស្អាន។<br>+បារាំង៖ សេន(បារ.)។<br>+បាលី-សំស្ក្រឹត៖ ហ័ន(សំ.បា.) ហនុមាន(សំ.) ហយិន(សំ.បា.) ហស្តិន(បា.សំ.) ហារិន(សំ.បា.) ហិន(សំ.បា.) ហិនហុន(ស.) ហិមពន្ត(បា.) ហីន(សំ.បា.) ហីនយាន(សំ.បា.) ហ៊ូពាន់(សំ.) ហេមន្ត(សំ.បា.) |

| | | |
|---|---|---|
| ហ<br><br>ឡ<br><br>អ | ន | ហេមពន្ត(បា.សំ.) ហេមវ័ន្ត(បា.សំ.) ហេម្ពូពន្ត(បា.សំ.)<br>+ខ្មែរ៖ ហាន ហាន់ ហ៊ាន ហូងហែន ហៀន ហ្វឹកហ្វឺន។<br>+ចិន៖ ហ៊ុន(ចិន)<br>+សៀម៖ ហៃសាន ហៅហាន(ស.) ហ្មឺន ហ្វូងជិន(ស.)។<br>+ខ្មែរ៖ ឡាន ឡាន់ ឡែកឡាន់។<br>+សៀម៖ ឡិន(ស.)។<br>+បាលី-សំស្ក្រឹត៖ អក្សរទេវិន(បា.សំ.) អង្កន់(សំ.បា.) អចៃជន្យ(សំ.) អជ្ឈត្តសន្តាន(បា.សំ.) អជ្ឈត្តិកទាន(បា.) អជ្ឈោសាន(បា.) អញ្ជ័ន(សំ.បា.) អញ្ញាតកជន ឬ អញ្ញាតកជន(បា.) អដ្ឋបាន(បា.) អឌ្ឍចន្ទ(បា.សំ.) អត្រានុកូលដ្ឋាន(បា.សំ.) អថ័ន(បា.សំ.) អទារជន(សំ.បា.) អទិស្សមាន(បា.) អទ្ធាន(បា.សំ.) អធរមាន(បា.) អធិដ្ឋាន ឬ អធិស្ឋាន(បា.សំ.) អធីន(សំ.បា.) អធ្វ័ន(សំ.បា.) អន(ស.) អន់ អនន្ត(សំ.បា.) អនវ៉ន(ស.) អនាត្ម័ន(សំ.) អនិមន្តន៍(បា.សំ.) អនុបវាទិន(បា.សំ.) អនុបសម្បន្ន(សំ.បា.) អនុបាទិសេសនិព្វាន(បា.) អន្តរធាន(សំ.បា.) អន្តេវាសិន(សំ.បា.) អបរគោយាន (សំ.បា.) អបរិយោសាន(បា.សំ.) អប្បសាន្ត(បា.សំ.) អប្បាន្ត(បា.សំ.) អព្ភក្ខាន (បា.សំ.) អព្ភាន(បា.) អភិធាន(សំ.បា.) អភិវន្ទ ឬ អភិវន្ទន៍(សំ.បា.) អមរគោយាន(បា.សំ.) អមរិន្ទ(បា.សំ.) អយស្កាន្ត(សំ.បា.) អយោគិន(បា.សំ.) អយោធិន(បា.សំ.) អរជុន(សំ.បា.) អរជូន(បា.សំ.) អរពិន្ទ(សំ.បា.) អរហន្ត(បា .សំ.) អជំន(បា.សំ.) អវជ្ឈាន(បា.) អវទាន(សំ.បា.) អវធាន(សំ.បា.) អវមាន (សំ.បា.) អវសាន(សំ.បា.) អវិជ្ជមាន(បា.) អសទិសទាន(បា.សំ.) អសុរិន្ទ(បា. សំ.) អស្វិន(សំ.) អស្វែរិន(បា.សំ.) អហង្ការិន(សំ.បា.) អាខ្យាន(សំ.បា.) អាគតដ្ឋាន(សំ.បា.) អាណិកជន(បា.) អាត្ម័ន(សំ.បា.) អាត្មាធីន(សំ.បា.) អាត្មោបជីវិន(សំ.បា.) អាទាហនស្ថាន(បា.សំ.) អាទ្យូន(សំ.) អាបុច្ឆន(បា.) អាមេណ្ឌន(បា.សំ.) អាយ៉េន(បា.សំ.) អាលិង្គន(សំ.បា.) អាសយដ្ឋាន(បា.) អាស្ថាន(សំ.) អាឡាហណដ្ឋាន(បា.សំ) ឥន្ទ(បា.សំ.) ឥន្ទវជិរច្ឆន្ទ(បា.សំ.) ឦសាន(បា.សំ.) ឧជ្ឈាន(បា.សំ.) ឧដ្ឋាន(បា.សំ.) ឧត្តាន(សំ.បា.) ឧទាន(សំ. បា.) ឧទេន(សំ.បា.) ឧទ្ធាន(សំ.បា.) ឧទ្និន(សំ.) ឧទ្យាន(សំ.បា.) ឧបជាតិច្ឆន្ទ (សំ.បា.) ឧបជីវិន(សំ.បា.) ឧបដ្ឋាន(បា.សំ.) ឧបនិមន្តន៍(បា.សំ.) ឧបមាន(សំ. បា.) ឧបាទាន(សំ.បា.) ឧបាហន(បា.សំ.) ឧបេន្ទវជិរច្ឆន្ទ(បា.សំ.) ឧយ្យាន(បា. សំ.) ឱទ្យាន(បា.សំ.) ឱន(បា.) អំព័ន្ធ(បា.សំ.)<br>+ខ្មែរ៖ អង្កាន់ អង្រន់ អង្រួន អផ្សាន អាន អាកៀន ឥណ្ឌូចិន អីវ៉ាន់ ឪទឹន អូន អួន អៀន អែនអន អំពាន់ អ្នកដូន។<br>+សៀម-លាវ៖ អាប់ចុន(ស.ល.)។<br>+បារាំង៖ ឥណ្ឌូស៊ីន(បារ.)។ |

## ២- សំណេរ ណ និង ន ជាធាតុមួយនៃផ្នត់កម្លាយ

### ២.១- ផ្នត់ដើម

| ផ្នត់ដើម | ពាក្យឫស | ពាក្យក្លាយ | ទម្រង់ផ្នត់ |
|---|---|---|---|
| [ក˴ណ-] | ដក់ | កណ្ដក់ | /ពសព-/ |
| | ដក | កណ្ដក | /ពសព-/ |
| | ដាច | កណ្ដាច | /ពសព-/ |
| | ដាច់ | កណ្ដាច់ | /ពសព-/ |
| [ក˴ន-] | តុញ | កន្តុញ | /ពសព-/ |
| | តុល | កន្តុល | /ពសព-/ |
| | ត្រ | កន្ត្រ | /ពសព-/ |
| | ត្រង | កន្ត្រង | /ពសព-/ |
| | ត្រាក | កន្ត្រាក | /ពសព-/ |
| | ទែក | កន្ទែក | /ពសព-/ |
| | ទ្រម | កន្ទ្រម | /ពសព-/ |
| | ទ្រុប | កន្ទ្រុប | /ពសព-/ |
| | ទ្រួក | កន្ទ្រួក | /ពសព-/ |
| | ទ្រួប | កន្ទ្រួប | /ពសព-/ |
| | ទ្រើង | កន្ទ្រើង | /ពសព-/ |
| | ធាត់ | កន្ធាត់ | /ពសព-/ |
| | លង | គន្លង | /ពសព-/ |
| /គ˴ន-/ | លាក់ | គន្លាក់ | /ពសព-/ |
| /ជ˴ន-/ | ដើរ | ជណ្ដើរ | /ពសព-/ |
| | ល | ជន្ល | /ពសព-/ |
| /ជ˴ណ-/ | ដឹង | ជណ្ដឹង | /ពសព-/ |
| | ដាំ | ជណ្ដាំ | /ពសព-/ |
| /ទ˴ន-/ | ទ្រាន | ទន្ទ្រាន | /ពសព-/ |
| /ប˴ណ-/ | ដាក់ | បណ្ដាក់ | /ពសព-/ |
| | ដាច់ | បណ្ដាច់ | /ពសព-/ |
| | ដាល | បណ្ដាល | /ពសព-/ |
| /ប˴ណ-/ | ដុន | បណ្ដុន | /ពសព-/ |
| | ដុះ | បណ្ដុះ | /ពសព-/ |
| | ដើរ | បណ្ដើរ | /ពសព-/ |

| | | | |
|---|---|---|---|
| /ប´ណ-/ | ដេញ | បណ្ដេញ | /ពសព-/ |
| | ដោយ | បណ្ដោយ | /ពសព-/ |
| | ដោះ | បណ្ដោះ | /ពសព-/ |
| | ដៅ | បណ្ដៅ | /ពសព-/ |
| | ដុំ | បណ្ដុំ | /ពសព-/ |
| /ប´ន-/ | ត | បន្ត | /ពសព-/ |
| | តម | បន្តម | /-ពសព-/ |
| | តិច | បន្តិច | /-ពសព-/ |
| | តឹង | បន្តឹង | /-ពសព-/ |
| | តុប | បន្តុប | /-ពសព-/ |
| | តុះ | បន្តុះ | /-ពសព-/ |
| | តូច | បន្តូច | /-ពសព-/ |
| | តួច | បន្តួច | /-ពសព-/ |
| | តោង | បន្តោង | /-ពសព-/ |
| | ថយ | បន្ថយ | /-ពសព-/ |
| | ថុច | បន្ថុច | /-ពសព-/ |
| | ថើរ | បន្ថើរ | /-ពសព-/ |
| | ថែ | បន្ថែ | /-ពសព-/ |
| | ថែម | បន្ថែម | /-ពសព-/ |
| | ថោក | បន្ថោក | /-ពសព-/ |
| | ទច់ | បន្ទច់ | /-ពសព-/ |
| | ទន់ | បន្ទន់ | /-ពសព-/ |
| | ទាន់ | បន្ទាន់ | /-ពសព-/ |
| | ទាប | បន្ទាប | /-ពសព-/ |
| | ទាល | បន្ទាល | /-ពសព-/ |
| /ប´ន-/ | ទាល់ | បន្ទាល់ | /-ពសព-/ |
| | ទាស | បន្ទាស | /-ពសព-/ |
| | ទុល | បន្ទុល | /-ពសព-/ |
| | ទូល | បន្ទូល | /-ពសព-/ |
| | ទើរ | បន្ទើរ | /-ពសព-/ |
| | ទេរ | បន្ទេរ | /-ពសព-/ |
| | ទោស | បន្ទោស | /-ពសព-/ |
| | ទុំ | បន្ទុំ | /-ពសព-/ |

| | | | |
|---|---|---|---|
| /ប′ន-/ | ទំ | បន្ទំ | /-ពសព-/ |
| | ទ្រាន់ | បន្ទ្រាន់ | /-ពសព-/ |
| | ទ្រេត | បន្ទ្រេត | /-ពសព-/ |
| | ទ្រោម | បន្ទ្រោម | /-ពសព-/ |
| | ធាត់ | បន្ទាត់ | /-ពសព-/ |
| | ធូរ | បន្ធូរ | /-ពសព-/ |
| | ធំ | បន្ធំ | /-ពសព-/ |
| | ឡប់ | បន្លប់ | /-ពសព-/ |
| | លេច | បន្លិច | /-ពសព-/ |
| | លឹម | បន្លឹម | /-ពសព-/ |
| | លឺ | បន្លឺ | /-ពសព-/ |
| | លៀន | បន្លៀន, ពន្លៀន | /-ពសព-/ |
| | លេង | បន្លែង | /-ពសព-/ |
| | សល់ | បន្សល់ | /-ពសព-/ |
| | សាប | បន្សាប | /-ពសព-/ |
| | សាល់ | បន្សាល់ | /-ពសព-/ |
| | ស៊ី | បន្សី | /-ពសព-/ |
| | សុទ្ធ | បន្សុទ្ធ | /-ពសព-/ |
| | សើច | បន្សើច | /-ពសព-/ |
| | សើម | បន្សើម | /-ពសព-/ |
| /ប′ន-/ | សោះ | បន្សោះ | /-ពសព-/ |
| | សាំ | បន្សាំ | /-ពសព-/ |
| | សះ | បន្សះ | /-ពសព-/ |
| **/ព′ន-/** | **យល់** | **ពន្យល់** | **/-ពសព-/** |
| | យារ | ពន្យារ | /-ពសព-/ |
| | យឺ | ពន្យឺ | /-ពសព-/ |
| | យឺត | ពន្យឺត | /-ពសព-/ |
| | យឺន | ពន្យឺន | /-ពសព-/ |
| | យុយ | ពន្យុយ, ពន្យួយ | /-ពសព-/ |
| | យុល | ពន្យុល | /-ពសព-/ |
| | យុះ | ពន្យុះ | /-ពសព-/ |
| | យើ | ពន្យើ | /-ពសព-/ |
| | យោល | ពន្យោល | /-ពសព-/ |

| | | | |
|---|---|---|---|
| /ព´ន-/ | យះ | ពន្យះ | /-ពសព-/ |
| | លង់ | ពន្លង់ | /-ពសព-/ |
| | លាញ | ពន្លាញ | /-ពសព-/ |
| | លាត់ | ពន្លាត់ | /-ពសព-/ |
| | លិច | ពន្លិច | /-ពសព-/ |
| | លឹប | ពន្លឹប | /-ពសព-/ |
| | លុត | ពន្លុត | /-ពសព-/ |
| | លុន | ពន្លុន | /-ពសព-/ |
| | លូត | ពន្លូត | /-ពសព-/ |
| | លូន | ពន្លូន | /-ពសព-/ |
| | លើស | ពន្លើស | /-ពសព-/ |
| | លៀន | ពន្លៀន, បន្លៀន | /-ពសព-/ |
| | លែង | ពន្លែង | /-ពសព-/ |
| | លោត | ពន្លោត | /-ពសព-/ |
| | លះ | ពន្លះ | /-ពសព-/ |
| /រ´ណ-/ | ដំ | រណ្ដំ | /ពសព-/ |
| /ល´ន-/ | លឹម | លន្លឹម | /ពសព-/ |
| /ស´ណ-/ | ដក | សណ្ដក | /ពសព-/ |
| /ស´ន-/ | លាង | សន្លាង | /ពសព-/ |
| | សើម | សន្សើម | /ពសព-/ |
| /អ´ណ-/ | ដោត | អណ្ដោត | /ពសព-/ |
| /អ´ន-/ | ត្រតៗ | អន្ត្រត | /ពសព-/ |
| | ត្រាក់ៗ | អន្ត្រាក់ | /ពសព-/ |
| | ត្រឹកៗ | អន្ត្រឹក | /ពសព-/ |
| | ត្រុកៗ | អន្ត្រុក | /ពសព-/ |
| | ត្រើកៗ | អន្ត្រើក | /ពសព-/ |
| | ត្រោក | អន្ត្រោក | /ពសព-/ |
| | ទាក់ | អន្ទាក់ | /ពសព-/ |
| | ទ្រក់ៗ | អន្ទ្រក់ | /ពសព-/ |
| | ទ្រតៗ | អន្ទ្រត | /ពសព-/ |
| | ទ្រាកៗ | អន្ទ្រាក | /ពសព-/ |
| | ទ្រឹតៗ | អន្ទ្រឹត | /ពសព-/ |
| | ទ្រុកៗ | អន្ទ្រុក | /ពសព-/ |

| | | | |
|---|---|---|---|
| /អ់ន-/ | ទ្រើតៗ | អន្ទ្រើតៗ | /ពសព-/ |
| | ទ្រើមៗ | អន្ទ្រើម | /ពសព-/ |

## ២.២- ផ្នត់ដែក

| ពាក្យឫស | ផ្នត់ដែក | ពាក្យក្លាយ | ទម្រង់ផ្នត់ |
|---|---|---|---|
| ក្ដាប់ | /-អ់ណ-/ | កណ្ដាប់ | /-សព-/ |
| ក្ដារ | | កណ្ដារ | /-សព-/ |
| ប្ដឹង | | បណ្ដឹង | /-សព-/ |
| ផ្ដុំ | | បណ្ដុំ | /-សព-/ |
| ផ្ដាំ | | បណ្ដាំ | /-សព-/ |
| ស្ដាប់ | | សណ្ដាប់ | /ពសព-/ |
| ស្ដូក | | សណ្ដូក | /ពសព-/ |
| ស្ថិត | | សណ្ឋិត | /ពសព-/ |
| ផ្ដក់ | /-អ់ន-/ | បន្ដក់ | /-សព-/ |
| ផ្ទាប់ | | បន្ទាប់ | /-សព-/ |
| ផ្សំ | | បន្សំ | /-សព-/ |
| ផ្ទុក | | បន្ទុក | /-សព-/ |
| ផ្លាស់ | | បន្លាស់ | /-សព-/ |
| ក្លាស់ | | កន្លាស់ | /-សព-/ |
| ខ្ទះ | | កន្ទះ | /-សព-/ |
| ខ្លោង | | កន្លោង | /-សព-/ |
| ខ្លះ | | កន្លះ | /-សព-/ |
| ផ្លៀក | | បន្លៀក, ពន្លៀក | /-សព-/ |
| ផ្សារ | | បន្សារ | /-សព-/ |
| ផ្សើម | | បន្សើម | /-សព-/ |
| ផ្សោះ | | បន្សោះ | /-សព-/ |
| ផ្សាំ | | បន្សាំ | /-សព-/ |
| ផ្សះ | | បន្សះ | /-សព-/ |
| ស្ទុះ | | សន្ទុះ | /-សព-/ |
| ស្ទូង | | សន្ទូង | /-សព-/ |
| ស្ទូច | | សន្ទូច | /-សព-/ |
| ស្ទះ | | សន្ទះ | /-សព-/ |
| ស្លង់ | | សន្លង់ | /-សព-/ |

| | | | |
|---|---|---|---|
| ស្លឹក | | សន្លឹក | /-សព-/ |
| **ឃ្លោង** | /-អ៊ិ´ន-/ | **គន្លោង** | **/-សព-/** |
| ធ្លាក់ | | ទន្លាក់ | /-សព-/ |
| **ភ្លឹក** | | **ពន្លឹក** | **/-សព-/** |
| ភ្លឹប | | ពន្លឹប | /-សព-/ |
| ភ្លឺ | | ពន្លឺ | /-សព-/ |
| ភ្លូក | | ពន្លូក | /-សព-/ |
| រាប | | រនាប | /-សព-/ |
| រាស់ | /-អ៊ិ´/ន-/ | រនាស់ | /-សព-/ |
| រុក | | រនុក | /-សព-/ |
| **កក** | /-អ´ម/ណ-/ | **កំណក** | **/-សពព-/** |
| កត់ | | កំណត់ | /-សពព-/ |
| កប់ | | កំណប់ | /-សព/ព-/ |
| កល់ | | កំណល់ | /-សព/ព-/ |
| ការ | | កំណារ | /-សព/ព-/ |
| កាច | | កំណាច | /-សព/ព-/ |
| កាញ់ | | កំណាញ់ | /-សព/ព-/ |
| កាត់ | | កំណាត់ | /-សព/ព-/ |
| កាព្យ | | កំណាព្យ | /-សព/ព-/ |
| កិន | | កំណិន | /-សព/ព-/ |
| កួច | | កំណួច | /-សព/ព-/ |
| កើត | | កំណើត | /-សព/ព-/ |
| កើន | | កំណើន | /-សព/ព-/ |
| កើល | | កំណើល | /-សព/ព-/ |
| កៀង | | កំណៀង | /-សព/ព-/ |
| កៀច | | កំណៀច | /-សព/ព-/ |
| កៀរ | | កំណៀរ | /-សព/ព-/ |
| កៀវ | | កំណៀវ | /-សព/ព-/ |
| កៀស | | កំណៀស | /-សព/ព-/ |
| កេះ | | កំណេះ | /-សព/ព-/ |
| កែ | | កំណែ | /-សព/ព-/ |
| កោង | | កំណោង | /-សព/ព-/ |
| កោត | | កំណោត | /-សព/ព-/ |

| | | | |
|---|---|---|---|
| កោន | /-អ៑ម/ណ-/ | កំណោន | /-សព/ព-/ |
| កោរ | | កំណោរ | /-សព/ព-/ |
| កោស | | កំណោស | /-សព/ព-/ |
| កោះ | | កំណោះ | /-សព/ព-/ |
| **ដក** | | **ដំណក** | **/-សព/ព-/** |
| ដក់ | | ដំណក់ | /-សព/ព-/ |
| ដង | | ដំណង | /-សព/ព-/ |
| ដល់ | | ដំណល់ | /-សព/ព-/ |
| ដាក់ | | ដំណាក់ | /-សព/ព-/ |
| ដាច់ | | ដំណាច់ | /-សព/ព-/ |
| ដាប់ | | ដំណាប់ | /-សព/ព-/ |
| ដាល | | ដំណាល | /-សព/ព-/ |
| ដាល់ | | ដំណាល់ | /-សព/ព-/ |
| ដាស់ | | ដំណាស់ | /-សព/ព-/ |
| ដិត | | ដំណិត | /-សព/ព-/ |
| ដឹង | | ដំណឹង | /-សព/ព-/ |
| ដុត | | ដំណុត | /-សព/ព-/ |
| ដុស | | ដំណុស | /-សព/ព-/ |
| ដូច | | ដំណូច | /-សព/ព-/ |
| ដូរ | | ដំណូរ | /-សព/ព-/ |
| ដួច | | ដំណួច | /-សព/ព-/ |
| ដួល | | ដំណួល | /-សព/ព-/ |
| ដួស | | ដំណួស | /-សព/ព-/ |
| ដើរ | | ដំណើរ | /-សព/ព-/ |
| ដៀង | | ដំណៀង | /-សព/ព-/ |
| ដៀល | | ដំណៀល | /-សព/ព-/ |
| ដេក | | ដំណេក | /-សព/ព-/ |
| ដេញ | | ដំណេញ | /-សព/ព-/ |
| ដេរ | | ដំណេរ | /-សព/ព-/ |
| តែង | | ដំណែង | /-សព/ព-/ |
| ដែល | | ដំណែល | /-សព/ព-/ |
| ដោត | | ដំណោត | /-សព/ព-/ |
| ដោយ | | ដំណោយ | /-សព/ព-/ |

| | | | |
|---|---|---|---|
| ដោល | | ដំណោល | /-សព/ព-/ |
| ដៅ | **/-អ´ម/ណ-/** | ដំណៅ | /-សព/ព-/ |
| ដោះ | | ដំណោះ | /-សព/ព-/ |
| ដំ | | ដំណំ | /-សព/ព-/ |
| ដាំ | | ដំណាំ | /-សព/ព-/ |
| **ត** | | **តំណ** | **/-សព/ព-/** |
| តក់ | | តំណក់ | /-សព/ព-/ |
| តាង | | តំណាង | /-សព/ព-/ |
| តិះ | | តំណិះ | /-សព/ព-/ |
| តិច | | តំណិច | /-សព/ព-/ |
| តឹង | | តំណឹង | /-សព/ព-/ |
| តុះ | | តំណុះ | /-សព/ព-/ |
| តូច | | តំណូច | /-សព/ព-/ |
| តែង | | តំណែង | /-សព/ព-/ |
| តោង | | តំណោង | /-សព/ព-/ |
| តាំង | | តំណាំង | /-សព/ព-/ |
| **ច** | | **ចំណ** | **/-សព/ព-/** |
| ចរ | | ចំណរ | /-សព/ព-/ |
| ចង | | ចំណង | /-សព/ព-/ |
| ចង់ | | ចំណង់ | /-សព/ព-/ |
| ចត | | ចំណត | /-សព/ព-/ |
| ចត់ | | ចំណត់ | /-សព/ព-/ |
| ចាក់ | | ចំណាក់ | /-សព/ព-/ |
| ចាញ់ | | ចំណាញ់ | /-សព/ព-/ |
| ចាប់ | | ចំណាប់ | /-សព/ព-/ |
| ចាយ | | ចំណាយ | /-សព/ព-/ |
| ចារ | | ចំណារ | /-សព/ព-/ |
| ចារ | | ចំណារ | /-សព/ព-/ |
| ចាល | | ចំណាល | /-សព/ព-/ |
| ចាល់ | | ចំណាល់ | /-សព/ព-/ |
| ចាស់ | | ចំណាស់ | /-សព/ព-/ |
| ចិត | | ចំណិត | /-សព/ព-/ |
| ចី | | ចំណី | /-សព/ព-/ |

| | | | |
|---|---|---|---|
| ចឹក | | ចំណឹក | /-សព/ព-/ |
| ចឹប | **/-អ៉ម/ណ-/** | ចំណឹប | /-សព/ព-/ |
| ចុក | | ចំណុក | /-សព/ព-/ |
| ចុច | | ចំណុច | /-សព/ព-/ |
| ចុះ | | ចំណុះ | /-សព/ព-/ |
| ចូក | | ចំណូក | /-សព/ព-/ |
| ចូរ | | ចំណូរ | /-សព/ព-/ |
| ចូល | | ចំណូល | /-សព/ព-/ |
| ចៀស | | ចំណៀស | /-សព/ព-/ |
| ចេញ | | ចំណេញ | /-សព/ព-/ |
| ចិរ,ចីរ | | ចំណេរ | /-សព/ព-/ |
| ចេះ | | ចំណេះ | /-សព/ព-/ |
| ចែក | | ចំណែក | /-សព/ព-/ |
| ឆែង | | ចំណែង | /-សព/ព-/ |
| ចែវ | | ចំណែវ | /-សព/ព-/ |
| ចោត | | ចំណោទ | /-សព/ព-/ |
| ចោទ | | ចំណោទ | /-សព/ព-/ |
| ចោម | | ចំណោម | /-សព/ព-/ |
| ចោល | | ចំណោល | /-សព/ព-/ |
| ចោះ | | ចំណោះ | /-សព/ព-/ |
| ចំ | | ចំណំ | /-សព/ព-/ |
| ចាំ | | ចំណាំ | /-សព/ព-/ |
| ចាំង | | ចំណាំង | /-សព/ព-/ |
| ឆាប | | ចំហាប | /-សព/ព-/ |
| ឆ្អូល | | ចំហួល | /-សព/ព-/ |
| ឆេះ | | ចំហេះ | /-សព/ព-/ |
| **ប៉ង** | | **បំណង** | **/-សព/ព-/** |
| បន់ | | បំណន់ | /-សព/ព-/ |
| បាក់ | | បំណាក់ | /-សព/ព-/ |
| បាច់ | | បំណាច់ | /-សព/ព-/ |
| បាត់ | | បំណាត់ | /-សព/ព-/ |
| បិទ | | បំណិទ | /-សព/ព-/ |
| បុល | | បំណុល | /-សព/ព-/ |

| | | | |
|---|---|---|---|
| ប៉ែក | | បំណែក | /-សព/ព-/ |
| បើក | **/-អ´ម/ណ-/** | បំណើក | /-សព/ព-/ |
| បោក | | បំណោក | /-សព/ព-/ |
| ប៉ះ | | បំណះ | /-សព/ព-/ |
| សក | | សំណក | /-សព/ព-/ |
| សង | | សំណង | /-សព/ព-/ |
| សង់ | | សំណង់ | /-សព/ព-/ |
| សល់ | | សំណល់ | /-សព/ព-/ |
| សាក | | សំណាក | /-សព/ព-/ |
| សាង | | សំណាង | /-សព/ព-/ |
| សាញ | | សំណាញ | /-សព/ព-/ |
| សាត់ | | សំណាត់ | /-សព/ព-/ |
| សាប | | សំណាប | /-សព/ព-/ |
| សិង | | សំណិង | /-សព/ព-/ |
| សឹក | | សំណឹក | /-សព/ព-/ |
| សុស | | សំណុស | /-សព/ព-/ |
| សូក | | សំណូក | /-សព/ព-/ |
| សូម | | សំណូម | /-សព/ព-/ |
| សួរ | | សំណួរ | /-សព/ព-/ |
| សើច | | សំណើច | /-សព/ព-/ |
| សើម | | សំណើម | /-សព/ព-/ |
| សើ | | សំណើ | /-សព/ព-/ |
| សែន | | សំណែន | /-សព/ព-/ |
| សេព | | សំណែព | /-សព/ព-/ |
| សេស | | សំណែស | /-សព/ព-/ |
| សោក | | សំណោក | /-សព/ព-/ |
| សៀង | | សំនៀង | /-សព/ព-/ |
| អត់ | | អំណត់ | /-សព/ព-/ |
| អរ | | អំណរ | /-សព/ព-/ |
| អស់ | | អំណស់ | /-សព/ព-/ |
| អាច | | អំណាច | /-សព/ព-/ |
| ឱ្យ | | អំណោយ | /-សព/ព-/ |
| **ចួន** | **/-អ´ម/ន-/** | **ចំនួន** | **/-សព/ព-/** |

| | | | |
|---|---|---|---|
| ចួប,ជួប | **/-អ៑ម/ន-/** | ចំនួប,ជំនួប | /-សព/ព-/ |
| ចៀរ | | ចំនៀរ | /-សព/ព-/ |
| **តឿ** | | **តំនឿ** | **/-សព/ព-/** |
| តឿន | | តំនឿន | /-សព/ព-/ |
| អួត | | អំនួត | /-សព/ព-/ |
| កប់ | /-ន-/ | ខ្នប់ | /-ព-/ |
| កល់ | | ខ្នល់ | /-ព-/ |
| កាច់ | | ខ្នាច់ | /-ព-/ |
| កាយ | | ខ្នាយ | /-ព-/ |
| ការ | | ខ្នារ | /-ព-/ |
| កិច្ច | | ខ្និច | /-ព-/ |
| កិត | | ខ្និត | /-ព-/ |
| កួច | | ខ្នួច | /-ព-/ |
| កួត | | ខ្នួត | /-ព-/ |
| កើត | | ខ្នើត | /-ព-/ |
| កើយ | | ខ្នើយ | /-ព-/ |
| កែង | | ខ្នែង | /-ព-/ |
| កៀរ | | ខ្នៀរ | /-ព-/ |
| កៀស | | ខ្នៀស | /-ព-/ |
| កោស | | ខ្នោស | /-ព-/ |
| សប់ | | ស្នប់ | /-ព-/ |
| សិត | | ស្និត | /-ព-/ |
| សួរ | | ស្នួរ | /-ព-/ |
| សួ | | ស្នួ | /-ព-/ |
| សើ | | ស្នើ | /-ព-/ |
| សៀត | | ស្នៀត | /-ព-/ |
| សែង | | ស្នែង | /-ព-/ |
| **ចាប់** | | **ឆ្នាប់** | **/-ព-/** |
| ចុក | | ឆ្នុក | /-ព-/ |
| ឆូត | | ឆ្នូត | /-ព-/ |
| **គង** | | **ឃ្នង** | **/-ព-/** |
| គាប | | ឃ្នាប | /-ព-/ |
| គូស | | ឃ្នូស | /-ព-/ |

| | | | |
|---|---|---|---|
| **ជាន់** | /-ន-/ | **ឈ្នាន់** | **/-ព-/** |
| ជូត | | ឈ្នូត | /-ព-/ |
| ជួត | | ឈ្នួត | /-ព-/ |
| ជួល | | ឈ្នួល | /-ព-/ |
| ធៀង | | ឈ្នៀង | /-ព-/ |
| **ដក់** | | **ថ្នក់** | **/-ព-/** |
| ដូរ | | ថ្នូរ | /-ព-/ |
| ដើរ | | ថ្នើរ | /-ព-/ |
| ដោល | | ថ្នោល | /-ព-/ |
| ទស់ | | ធ្នស់ | /-ព-/ |
| ទាក់ | | ធ្នាក់ | /-ព-/ |
| ទើរ | | ធ្នើរ | /-ព-/ |
| **បត់** | | **ផ្នត់** | **/-ព-/** |
| បូល | | ផ្នូល | /-ព-/ |
| បួង | | ផ្នួង | /-ព-/ |
| បួស | | ផ្នួស | /-ព-/ |
| ប៉ែក | | ផ្នែក | /-ព-/ |
| បោល | | ផ្នោលៗ | /-ព-/ |
| បោះ | | ផ្នោះ | /-ព-/ |
| **ពាក់** | | **ភ្នាក់** | **/-ព-/** |
| ពាស | | ភ្នាស | /-ព-/ |
| ពេន | | ភ្នេន | /-ព-/ |
| ពែន | | ភ្នែន | /-ព-/ |
| **ទ្រាប់** | **/-អ៊ុ/ន-/** | **ទ្រនាប់** | **/-ស/ព-/** |
| រាស់ | | រនាស់ | /-ស/ព-/ |
| រឹង | | រនិង | /-ស/ព-/ |
| រុក | | រនុក | /-ស/ព-/ |
| រេល | | រនេល | /-ស/ព-/ |
| រោច | | រនោច | /-ស/ព-/ |
| រាំង | | រនាំង | /-ស/ព-/ |
| គង | /-អ៊ុម/ន-/ | គំនង | /-សព/ព-/ |
| គម | | គំនម | /-សព/ព-/ |
| គប់ | | គំនប់ | /-សព/ព-/ |

| | | | |
|---|---|---|---|
| គរ | /-អ៊ំម/ន-/ | គំនរ | /-សព/ព-/ |
| គាក់ | | គំនាក់ | /-សព/ព-/ |
| គាត | | គំនាត | /-សព/ព-/ |
| គាប | | គំនាប | /-សព/ព-/ |
| គាប់ | | គំនាប់ | /-សព/ព-/ |
| គាល់ | | គំនាល់ | /-សព/ព-/ |
| គាស់ | | គំនាស់ | /-សព/ព-/ |
| គិត | | គំនិត | /-សព/ព-/ |
| គូរ | | គំនូរ | /-សព/ព-/ |
| គូស | | គំនូស | /-សព/ព-/ |
| គួប | | គំនួប | /-សព/ព-/ |
| គួរ | | គំនួរ | /-សព/ព-/ |
| គោះ | | គំនោះ | /-សព/ព-/ |
| គុំ | | គំនុំ | /-សព/ព-/ |
| **ជក់** | | **ជំនក់** | **/-សព/ព-/** |
| ជង់ | | ជំនង់ | /-សព/ព-/ |
| ជច់ | | ជំនច់ | /-សព/ព-/ |
| ជាត់ | | ជំនាត់ | /-សព/ព-/ |
| ជាវ | | ជំនាវ | /-សព/ព-/ |
| ជីប | | ជំនីប | /-សព/ព-/ |
| ជួត | | ជំនួត | /-សព/ព-/ |
| ជួល | | ជំនួល | /-សព/ព-/ |
| ជេរ | | ជំនេរ | /-សព/ព-/ |
| ជែង | | ជំនែង | /-សព/ព-/ |
| ជោះ | | ជំនោះ | /-សព/ព-/ |
| **ទន់** | | **ទំនន់** | **/-សព/ព-/** |
| ទើស | | ទំនើស | /-សព/ព-/ |
| **ពត់** | | **ពំនត់** | **/-សព/ព-/** |
| ពាក់ | | ពំនាក់ | /-សព/ព-/ |
| ពិត | | ពំនិត | /-សព/ព-/ |
| ពឹង | | ពំនឹង | /-សព/ព-/ |
| ពូក | | ពំនូក | /-សព/ព-/ |
| ពូត | | ពំនូត | /-សព/ព-/ |

| | | | |
|---|---|---|---|
| ពូន | /-អិ៍ម/ន-/ | ពំនូន | /-សព/ព-/ |
| ពួត | | ពំនួត | /-សព/ព-/ |
| ពៀរ | | ពំនៀរ | /-សព/ព-/ |
| ពោល | | ពំនោល | /-សព/ព-/ |
| **ទញ់** | | **ទំនញ់** | **/-សព/ព-/** |
| ទត | | ទំនត | /-សព/ព-/ |
| ទប់ | | ទំនប់ | /-សព/ព-/ |
| ទាក់ | | ទំនាក់ | /-សព/ព-/ |
| ទាញ | | ទំនាញ | /-សព/ព-/ |
| ទាប | | ទំនាប | /-សព/ព-/ |
| ទាយ | | ទំនាយ | /-សព/ព-/ |
| ទាល់ | | ទំនាល់ | /-សព/ព-/ |
| ទាស់ | | ទំនាស់ | /-សព/ព-/ |
| ទិញ | | ទំនិញ | /-សព/ព-/ |
| ទុក | | ទំនុក | /-សព/ព-/ |
| ទូល | | ទំនូល | /-សព/ព-/ |
| ទួញ | | ទំនួញ | /-សព/ព-/ |
| ទួល | | ទំនួល | /-សព/ព-/ |
| ទើង | | ទំនើង | /-សព/ព-/ |
| ទើប | | ទំនើប | /-សព/ព-/ |
| **ជន់** | | **ជំនន់** | **/-សព/ព-/** |
| ជា | | ជំនា | /-សព/ព-/ |
| ជាង | | ជំនាង | /-សព/ព-/ |
| ជាញ | | ជំនាញ | /-សព/ព-/ |
| ជាន់ | | ជំនាន់ | /-សព/ព-/ |
| ជាប់ | | ជំនាប់ | /-សព/ព-/ |
| ជិត | | ជំនិត | /-សព/ព-/ |
| ជិះ | | ជំនិះ | /-សព/ព-/ |
| ជីក | | ជំនីក | /-សព/ព-/ |
| ជូន | | ជំនូន | /-សព/ព-/ |
| ជួញ | | ជំនួញ | /-សព/ព-/ |
| ជួយ | | ជំនួយ | /-សព/ព-/ |
| ជួស | | ជំនួស | /-សព/ព-/ |

| | | | |
|---|---|---|---|
| ជឿ | /-អ៊ំម/ន-/ | ជំនឿ | /-សព/ព-/ |
| ជឿន | | ជំនឿន | /-សព/ព-/ |
| ជោរ | | ជំនោរ | /-សព/ព-/ |
| ជុំ | | ជំនុំ | /-សព/ព-/ |
| ជីក | /-រ/ន-/ | ជ្រនីក | /-ពស/ព-/ |
| ទិច | | ទ្រនិច | /-ពស/ព-/ |
| ទើរ | | ទ្រនើរ | /-ពស/ព-/ |
| ទំ | | ទ្រនំ | /-ពស/ព-/ |
| ព | | ព្រនរ | /-ពស/ព-/ |
| ពាក់ | | ព្រនាក់ | /-ពស/ព-/ |
| ពួត | | ព្រនួត | /-ពស/ព-/ |
| **អប** | **/-អ៊/ណ-/** | **រណប** | **/-ស/ព-/** |
| អារ | | រណារ | /-ស/ព-/ |
| អែប | | រណែប | /-ស/ព-/ |

## គន្ថនិទ្ទេស


កេង វ៉ាន់សាក់ *សូរសទ្ទខ្មែរ* : ភ្នំពេញ។

ក្រុមប្រឹក្សាជាតិភាសាខ្មែរ (២០០៨) *សម្រង់ពាក្យដែលសរសេរជាមួយ «ណ» (មិនសរសេរជាមួយ «ន» ទេ) និងពាក្យដែលសរសេរជាមួយ «ឡ» ឬជាព្យាង្គតម្រួត (មិនសរសេរជាមួយ «ល» ទេ)* : ភ្នំពេញ។

ច័ន្ទ សំណព្វ (២០១២) *សំណេរនិងអក្ខរាវិរុទ្ធក្នុងភាសាខ្មែរ* រាជបណ្ឌិត្យសភាកម្ពុជា : ភ្នំពេញ។

លី សុវីរ (តុលា ២០០៤) *ន ជំនួស ណ ល ជំនួស ឡ ហេតុអ្វីក្រសួងអប់រំ យុវជន និងកីឡាសរសេរបែបនេះ?* : ភ្នំពេញ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ (១៩៦៧) *វចនានុក្រមខ្មែរភាគ១-២* វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ : ភ្នំពេញ។

សូ មុយឃៀង (២០០៤) *ទំរង់ផ្នត់ដែកខ្មែរ(ភាគ១-៤)* : ភ្នំពេញ។

អៀវ កើស (១៩៦៧) *ភាសាខ្មែរ* សាកល្បងពិនិត្យរកហេតុផល បណ្ណាគារមិត្តសេរី : ភ្នំពេញ។

# ពិចារណាអំពីឯកភាពភាសាខ្មែរ

បណ្ឌិត ជុំ ស៊ុនណាង
មន្ត្រីវិទ្យាស្ថានភាសាជាតិ

ខ្ញុំសូមឧទ្ទិសអត្ថបទនេះជូនចំពោះព្រលឹងវិញ្ញាណក្ខន្ធលោកគ្រូបណ្ឌិត ដៅ ស៊ុន ដែលជាគ្រូដឹកនាំសារណាថ្នាក់អនុបណ្ឌិតរបស់ខ្ញុំបាទ(២០០២-២០០៣) និងសូមឧទ្ទិសជូនព្រលឹងវិញ្ញាណក្ខន្ធវីរៈជនអ្នកប្រាជ្ញខ្មែរទាំងអស់ ដែលបានសាងស្នាដៃបន្សល់ទុកមរតកអក្សរសាស្ត្រភាសាជាតិដល់កូនចៅជំនាន់ក្រោយបានប្រើប្រាស់ សិក្សាសូត្ររៀន។ សូមព្រលឹងវិញ្ញាណក្ខន្ធរបស់អស់លោកបានទៅសោយសុខទៅសុគតិភព។

## ១- សេចក្តីផ្តើម

ភាសាខ្មែរជាភាសាដែលមានវ័យចំណាស់មួយនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍។ ផ្អែកតាមរចនាសម្ព័ន្ធនិងទិដ្ឋភាពនានានៃភាសាខ្មែរ ភាសានេះមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងទំនាក់ទំនង និងបំពេញតម្រូវការមួយចំនួនដែលកើតពីលំហូរចូលនៃបច្ចេកវិជ្ជាទំនើបៗ ទាំងនៅអតីតកាលនិងបច្ចុប្បន្នកាល។ ប៉ុន្តែដោយអ្នកជាម្ចាស់ភាសាមួយចំនួនមិនសូវរវីរវល់អើពើនិងឱ្យ[១] តម្លៃភាសាជាតិខ្លួន ដោយគេយល់ថាភាសានេះរត់មិនទាន់ការរីកចម្រើននៃវិទ្យាសាស្ត្របច្ចុប្បន្ន អ្នកខ្លះចូលចិត្តនាំយកពាក្យភាសាបរទេសទាំងដុលមកប្រើក្នុងភាសាខ្មែរ មិនព្យាយាមបកប្រែមកជាភាសាជាតិ មិនស្វះស្វែងគាស់កកាយអ្វីដែលគុណសម្បត្តិដែលភាសានេះមានយកមកប្រើ។ អ្នកប្រើប្រាស់ភាសាខ្លះចេះតែនាំគ្នាប្រើភាសាដោយមិនសូវបានគិតគូរវែងឆ្ងាយ ខ្ជីខ្ជារ គឺចេះតែប្រើឱ្យបានៗ ដោយគិតថាខ្លួនជាខ្មែរ ប្រើភាសាខ្មែរយ៉ាងម៉េចក៏បាន សរសេរយ៉ាងម៉េចក៏បាន ឱ្យតែស្តាប់គ្នា គឺបានហើយ។ អ្នកខ្លះតាំងខ្លួនជាអ្នកចេះខ្មែរគ្រប់ជប់ ខ្លួនជំនាញភាសាហើយ មិនស្តាប់មតិស្ថាបនាកែតម្រូវពីអ្នកឯទៀត ឃើញតែខ្លួនល្អ ខ្លួនពូកែ។ បន្តិចម្តងៗកត្តាអវិជ្ជមានទាំងនេះបានផ្សំពូតផ្តុំធ្វើឱ្យលេចឡើងនូវបាតុភាពជាអវិជ្ជមាននានាកើតឡើងជាបន្តបន្ទាប់ក្នុងចរន្តប្រើប្រាស់ភាសាខ្មែរតាំងពីដើមរៀងមកដល់បច្ចុប្បន្ន។ មានកំហុសជាច្រើនដែលទាំងម្ចាស់អត្ថ-បទនេះ ទាំងអ្នកប្រើភាសាខ្មែរឯទៀតបានទទួលនិងសាងឡើងទាំងដោយចេតនានិងអចេតនា។

អត្ថបទនេះនឹងលើកយកបញ្ហាមួយចំនួនខាងលើមកឆ្លុះបញ្ចាំងនិងពិចារណាដើម្បីស្វែងយល់ទាំងអស់គ្នានិងជាការរួមចំណែកជួយអភិរក្សភាសាខ្មែរឱ្យមានឯកភាព។

---

[១] នៅក្នុងវចនានុក្រមរបស់ពុទ្ធសាសនបណ្ឌិត្យ(១៩៦៧:ក, ១៨៤៤) លោកបានណែនាំអំពីសំណេរពាក្យ ឱ្យ អោយ និងឱយ ដោយកំណត់ឱ្យសរសេរជា ឱ្យ តែប៉ុណ្ណោះ។ ប៉ុន្តែនៅស្ទើរគ្រប់ទំព័រនៃវចនានុក្រមនេះរួមទាំងទំព័រដែលពន្យល់អំពីពាក្យនេះផងមិនឃើញមានសរសេរជា ឱ្យ យ៉ាងដូច្នេះទេ ឃើញប្រើតែ ឲ្យ នេះទៅវិញ។ គ្រប់អត្ថបទសិក្សាស្រាវជ្រាវ ម្ចាស់អត្ថបទមានទម្លាប់សរសេរ ឲ្យ នេះជរាបមក។ ដោយសារនៅក្នុងព្រឹត្តិបត្រគ្រប់លេខរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ លោកប្រើរូបសំណេរ ឱ្យ មួយនេះ។ ហេតុនេះម្ចាស់អត្ថបទនឹងព្យាយាមកែទម្លាប់ពីការសរសេរ ឲ្យ មកជា ឱ្យ វិញ ដោយចាប់ផ្តើមពីអត្ថបទនេះតទៅ។

## ២- បាតុភូតបម្រែបម្រួលនិងបន្លែកក្នុងភាសា

អ្នកភាសាបានចាត់ទុកថាភាសាដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ននៅឡើយជាភាសាមានជីវិត និងភាសាដែលលែងមានអ្នកប្រើប្រាស់ទៅហើយជាភាសាដែលស្លាប់ ដូចយ៉ាងភាសាបាលី សំស្រ្កឹត ជាដើម (David Crystal. 2000:1)។ ដោយសារភាសាមានជីវិត ហេតុនេះយើងមិនអាចបដិសេធន៍បាតុភូតបម្រែបម្រួលនានាដែលតែងតែកើតមានឡើងនៅក្នុងភាសាបានទេ។ បម្រែបម្រួលនេះគឺចង់សំដៅដល់បាតុភូតនានាដែលកើតឡើងតាមបែបធម្មជាតិនៃភាសា មិនមែនបម្រែបម្រួលដែលកើតឡើងដោយការតាំងចិត្តរបស់អ្នកប្រើភាសាឬបុគ្គលណាម្នាក់នោះទេ។

ពាក្យថា មួយដុំ មួយដង មួយនាក់ និង នគរ ជាដើម បានរួញឬបានដូរមកជា មុំ ម្តង ម្នាក់ និង អង្គរ តាមលំដាប់។ ទាំងទម្រង់ដើមនិងទម្រង់ថ្មីនៅមានវត្តមាននិងប្រើប្រាស់ក្នុងភាសាខ្មែរបច្ចុប្បន្ន និងជួនកាលមានការប្រើប្រាស់នៅក្នុងបរិបទដូចគ្នាក៏មាន និងផ្សេងគ្នាក៏មាន។

ព្យញ្ជនៈនៅក្នុងភាសាខ្មែរមួយចំនួននៅរក្សាធម្មភាព(feature)របស់ខ្លួននៅគ្រប់បរិបទ ឯព្យញ្ជនៈខ្លះទៀតបានបាត់បង់លក្ខណៈរបស់ខ្លួននៅក្នុងបរិបទមួយចំនួន។

ព្យញ្ជនៈ ក /k/ ដែលស្ថិតនៅទីតាំងចុងព្យាង្គ ឬព្យញ្ជនៈប្រកប(coda) បានបាត់បង់ធម្មភាពរបស់ខ្លួន ដោយដូរពី /k/ ទៅជា [ʔ] នៅក្នុងបរិបទនៃស្រៈមួយចំនួន (Huffman. 1967:36, ជុំ ស៊ុនណាង. ២០១៤:២៣)។ ប៉ុន្តែតាមការសង្កេតជាទូទៅ បម្រែបម្រួលបែបនេះបានកើតមានឡើងតែក្នុងរង្វង់ភាសាខ្មែរកណ្តាល។ គួររំលឹកថា ភាសាខ្មែរត្រូវបានបែងចែកជាបី គឺ ភាសាខ្មែរលើ(ភាគច្រើនប្រើប្រាស់នៅប្រទេសថៃភាគឦសាន្ត) ភាសាខ្មែរកណ្តាល(ប្រើប្រាស់ជាភាសាផ្លូវការក្នុងប្រទេសកម្ពុជា) និងភាសាខ្មែរក្រោម(ប្រើប្រាស់នៅក្នុងទឹកដីវៀតណាមភាគខាងត្បូង) (Prakorb. 1987:3, Smaley. 1994:136)។ ឧទាហរណ៍(១) បង្ហាញអំពីបន្លែកនេះ។

(១)

| | | ទម្រង់សទ្ទតាវិទ្យា | ទម្រង់សូរវិទ្យា | |
|---|---|---|---|---|
| | | | ខ្មែរក្រោម | ខ្មែរកណ្តាល |
| ក. | ត្រចៀក | /trɑ ciek/ | [trɑ ciek] | [trɑ cieʔ] |
| ខ. | កាក់ | /kak/ | [kak] | [kaʔ] |
| គ. | ពួក | /puok/ | [puok] | [puoʔ] |
| ឃ. | សក | /sɑk/ | [sɑk] | [sɑʔ] |

ខ្មែរកម្ពុជាក្រោមអាចនៅបន្លឺព្យញ្ជនៈនេះបានត្រឹមត្រូវជាង ប៉ុន្តែត្រចៀកខ្មែរកណ្តាលកាលបើបានឮខ្មែរកម្ពុជាក្រោមបន្លឺដូចនេះ គេជួនកាលគិតថាខុស ឬប្លែកៗត្រចៀកគួរឱ្យចង់សើចទៅវិញ។

ព្យញ្ជនៈ រ /r/ ដែលស្ថិតនៅចុងព្យាង្គក្នុងពាក្យ ការងារ ពីរ ខ្មែរ ជាដើម មិនត្រូវបានបន្លឺ (silence) សូមមើលឧទាហរណ៍(២ក-គ)។ ប៉ុន្តែព្យញ្ជនៈ រ នៅរក្សាលក្ខណៈរបស់ខ្លួនខ្លះនៅក្នុងភាសាខ្មែរតាមតំបន់ ដូចជាខ្មែរនៅសៀមរាប ខ្មែរសុរិន្ទ្រជាដើម។ ខ្មែរកណ្តាលទំនងមិនដឹងថាខ្លួនមិនបានបន្លឺសូរ រ នេះទេ ឬជួនកាលបានលើកជាសំណួរថា ចាំបាច់មាន រ ហ្នឹងធ្វើអី ក៏មាន។ ព្យញ្ជនៈ រ នៅ

ក្នុងពាក្យខ្លះត្រូវបាត់ធម្មភាពរបស់ខ្លួនទៅជាព្យញ្ជនៈ ល ដែលជាព្យញ្ជនៈសូរលំហូរដូចគ្នា ដូចយ៉ាង ពាក្យ ខ្នុរ កុរ កណ្ដុរ ហឹរ សម្បុរ ជាដើម, ឧទាហរណ៍(២ឃ-ជ)។

(២)

| | | ទម្រង់សទ្ទតាវិទ្យា | ទម្រង់សូរវិទ្យា |
|---|---|---|---|
| ក. | ការងារ | /ka:r ŋḙa:r/ | [ka: ŋḙa:] |
| ខ. | ពីរ | /pi:r/ | [pi:] |
| គ. | ខ្មែរ | /khmɛr/ | [khmɛ] |
| ឃ. | កុរ | /kor/ | [kol] |
| ង. | កណ្ដុរ | /kɑn dor/ | [kɑn dol] |
| ច. | ហឹរ | /hœr/ | [hœl] |
| ឆ. | សម្បុរ | /sm bor/ | [sɑm bol] |
| ជ. | ខ្នុរ | /khnor/ | [khnol] |

ព្យញ្ជនៈ ស /s/ ក្នុងសៀវភៅរបស់លោក អៀវ កើស(១៩៦៧:២៧៥)[2] ក្នុងពាក្យ ឈ្លាស ដែលថៃខ្ចីទៅ ដូរជា ឆ្លាត។ លោកសរសេរថា ថៃបញ្ចេញសូរអក្សរ ស នៅក្នុងពាក្យដែលថៃខ្ចីពាក្យពីខ្មែរទៅមិនត្រូវ ថៃអានអក្សរ ស ជាសូរ ដ។ ខ្មែរនៅសម័យមុនឬ/និងសម័យក្រោយគ្រាដែលសៀវភៅលោកចងក្រងឡើងនោះ ទំនងជាមិនអាចបន្លឺសូរ ស នៅក្នុងទីតាំងចុងព្យាង្គត្រូវតាមធម្មភាពនៃព្យញ្ជនៈនេះបានទេ។ ត្រង់នេះបញ្ជាក់ថា លោកអៀវ កើស មិនបានដឹងថាខ្លួនគាត់ ក៏ដូចជាខ្មែរទូទៅបន្លឺសូរ ស នេះខុសទេ។ ក្នុងបរិបទនៃការសិក្សាស្រាវជ្រាវអំពីភាសាខ្មែរ លោក អៀវ កើស ត្រូវបានចាត់ទុកថាជាភាសាវិទូខ្មែរដំបូងម្នាក់នាសម័យនោះ ដែលទម្លុះទម្លាយត្រួសត្រាយលើការសិក្សាភាសាខ្មែរតាមបែបភាសាវិទ្យា(linguistics) តាមរយៈការពិនិត្យ អង្កេត សាកល្បង ដែលជំហានទាំងនេះត្រូវបានប្រើក្នុងវិទ្យាសាស្ត្រនានា។

ទោះការលើកឡើងទាំងអម្បាលម៉ានខាងលើនេះមានចំណុចខ្លះស្ថិតនៅក្នុងបន្លែកភាសា ឬពិពិធភាពនៃភាសា(Language Variety) ពុំមែនជាបម្រែបម្រួលភាសាក្តី ក៏ទាំងនេះជាចំណែកមួយបង្ហាញអំពីចំណុចផ្ដើមនៃបម្រែបម្រួលក្នុងភាសាដែលមានលក្ខណៈជាធម្មជាតិ។ ពោលគឺ ម្ចាស់ភាសាមិនបានតាំងចិត្តនឹងធ្វើឱ្យមានបន្លែកទាំងនេះ ឬមិនបានព្យាយាមប្តូរសូរឱ្យខុសពីលក្ខណៈដើមឡើយ។

ផ្ទុយទៅវិញបម្រែបម្រួលមួយទៀតបានកើតឡើងពីការតាំងចិត្ត ការបង្កើតក្បួនច្បាប់ជាបុគ្គលឬជាក្រុមដើម្បីឱ្យអ្នកឯទៀតធ្វើតាម ដែលជួនកាលអាចផ្ទុយពីក្រិត្យក្រមធម្មជាតិនៃភាសា ដែលលក្ខណៈនេះច្រើនប្រទះឃើញក្នុងវង្វង់វេយ្យាករណ៍ប្រពៃណី(traditional grammar)។

យើងនឹងពិចារណាឡើងវិញបន្តិចអំពីបម្រែបម្រួលនៃព្យញ្ជនៈ ស។ ព្យញ្ជនៈនេះនៅរក្សាធម្មភាពរបស់ខ្លួនតែក្នុងបរិបទនៃទីតាំងដើមព្យាង្គ(onset)។ ប៉ុន្តែព្យញ្ជនៈនេះបានត្រូវផ្លាស់ប្តូរនៅក្នុងទី

---

[2] តាមរយៈ *សេចក្ដីជំរាបជាមុន* លោកអៀវ កើស បានចុះកាលបរិច្ឆេទ ថ្ងៃ១០ ខែតុលា គ.ស. ១៩៤៧ ដែលអាចជាឆ្នាំសៀវភៅរបស់លោកបានសរសេរចប់សព្វគ្រប់ហើយ។ ចំណែកឆ្នាំ១៩៦៧ ជាឆ្នាំបោះពុម្ពសៀវភៅរបស់លោក។

តាំងចុងព្យាង្គស្ទើរគ្រប់ករណី។ ផ្ទុយទៅវិញ ខ្មែរយើងគ្រប់រូបពិតជាច្បាស់ក្នុងខ្លួនថាខ្លួនប្រាកដជាបន្លឺសូរនេះច្បាស់ត្រឹមត្រូវមួយរយភាគរយ។ ដូចយ៉ាងពាក្យ៖

| (៣) | | ទម្រង់សទ្ទតាវិទ្យា | ទម្រង់សូរវិទ្យា |
|---|---|---|---|
| ក. | ចាស់ | /cas/ | [cah] |
| ខ. | លៀស | /lies/ | [lieh] |
| គ. | ប្រកាស | /prɑ ka:s/ | [prɑ ka:h] |
| ឃ. | ពាស | /peas/ | [peah] |

កន្លងមកនៅមិនទាន់ឃើញមានការសិក្សាណាមួយស្ដីអំពីវត្តមានព្យញ្ជនៈ s ក្នុងភាសាខ្មែរនៅទីតាំងចុងព្យាង្គនៅឡើយទេ។ យើងមិនដឹងថាសូរនេះត្រូវប្រែប្រួលតាំងពីពេលណាមកទេ ឬមួយភាសាយើងគ្មានសូរ ស ប្រកបក៏មិនដឹង។ ទោះជាយ៉ាងណាក្ដី ជាសម្មតិកម្ម រូបសំណេរជួនកាលក៏អាចជួយឱ្យយើងបានដឹងថា ភាសាខ្មែរទំនងជាមានសូរនេះជាព្យញ្ជនៈប្រកបក្នុងពាក្យនៃភាសារបស់ខ្លួនតាំងពីដើមរៀងមកដែរ ហើយប្រហែលជាបុព្វបុរសយើងបន្លឺសូរនេះបានដូចយ៉ាងភាសាបរទេសមួយចំនួនដែរ។ ក្នុងភាសាបារាំងអង់គ្លេស គេមានព្យញ្ជនៈ s ដែលត្រូវឬប្រហែលគ្នានឹង ស ខ្មែរយើងដែរ។ ប៉ុន្តែធម្មភាពនៃ s របស់ភាសាគេនៅរក្សាបន្នែកលក្ខណៈ (distinctive feature) ទាំងក្នុងមុខងារជាព្យញ្ជនៈប្រកបនិងព្យញ្ជនៈដើមព្យាង្គនៅក្នុងភាសាមួយចំនួនធំ។ ពោលគឺ គេបន្លឺសូរ s នេះបានស្ទើរគ្រប់មុខងារនៃព្យញ្ជនៈនេះ, ឧទាហរណ៍ (៤) ។

| (៤) | | |
|---|---|---|
| ក. | base | /beis/ |
| ខ. | desk | /desk/ |
| គ. | safe | /seif/ |
| ឃ. | de-signs | /di'zainz/ |

(Longman. 1992:73, 277, 921, 277)

តាមរយៈឧទាហរណ៍ខាងលើ ព្យញ្ជនៈ s នៅរក្សាតម្លៃរបស់ខ្លួន ទោះជានៅក្នុងពាក្យខ្លះ (៤ឃ) លក្ខណៈរបស់សូរបានប្រែប្រួលបន្តិច (s → z) ក្ដី ក៏មិនបានធ្វើឱ្យសូរឃ្លាតឆ្ងាយពីលក្ខណៈដើមប៉ុន្មានទេ ព្រោះ s ជាព្យញ្ជនៈអឃោសៈ និង z ព្យញ្ជនៈឃោសៈ។

យើងវិលមកពិនិត្យលើព្យញ្ជនៈ ស នៅក្នុងពាក្យ ប្រកាស (៣គ)។ នៅក្នុងពាក្យនេះ ព្យញ្ជនៈ ស បានដូរជា h ដូចពាក្យឯទៀតក្នុងឧទាហរណ៍ (៣) ដែរ។

វចនានុក្រមរបស់លោក Headely (1977:564) បានសរសេរសូរអាននៃពាក្យនេះ យ៉ាងដូច្នេះថា៖

ទេស /teeh/ (=ប្រទេស, ស្រុកទេស)

ប្រកាស /prɑkaah/

(Headley. 1977:405, 564)

ពេលពាក្យទាំងនេះត្រូវនាំមកធ្វើជាពាក្យសមាស(compound word) ព្យញ្ជនៈ s ហាក់ដូចជានៅរក្សាលក្ខណៈដើម។

ទេសកាល /teehsaʔkaal/

ទេសចរ /teehsaʔcɑɑ/

ប្រកាសនីយប័ត្រ /prɑkaasaʔniiyeaʔbat/

(Headley. 1977:405, 564)

ទេសកាល (ទេស-កាល)

ទេសចរ (ទេសៈច)

ប្រកាសនីយប័ត្រ (_សៈនីយៈប័ត)

(ពុទ្ធសាសនបណ្ឌិត្យ. ១៩៦៧:៤៥២, ៦៤០)

យើងឃើញថា ព្យញ្ជនៈ s ដែលនៅក្នុងលក្ខណៈជាពាក្យទោលបានបាត់បន្លែកលក្ខណៈ ប៉ុន្តែពេលនាំពាក្យទៅចូលរួមជាមួយពាក្យឯទៀតដើម្បីបង្កើតពាក្យសមាស ព្យញ្ជនៈ s នៅរក្សាលក្ខណៈដើម។ ហេតុនេះយើងទាញជាសម្មតិកម្មជាបឋមថាព្យញ្ជនៈ s ទំនងជាមានក្នុងទីតាំងចុងព្យាង្គនៅក្នុងពាក្យភាសាខ្មែរ និងមិនមានការប្រែប្រួលដូចដែលបានឃើញនាបច្ចុប្បន្ននេះទេ។

តាមបន្លែកលក្ខណៈ(distinctive feature) ព្យញ្ជនៈ s មានបន្លែកលក្ខណៈ [+sibilant] និង h មានបន្លែកលក្ខណៈជា [-sibilant] ហើយព្យញ្ជនៈទាំងពីរមានបន្លែកលក្ខណៈ [fricative] ដូចគ្នា។

| s | h |
|---|---|
| [+sibilant] | [-sibilant] |
| [fricative] | [fricative] |

(Chom Sonnang. 2016 :19)

អ្នកភាសាមាននាទីសង្កេត ពិពណ៌នាទៅលើទិដ្ឋភាពបាតុភូតនានាដែលកើតឡើងក្នុងរង្វង់អ្នកប្រើប្រាស់ភាសា ដែលនេះហើយជាលក្ខណៈពិសេសរបស់ភាសាវិទ្យា។ ពិពណ៌នាថា តើពាក្យនេះគេបន្លឺយ៉ាងម៉េច ប្រើដូចម្ដេច បន្ទាប់ពីការសិក្សាសង្កេត នាំទៅធ្វើពិសោធន៍រួចហើយ ទើបឈានទៅរកសេចក្ដីសន្និដ្ឋានដើម្បីបង្ហាញលទ្ធផលរួម។

តាមរយៈពាក្យក្នុងឧទាហរណ៍(៣) បម្រែបម្រួលរបស់ព្យញ្ជនៈ /s/ ទៅជា [h] បានកើតឡើងក្នុងបរិបទចុងព្យាង្គ ដែលនាំឱ្យយើងអាចទាញជារូបមន្តដូចខាងក្រោម៖

$$s \rightarrow h/V_$$

<u>អានថា</u>៖ ព្យញ្ជនៈ s ប្ដូរទៅជា h ក្នុងករណីដែលព្យញ្ជនៈ s នៅបន្ទាប់ស្រះ។

## ៣- កម្ចីភាសា[៣]

ភាសាតែងមានឥទ្ធិពលលើគ្នាទៅវិញទៅមក។ ជាទូទៅភាសានៃសង្គមដែលមានការរីកចម្រើនជាង ច្រើនជះឥទ្ធិពលលើភាសានៃសង្គមដែលមិនសូវមានការរីកចម្រើន។ ការជះឥទ្ធិពលនេះជាបុព្វហេតុមួយនៃកម្ចីភាសា។ ស្ថិតក្នុងន័យនេះ លោកអៀវ កើស (១៩៦៧:២៦៩) បានលើកឡើងទាក់ទងនឹងការជះឥទ្ធិពលរវាងខ្មែរនិងសៀមយ៉ាងដូច្នេះថា *តាំងពីជាតិយើងធ្លាក់ខ្លួនពេញទី ចាប់ពីខួចបង់បន្ទាយលង្វែកមក អារ្យធម៌ដែលធ្លាប់ហូរពីស្រុកខ្មែរទៅតាមទិសឯជើងនិងឯលិច កាលយើងជានាយចៅហ្វាយគេ ក៏ត្រឡប់ហូរបញ្ច្រាសមកពីទិសឯលិច កាលយើងបរាជ័យនៅក្រោមបង្គាប់គេវិញ។* ភាសាជាធាតុមួយនៃអារ្យធម៌។

លក្ខណៈនៃការខ្ចីពាក្យពីភាសាបរទេសមានច្រើនយ៉ាង។ ប៉ុន្តែលក្ខណៈកម្ចី[៤] ដែលនិយមប្រើជាងគេគឺ កម្ចីទាំងដុល loanword, កម្ចីបន្សំ loanblend, កម្ចីប្រែ loanshift ( Apichai. 2004:10-11 )។

១. កម្ចីពាក្យ ឬកម្ចីទាំងដុល loanword

ស៊ីម៉ងត៍ ( ពុទ្ធសាសនបណ្ឌិត្យ. ១៩៦៧:១៣៥៩ ), ម៉ែត្រ, ក្រាហ្វិក(វិទ្យាស្ថានភាសាជាតិ. ២០០៥:៥៨), អ័ក្ស ( ក្រសួងអប់រំយុវជននិងកីឡា.២០០៦:១១៨), វីនដូ ( គណៈកម្មការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា. ២០១៤:៧០ )

២. កម្ចីបន្សំ Loanblend

ខ្សែកាប[៥] , នំប៉័ង, ឡានតាក់ស៊ី,

៣. កម្ចីប្រែ Loanshift

ក្ដារចុច, កំណែទម្រង់, តម្លាភាព, ព័ត៌មានវិទ្យា, ប្រាក់កម្ចី ជាដើម។

តទៅនេះយើងនឹងពិចារណាទៅលើកម្ចីពាក្យនិងពាក្យកម្ចីមួយចំនួនដែលកំពុងចរាចរនៅក្នុងចរន្តសំដីនៃភាសាខ្មែរ។

នៅក្នុងលក្ខណៈកម្ចីទាំងដុល គណៈកម្មការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា(២០១៤:៧៣)បានចម្លងផ្ទាប់សូរ( transcribe ) ពាក្យ software មកជាភាសាខ្មែរថា សុសវែរ។ ខណៈនោះដែរ មានស្ថាប័ននិងអ្នកប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាមួយចំនួនបាននាំពាក្យនេះមកប្រើតាមវិធីកម្ចីប្រែ គឺ បានបកប្រែពាក្យនេះជាភាសាខ្មែរថា ផ្នែកទន់ ។ ដូចជា វចនុក្រម dict.antkh.com ( បច្ចេកវិទ្យានិងវិទ្យាសាស្ត្រ ) ប្រែពាក្យ software ថា គ្រឿងទន់, ផ្នែកទន់ ( កុំព្យូទ័រ ) ជាដើម។

---

[៣] អ្នកភាសាទំនងជាប្រើពាក្យ ខ្ចី ( borrow ) ក្នុងបរិបទដែលពាក្យឬធាតុណាមួយនៃភាសាមួយត្រូវបាននាំយកមកប្រើក្នុងភាសាមួយទៀត ដើម្បីសម្រួលដល់ការប្រើពាក្យថា លួច។ តាមពិតទៅន័យរបស់ពាក្យ ខ្ចី ( ខ្ចី > កម្ចី ) នេះត្រូវមានភាគីដែលសុំខ្ចីនិងភាគីដែលអនុញ្ញាតឱ្យខ្ចី។ មិនមានភាសាឬអ្នកប្រើប្រាស់ភាសាណាមួយធ្វើតាមន័យនៃពាក្យនេះទេ។

[៤] ខ្ញុំសូមប្រែពាក្យអង់គ្លេស loanword ជា កម្ចីទាំងដុល, loanblend ជា កម្ចីបន្សំ, និង loanshift ជា កម្ចីប្រែ យ៉ាងដូច្នេះជាបណ្ដោះអាសន្នសិន និងសង្ឃឹមថានឹងមានការបកប្រែពាក្យទាំងនេះជាផ្លូវការពីក្រុមអ្នកជំនាញភាសានាអនាគត។

[៥] តាមការយល់ឃើញរបស់ខ្ញុំ ពាក្យនេះគួរសរសេរជា កាប្លិ៍ ( cable ) ដើម្បីរក្សាជាតិសព្ទរបស់ពាក្យ ដូចពាក្យ ស៊ីម៉ង់ត៍ ជាដើម។

នៅក្នុងពាក្យមានព្យញ្ជនៈផ្សំ ft ជាព្យញ្ជនៈចុងព្យាង្គ។ នៅក្នុងសទ្ទតាភាសាខ្មែរបច្ចុប្បន្នដែលធ្វើឡើងដោយអ្នកជំនាញភាសាខ្មែរមួយភាគធំជាទូទៅមិនមានព្យញ្ជនៈ f ទេ។ ចំណែកអ្នកភាសាមួយចំនួនទៀតបានដាក់បញ្ចូលព្យញ្ជនៈនេះទៅក្នុងតារាងសទ្ទតាព្យញ្ជនៈខ្មែររបស់ខ្លួន(Madeline. 1972:4; Huffman. 1967:15; Headley. 1977:35)។

ក្រៅពីព្យញ្ជនៈ f នេះ ក៏ឃើញមានព្យញ្ជនៈមួយចំនួនទៀត ដូចជា ហ្គ(g) ស្ស(z) ជាដើមត្រូវបានប្រើនៅក្នុងការកត់សូរពាក្យកម្ចីបរទេសមកក្នុងភាសាខ្មែរ។ ទោះបីវិទ្យាស្ថានខេមរយានកម្មដែលនិយមហៅខ្លីៗថា ខេមរយានកម្ម បានព្យាយាមបកប្រែពាក្យពីបរទេសបានមួយចំនួនធំក្តី និងព្យាយាមបញ្ចៀសការបន្ថែមអក្សរនៃសូរភាសាបរទេសទាំងអម្បាលម៉ាននេះក្តី ក៏អ្នកប្រើប្រាស់ភាសាមួយចំនួននិយមប្រើព្យញ្ជនៈទាំងនេះនៅក្នុងពាក្យជាច្រើនដូចជា៖

(៥)

ក. អាហ្វ្រិក (ក្រុមប្រឹក្សាជាតិភាសាខ្មែរ. ២០១៣:១៧)

ខ. កាហ្វេ (Headley. 1977:35; វិទ្យាស្ថានភាសាជាតិ. ២០០៥:២៤; ...)

គ. ក្រាហ្វ (នេត បារ៉ុម. ២០១៧:១៨៩, ក្រសួងអប់រំយុវជននិងកីឡា. ២០០៨:៧; ...)

ឃ. ហ្វីលីពីន (ក្រុមប្រឹក្សាជាតិភាសាខ្មែរ. ២០១៣:១៥)

ពាក្យ អាហ្វ្រិក (៥ក) នៅក្នុងវចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែររបស់វិទ្យាស្ថានភាសាជាតិ (២០០៥:៨៣២) សរសេរពាក្យនេះ ជា អាហ្វ្រិក។

ពាក្យ កាហ្វេ(café) ដែលពាក្យនេះកាលដើមឡើយ រាមច្បងយើងបានព្យាយាមសរសេរជា កាផែ តែក្រោយមកត្រូវនិយមសរសេរជា កាហ្វេ អស់ទៅហើយ។ នេះក៏ដោយសារតែខ្មែរមួយភាគធំអាចបន្លឺសូរ f នេះបានឬយ៉ាងណា?

តើព្យញ្ជនៈ f មានវត្តមាននៅក្នុងភាសាខ្មែរយូរមកហើយឬខ្មែរទើបទទួលពីបរទេសថ្មីៗនេះទេ?

នៅក្នុងភាសាខ្មែរបុរាណឃើញមានរូបសំណេរ ហ្វ នេះទាំងនៅដើមព្យាង្គនិងនៅចុងព្យាង្គ៖

| | | | | |
|---|---|---|---|---|
| OK | *rval* or *rhval* | MK | *raval* | busy |
| | *veṅ* or *hveṅ* | | *vɛṅ* | long |
| | cf. also *hvek* | | *vɛk* | ladle |

jāhv, jāv to barter (Jacob. 1993:3, 15)

យើងនៅមិនទាន់ដឹងច្បាស់ថា ខ្មែរបុរាណលោកអានបន្សំអក្សរ ហ្វ នៅក្នុងពាក្យ រវល់ ឬ រហ្វល់, វេង ឬ ហ្វេង (វែង) និង ហ្វេក (វែក) យ៉ាងដូចម្តេចទេ។ លោកម៉ាស្ប៉េរ៉ូ(Maspéro. 1915:25) អានពាក្យ ចៅហ្វាយ ថា caovhày ពោលគឺ ហ្វ ត្រូវនឹង vh ទៅវិញ។ នៅក្នុងភាសាថៃមានពាក្យដែលមានព្យញ្ជនៈ f ហើយពាក្យទាំងនោះត្រូវគ្នានឹងពាក្យខ្មែរមួយចំនួន សូមមើលឧទាហរណ៍(៦)។

| (៦) | ថៃ | | ខ្មែរ | |
|---|---|---|---|---|
| ក. | ฝูง | /fǔŋ/ | ហ្វូង | /foːŋ/ ឬ /woːŋ/ |
| ខ. | ฝึก | /fɯ̀k/ | ហ្វឹក | /fɯk/ ឬ /wɯk/ |

តើពាក្យទាំងនេះមានទំនាក់ទំនងនឹងគ្នាទេ?

ទាំងវចនានុក្រមភាសាខ្មែររបស់ពុទ្ធសាសនបណ្ឌិត្យ(១៩៦៧) និងរបស់លោក Headley (១៩៧៧) សុទ្ធតែបង្ហាញថា ពាក្យទាំងនេះជាពាក្យកម្ចីភាសាថៃ។ ប៉ុន្តែយើងនឹងនៅមានចម្ងល់ថា តើទម្រង់ ហ្វ ដែលមានរូបសំណេរនៅក្នុងភាសាខ្មែរបុរាណមានសូរដូចម្ដេច ឬពាក្យខាងលើថៃខ្ចីពីខ្មែរទៅទេដឹង? ការនេះទាមទារឱ្យមានការសិក្សាស៊ីជម្រៅលើបញ្ហានេះ។

លោកអៀវ កើស(១៩៦៧:៣៣៤) បានបង្ហាញអំពីគន្លងនៃការបង្កើតពាក្យថ្មីនៅក្នុងស្នាដៃរបស់លោក។ ក្នុងនោះលោកបានប្រើ ហ្វ ក្នុងការកត់សូរភាសាបរទេស ដូចជា តេឡេក្រាហ្វ, តេឡេហ្វូន, ហ្វៃហ្វា, ស៊ុហ្វាត ជាដើម។

ដោយសារវត្តមាននៃ ហ្វ ទោះជាយើងមានមកពីបូរាណមកក្ដី ឬទើបទទួលនាបច្ចុប្បន្នក្ដី ក៏ ហ្វ ត្រូវបានសាធារណជនខ្មែរមួយភាគធំបានស្គាល់ព្យញ្ជនៈទៅហើយ។ ហេតុនេះ ពាក្យ software មិនគួរត្រាប់សូរទៅជា សុសវែរ ទេ ហើយម្យ៉ាងទៀត តើត្រូវអានថា soh wae ឬ sos wae?

តាមលក្ខណៈបន្លឺសូរ ព្យញ្ជនៈដែលនៅក្បែរព្យញ្ជនៈ f គឺ p និង b។ ជាការពិតហើយដែលម្ចាស់ភាសាមួយពិបាកនឹងបន្លឺសូរពាក្យនៃភាសាមួយទៀតឱ្យបានដូចគ្នាបេះបិទទៅនឹងម្ចាស់ភាសាគេណាស់។ ប៉ុន្តែយើងក៏មិនគួរធ្វើឱ្យពាក្យដែលខ្ចីមកនោះស្ថិតនៅឆ្ងាយពេកពីភាសាដើមដែរ។

តាមរយៈការលើកឡើងខាងលើ ភាសាខ្មែរមានលទ្ធភាពច្រើនដែលអាចសងទៅនឹងអ្វីដែលហូរមកពីក្រៅបានច្រើនសមល្មម។ ម្ចាស់ភាសាគួរខិតខំឱ្យអស់លទ្ធភាពដោយប្រើធនធាននៃភាសា។ ដូចយ៉ាងករណី ft ឬ f ហោចណាស់គួររក្សាសូរឱ្យនៅប្រហាក់ប្រហែលគ្នា f > p។ ប្រសិនបើ ft ក្នុងពាក្យ software ត្រូវបានសម្រួលមកជា h អំណឹះតទៅអនាគតអ្នកសិក្សាជំនាន់ក្រោយនឹងលើកយកប្រធានបម្រែបម្រួលព្យញ្ជនៈ ft នៅក្នុងភាសាខ្មែរមកជា h។ ទោះករណីនេះចាត់ទុកជាបញ្ហាតូចតាចរបស់អ្នកសិក្សាស្រាវជ្រាវមួយចំនួនក្ដី ក៏បញ្ហានេះមិនគួរមើលរំលងដែរ គួរនាំគ្នាដោះស្រាយឱ្យបានជ្រះស្រឡះទើបជាការល្អ។ បញ្ហាតូចជាធាតុផ្សំនៃបញ្ហាធំ។

កម្ចីទាំងដុល(loanword) គួរផ្អែកលើគោលការណ៍ច្បាស់លាស់ ឱ្យសមស្របទៅតាមភាពពិតនៃសូរក្នុងភាសានិងអ្នកប្រើប្រាស់ទូទៅ ដោយមានការស្ទាបស្ទង់អំពីការប្រើប្រាស់ពាក្យនេះ តើគេនិយមនិយាយ ឬបន្លឺសូរដូចម្ដេច?

តាមរយៈការស្វែងរក(search engine)នៅក្នុង Google(៣ មករា ២០១៨) រវាងរូបសំណេរនៃពាក្យ software ជាភាសាខ្មែរ លទ្ធផលបង្ហាញដូចខាងក្រោម៖

(៧)

ក. សុសវែរ About 109 results (0.46 seconds)

ខ. សុហ្វវែរ About 153 results (0.41 seconds)

គ. សហ្វវែរ About 1,120 results (0.47 seconds)

ឃ. សូហ្វវែរ About 99,700 results (0.41 seconds)

តាមរយៈលទ្ធផលខាងលើ ការខ្ចីពាក្យ software មកជារូបសំណេរខ្មែរ សូហ្វវែរ ហាក់ដូចជាមានអ្នកនិយមប្រើច្រើនជាងរូបសំណេរផ្សេងទៀត។ កន្លងមក ក្រសួងអប់រំ(២០០៨:៧) ក៏បានសរសេរ ម៉ៃក្រូសូហ្វ របស់ពាក្យកម្ចី Microsoft មកហើយដែរ។

ហេតុនេះគួរមានសិក្សាប្រកបដោយលក្ខណៈវិទ្យាសាស្ត្រមុននឹងឈានទៅប្រកាសឱ្យប្រើពាក្យថ្មីណាមួយជាផ្លូវការ ពោលគឺព្យាយាមកាត់បន្ថយកំហុសឱ្យនៅសល់តិចបំផុត។

កម្ចីប្រែ(loanshift) ជាវិធីខ្ចីភាសាមួយបែបទៀតដោយបម្រែពាក្យនៃភាសាដែលខ្ចីមកជាពាក្យនៃភាសាមួយទៀត។ ប្រសិនបើភាសាដែលសុំខ្ចីពាក្យពីភាសាមួយទៀតមានលទ្ធភាពគ្រប់គ្រាន់នឹងរកន័យត្រូវពាក្យដែលត្រូវខ្ចីមកនោះ គេអាចប្រែពាក្យដែលខ្ចីនោះមកជាភាសារបស់ខ្លួនឱ្យត្រូវនឹងបញ្ញត្តិថ្មី។ ទាក់ទងនឹងបញ្ហានេះ នៅតាមស្ថាប័នឧត្តមសិក្សាមួយចំនួនមានប្រើពាក្យ ដេប៉ាតឺម៉ង់ ត្រូវនឹងពាក្យបារាំងថា départemente។ ដូចជាដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា ដេប៉ាតឺម៉ង់ភូមិវិទ្យា ជាដើម។ តើពាក្យនេះគួរត្រូវបកប្រែមកជាភាសាខ្មែរដូចម្ដេចខ្លះ?

ខាងក្រោមនេះជាសេចក្ដីបកប្រែពាក្យ départemente និង department ពីក្នុងប្រភពផ្សេងៗ៖

départemente n.m. ខេត្ត, ក្រុង (តឹប យក់ និង ថាវ គន្ធ (១៩៦៧:៣៣៤)

départemente m. មន្ទីររដ្ឋមន្ត្រី(អនុវចនានុក្រម បារាំង-ខ្មែរ-តូច.១៩៦?:១២២)

department n. x of Defense ក្រសួង, history x ផ្នែក (Huffman.1978:159)

តាមរយៈបម្រែពាក្យខាងលើ យើងឃើញថា ពាក្យមានន័យផ្សេងៗគ្នាយោងទៅតាមបរិបទនៃការប្រើប្រាស់ពាក្យ។ ក្នុងនោះលោក Huffman ប្រែពាក្យ department ថា ផ្នែក ដូចជាផ្នែកប្រវត្តិសាស្ត្រ។ ម្ចាស់អត្ថបទនេះចាប់អារម្មណ៍នឹងសេចក្ដីប្រែពាក្យនេះថា ផ្នែក។ តើពាក្យនេះមានន័យដូចម្ដេចខ្លះ?

ផ្នែក ន. ប៉ែក, សង្កាត់, ក្រុម៖ របស់នេះមួយផ្នែក, របស់នោះមួយផ្នែក; ផ្នែកទី១, ផ្នែកទី២ នាយផ្នែក (ពុទ្ធសាសនបណ្ឌិត្យ. ១៩៦៧:៧១២)

ផ្នែក /pnaek/ n. part, portion, section, division, department. <បែក 'to be broken'> (Headley. 1977:620)

ទំនងមកពីន័យរបស់ពាក្យខាងលើនេះហើយ ទើបមានក្រសួង ស្ថាប័នខ្លះប្រើពាក្យ ផ្នែក ប្រែសងទៅនឹងពាក្យ department ឬ départemente នេះ ពោលគឺគេមិនបានប្រើពាក្យ ដេប៉ាតឺម៉ង់ ទេ។ នៅក្នុងភាសាថៃមានពាក្យ แผนก(ផ្នែក) ដែលជាពាក្យកម្ចីពីភាសាខ្មែរទៅ។ ពាក្យនេះមានន័យត្រូវនឹងពាក្យ department ដែលគេប្រើសម្រាប់ហៅផ្នែកនានាដែលឋានៈទាបជាងឬនៅក្រោមឧិវាទមហាវិទ្យាល័យ។ ហេតុអ្វីបានជាខ្មែរយើងមួយចំនួនមិនហ៊ានប្រើដើម្បីហៅទីកន្លែងដូចនេះ បែរជានាំគ្នាគ្រាប់សូរសព្ទពាក្យនៃបរទេស ដេប៉ាតឺម៉ង់ ជំនួសឱ្យការប្រើពាក្យ ផ្នែក ទៅវិញ? សូមទុកចំណុចនេះឱ្យអ្នកអានជាអ្នកពិចារណាសិក្សាបន្ត។

ខ្មែរយើងមួយចំនួនច្រើនមានទម្លាប់ប្រើពាក្យខ្ពស់សម្រាប់កំណត់បញ្ញត្តិមួយឬអ្វីមួយដែលខ្លួនឱ្យតម្លៃ ឬលើកតម្កើងជាងគេ ដូចជា មហាលោតផ្លោះ មហាអស្ចារ្យ។

យើងនិយមហៅអ្នកដែលមាននាទីបង្រៀនតាំងពីបឋមសិក្សារហូតដល់ថ្នាក់មហាវិទ្យាល័យថា សាស្ត្រាចារ្យ(professor) ហើយពាក្យនេះ ត្រូវបានប្រើយ៉ាងទូលំទូលាយនាពេលបច្ចុប្បន្ន។ តើន័យរបស់ពាក្យនេះដូចម្ដេចដែរ?

សាស្ត្រាចារ្យ (សំ. គាស្ត្រ + អាចារ្យ៍) គ្រូបង្រៀនសាស្ត្រ ។ល។ (ពុទ្ធសាសនបណ្ឌិត្យ. ១៩៦៧:១៣៤៥)

សាស្ត្រាចារ្យ (សាស-ស្ត្រា-ចា) ន. គ្រូបង្រៀនថ្នាក់មធ្យមសិក្សា (Professeur) ឧទា. ខ្ញុំធ្លាប់ធ្វើជាសាស្ត្រាចារ្យ នៅវិទ្យាល័យស៊ីសុវត្ថិ។ (រ.គោវិទ. ១៩៦១:៣៦៣)

និយមន័យរបស់ពាក្យដូចដែលបានលើកឡើងខាងលើបានបង្ហាញថា ខ្មែរយើងបានប្រើពាក្យនេះសំដៅដល់ គ្រូបង្រៀន ដែលបានដក់ក្នុងផ្នត់គំនិតអ្នកប្រើភាសាខ្មែរយូរដែរហើយ។ ដោយឡែកនៅក្នុងភាសាមួយចំនួន ពាក្យ សាស្ត្រាចារ្យ ជាពាក្យប្រើសម្រាប់ហៅតំណែងគុណវុឌ្ឍិសិក្សាស្រាវជ្រាវ (Academic Position) របស់ប្រព័ន្ធអប់រំខាងប៉ែកបស្ចឹមប្រទេស ជាអាទិ៍ អង់គ្លេស អាមេរិក... ដែលឥទ្ធិពលនេះបានត្រូវទទួលយកមកប្រើដោយប្រទេសមួយចំនួននៅអាស៊ី ដូចជា ថៃ ភូមា ជាដើម។ អ្នកដែលទទួលបានតំណែងជា សាស្ត្រាចារ្យ គឺជាអ្នកដែលបានឆ្លងកាត់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់តាមលក្ខខ័ណ្ឌនៃស្ថាប័នសិក្សានៃប្រទេសនោះកំណត់ឱ្យ។ គ្រូខ្លះឬអ្នកសិក្សាស្រាវជ្រាវខ្លះបានសម្រេចគោលដៅរបស់ខ្លួនត្រឹមសាស្ត្រាចារ្យជំនួយ(Assistant Professor) ក៏ដល់អាយុចូលនិវត្តន៍ទៅហើយ។ ខ្មែរយើងទំនងជាប្រើពាក្យនេះតាមលំនាំការសិក្សាអប់រំបែបបារាំងទេដឹង? ទីនេះគ្រាន់តែសួរថា តើខ្មែរយើងមានកំណត់តំណែងក្នុងវិស័យសិក្សាស្រាវជ្រាវដែរឬទេ? ប្រសិនបើមានមែនតើយើងហៅអ្នកដែលស្ថិតក្នុងតំណែងទាំងនោះសមមូលទៅនឹងពាក្យ Assistant Professor, Associate Professor និង Professor ដែរឬទេ? ម្ចាស់អត្ថបទពេញចិត្តនឹងពាក្យទាំងបីខាងលើសម្រាប់ប្រើកំណត់តំណែងសិក្សាស្រាវជ្រាវនេះតាមបែបប្រទេសមួយចំនួនដូចបានលើកឡើងខាងលើ។

ព្រះរាជក្រឹត្យស្ដីពីការផ្ដល់ឋានៈសាស្ត្រាចារ្យ(២០១៣:៥) បានបែងចែកឋានៈរបស់សាស្ត្រាចារ្យជាបី គឺ៖

សាស្ត្រាចារ្យជំនួយ
សាស្ត្រាចារ្យរង និង
សាស្ត្រាចារ្យ

តែទោះជាយ៉ាងនេះក្ដី ការប្រើពាក្យសាស្ត្រាចារ្យបានជ្រួតជ្រាបនិងជាទីពេញនិយមរបស់អ្នកប្រើភាសាខ្មែររួចទៅហើយ។ ហេតុនេះការប្រើពាក្យ សាស្ត្រាចារ្យ នាពេលបច្ចុប្បន្នហាក់នៅមិនទាន់ស្របតាមខ្លឹមសារដែលមានចែងក្នុងរាជក្រឹត្យនោះនៅឡើយទេ ពោលគឺឱ្យតែមានអាជីពជាគ្រូបង្រៀនខ្មែរយើងចូលចិត្តហៅអ្នកនោះថាជា សាស្តាចារ្យ ទាំងនៅក្នុងភាសាប្រើប្រាស់ទូទៅនិងនៅក្នុងលិខិតបទដ្ឋានមួយចំនួន។ ម្យ៉ាងទៀតពាក្យ ដោយផ្អែកលើលក្ខណៈសម្ព័ន្ធ ថាតើពាក្យ សាស្ត្រាចារ្យជំនួយ

និងសាស្ត្រាចារ្យរង ត្រូវគ្នានឹង ជំនួយសាស្ត្រាចារ្យ និង រងសាស្ត្រាចារ្យ តាមលំដាប់នោះដែរឬទេ។ នេះក៏ជាចំណុចដែលត្រូវពិភាក្សានៅក្នុងការសិក្សាណាមួយដែរ។

## សេចក្តីសន្និដ្ឋាន

ទឡ្ហីករណ៍ទាំងអម្បាលម៉ានដែលបានលើកមកបង្ហាញខាងលើ បញ្ជាក់ថាភាសាខ្មែរមានគុណសម្បត្តិនិងលទ្ធភាពគ្រប់គ្រាន់ឆ្លើយតបទៅនឹងលំហូរចូលនៃភាសាបរទេសមកក្នុងភាសាខ្មែរ។ អ្នកជំនាញភាសាអាចប្រើលទ្ធភាពទាំងនេះសម្រាប់បកប្រែពាក្យពីបរទេស ឬប្រសិនបើយើងខ្ចីភាសាគេទាំងដុល (loanword) មកប្រើ ក៏យើងអាចរក្សាលក្ខណៈសូរដើមនៃភាសាគេបានក្នុងកម្រិតមួយខ្ពស់ពោលគឺមិនឆ្ងាយពីសូរដើមប៉ុន្មានទេ។

រាល់ភាពមិនប្រក្រតីមួយចំនួននៃការប្រើភាសា ដែលបានលើកឡើងខាងលើគ្រាន់តែជាចំណែកតូចមួយនៃបញ្ហា ដែលបានកើតមានឡើងនៅក្នុងរង្វង់ភាសាខ្មែរតាំងពីពេលអតីតកាលរហូតដល់បច្ចុប្បន្នកាល។ មានមតិមួយចំនួនចាត់ទុកថា នេះជារឿងកំប៉ិកកំប៉ុក។ ម្ចាស់អត្ថបទយល់ថា ទោះជានេះជាបញ្ហាតូចក៏ពិតមែន ប៉ុន្តែគួរយល់ថា បញ្ហាតូចអាចពូតផ្តុំជាបញ្ហាធំបាន ប្រសិនបើគេមិននាំគ្នាព្យាយាមដោះស្រាយឱ្យទាន់ពេលវេលា។ បញ្ហាមួយចំនួនគួរត្រូវបានដោះស្រាយដោយរលូន ប្រសិនបើអ្នកជំនាញខាងភាសាឈរលើមូលដ្ឋានវិទ្យាសាស្ត្រ មានគោលការណ៍មាំទាំប្រកបដោយហេតុផលច្បាស់លាស់ ដោយវៀរលែងទំនោរគំនិតជាបុគ្គល ពិសេសត្រូវមានការសិក្សាស្រាវជ្រាវបន្ថែមឲ្យបានល្អិតល្អន់។ ការប្រើភាសាតាមតែអំពើចិត្តមិនបានផ្តល់ផលវិជ្ជមានដល់ភាសាប៉ុន្មានទេ មានតែជំរុញឱ្យភាសារេទៅរកវិបត្តិកាន់តែធ្ងន់ធ្ងរទៅៗ។ ការបង្កើតពាក្យស្អេកស្កះសម្រាប់បញ្ញត្តិមួយ មិនបានឆ្លុះបញ្ចាំងអំពីភាពសម្បូរបែបនៃភាសាទេ។ អ្វីដែលល្អ គឺការរិះរកបង្កើតអ្វីដែលថ្មីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ដើរឱ្យទាន់លំហូរចូលនៃភាសាបរទេសតាមរយៈបច្ចេកវិទ្យានាពេលបច្ចុប្បន្ន។

ការធ្វេសប្រហែសនឹងភាសារបស់ខ្លួននឹងនាំទៅរកការមិនឱ្យតម្លៃភាសាខ្លួន រហូតអ្នកខ្លះមានទស្សនៈថា ភាសានេះគ្មានវេយ្យាករណ៍ មានការកំណត់ន័យមិនច្បាស់លាស់ ពិសេសន័យនៅក្នុងសម្ព័ន្ធសាស្ត្រ។ ផ្ទុយទៅវិញអ្នកដែលមានទស្សនៈបែបនេះច្រើនតែជាអ្នកដែលមានទស្សនៈប្រសូត្រចេញពីការទន្ទេញតាមទស្សនៈជនជាតិបរទេសមួយចំនួនប៉ុណ្ណោះ គឺមិនមែនចេញពីការពិនិត្យពិច័យប្រកបដោយហេតុផលរបស់ខ្លួនទៅក្នុងភាសាទេ។ ប្រសិនបើការលើកឡើងនេះខុសពីការពិត សូមខន្តីអភ័យទោសផង ។

## សំណូមពរ

គួរមានការសិក្សាឱ្យបានទូលំទូលាយ ពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយមុននឹងសម្រេចលើបញ្ហានានាក្នុងរង្វង់ភាសា។ ការធ្វើឱ្យតែរួច ឬតាមមតិយល់ឃើញជាបុគ្គលិកនឹងនាំដល់ការរើុះគ្មានទីបំផុត និងនាំទៅវិបត្តិក្នុងបម្រើបម្រាស់ភាសា។

ពាក្យពីបរទេសទាំងឡាយ ប្រសិនបើអាចធ្វើបានគួរព្យាយាមបកប្រែពាក្យថ្មីទាំងនេះជាភាសាខ្មែរឱ្យអស់ពីលទ្ធភាព ព្រោះដូចដែលបានលើកឡើងខាងលើ ភាសាខ្មែរមានលទ្ធភាពគ្រប់គ្រាន់ក្នុងការឆ្លើយតបនឹងលំហូរចូលនៃបច្ចេកវិទ្យាថ្មី ដោយព្យាយាមលះបង់នូវទស្សនៈដែលតែងតែថា មិនដឹងថាអ្នកប្រើគេនឹងប្រើតាមដែរឬទេ ព្រោះពាក្យហ្នឹងគេនិយាយមួយនគរទៅហើយ តើប្រឹងប្រែធ្វើអីទៀតជាដើម។ តាមចំណេះដឹងពីរៀមច្បង បញ្ហាស្រដៀងគ្នានេះក៏បានកើតឡើងមិនតិចដែរនៅក្នុងគ្រាដែលខេមរយានកម្មកំពុងធ្វើនាពេលនោះ។ ក្នុងមោទនភាពជាតិ អ្នកជំនាញភាសាពិតប្រាកដគួរនាំគ្នាបកប្រែឱ្យអស់ពីលទ្ធភាពមុននឹងឈានទៅប្រើកម្ចីទាំងដុល និងកម្ចីបន្សាំ។

ពាក្យបរទេសដែលបកប្រែមិនបាន គួររក្សាជាតិសព្ទរបស់ពាក្យឱ្យស្ថិតនៅក្នុងកម្រិតអតិបរមា។ អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗនឹងមិនពិបាកសិក្សាស្វែងយល់អំពីប្រភពពាក្យទាំងនោះ។ អ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរក៏មានកម្ចីដោយរក្សាជាតិសព្ទរបស់ពាក្យមកហើយដែរ ដូចជាពាក្យ ស៊ីម៉ង់ត៍។ វិធីនេះក៏មានប្រើនៅក្នុងភាសាជាច្រើនផងដែរ។ ភ្ជាប់ទៅនឹងបញ្ហានេះ ពាក្យ cable គួរខ្ចីមកជា កាប្ល៍។

## គន្ថនិទ្ទេស

ក្រសួងអប់រំយុវជននិងកីឡា, *គណិតវិទ្យាថ្នាក់ទី១១*, ភ្នំពេញ : ក្រសួងអប់រំ, ២០០៦;

ក្រសួងអប់រំយុវជននិងកីឡា, *សៀវភៅកុំព្យូទ័រសម្រាប់បង្រៀននិងការរៀន* បោះពុម្ពលើកទី១, ភ្នំពេញ : ក្រសួងអប់រំ, ២០០៨;

គណៈកម្មការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា. *សទ្ទានុក្រមវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា*. ភ្នំពេញ : ក្រុមប្រឹក្សាជាតិភាសាខ្មែរ, ២០១៤;

ជុំ ស៊ុនណាង, "ឥទ្ធិពលនៃការប្រើប្រាស់ពាក្យ 'អង្គរ' នៅក្នុងសង្គមខ្មែរ" អត្ថបទអន្តរាគមន៍នៅក្នុងសន្និសីទអន្តរជាតិលើកទី៤ ស្ដីពី*តម្លៃវប្បធម៌អាស៊ីអាគ្នេយ៍៖ អង្គរជានិមិត្តរូបនៃកិត្យានុភាពវប្បធម៌ក្នុងតំបន់អាស៊ីអាគ្នេយ៍*, ១៥-១៦ ធ្នូ ២០០៨, ១២៩-១៤០, ភ្នំពេញ : រាជបណ្ឌិតសភាកម្ពុជា;

ជុំ ស៊ុនណាង, *ការសិក្សាប្រៀបធៀបព្យញ្ជនៈជនិតក្នុងភាសាខ្មែរនិងថៃ*, នៅក្នុងទស្សនាវដ្ដីម្សៅសារ, ឆ្នាំទី១២ ច្បាប់ទី២ (កក្កដា-ធ្នូ) ទំព័រ១៧-៣៨. បុរីរម្យ : សាកលវិទ្យាល័យរាជភ័ដ្ឋបុរីរម្យ, ២០១៤;

តិប យក់ និង ថាវ គន្ធ. *វចនានុក្រមតូច បារាំង-ខ្មែរ*. ភ្នំពេញ : បណ្ណាគារភ្នំពេញ, ១៩៦៧;

នេត បារ៉ុម. *វិធីសាស្ត្រស្រាវជ្រាវឆ្ពោះទៅការរៀបចំនិក្ខេបបទ*, ភ្នំពេញ : រាជបណ្ឌិត្យសភាកម្ពុជា;

ពុទ្ធសាសនបណ្ឌិត្យ, *វចនានុក្រមភាសាខ្មែរ* ភាគទី១និងទី២, ភ្នំពេញ : ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧;

ព្រះបរមរាជវាំង. *ព្រះរាជក្រឹត្យស្ដីពីការផ្ដល់ឋានៈសាស្ត្រាចារ្យ*(២៣ មករា ២០១៣);

មិនស្គាល់អ្នកនិពន្ធ. *អនុវចនានុក្រមបារាំង-ខ្មែរ-តូច Petit dictionnaire franco-khmer*, ភ្នំពេញ : បណ្ណាគារភ្នំពេញ៥៩ប៉ាស្ទ័រ, ១៩??;

រ.គោរិទ. *វចនានុក្រមពាក្យថ្មី*. ភ្នំពេញ, ១៩៦១;
វិទ្យាស្ថានខេមរយានកម្ម, *សទ្ទនុក្រមខេមរយានកម្ម*, ភ្នំពេញ : ១៩៧២;
វិទ្យាស្ថានភាសាជាតិ. *វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ*. ភ្នំពេញ : ការផ្សាយរបស់វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា, ២០០៥;
អៀវ កើស, *ភាសាខ្មែរ ការល្បងពិនិត្យដោយរកហេតុផល*, បណ្ណាគារមូលមិត្ត ភ្នំពេញ ១៩៦៧។
Chom Sonnang, *The Consonant Adaptation of Khmer Loanwords in Thai: Based on the Optimality Theory*, Mahasarakham: Mahasarakham University, 2016;
David Crystal. *Language Death*. Cambridge: Cambridge University Press, 2000.
Google. *Google Search* (ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៨);
Headleay, Robert K. *Cambodian-English Dictionary*. Washington, DC.: The Catholic University of America Press, 1977;
http://dict.antkh.com/dictionaries/software.aspx (Retrieved: 5 January 2016);
Huffman, Franklin E. An Outline of Cambodian Grammar. Doctor's Thesis. Cornell University, 1967;
Huffman, E. Franklin. *វិជ្ជាខេមរភាសា Modern Spoken Cambodian.* New York: Cornell University, 1970;
Huffman, Franklin E. English-Khmer Dictionary (with phonetic symbol). Yale University Press, 1978;
Jacob, Judith M. *Cambodian Linguistics, Literature and History*. London: School of Oriental and African Studies, 1993;
Longman, *Longman Dictionary of Contemporary English*, New edition, Essex: Longman Group UK Limited, 1992;
Madeline E. Ehrman and others, *Contemporary Cambodian: Grammatical Sketch*, Wasington, D.C.: Foreign Service Institute, 1972;
Maspéro, Georges. *Grammaire de la langue khmère*. Paris: École française d'Extrême-Orient, 1915;
Prakorb Phon-ngam. *A Phonology Comparison of Spoken Central Khmer (Phnom Penh) and Nothern Khmer (Surin)*. M.A.'s Thesis. Bangkok: Mahidol University, 1987;
Smalley, William A. *Linguistic Diversity and National Unity Language Ecology in Thailand*. London: The University of Chicago Press, 1994.

# ន័យ អត្ថន័យ បំណកស្រាយន័យក្នុងទិដ្ឋភាពអក្សរសាស្ត្រនូវសុភាសិតបុរាណខ្មែរ «កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប»

បណ្ឌិត ជួរ គារី
ប្រធានវិទ្យាស្ថានភាសាជាតិ

## សេចក្តីផ្តើម

ដោយមើលឃើញការប្រព្រឹត្តរបស់កូនចៅជំនាន់ក្រោយនៅតែដើរជាន់ដាននូវអ្វីដែលដូនតាខ្មែរ បានហាមប្រាម ខ្ញុំក៏បាននឹកឃើញដល់សុភាសិតមួយឃ្លាដែលបុរាណលោកលើកឡើង «កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប»នេះដែលមានន័យហាមប្រាមដាច់ខាតកុំឱ្យកូនចៅប្រុសស្រីប្រព្រឹត្តដូចសត្វទាំងពីរ។ ការយល់ទៅដល់គំនិតនៃការអប់រំរបស់សុភាសិតនេះ ខ្ញុំក៏បានសាកល្បងវិភាគវែកញែកផ្ទុះបញ្ចាំងពីសភាពពិតនៃសកម្មភាពរបស់សត្វទាំងពីរ ទៅនឹងការប្រព្រឹត្តរបស់កូនចៅប្រុសស្រី ហើយបានបកស្រាយទៅតាមលំដាប់លំដោយមានន័យសេចក្តី ដូចខាងក្រោមនេះ។

## កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប

*កុំស្លាប់ដូចពស់* តើសត្វពស់ស្លាប់ដោយរបៀបណាខ្លះ? តើគុណវិបត្តិនៃរូបរាងកាយរបស់សត្វពស់និងឥរិយាបថរស់នៅរបស់សត្វពស់មានគុណវិបត្តិបែបណាទៅ ទើបបុរាណលោកប្រដៅកុំឱ្យកូនចៅស្លាប់ដូចសត្វពស់បែបនេះ? និង កុំឱ្យរស់ដូចសត្វកង្កែបបែបនេះ?

**ន័យត្រង់(ន័យអត្ថានុរូប)**

ជាទូទៅសត្វពស់មានពីរប្រភេទគឺ ពស់មានពិសនិងពស់អត់ពិស។ សត្វពស់មានពិសជាសត្វដែលកាចសាហាវព្រហើន កោងកាច ធ្វើឱ្យអ្នកផងតែងតែខ្លាចអាសត្វនេះចឹកឬខាំពេលវានៅរស់។ នៅពេលវាស្លាប់ទៅ មនុស្សក៏នៅតែខ្លាចឆ្អឹងឬធ្មេញរបស់វាទៀត ព្រោះអាចមានពិសនៅជាប់នឹងឆ្អឹងនោះ នៅពេលមុត គឺអាចនឹងស្លាប់បានដែរ។ សត្វពស់មានពិសវាអាចចិកឬខាំសម្លាប់គេភ្លាមៗ ហេតុនេះនៅពេលមនុស្សបានជួបវា តែងតែដេញវាយសម្លាប់ចោលមិនទុកឱ្យវារស់នៅឡើយ។ រីឯសត្វពស់គ្មានពិសដូចជា*ពស់ព្រលិត ពស់ថ្លាន់* ជាដើម គឺជាពពួកសត្វពស់ដ៏ស្លូត មនុស្សចាប់ឬសម្លាប់បានគ្រប់ពេល គឺជាសត្វដែលស្លូតស្លាប់ខ្លួនដូចពាក្យខ្មែរមួយឃ្លាលើកឡើងថា*ស្លូតស្លាប់* ។ ដូចនេះ សត្វពស់ទាំងពីរប្រភេទនេះ ទាំងកាចទាំងស្លូតអាចស្លាប់ខ្លួនបានគ្រប់ពេល គឺគេតែងតែតាមសម្លាប់ពួកវាគ្រប់កន្លែងនៅពេលបានជួប។

មួយវិញទៀត ធម្មជាតិរបស់សត្វពស់រស់នៅតែងតែចោលដានជានិច្ច។ ដល់វេលាសក វាតែងចោលសំណកនៅតាមទីដែលវាបានវារចេញចូល។ ពេលលូនក៏ដូច្នោះដែរ វាតែងតែចោលដានឬស្នាមនៅលើដីជានិច្ច ជាពិសេសនៅលើដីផុសៗប្រភេទដីល្បាយខ្សាច់។ តាមរយៈដានទាំងនេះ មនុស្សអាចដឹងថាមានសត្វពស់រស់នៅទីនេះមានទំហំប៉ុណ្ណាៗជាប្រភេទពស់អ្វីថែមទៀតផង រួចហើយមនុស្សនឹង

តាមដាននឹងរកឃើញសត្វពស់បានដោយងាយ។ ពេលនោះ សត្វពស់នឹងស្លាប់ខ្លួនតាមរយៈស្លាកស្នាមដែលខ្លួនបានបន្សល់ទុក។

ធម្មជាតិនៃសត្វពស់មានដងខ្លួនវែងដែលជាគុណវិបត្តរបស់សត្វនេះ។ នៅពេលមានការប្រយុទ្ធគ្នា គូសត្រូវអាចវាយប្រហារត្រង់កន្លែងណាក៏បានឬសត្រូវងាយស្រួលខ្លាំងក្នុងការតាមសម្លាប់។ ពាក្យបុរាណខ្មែរបានពោលមកថា« *ទុកគេទុកខ្លីងាយនឹងបត់បែន ទុកឯងទុកវែងពិបាកនឹងបត់បែនតាម*»។

ពស់ក៏ជាសត្វដែលចូលចិត្តប្រយុទ្ធជាមួយនឹងគ្នាឯង ហើយខាំស៊ីគ្នាឯងជាអាហារ ដោយគ្មានត្រាប្រណី។ គឺពស់ស្លាប់ខ្លួនព្រោះតែខាំស៊ីគ្នាឯង សម្លាប់ពូជឯង។

លក្ខណៈម្យ៉ាងទៀត ការស្លាប់របស់សត្វពស់ គឺនៅពេលគេវាយ វាមិនងាយនឹងបញ្ចេញសម្រែកឱ្យឮដូចសត្វដទៃទេឡើយ ទោះបីវាយវារហូតដល់ស្លាប់ខ្លួន ក៏វាស្រែកមិនឮដែរ។

សត្វពស់ស៊ីចំណី ដូចជា ឈ្លូស ប្រើស ក្តាន់ រមាំង ជាដើម ទាំងមូលមិនមានបន្សល់ទុកកាកសំណល់អ្វីឱ្យកូនចៅឬសត្វដទៃស៊ីឡើយ។ ពេលខ្លះ វាស៊ីទាល់តែធ្លាយពោះ ហើយលេបទាំងពោះទៀតផង នៅពេលដែលសត្វវាបានស៊ីនោះហើមលេបយ។

មើលឃើញចំណុចអវិជ្ជាមានក្នុងការរស់នៅរបស់សត្វពស់បែបនេះ ទើបចាស់បុរាណលោកប្រដៅកូនចៅ រស់នៅត្រូវប្រយ័ត្នខ្លួន *កុំឱ្យស្លាប់ដូចសត្វពស់*។

**ន័យធៀប(ន័យអត្ថបដិរូប)**

ចាស់បុរាណលោកប្រដូចនឹងមនុស្សណាដែលមានចរិតកំណាចឃោរឃៅ អាងកាប់អាងចាក់សម្លាប់ រស់នៅដើររាតត្បាតធ្វើទុកបុកម្នេញគេឯង រស់នៅបំផ្លាញសង្គមជាតិ។ មនុស្សប្រភេទនេះ អ្នកផងគេស្អប់ គេខ្ពើមមិនចង់ឱ្យរស់នៅជិតឡើយ។ ពេលខ្លះ ដោយសារតែអំពើកំណាចរបស់ខ្លួន អ្នកដទៃអាចតាមយាយីយកជីវិតក៏មាន។ មនុស្សប្រភេទនេះ ទោះបីមិនទាន់ស្លាប់ក៏គេឯងបន់ឱ្យតែស្លាប់ឆាប់ដែរ ហើយកុំថាឡើយនៅរស់ដែលគេមិនចង់ជួបមុខ សូម្បីស្លាប់ទៅហើយក្តី ក៏គេនៅតែស្អប់មិនចង់ឃើញសាកសពដែរ ហើយមនុស្សប្រភេទនេះ គេឃើញមានជាហូរហែនៅតាមស្រុកភូមិមួយចំនួននិងនៅបណ្តាប្រទេសមួយចំនួនផងដែរ។ ម្យ៉ាងទៀត មនុស្សណាដែលស្លូតខ្លាំងពេក គេតែងតែធ្វើបាប គេតែងតែជិះជាន់តាមអំពើចិត្ត ទោះបីគេមកកាប់សម្លាប់ ធក់ប្លន់ ក៏មិនហ៊ានតដៃទៅគេវិញដែរ ដែលបុរាណលោកតែងពោលមកថា «*ស្លូតស្លាប់*» គឺបុរាណលោកប្រដូចទៅនឹងសត្វពស់ដែលគ្មានពិសនេះឯង។

បុរាណលោកប្រដៅកូនចៅជំនាន់ក្រោយធ្វើអ្វីៗនៅក្នុងជីវភាពរស់នៅត្រូវតែចេះលាក់កំបាំងឬលាក់ការណ៍សម្ងាត់ ពិសេស អ្នកដែលជាមេគេ អ្នកដឹកនាំគេ ធ្វើការអ្វីនីមួយៗ កុំបន្សល់ទុកនូវដានឱ្យសត្រូវរបស់ខ្លួនចាប់ចំណុចខ្សោយបានឱ្យសោះឬហៅថាបែកការណ៍សម្ងាត់ បើមិនដូច្នោះទេ មុខជាស្លាប់ខ្លួនឬបរាជ័យក្នុងមុខរបរណាមួយ បើបែកការណ៍សម្ងាត់របស់ប្រទេសជាតិ ជាតិនឹងបរាជ័យវិនាសដល់នគរនិងប្រជារាស្ត្ររងទុក្ខវេទនាខ្លោចផ្សាជាក់ជាមិនខាន ប្រៀបដូចជាសត្វពស់ដែលមនុស្សអាចដឹងបានតាមរយៈការបន្សល់ស្លាកស្នាម ការចោលសំណាក ការចោលដានរបស់វា ដូច្នោះដែរ។

នៅពេលប្រទេសជាតិមានកើតភាន់ប្រែផ្លាស់ប្ដូររបបសង្គមឬផ្លាស់ប្ដូរអ្នកដឹកនាំម្ដងៗ ចាស់ៗតែងនិយាយថា *ទូកគេខ្លីងាយស្រួលបត់បែន* រីឯ *ទូកឯងវែងពិបាកបត់បែនតាម* ។ ក្នុងន័យនេះហើយដែលអ្នកដឹកនាំជាតិ ក៏ដូចជាប្រជារាស្ត្រសាមញ្ញ ត្រូវតែចេះស្វែងយល់ពីមាគ៌ានយោបាយ ច្បាប់ទម្លាប់របស់ប្រទេសជាតិឬអន្តរជាតិឱ្យបានច្រើននិងទូលាយ កុំងប់ងល់នឹងមនោគមវិជ្ជាណាមួយឱ្យសោះ។ ទាំងអស់គ្នាត្រូវតែរៀនស្វែងយល់ពីសភាពការណ៍ស្រុកទេសក៏ដូចជាពិភពលោក ទើបការរស់នៅអាចបត់បែនទៅតាមសភាពការណ៍ដែលបម្រុងនឹងកើតឬកំពុងនឹងកើតឡើងបាន។ ប្រសិនបើយើងមិនតាមដានសភាពការណ៍នយោបាយ របបសង្គម និងសេដ្ឋកិច្ចរបស់ស្រុកទេសនិងពិភពលោកទេ យើងមិនអាចតាមទាន់សភាពការណ៍ប្រទេសនិងពិភពលោកបានឡើយ។ ករណីសង្គ្រាមដែលកើតឡើងនៅស្រុកខ្មែរក្នុងទសវត្សរ៍នៃឆ្នាំ១៩៧០ បើតាមសាស្ត្រាចារ្យប្រវត្តិវិទ្យាក៏ដូចសាស្ត្រាចារ្យវិទ្យាសាស្ត្រនយោបាយមួយចំនួន លោកបានលើកឡើងថា ខ្មែរយើងជំនាន់នោះតាមសភាពការណ៍របស់ពិភពលោកមិនទាន់ ទើបបង្កឱ្យមានសង្គ្រាមក្នុងស្រុកកើតឡើង...។ ប្រៀបបាននឹងសត្វពស់មានដងខ្លួនវែងដែលពិបាកនឹងរត់គេចខ្លួនឬការពារខ្លួននៅពេលប្រយុទ្ធជាមួយសត្រូវដូច្នោះឯង។

សត្វពស់វាខាំស៊ីតែគ្នាឯង បុរាណលោកប្រដៅកូនចៅកុំឱ្យស្លាប់ដូចពស់បែបនេះ ក្នុងសង្គមជាតិតែមួយ កូនចៅត្រូវចេះសាមគ្គីរួបរួមគ្នា កុំឈ្លោះគ្នា ស៊ីតែពីគ្នាឯងឬស៊ីពីជាតិឯង ពុករលួយឬកេងប្រវញ្ចពីសង្គមជាតិ កុំកាប់សម្លាប់តែគ្នាឯង ព្រោះតែគំនុំគុំកួន ពីព្រោះតែការងប់នឹងមនោគមវិជ្ជាបរទេស ពីព្រោះតែលាភសក្ការៈផ្ទាល់ខ្លួនមកបំផ្លាញគ្នា សងសឹកគ្នា បណ្ដាលឱ្យកិច្ចការប្រទេសជាតិមិនដំណើរការ ខូចការ ឬអន្តរាយដល់នគរ... ដូចនៅក្នុងសម័យប៉ុល ពត គឺខ្មែរសម្លាប់ខ្មែរនេះហើយដែល *ស្លាប់ដូចពស់* នោះ។ សង្គមជាតិមួយត្រូវមានឯកភាពជាតិជាដរាប មិនត្រូវបែកបាក់គ្នាបង្កឱ្យទៅជាពួកនេះ ក្រុមនោះ ប្រកាន់ឯងអញ ឈ្លោះទាស់ទែងបង្កទំនាស់នឹងគ្នាដែលនាំឱ្យបែកបាក់សាមគ្គីទាំងនៅមូលដ្ឋាន ភូមិ-ឃុំ ទាំងនៅក្នុងសង្គមជាតិ។ល។

ការដែលគេវាយសម្លាប់សត្វពស់ វាមិនបានស្រែកឬបន្លឺសំឡេងឱ្យឮនោះទេ បុរាណលោកប្រដៅមនុស្ស កុំឱ្យស្លាប់បែបនេះ ប្រសិនបើមានអំពើជិះជាន់កេងប្រវញ្ច ជញ្ជក់ឈាម ធ្វើបាប ឆក់ប្លន់ ឬឯការជិះជាន់ពីបរទេសណាមួយ យើងត្រូវតែចេះស្រែកតវ៉ា រើបម្រះ ដើម្បីឱ្យគេឯងបានដឹងឮ ត្រូវរត់រកផ្លូវច្បាប់ជាតិឬអន្តរជាតិមកគាំពារ មិនត្រូវសំងំស្ងៀមឱ្យគេរំលោភបំពានតាមអំពើចិត្តនោះទេ។ ដូចសម័យប៉ុល ពត មានការកាប់សម្លាប់ប្រជាជនខ្មែរទូទាំងប្រទេស តែមានវីរជនខ្មែរមួយក្រុមមានសម្ដេចធម្មពោធិសាល **ជា ស៊ីម** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** សម្ដេចពញ្ញាចក្រី **ហេង សំរិន** ពួកលោកបានរត់ចេញក្រៅប្រទេស ហៅមិត្តភក្តិបរទេសមកជួយរំដោះប្រជាជនពីការកាប់សម្លាប់របស់ពួកប៉ុល ពត គឺបានសេចក្ដីថា ពួកលោកមិនសុខចិត្តស្លាប់ដោយគ្មានសម្រែកដូចសត្វពស់នោះទេ។ ផ្ទុយទៅវិញ ប្រជាជន បញ្ញវន្ត អ្នកតស៊ូខ្មែរដ៏ច្រើនដែលពួកឈ្លបប៉ុលពតចាប់ចងម្ដងម្នាក់ៗ យកទៅសម្លាប់ មិនដែលហ៊ានស្រែកតវ៉ាចំពោះការកាប់សម្លាប់នោះឡើយ ទោះបីជាដឹងខ្លួនថា គេនឹងយកខ្លួនទៅសម្លាប់ឥឡូវហើយក្ដី គឺអ្នកទាំងនោះសុខចិត្តស្លាប់ខ្លួន ប្រៀបដូចសត្វពស់ដែលមិនហ៊ានស្រែកនេះ

ឯង។ បញ្ហានេះហើយដែលបុរាណលោកប្រដៅកូនចៅ *កុំឱ្យស្លាប់ដូចពស់* គឺស្លាប់ដោយស្ងៀមស្ងាត់ មិនមានការតវ៉ាអ្វីសោះ សុខចិត្តសំងំឱ្យគេសម្លាប់ រំលោភបំពានតាមអំពើចិត្ត ដោយមិនស្រែកតវ៉ារកខុសត្រូវឬរកយុត្តិធម៌។

លោកប្រដៅកូនចៅនៅពេលបានទទួលប្រយោជន៍ឬលាភសក្ការៈអ្វីៗ ត្រូវចេះចែករំលែកដល់គ្នីគ្នា កុំលោភលន់ហួសហេតុ កុំកេងប្រវ័ញ្ចជញ្ជក់ឈាមជាតិនិងប្រជាជនយកទៅធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនឯង ប្រយ័ត្នប្រជាជនឬផ្លូវច្បាប់រកខុសត្រូវ ត្រូវស្អុយឈ្មោះ ស្លាប់ទាំងកេរ្តិ៍ឈ្មោះស្លាប់ទាំងខ្លួន ប្រៀបដូចជាសត្វពស់ដែលវាស៊ីចំណីទាល់បែកពោះឬពេលចំណីនោះវាហើមឡើង ពោះរបស់សត្វពស់ក៏ឡើងប៉ោងធ្លាយធ្លុះរលេះរលួយទាំងរំពា រលួយទាំងខ្លួនពស់ អាចស្លាប់ខ្លួនដោយសារតែស៊ីចំណីមិនដឹងប្រមាណខ្លួនឬដោយសារតែការលោភលន់គ្មានព្រំដែន ប្រព្រឹត្តតែអំពើពុករលួយរហូតអន្តរាយដល់ប្រទេសជាតិ សង្គមជាតិក៏នៅតែប្រព្រឹត្តអំពើពុករលួយ កេងប្រវ័ញ្ចពីជាតិមិនឈប់ឈរ។

### *កុំរស់ដូចកង្កែប*

តើសត្វកង្កែបវារស់នៅបែបណា ទើបបុរាណលោកប្រដៅ កូនចៅ កុំឱ្យរស់ដូចសត្វមួយនេះ?

**ន័យត្រង់(ន័យអត្ថានុរូប )**

ជីវិតសត្វកង្កែបរស់នៅទីណាក៏បានដែរ លើគោក ក្នុងទឹក ក្រោមភក់ ក្រាំងក្នុងដី ក្រោមកន្សៀតថ្ម ក្រោមគំនរសម្រាម ។ល។ គឺទីណាដែលមានសំណើម...។

សត្វកង្កែបមិនចេះធ្វើរូងដោយខ្លួនឯងនោះទេ វារស់នៅអាស្រ័យតែជាមួយនឹងរូងក្តាម សំឡេងស្រែករបស់វាបង្កទុក្ខលំបាកដល់សត្វក្តាមដែលមិនមានសម្រេក។

នៅក្នុងវាលស្រែមានសត្វកង្កែបតែពីរបីក្បាល វាស្រែកទ្រហឹងប្រៀបដូចមានច្រើនរយក្បាល អ៊ឹបឹង។

តាមកត្តាជីវសាស្ត្រ សត្វកង្កែបគ្មានឃានវិញ្ញាណទេ ប្រមុះវាមិនដឹងក្លិនអ្វីទាំងអស់។ វារស់នៅក្នុងបឹងឈូក តែវាមិនដែលស្គាល់ក្លិនក្រអូបនៃផ្កាឈូកដូចម្តេចឡើយ។

នៅពេលមានភ្លៀងធ្លាក់ដើមឆ្នាំ សត្វកង្កែបសប្បាយភ្លេចខ្លួន (គេច្រើននិយាយថា *កង្កែបពុល* ) ព្រានដើរឆ្លុះយកច្បូកចាក់ឬដើរចាប់ដាក់ក្នុងទ្រុង ក៏សត្វនេះមិនខ្លាចសេចក្តីស្លាប់ដែរ វាពោបពីលើគ្នាហើយនៅតែស្រែក អូប!អូប! កូប!កូប! យ៉ាងគ្រេកគ្រអាលមិនឈប់។

**ន័យធៀប(ន័យអត្ថបដិរូប)**

បុរាណលោកប្រដៅកូនចៅកុំឱ្យរស់នៅបែបសត្វកង្កែបនោះគឺ មុនដំបូងមនុស្សត្រូវមានទីលំនៅ(អសយដ្ឋាន)មានជម្រកពិតប្រាកដៗ កុំឱ្យរស់នៅទីណាក៏បាន តាមសំយាបផ្ទះផ្សារក៏បាន តាមចិញ្ចើមផ្លូវក៏បាន តាមវត្តលោកក៏បាន...។ល។ បើមានជម្រកហើយ ជម្រកត្រូវបិទបាំងជញ្ជាំងមានដំបូលគត់មត់ល្អមិនឱ្យមានធ្លុះធ្លាយ នោបក្តី ជណ្តើរក្តី ប្រសិនបើវាបាក់បែកត្រង់ណា ត្រូវតែជួសជុលវិញភ្លាម មិនត្រូវរស់នៅទាំងបាក់បែកធ្លុះធ្លាយនោះឡើយ។ មនុស្សរស់នៅត្រូវចេះរៀបចំទ្រព្យសម្បត្តិ

ក្នុងផ្ទះឱ្យមានរបៀបរៀបរយ បោសសម្អាតផ្ទះសម្បែងជាអលជ្ជី មិនត្រូវទុកផ្ទះសម្បែងឱ្យមានដី ធូលី សម្បុកពីងពាងស្រកេកស្រកាក ដោយរស់នៅរុលទាំងសម្បុកពីងពាង ទាំងធូលីដីនោះទេ។ ការស្លៀកពាក់ក៏ដូច្នោះដែរ ត្រូវតែចេះប្រិតប្រៀងសម្អិតសម្អាតនិងត្រូវចេះរៀបចំខ្លួនប្រាណឱ្យបានស្អាតបាតជានិច្ច កុំចេះតែខ្ជីខ្ជា កុំចេះតែយល់ថាមិនអី។

បុរាណប្រដៅកូនចៅ កុំរស់នៅយ៉ាងម៉េចក៏បាន បែបម៉េចក៏បាន របៀបសត្វកង្កែបបែបនេះ ព្រោះវាមិនមានសេចក្ដីសុខ សេចក្ដីចម្រុងចម្រើន និងសិរីសួស្ដីនោះទេ។

បុរាណលោកអប់រំកូនចៅក្នុងការរស់នៅត្រូវមានជំហររឹងប៉ឹង មិនត្រូវពឹងផ្អែកលើគេនោះទេ ហើយបើមានពឹងពាក់ឱ្យគេជួយយកអាសាខ្លួន ក៏មិនត្រូវបង្កការលំបាកដល់គេឯងឬអ្នកដែលជួយយកអាសាយើងនោះដែរ។ ម្យ៉ាងទៀត រស់នៅជាមនុស្សមិនត្រូវមាត់កោកកាកឥតប្រយោជន៍នាំឱ្យខាតលាភសក្ការៈរបស់អ្នកដទៃ ប៉ះពាល់ដល់គេឯងឬសង្គមជាតិ នាំឱ្យខាតលាភ ខាតប្រយោជន៍ ដោយសារតែមាត់ឥតគម្របរបស់ខ្លួននោះទេ។ ពេលខ្លះអាចស្លាប់ខ្លួនព្រោះតែមាត់មិនបានការនេះឯង។ ពេលខ្លះរស់នៅក្នុងសង្គមជាតិ មិនត្រូវហែកហួគ្នាយករឿងជាតិមកបង្ហាញជាសាធារណៈនោះទេករណីដូចជាអ្នកមានសិទ្ធិបញ្ចេញសំឡេងផ្សព្វផ្សាយទូលាយមាន អ្នកព័ត៌មាន អ្នកនិពន្ធ អ្នកនយោបាយ ឬប្រជារាស្ត្រក្នុងនគរក្ដី មិនត្រូវយករឿងឬកិច្ចការងាប់រស់របស់នគរ របស់ជាតិសាសន៍ខ្លួនមកលាតត្រដាងព្រោះតែផលប្រយោជន៍របស់ខ្លួនមួយក្ដាប់តូចឬបក្សពួកខ្លួនមួយក្រុមណានោះទេ យើងត្រូវដឹងថា រឿងខ្លះជារឿងត្រូវតែសំងំលាក់ទុក មិនត្រូវបញ្ចេញជាសាធារណៈនោះឡើយ ទោះបីរឿងនោះជារឿងពិតឬរឿងដែលខ្លួនបានដឹងច្បាស់ក៏ដោយ តែដើម្បីផលប្រយោជន៍ជាតិទាំងមូល យើងមិនគប្បីលើកយកមកនិយាយដើម្បីចំណេញហោប៉ៅខ្លួនតែម្នាក់នោះទេ។ ករណីសត្វកង្កែបដែលរស់នៅក្នុងរូងក្ដាមឬត្រពាំងមួយមានកង្កែបតែពីរឬបីក្បាលស្រែកឮរំពងពេញត្រពាំង បឹងបួ ធ្វើឱ្យព្រានដើរចាប់ខ្វារដោយមកបានទាំងកង្កែប ទាំងក្ដាម ងាប់អសារបង់។

លោកចង់ប្រដៅកូនចៅប្រុសស្រីថា បើម៉ែឪឱ្យទៅសិក្សារៀនសូត្រ ត្រូវតែចេះត្រងត្រាប់ស្ដាប់គ្រូបាអាចារ្យ ខិតខំប្រឹងប្រែងដោយយកចិត្តទុកដាក់ក្រេបជញ្ជក់យកចំណេះពីលោកឱ្យបាន កុំខ្ជិលឡេះឡោះ។ ម្យ៉ាងវិញទៀត កាលបើរស់នៅជិតអ្នកចេះដឹងឬអ្នកប្រាជ្ញបណ្ឌិត យើងត្រូវតែខិតខំសិក្សារៀនសូត្រស្វែងយល់ពីអស់លោកទាំងនោះ ដោយត្រូវក្រេបជញ្ជក់យកចំណេះដឹងពីអស់លោកអ្នកប្រាជ្ញទាំងនោះឱ្យបាន កុំធ្វើឡេះឡោះចោលម្សៀត។ កាលបើបានរស់នៅជាមួយឬនៅជិតអ្នកចេះដឹងឬអ្នកប្រាជ្ញហើយ បែរជាមិនខិតខំស្វាធ្យាយយកចំណេះដឹងទុកក្នុងខ្លួន គឺប្រៀបដូចជាសត្វកង្កែបដែលវារស់ក្នុងបឹងឈូក តែមិនស្គាល់ក្លិនផ្កាឬគន្ធពិដោរដ៏ក្រអូបនៃផ្កាឈូកនេះសោះ។ ការសិក្សារៀនសូត្រទីនេះ គឺមិនសំដៅតែទៅលើការសិក្សានៅតាមសាលានោះទេ ចំណេះដឹងមាននៅគ្រប់ទីកន្លែង នៅជិតអ្នកមានចំណេះអ្វីមួយ យើងត្រូវចេះសង្កេតពិនិត្យត្រងត្រាប់តាម យកចំណេះនោះមកដាក់ក្នុងខ្លួន រួមទាំងគំនិតគេផងដែរ។ ត្រូវចេះសង្កេតនិងរៀនសូត្រពីសង្គមដែលខ្លួនកំពង់រស់នៅ មិនត្រូវព្រងើយកន្តើយក្នុងការតាមដានព័ត៌មានសង្គម ឥរិយាបថសង្គម ទំនោរសង្គមនោះទេ។

ក្នុងការរស់នៅ ចាស់បុរាណលោកហាមមិនឱ្យកូនចៅសប្បាយភ្លេចខ្លួន ភ្លើតភ្លើនទៅតាមអ្វីដែលជាមនោគមវិជ្ជាបរទេស វប្បធម៌បរទេសដែលមិនមែនជារបស់ជាតិខ្លួន មានដូចជា វប្បធម៌ពាលាអាវាសែ ប្រើប្រាស់ថ្នាំញៀន ស្លៀកសម្លៀកបំពាក់ប្រាសចាកប្រពៃណីជាតិ ឈ្លក់វង្វេងនឹងរបស់របរបរទេស សម្ភារៈនិយម ផឹកស៊ីមិនគិតរកស៊ី ផឹកស៊ីមិនខ្លាចខ្លួនក្រ ផឹកស៊ីមិនខ្លាចឈឺស្លាប់ បង្កើតបនបារឬចូលបនបារ ...។ល។ ដោយមិនគិតពីរឿងការងារ ប្រកបរបររកស៊ីចិញ្ចឹម គ្រួសារឬមិនអើពើនឹងកិច្ចការរួមរបស់សហគមន៍ឬប្រទេសជាតិ ជាដើម។ ការរស់នៅសប្បាយមិនដឹងស្លាប់ខ្លួន មិនដឹងស្លាប់ជាតិយ៉ាងនេះឯង ទើបចាស់ទុំបុរាណលោកហាមដោយប្រើពាក្យថា *«កុំ»* គឺ កុំឱ្យរស់នៅដូចសត្វកង្កែបដែលសប្បាយមិនដឹងស្លាប់ ទោះបីជាព្រានចាប់ដាក់ក្នុងទ្រុងហើយក្តី ក៏នៅតែសប្បាយដោយញីឈ្មោល ពពាក់ពពូនពីលើគ្នា ស្រែកបង្អូក អូក!អូក! អែប!អែប! ពេញទ្រុងព្រាន។

**សរុបមក**

ពាក្យសុភាសិតនេះ លោកប្រៀនប្រដៅដល់យើងគ្រប់គ្នាកុំឱ្យមានឥរិយាបថនិងរបៀបរស់នៅដូចសត្វទាំងពីរ ដោយលោកប្រើពាក្យថា *កុំឱ្យស្លាប់* និង *កុំឱ្យរស់* ប្រសិនបើយើងរស់នៅប្រព្រឹត្តដូចសត្វទាំងនេះ ក្តីអន្តរាយនឹងកើតមានដល់ខ្លួន។ ជម្រៅនៃន័យសុភាសិតដូចសេចក្តីបកស្រាយខាងលើនេះ កូនចៅជំនាន់ក្រោយត្រូវជៀសវាងឱ្យបានជាដាច់ខាត ទើបការរស់នៅមានសេចក្តីចម្រុងចម្រើន៕

ថ្ងៃអង្គារ ១០កើត ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា គ.ស.២០១៧

# ការគ្រប់គ្រងដីធ្លីនៅប្រទេសកម្ពុជាសម័យបុរាណ

លោក កែវ លីណែត
មន្ត្រីវិទ្យាស្ថានភាសាជាតិ

## ១.០- សេចក្ដីផ្ដើម

ព្រះអង្គម្ចាស់ យុគន្ធរ ជាព្រះរាជបុត្រមួយព្រះអង្គរបស់ព្រះបាទ នរោត្តម។ ទ្រង់កត់សម្គាល់ទាក់ទងនឹងការគ្រប់គ្រងដីធ្លីនៅប្រទេសកម្ពុជាថា «កាលពីដើម ដីធ្លីទាំងអស់របស់គឺជាកម្មសិទ្ធិពេញច្បាប់របស់ព្រះមហាក្សត្រ។ តាមពិត វាជាកម្មសិទ្ធិរបស់អ្នកណាដែលកាន់កាប់ និងដែលដាំដុះវា»[1]។

ជាទូទៅ អ្នកប្រវត្តិសាស្ត្រតែងចែកព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្មែរមុនសម័យអង្គរជា២គឺ សម័យនគរភ្នំនិងសម័យចេនឡា។ សម័យនគរភ្នំមានក្សត្រចំនួន១០អង្គដែលលាតសន្ធឹងពីសតវត្សរ៍ទី១ដល់សតវត្សរ៍ទី៦, សម័យ ចេនឡាមានក្សត្រចំនួន៥អង្គដែលលាតសន្ធឹងពីសតវត្សរ៍ទី៦ដល់សតវត្សរ៍ទី៨។ ដោយឡែក សម័យអង្គរមានក្សត្រចំនួនជាង៣០អង្គដែលលាតសន្ធឹងពីសតវត្សរ៍ទី៩ដល់សតវត្សរ៍ទី១៥។[2]

ព្រះមហាក្សត្រជាមេដឹកនាំស្ថាប័នកំពូលរបស់ជាតិ។ ព្រះអង្គមានអំណាចគ្របដណ្ដប់លើផ្នែកសាសនានិងសង្គម។ នៅអំឡុងពេលនោះ, ជាពិសេស ពីសតវត្សរ៍ទី១ដល់ទី១៥, ប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍នេះទទួលឥទ្ធិពលលទ្ធិសាសនាពីប្រទេសឥណ្ឌា។ ការគ្រប់គ្រងរដ្ឋទទួលឥទ្ធិពលដោយផ្ទាល់ពីច្បាប់សាសនា។ លទ្ធិព្រាហ្មណ៍ក្ដីលទ្ធិពុទ្ធសាសន៍ក្ដីមានគម្ពីរក្បួនច្បាប់ ហើយ លទ្ធិទាំងនេះបានបែកញែកជានិកាយជាច្រើន។ លទ្ធិដើមនិងនិកាយទាំងនេះក៏មានឥទ្ធិពលនិងវត្តមានក្នុងប្រទេសកម្ពុជាដែរ។

យោងតាមច្បាប់ខាងលើ ព្រះរាជាមានកាតព្វកិច្ច គោរពសាសនា និង គ្រប់គ្រងចាត់ចែងលើអ្នកដែលស្ថិតក្នុងដែនអំណាច។ ទ្រង់មានកាតព្វកិច្ចធ្វើឱ្យប្រទេសជាតិនិងប្រជារាស្ត្ររស់នៅសម្បូរសប្បាយនិងការពារភយន្តរាយទាំងឡាយ។ ទ្រង់មានសិទ្ធិប្រទានដីធ្លីស្រែចម្ការច្បារដំណាំដល់ជនទាំងឡាយដែលមកសុំព្រះរាជទានឬមានគុណបំណាច់ក្នុងរាជការ។ «រាជសភា» នៅពេលនោះ ជាតុលាការដែលមានអំណាចកាត់ក្ដីទាំងផ្នែកព្រហ្មទណ្ឌទាំងផ្នែករដ្ឋប្បវេណី។ ដំណើរការក្ដីមានលំដាប់លំដោយរដ្ឋបាលពីថ្នាក់រាជធានីដល់ថ្នាក់ខេត្ត។

បុគ្គលណាម្នាក់ដែលកាន់កាប់ដីធ្លីមានសិទ្ធិលក់ដូរ ដោយប្រើរូបិយវត្ថុជាលោហៈ មានមាសប្រាក់ជាដើម និង ដោយដោះដូរនឹងវត្ថុដទៃជាចលនៈក្ដីអចលនៈក្ដី មានគោក្របីនិងគ្រឿងឧបភោគបរិភោគជាដើម។ សិទ្ធិនៃការកាន់កាប់ដីធ្លីមានលក្ខណៈពិសេសក្នុងប្រវត្តិសាស្ត្រខ្មែរ។ អ្នកមានដីធ្លីមាន

---

[1] ទីឃាយុ (ប្រែសម្រួល), *រឿងរ៉ាវរបស់ព្រះអង្គម្ចាស់ យុគន្ធរ (L'affaire Yukanthor: Autopsie d'un scandale colonial)*, ទំ.202។

[2] Cf. A. Dauphin-Meunier, *Histoire du Cambodge.* Paris : Presse universitaires de France, 1961; G. Coedès, *The Indianized States of Southeast Asia,* Walter F. Vella, ed. Sue Brown Cowing, trans. Honolulu: University of Hawaii Press, 1968.M. Giteau, *Histoire du Cambodge,* Paris : Didier, 1957.

សិទ្ធិគ្រប់គ្រងជារៀងរហូត គឺ ហួសពីរាជ្យដែលព្រះរាជាមួយព្រះអង្គសោយរាជ្យទៅទៀត។ តាមបែបសិលាចារឹក ដរាបណាព្រះអាទិត្យព្រះចន្ទ្រនៅតែមាន ដរាបម្ចាស់ដីមានសិទ្ធិគ្រប់គ្រងជានិច្ច។

យើងសង្កេតឃើញថា អ្នកមានដីធ្លីមិនមែនសុទ្ធតែវណ្ណៈអភិជនជាន់ខ្ពស់នោះទេ សូម្បីប្រជារាស្ត្រស្រទាប់ កណ្ដាលតាមខេត្តខណ្ឌដែលយើងអាចហៅថា កុដុម្ពីក៍ នោះក៏ទទួលបានសិទ្ធិនិងមានការគោរពសិទ្ធិគ្រប់គ្រងពីអាជ្ញាធររដ្ឋបាលដែនដីរបស់ខ្លួនរស់នៅ។ ក្នុងករណីនេះ យើងរាប់បញ្ចូលដីធ្លីស្រែចម្ការទាំងឡាយដែលជាដីពិសិដ្ឋផង មានន័យថា តង្វាយដែលគេថ្វាយដល់ ព្រះពុទ្ធ, ព្រះអាទិទេព, ព្រះវិហារ ឬ អាស្រម ជាដើម។ ខ្លឹមសារនៃបញ្ហាដែលយើងលើកនេះបង្ហាញពីកាតព្វកិច្ចរបស់ព្រះរាជាក៏ដូចនាម៉ឺនមុខមន្ត្រីតូចធំដែលត្រូវបំពេញតាមតួនាទីទាក់ទងនឹងសេចក្ដីសុខទុក្ខរបស់ប្រជារាស្ត្ររបស់អ្នកប្រព្រឹត្តធម៌ក្នុងសាសនានិងដើម្បីភាពរីកចម្រើនរបស់សង្គមទាំងមូល។

ជាញឹកញយ ក្នុងសិលាចារឹក ដែលគេឃើញមានបណ្ដឹងឱ្យទទួលស្គាល់កម្មសិទ្ធិលើដីធ្លីដែលមានប្រវត្តិជាង២០០ឆ្នាំមកហើយ ហើយ តុលាការនៅតែផ្ដល់សិទ្ធិដល់ម្ចាស់ដីដែលប្ដឹងនិងដែលមានបុព្វបុរសបានស្លាប់ទៅរាប់តំណមកហើយនោះ។

ជាការពិត យើងទទួលស្គាល់វណ្ណៈមនុស្សជាន់ទាបត្រូវគេទិញដូរឬលក់ជាប់ជាមួយនឹងដីធ្លីស្រែចម្ការដែលទិញដូរឬលក់ តែ យើងត្រូវទទួលស្គាល់, ជាទិដ្ឋភាពទូទៅ, ចំពោះស្ថានភាពច្បាប់និងទំនៀមទម្លាប់នៃប្រទេសនានានាពេលនោះ និង, ជាទិដ្ឋភាពដោយឡែក, ចំពោះស្ថានភាពសង្គមខ្មែរនិងច្បាប់ខ្មែរ។

ដីធ្លីជាអចនវត្ថុដែលគេទទួលបានតាមរយៈការដោះដូរជាមួយនឹងវត្ថុឯទៀតឬជាមួយនឹងវត្ថុមានតម្លៃ មានមាសប្រាក់ជាដើម។ កាសជារូបិយវត្ថុក្នុងអាជីវកម្មពាណិជ្ជកម្មឬជាតង្វាយដល់អាទិទេពឬវត្តអារាម។ ការប្រើកាសមានជាទូទៅក្នុងតំបន់អាស៊ីអាគ្នេយ៍ពីដើមគ្រិស្តសករាជដល់សតវត្សរ៍ទី៧។ ក្រៅពីនេះ លោហៈមានតម្លៃនានាត្រូវបានប្រើដោយការថ្លឹងតាមរង្វាស់ទម្ងន់ដែលគេព្រមព្រៀងគ្នា។[3]

---

[3] តាមអ្នកស្រាវជ្រាវរូបិយវត្ថុបុរាណ គេដឹងថា ប្រាក់កាសដែលប្រើនៅតំបន់អាស៊ីអាគ្នេយ៍តាមរយៈវត្ថុដែលគេរកឃើញនៅ អូរកែវ (កំពង់ផែរបស់នគរភ្នំ, ប្រទេសវៀតណាមភាគខាងត្បូងសព្វថ្ងៃ), ហរិកេលៈ (តំបន់បឹងហ្គាល់សព្វថ្ងៃ); អារ៉ាកាន់, ហាលិ, ស្រីក្សេត្ត័ន (ប្រទេសភូមាសព្វថ្ងៃ); នគរបឋម, បស្ចិមបុរី(ប្រទេសថៃសព្វថ្ងៃ)។ ជាទូទៅ រូបលើកាសមានលក្ខណៈ៥បែបៈ ស្រីវត្ស(ព្រះអាទិត្យ), សង្ខ, បល្លង្ក, ព្រះអាទិត្យរះ និង គោ។ កាសនៅអូរកែវ, អ៊ូថង, បេកថានោ (Beikthano), ហាលិន និង ស្រីក្សេត្រ មានរូបស្រីវត្សនិងរូបព្រះអាទិត្យរះ ដែលរូបនេះមើលទៅមានជារូបរាងមនុស្ស។

នៅឆ្នាំ២០១៣ អ្នកស្រាវជ្រាវបានរកឃើញកាសមាសសម័យព្រះបាទ ឥសានវរ្ម័ន។ រូបម្ខាងនៃកាសជារូបគោមានបូកដែលចារឹកឈ្មោះរាជធានីព្រះបាទ ឥសានវរ្ម័ន (៥៩០-៦៣៧) គឺ *ឥឝានបុរ]* និង រូបម្ខាងទៀតជារូបព្រះអាទិទេពស្រីដែលគេហៅថា *ឝ្រី* ជាន់លើផ្កាឈូក, ខាងលើព្រះអាទិទេពមានចារឹកព្រះនាមព្រះបាទ *ឝ្រីឝានវរ្ម៌* ។ កាសនេះមានលក្ខណៈដូចគ្នាច្រើននឹងប្រភេទកាសសមាតាតា (Samatata), នគរបុរាណនៅភាគនិរតីបឹងហ្គាល់សព្វថ្ងៃ, ដែលមានទម្ងន់ប្រមាណ៥.៧៥ក្រាម។ ជាទូទៅ កាសដែលគេរកឃើញកន្លងមកនៅតំបន់អាស៊ីអាគ្នេយ៍សម័យបុរាណមានទម្ងន់រវាងពី២ទៅ៩ក្រាម។ ថ្វីត្បិតរូបសញ្ញាលើកាសទទួលឥទ្ធិពលពីប្រទេសឥណ្ឌាជាពិសេសពីសតវត្សរ៍ទី៤ដល់ទី៦ក្ដី ក៏ចំណុចខ្លះជាគំនិតម្ចាស់ស្រុក ដូចជា ស្រិវត្សនិងសញ្ញាទាក់ទងលោកធាតុនៅខាងលើហើយសញ្ញាទាក់ទងនឹងទឹកនៅខាងក្រោមជាដើម។ Cf. Pamela Gutman, *The Ancient Coinage of Southeast Asia,* paper presented at *the 7th Conference of the International Association of Historians of Asia, at Bangkok, August 1977;* Joe Cribb, First Coin of Ancient Khmer Kingdom Discovered, *Revue de la Société de Numismatique Asiatique,* Noméro 6, Juin 2013.

ការសិក្សាសង្គមបុរាណ គេពិតជាពិបាកនឹងយកច្បាប់ទម្លាប់បច្ចុប្បន្នវាយតម្លៃសង្គមមនុស្សកាលពីពីរបីរយឆ្នាំមុន។[4] ដូច្នេះ ការឈ្វេងយល់ពីប្រភពច្បាប់ទំនៀមទម្លាប់និងគម្ពីរដីកាសាស្ត្រទាំងឡាយជាដើមនៅសម័យនោះ ជាជំនួយសំខាន់ដែលអាចឱ្យយើងស្គាល់ប្រព័ន្ធច្បាប់និងទិដ្ឋភាពសង្គមសេដ្ឋកិច្ចក៏ដូចជាស្ថានភាពនយោបាយនាយុគសម័យនោះ។

យើងនឹងលើកប្រវត្តិខ្លះទាក់ទងនឹងសង្គមសាសនាឥណ្ឌាសម័យបុរាណដែលមានឥទ្ធិពល, ទោះតិចក្តីច្រើនក្តី, លើសង្គមនៅតំបន់អាស៊ីអាគ្នេយ៍នេះ, ជាពិសេស, តាំងពីដើមគ្រិស្តសករាជមកទល់នឹងសតវត្សរ៍ទី១៦។ តាមលទ្ធិហិណ្ឌូនិងលទ្ធិវេទ ចាប់តាំងពីថ្ងៃគ្រោងរាជ្យមក ព្រះរាជាមានកាតព្វកិច្ចការងារវណ្ណៈទាំង៤និងអាស្រមនានា។ ព្រះអង្គ ត្រូវការពារដែនដី, ត្រូវយកចិត្តទុកដាក់គាំពារមនុស្សកំព្រា, ពិកល, ពិការ, ស្រីមេម៉ាយ, ស្រីមានផ្ទៃពោះ ដោយផ្តល់ជា ថ្នាំសង្កូវ, ទីជម្រក, ចំណីអាហារ, សម្លៀកបំពាក់។[5] ទ្រង់ក៏មានកាតព្វកិច្ច ជំរុញការអប់រំ, សាងមន្ទីរពេទ្យ, សាងសាលាឆទាន, សង់ប្រព័ន្ធស្រោចស្រព និង ផ្តល់ការងារដល់អ្នកអត់ការងារធ្វើ។[6] ព្រះអង្គត្រូវចាត់ទុកប្រជារាស្ត្រជាកូនរបស់ខ្លួន។[7]

រាល់ជម្លោះទាំងឡាយត្រូវដោះស្រាយក្នុងសភា។ «សភា»ក្នុងន័យកាលនោះ គឺត្រូវនឹង«តុលាការ» នាពេលបច្ចុប្បន្ន។ សភាដោះស្រាយទាំងវិវាទរដ្ឋប្បវេណីទាំងវិវាទព្រហ្មទណ្ឌ។

នៅក្នុងសង្គមឥណ្ឌាបុរាណ ព្រះមហាក្សត្រក៏ដូចជាមន្ត្រីតុលាការត្រូវមានចំណេះដឹងផ្នែកផ្លូវលោកនិងផ្លូវធម៌ឬត្រូវចេះគម្ពីរធម៌សាស្ត្រនិងគម្ពីរអាថ៌សាស្ត្រ។ ចៅក្រមត្រូវមានព្រាហ្មណ៍ជាជំនួយក្នុងការងាររបស់ខ្លួន។ ចៅក្រម, ក្រៅពីមានចំណេះដឹងខាងផ្លូវលោកផ្លូវធម៌, ត្រូវមានគុណធម៌ដូចជាមិនកាត់ក្តីមិនលម្អៀងដោយអគតិធម៌។ មិនតែប៉ុណ្ណោះ គេត្រូវជ្រើសចៅក្រមតុលការនេះពីគ្រួសារដែលមានកេរ្តិ៍ឈ្មោះល្អទៀតផង។[8]

ក្នុងការកាត់សេចក្តី ព្រះរាជាត្រូវថ្លឹងថ្លែងច្បាប់ផ្លូវលោកនិងផ្លូវធម៌ព្រមទាំងពិភាក្សាជាមួយនឹងព្រាហ្មណ៍ដែលមានចំណេះដឹងនិងមន្ត្រីតុលាការ។ តាមច្បាប់បុរាណខ្លះ ព្រះរាជានិងមន្ត្រីរបស់ព្រះអង្គមិនត្រូវធ្វើជាអ្នកប្តឹងទេហើយមិនត្រូវនៅស្ងៀមស្ងាត់ ពេលមានបណ្តឹងមកដល់នោះដែរ។ នៅពេលដែលភាគីទាំង២មានអំណាចដូចគ្នា ព្រះរាជាជាអ្នកចេញសេចក្តីសម្រេច។[9]

---

[4] លោក Adhir Chakravarti បានសិក្សាលើការស្នងរាជ្យនៅប្រទេសកម្ពុជាសម័យបុរាណ។ ក្នុងសេចក្តីសន្និដ្ឋាន លោកបញ្ជាក់ឱ្យយើងដឹងថា គោលការណ៍ស្នងរាជ្យបែបបិតាធិបតេយ្យ (patrilineal succession) របស់ឥណ្ឌាមិនត្រូវបានអនុវត្តនៅប្រទេសកម្ពុជាដែលគោរពតាមគោលការណ៍ស្នងរាជ្យបែបមាតាធិបតេយ្យ (matrilineal succession)នោះទេ។ ករណីនេះទាក់ទងនឹងអ្នកគ្រប់គ្រងជាន់ខ្ពស់ផង នេះនឹងចាំបាច់និយាយថ្មីដល់ទិដ្ឋភាពសង្គមដទៃទៀតនោះ។ ដូច្នេះ លោកទទួលស្គាល់ថា ឥទ្ធិពលវប្បធម៌ឥណ្ឌាលើប្រទេសកម្ពុជាមិនមែនជ្រាលជ្រៅដូចដែលអ្នកសិក្សាឥណ្ឌាបានគិតនោះឡើយ។ Cf. Adhir Chakravarti, *Royal Succession in Ancient Cambodia,* (Calcutta: The Asiatic Society), 1982, p. 106.

[5] Pandurang Vaman Kane, *History of Dhamrmaśastra (Ancient and Mediaeval Religious and Civil Law in India),* Vol. I, Poona: Bhandarkar Oriental Research Instittue, 1930, p. 59.

[6] *Ibid,* p. 60.

[7] *Ibid,* p. 62-63.

[8] *Ibid,* p. 271, 273.

[9] *Ibid,* p. 251, 269.

ដូច្នេះ ការគ្រប់គ្រងដីធ្លីនៅសម័យបុរាណផ្អែកច្រើនលើគោលសាសនា។ ប៉ុន្តែ ការអនុវត្តច្បាប់មិនសុទ្ធតែត្រូវធ្វើតាមច្បាប់ដែលមានក្នុងគម្ពីរច្បាប់ទាំងនោះឡើយ។ ចំណុចនេះជាការបង្ហាញពីឥទ្ធិពលច្បាប់និងប្រពៃណីក្នុងស្រុកលើការគ្រប់គ្រងសង្គម។

## ១.១- ការគ្រប់គ្រងដីធ្លីនៅសម័យមុនអង្គរ

### ១.១.១- ការគ្រប់គ្រងដីធ្លីនៅសម័យនគរភ្នំ

នៅសម័យនគរភ្នំ រាជបុត្រនិងមន្ត្រីជាន់ខ្ពស់នានាមានសិទ្ធិគ្រប់គ្រងភូមិភាគទៅតាមការប្រទានរបស់ព្រះរាជា[10]។ ព្រះរាជាធ្វើអំណោយដល់វត្តអារាមនិងអាស្រមបទនានា។ ក្នុងអំណោយជាដីនោះ មានជាប់ទាំងសំណង់ប្រព័ន្ធធារាសាស្ត្រ។ នៅបាភ្នំ កម្មសិទ្ធិលើស្រែចម្ការកើតមានឡើងតាមរយៈ«ការត្រួសត្រាយដីថ្លុកត្រពាំង»នៅជិតទំនាបទន្លេមេគង្គ។[11] ទំនាស់ផ្ទៃក្នុងរាជវង្សបណ្ដាលឱ្យអ្នកគ្រប់គ្រងខ្មែរមានការលំបាកក្នុងការគ្រប់គ្រងដីនៅភាគបស្ចិមនិងពាយ័ព្យ ជាពិសេស ទំនាស់ផ្ទៃក្នុងបានរីករាលដាលខ្លាំងនៅទសវត្សរ៍ទី៤ដល់ទី៥នៃសតវត្សរ៍ទី៦។[12] គេសង្កេតឃើញថា អភិជនដែលមានដីកាន់កាប់ភាគច្រើននៅជំនាន់នោះគឺ «ម្រតាង» និង «ប៉ោញ»។ ទាក់ទងនឹងឋានៈម្រតាងនេះ គេអាចប្រៀបប្រៀបគាត់ទៅនឹងកុដុម្ពីម្នាក់ហើយប៉ោញទៅនឹងម្ចាស់ដីមធ្យមម្នាក់[13]។

### ១.១.២- ការគ្រប់គ្រងដីធ្លីនៅសម័យចេនឡា

ជិតចូលសតវត្សរ៍ទី៧រដ្ឋបាលនគរភ្នំបានធ្លាក់មកក្នុងការគ្រប់គ្រងរបស់ព្រះបាទ មហេន្ទ្រវរ្ម័ន (គ.ស.៦០០-៦១៥)។ កាលព្រះអង្គមិនទាន់ឡើងគ្រងរាជ្យ ជាការពិត ព្រះរាជាជាម្ចាស់ដីទាំងអស់។

មានការត្រួសត្រាយដីថ្មីនៅភាគខាងជើងប្រទេស។ គេអាចកាន់កាប់ដីនេះបានតាមរយៈការទិញ។ នៅភាគកណ្ដាលនិងខាងត្បូងប្រទេស ចៅហ្វាយក្រុងនានាមានសិទ្ធិចាត់ចែងដីដូចជាធ្វើអំណោយឬលក់ដូរដីដែលខ្លួនកាន់កាប់។ ក្នុងរាជវង្សានុវង្ស ដីភូមិស្ថានមានលក្ខណៈកម្មសិទ្ធិនិងឯកសិទ្ធិ។ គេអាចប្រគល់ជាមរតកដល់កូនចៅខ្លួន។ ចំពោះអភិជន គេត្រូវបង់ពន្ធមួយភាគដល់រដ្ឋហើយមិនអាចប្រគល់ជាមរតកដល់កូនចៅឡើយ។ កសិករត្រូវបង់ពន្ធដោយផ្អែកលើផលដំណាំរបស់ខ្លួន មិនមែនទំហំដីទេ។[14]

មន្ត្រីរាជការមានឋានៈពី «តាង» ដែលជាឋានៈថ្នាក់មធ្យមដល់ឋានៈខ្ពស់បន្ទាប់គឺ «ប៉ោញ» និង ដល់ឋានៈខ្ពស់បំផុតគឺ «ម្រតាង»។ «ប៉ោញ»និង«ម្រតាង»បំពេញមុខងារជាចៅហ្វាយស្រុកចៅហ្វាយខេត្រ។ ដីស្រែចម្ការមានពីរប្រភេទគឺ របស់អភិជនប៉ោញនិងម្រតាង និង របស់វត្តអារាមនិង

---

[10] ឡុង សៀម (ប្រែសម្រួល), *ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា,* យ.យ. មីហេយេវ (និពន្ធនាយក), មូស្គូ, ការិយាល័យនិពន្ធនាយកផ្នែកអក្សរសិល្ប៍បូព៌ា នៃអង្គការបោះពុម្ពផ្សាយ«ណាអ៊ូកា», ១៩៨១, ទំ.19។

[11] -ដ-, ទំ.26។

[12] -ដ-, ទំ.31។

[13] -ដ-, ទំ.28។

[14] -ដ-, ទំ.38-39។

អាស្រមបទទាំងឡាយ។ នៅពេលដែលអភិជនទាំងនេះធ្វើអំណោយដល់វត្តអារាម គេក៏បានទទួលសិទ្ធិក្នុងការប្រើប្រាស់ដីដែលនៅសល់ឬទទួលផលចំណូលពីដីអំណោយនោះផងដែរ។[15]

«កម្មសិទ្ធិដីជាមូលដ្ឋាន មិនមែនជាដីភូមិទេ គឺដីសំរាប់ដំណាំស្រូវ។» កម្មសិទ្ធិនេះរាប់ទាំងច្បារដំណាំ សួនច្បារ ដីព្រៃ និង ត្រពាំងទឹក។[16]

តាមការសិក្សាតាមសិលាចារឹកសម័យមុនអង្គរ ទាក់ទងនឹងដីកសិកម្មនិងដីព្រៃដែលផ្ដល់ជាទិន្នផលផ្សេងៗ គេអាចកត់សម្គាល់លើចំណុចបី គឺ ១. ប្រភេទដី និង ២. ផលិតផលដែលកើតចេញពីដីនោះ។[17]

មានពាក្យមួយចំនួនបង្ហាញឱ្យយើងដឹងពីប្រភេទដីទាក់ទងនឹងកសិកម្ម ដូចជា *ករោមិ, ចំកា* (ពេលខ្លះ គេប្រើពាក្យសំស្ក្រឹត *មាល*), *ចំន្សថ្មរ៑, ចម្នោមិ, ច្បារ៑, ទំរីង៑, ស្រែ*។ ករោមិ ជាប្រភេទដីទំនាប, ចំន្សថ្មរ៑ ជាវាលស្មៅ, ច្បារ៑ ជាសួនបន្លែ, ទំរីង៑ ជាសួនបន្លែឡើងទ្រើង និង ស្រែ ជាប្រភេទដីធ្វើស្រែ។

មានពាក្យមួយចំនួនបង្ហាញឱ្យយើងដឹងពីផលិតផលនិងអនុផលព្រៃឈើដែលទាក់ទងនឹងដីធ្លីដាំដុះដំណាំនិងព្រៃឈើ។ ផលិតផលអនុផលទាំងនោះមាន ដូចជា *កល្មោន៑ (ក្រមួន), ក្របាស៑ (កប្បាស), ក្សីរ (ទឹកដោះ), ឃ្មុំ, ងរអោរ៑ (វង្វ), តោង៑ (ដូង), ត្នៅ (ថ្នៅ), ទន្ទុំ (ទឹកអប់), បរេង៑ (ប្រេង), មធុ (ទឹកឃ្មុំ), មធុច្ឆិស្ត (ក្រមួន), យវ (គ្រាប់ធញ្ញជាតិ), រង្គោ (អង្ករ), ល្ងោ (ល្ង), វ្នៃ (ពន្លៃ), ម្រេច, ក្រវាញ, សន្តេក (សណ្ដែក), ស្រុ ឬ ស្រូ (ស្រូវ), ម្លិ (ខ្ញី), អំបេល (អំបិល)* ជាដើម។

ចំពោះ តិណជាតិ ដំណាំហូបផ្លែ និង អនុផលព្រៃឈើ មានដូចជា ចន្ទន (ចន្ទន៍), ប្កាឈេ (ផ្កាឈើ), វ្ង (ផ្កាភ្ញី), ស្មៅ, ស្វាយ៑ (ស្វាយ), អន្លិក (ឪឡឹក), អំពៅ (អំពៅ) ជាដើម។

### *ករណីសិក្សាទី១៖ ការប្រទានដីធ្លីរបស់ព្រះរាជាថ្វាយវត្តអារាម*

នៅសតវត្សរ៍ទី៧, តាមសិលាចារឹកវត្តព្រៃវៀរ(K.49)ខេត្តព្រៃវែង, គេដឹងថា ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទីមួយ មានភិក្ខុ២អង្គមានព្រះនាមថា រត្នភានុ និង រត្នសិង្ហ ជាខ្សែរាជវង្ស ជាបងប្អូនបង្កើតនឹងគ្នា គង់នៅទីតាំងវត្តព្រៃវៀរនេះ។ ព្រះភិក្ខុទាំងពីរអង្គ ទ្រង់សីល, មានចំណេះដឹង, មានសេចក្ដីស្ងប់ក្នុងខ្លួន, មានខន្តី, មានករុណា និង មានការទូន្មានខ្លួន។ ព្រះមហាក្សត្រទ្រង់ត្រាស់បញ្ជាមិនឲ្យអ្នកណាបៀតបៀនសត្វទាំងឡាយព្រមទាំងទីព្រៃដីស្រែសួនច្បារនិងភូមិករដែលមាននៅទីនោះឡើយ ពោលគឺវៀរមិនត្រូវបៀតបៀន។ នាបច្ចុប្បន្នកាល ទីតាំងវត្ត«សុរិយារង្ស» ហៅ ព្រៃវៀរ នេះស្ថិតក្នុង ភូមិភ្នៅ ឃុំជ្រៃ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។

---

[15] -ដ-, ទំ.36-37។

[16] -ដ-, ទំ.40-41។

[17] សូមមើល Judith Jacob, "Pre-Angkor Cambodia: Evidence from Khmer Inscriptions", in *Cambodian Linguistics, Literature and History,* David A. Smyth, ed. (London: School of Oriental and African Studies, University of London, 1993), pp. 311-312.

## ករណីសិក្សាទី២៖ ការរួចពន្ធនិងការផ្ទេរសិទ្ធិដីមួយកន្លែង

តាមសិលាចារឹកបាសែត(K. 205), ខេត្តបាត់ដំបង, ប្រវត្តិគ្រួសារនេះមានប្រវត្តិតាំងពីរាជ្យព្រះបាទសូរ្យវរ្ម័នទី១មកដល់រាជ្យព្រះបាទ ហស៌វរ្ម័នទី៣។ ដំបូងឡើយ មានត្រកូលមួយ មានបុរសជាស្វាមីមានឋានៈជាអភិបាលស្រុក។ លោកមានភរិយាមានភក្តីភាពមានកិរិយាមារយាទ ប្រៀបបីដូចទេពធីតាមួយអង្គ។ លោកមានកូនចំនួន៨នាក់ ក្នុងនោះ ប្រុស៥នាក់, ស្រី៣នាក់។ កូនទាំងអស់របស់លោកមានគុណធម៌មានចរិតល្អ មានបវរភក្តីចំពោះព្រះសិវៈ និង ជាទីគាប់ព្រះទ័យរបស់ព្រះមហាក្សត្រហើយក៏ជាព្រះរាជគ្រូរបស់ ព្រះបាទ សូរ្យវរ្ម័នទី១, ព្រះបាទ ឧទយាទិត្យវរ្ម័នទី២ និង ព្រះបាទ ហស៌វរ្ម័នទី៣។

បណ្តាកូនប្រុសទាំង៥ កូនប្រុសម្នាក់ជាសិល្បករមួយរូបដូចឪពុករបស់ខ្លួនដែរ។ ព្រះបាទ ឧទយាទិត្យវរ្ម័នទី២ បានប្រទានងារដល់កូនប្រុសម្នាក់នេះថាជា វិស្វករ ជាអធិបតីនៃសិល្បករទាំងឡាយ។ វិស្វកររូបនេះបានស្ថាបនាបារាយណ៍ខាងកើត និង ប្រាសាទបាភួន ហើយ ក៏មានភារៈធំជាក់ ពោលគឺជាអ្នកត្រួតការងារសាងសង់រាជធានី។ នាពេលយាងសម្ពោធសមិទ្ធផល ព្រះមហាក្សត្របានប្រទានដែនដីមួយកន្លែងដែលរួចផុតរលត់ពីការទារពន្ធអាកររបស់ព្រះនគរដល់រាជវិស្វករបវរសម័យអង្គរនេះ។ ដែនដីនោះត្រូវបានគេហៅថា ឧទយាទិត្យប្រាសាទ (ឬ ដីព្រះរាជអំណោយព្រះបាទ ឧទយាទិត្យ)។

ដោយមានការចូលរួមធ្វើជាសាក្សីពីសម្នាក់ព្រាហ្មណ៍និងព្រះអម្ចាស់ទាំងឡាយ ព្រះរាជាទ្រង់បានប្រទានជាកិត្តិយសដោយបានយាងឆ្ពោះធ្វើជាព្រះប្រធាននៃរាជសភាក្នុងដំណើរការបោះបង្គោលព្រំដីនៃរាជវិស្វករ។ ព្រះមហាក្សត្រទ្រង់បញ្ជាឲ្យដាក់ដែនដីរបស់វិស្វករនេះស្ថិតក្នុងកម្មសិទ្ធិនៃដែនដីរបស់វណ្ណៈ ហេមករង្គ ស្ថិតក្នុងស្រុកភីមបុរៈ។ ដីនេះស្ថិតនៅលើភ្នំមួយមានចម្ការនិងមានអ្នកចាំជាំដុះ។ វិស្វករជាគុណកររូបនេះបានទទួលគោរម្យងារជាអធិបតីស្តីលើវិចិត្រករទាំងឡាយក្នុងព្រះនគរ។

នៅពេលដែលព្រះបាទ ឧទយាទិត្យវរ្ម័នទី២ ចូលទិវង្គតទៅ នៅមានបន្តចរចូលមករាជ្យព្រះបាទ ស្រី ហស៌-វរ្ម័ន ដែលទ្រង់ប្រកាន់សង្កត់កំណត់ជាថ្មីនៃព្រំដីខាងលើ ដោយទ្រង់បានយោងលើគុណធម៌បវររបស់រាជវិស្វករ។ ពេលរាជវិស្វកររូបនេះទទួលអនិច្ចកម្ម ព្រះមហាក្សត្របានប្រទានពិធីបុណ្យជូនគាត់។ ទ្រង់បានអនុញ្ញាតឲ្យក្មួយនៃរាជវិស្វករឈ្មោះ កុមារៈ ទទួលសិទ្ធិអាស្រ័យផលបន្ត។

## ករណីសិក្សាទី៣៖ ការច្រូតស្រូវនិងការដកបង្គោលព្រំដីស្រែអ្នកដទៃនៅសម័យអង្គរ

ដំណើររឿងនេះត្រូវបានប្រែសម្រួលពីសិលាចារឹកអ្នកតាចារឹក(K.181)ខេត្តព្រះវិហារ។ សិលាចារឹកនេះមានកាលបរិច្ឆេទស្ថិតក្នុងសតវត្សរ៍ទី១០ នៅក្នុងរាជ្យព្រះបាទ រាជេន្ទ្រវរ្ម័ន (៩៤៤-៩៦៨ នៃ គ.ស.)។

ព្រះបាទ រាជេន្ទ្រវរ្ម័ន មានព្រះរាជបញ្ជាឲ្យតុលាកាត់ក្តីរឿងខាងលើដោយសារបុរសម្នាក់ឈ្មោះ វីរភក្តិគរជ្ជិត។ លោក ជាអភិបាលស្រុក វីរបុរៈ។ លោកបានប្រើមនុស្សឲ្យទៅច្រូតស្រូវនិងដកបង្គោលដីមួយកន្លែងដែលបានបោះបង្គោលតាមព្រះរាជបញ្ជា។ ប្រវត្តិនៃដីនេះ គឺ ដំបូងឡើយ មានមន្ត្រី២នាក់ឈ្មោះ ស្រី វីរេន្ទ្រវម្ម៌ៈ និង ស្រី ន្ទបេន្ទ្រារិម-ថនៈ បានទិញជាទ្រព្យពីបុរសម្នាក់ឈ្មោះ ងាច ដើម្បីជូនដី

នេះដល់គ្រូភ្លេងម្នាក់ឈ្មោះ ចូ និង ក្រុមគ្រួសារ ហើយ ព្រមទាំងបានសុំព្រះរាជបញ្ជាបោះព្រំដីផង។ ភូមិខាងលើនេះហើយដែលលោកអភិបាលស្រុកបានបំពាន។ តុលាការបានសាកសួរ។ លោកអភិបាលស្រុកបានទទួលកំហុសថា គាត់បានប្រព្រឹត្តដូចការចោទមែន តែ មានសាក្សីម្នាក់ឈ្មោះ អម្រឹត បានប្រាប់តុលាការថា ដីដែលលោកអភិបាលស្រុកខាងលើប្រើគេឲ្យទៅដកបង្គោលនោះ គឺជាដីស្ថិតនៅកន្លែងផ្សេងទេ។

ជាចុងក្រោយ តុលាការបានពិន័យលោកអភិបាល ស្រុករូបនេះជា មាស១០តម្លឹង ហើយ ប្អូនរបស់គាត់ដែលបញ្ជាឲ្យគេទៅច្រូតស្រូវ នៅដីនោះត្រូវវាយខ្នងចំនួន១០២ផ្តៅ ចំណែកសាក្សី ដែលផ្តល់ចម្លើយខុសការពិត ត្រូវទទួលទោសដោយត្រូវវាយខ្នងចំនួន១០២ផ្ដៅ ដែរ។ ចំពោះបុរសម្នាក់ទៀតឈ្មោះ បិត ដែលនាំគ្នីគ្នាទៅច្រូតស្រូវនោះក៏ត្រូវពិន័យផងដែរ។

### *ករណីសិក្សាទី៤៖ ការលក់ដីស្រែនិងទំហំដីស្រែ*

សិលាចារឹកវត្តពោធិ៍(K. 22), សតវត្សរ៍ទី៧, ខេត្តតាកែវ រៀបរាប់ពីអំណោយរបស់សីលព្រ័តមុនីមួយរូបមាននាមថា ឥគានទត្ត។ លោកបានកសាងរូបបដិមាព្រះនរាយណ៍និងព្រះលិង្គនៅទីប្រាសាទនេះជាមួយនឹងអ្នកបម្រើប្រាសាទនិងដីស្រីដែលបានថ្វាយដល់ព្រះអាទិទេពដោយមនុស្សមួយចំនួន។ ក្នុងចំណោមនេះ មានដីស្រែខ្លះបានមកដោយការទិញ។ ក្នុងសិលាចារឹក ទាក់ទងនឹងស្ថានភាពលក់និងស្ថានភាពដី គេបានប្រាប់ ឈ្មោះអ្នកលក់ស្រែ ទីតាំងដី និង បរិមាណដី។ យើងសូមស្រង់ឧទាហរណ៍ខ្លះដូចខាងក្រោម ៖

*ក្ញោញបោញទិនរុទ្រគំកុលកិស្រែអំវិត្រវងំរាមបាលលោះត្រវង៑រុទ្រការត្តិមាសិ៣* (ប.២៥-២៦)

ឃ្លាពាក្យខាងលើមានន័យថា *មន្ត្រីម្នាក់មានងារជា ក្លោញបោញ ឈ្មោះ ទិនរុទ្រសំកុល លក់ស្រែដែលមានទីតាំងចាប់ពីត្រពាំងរាមបាលរហូតដល់ត្រពាំងរុទ្រការត្តិ មានទំហំចំនួន៣មាស។*

*នាគវិន្ទុលកស្រេត្វំឰកមរោំក្សេលិត្រវងំរាមបាលវាលកិតវ្រះអំរុង៑គ្មមាស៣* (ប.២៦-២៧)

ឃ្លាពាក្យខាងលើមានន័យថា *បុរសម្នាក់ឈ្មោះ នាគវិន្ទុ លក់ស្រែដើមនៅក្រោមខ្យល់ត្រពាំងរាមបាល គាត់លក់ថ្វាយព្រះ, ដីនោះទំហំ៣មាស។*

*ស្រេឰលេក្សេលៀវ្រះវិនាយលុះត្រវងំបោញភាញិសមាសិ១-១០*

ឃ្លាពាក្យខាងលើមានន័យថា *ស្រែលើខ្យល់ព្រះវិនាយរហូតដល់ត្រពាំងបោញភាញិសមានទំហំចំនួន១០មាស។*

*ស្រេករោមិក្សេលិវ្រះវិនាយលោះញងំស្រេគេត្វៃលុច្ចិអំរុង៑គ្មមាសិ៣* (ប.៣១-៣២)

ឃ្លាពាក្យខាងលើមានន័យថា ស្រែក្រោមខ្យល់(ទិសខាងជើង)ព្រះវិនាយរហូតដល់ជិតនឹងស្រែថ្ងៃលិច(ទិសខាងលិច)របស់ម្ចាស់មួយទៀតមានទំហំ៣មាស។

*ស្រែព្វតែលុចត្រូវធ្វើភាគស្រមានទុកអំរុងធ្វើដេ៣* (ប.៣៣-៣៤)

ស្រែថ្ងៃលិច(ទិសខាងលិច)ត្រពាំងភាគិសបានទិញទំហំ៣ដេ។

### *ករណីសិក្សាទី៥៖ ការអភិវឌ្ឍទឹកដី*

សិលាចារឹកថាប់មឿយ, សតវត្សរ៍ទី៦, ខេត្តដុងថាប់ ប្រទេសវៀតណាមបច្ចុប្បន្ន, បញ្ជាក់ពីព្រះបាទ ជ័យវរ្ម័នទី១, ព្រះរាជានៃនគរភ្នំ, ដែលតែងតាំងព្រះរាជបុត្ររបស់ព្រះអង្គព្រះនាម គុណវរ្ម័នឱ្យធ្វើជាអ្នកគ្រប់គ្រងគណៈសង្ឃនៅតំបន់នោះ។ អ្នកស្រាវជ្រាវបានបកស្រាយតាមរយៈសិលាចារឹកថាព្រះរាជាបានបញ្ជាឱ្យបង្ហូរទឹកនៅតំបន់វាលភក់នោះសម្រាប់ធ្វើកសិកម្ម។[18]

សិលាចារឹកមានបរិមាណច្រើនជាងសម័យមុនអង្គរដែលប្រការនេះអនុញ្ញាតឱ្យអ្នកស្រាវជ្រាវទូទៅយល់បានច្រើនពីការវិវត្តសង្គមនយោបាយសេដ្ឋកិច្ច។

## ១.២- ការគ្រប់គ្រងដីធ្លីនៅសម័យអង្គរ

ការគ្រប់គ្រងដីធ្លីមានលក្ខណៈច្បាស់លាស់នៅសម័យអង្គរ។ ទី១ បញ្ជាកម្មសិទ្ធិមានបញ្ជាក់ក្នុងសិលាចារឹក, ទី២ ព្រះរាជាផ្តល់ភាពស្របច្បាប់ដល់ម្ចាស់កម្មសិទ្ធិ, ទី៣ តុលាទទួលពាក្យបណ្តឹងនិងដោះស្រាយក្នុងករណីមានវិវាទដីធ្លី។

ទាក់ទងនឹងប្រវត្តិដីធ្លីនីមួយៗនៅសម័យអង្គរ ជាពិសេស នាសតវត្សរ៍ទី១០ដល់១៤ អ្នកសិក្សាសិលាចារឹកបានចាប់អារម្មណ៍លើពាក្យ«គាខា»។ ន័យដើមរបស់ពាក្យនេះមានន័យថា«សាខា, មែកធាង» វាក៏អាចមានន័យថា «ដំណើររឿង, ប្រវត្តិ» ផងដែរ។ ន័យចុងក្រោយខាងដើមច្រើនលេចឡើងក្នុងកន្សោមពាក្យ«គាខាខ្ញុំ»ឬ«គាខាសន្តាន»។ ថ្វីត្បិតតែកន្សោមពាក្យបញ្ជាក់ពីប្រវត្តិរបស់អ្នកបម្រើឬអ្នកធ្វើតាមស្រែចម្ការច្បារដំណាំក៏ពិតមែន តែ វាក៏បញ្ជាក់ផងដែរពីប្រវត្តិនិងពូជពង្សអ្នកគ្រប់គ្រងដីធ្លី។ សិលាចារឹកដែលមានប្រើពាក្យឬកន្សោមពាក្យទាំងនេះច្រើនចេញដោយមន្ត្រីនៅតាមខេត្តក្រុងនិងអភិជន។ ទោះបីខ្លឹមសារដំបូងមានការសរសេរលើកតម្កើងព្រះរាជាយ៉ាងណាក្តី ក៏ខ្លឹមសារសំខាន់ អ្នកនិពន្ធចង់បញ្ជាក់ពីទទួលសិទ្ធិគ្រប់គ្រងអ្នកបម្រើនិងដីធ្លីទាំងនោះ។[19]

### *ករណីសិក្សាទី៦៖ អ្នកភូមិព្រមព្រៀងគ្នាលក់ដីភូមិ*

សិលាចារឹកចារឹកវត្តបាសែត(K. 207), ខេត្តបាត់ដំបង, និយាយពីអ្នកភូមិបានព្រមព្រៀងគ្នាលក់ដីភូមិឱ្យមន្ត្រីម្នាក់ជាថ្នូរនឹងទ្រព្យមួយចំនួន (តសមាយុគយោគិឥស្សទ្រវ្យនោះផោងធិតជាថ្លៃភូមិ, ប.២៧) និង ធ្វើសម្បថមិនគេចកែសម្តី (គបថនុវ្រះគ្រឹយវ្នេកនិតកម្រតេងជគតវិទ្ធប្រតិជ្ញាពោះហ៊នេះហ៊)។

ចំណុចខាងលើបង្ហាញថា ការលក់ដូរដីធ្លីមិនមែនកើតឡើងត្រឹមបុគ្គលនិងបុគ្គលនោះទេ។

[18] Coedès Georges. Etudes cambodgiennes. XXV, «Deux inscriptions sanskrites du Fou-nan». In: BEFEO. Tome 31, 1931. pp.1-9.

[19] Ian Nathaniel Lowman, *The Descendants of Kambu: The Political Imagination of Angkorian Cambodia* (PhD diss. University of California, Berkeley, 2011), pp. 85-88.

### *ករណីសិក្សាទី៧៖ កម្មសិទ្ធិដីមួយកន្លែងមានប្រវត្តិប្រមាណ២០០ឆ្នាំ*

ប្រវត្តិកម្មសិទ្ធិដីមួយកន្លែងក្នុងសម័យអង្គរនេះ យើងបានដឹងតាមរយៈអ្នកចារសិលាចារឹក ហើយ អ្នកចារនេះមានដីជាកេរដំណែលរបស់បុព្វបុរសខ្លួនប្រមាណ១១រាជ្យព្រះមហាក្សត្រធំៗឬត្រូវនឹងរយៈពេលប្រមាណ២០០ឆ្នាំ មុននឹងដីត្រូវបានប្រទានដល់ព្រះមហេសីនៃព្រះបាទ សូរ្យវរ្ម័នទី១។

រាជ្យព្រះមហាក្សត្រដែលជាប់ទាក់ទងនឹងកម្មសិទ្ធិដីនេះមានរាជ្យ ព្រះបាទ ជ័យវរ្ម័នទី៣ (គ.ស . ៨៥៤-៨៧៧), ព្រះបាទ ឥន្ទ្រវរ្ម័នទី១ (គ.ស. ៨៧៧-៨៨៩), ព្រះបាទ យសោវរ្ម័នទី១ (គ.ស. ៨៨៩-៩០០), ព្រះបាទ ហស៌វរ្ម័នទី១ (គ.ស. ៩០០-៩២២), ឥសានវរ្ម័នទី២ (៩២២-៩២៨), ព្រះបាទ ជ័យវរ្ម័នទី៤ (គ.ស. ៩២៨-៩៤១), ព្រះបាទ ហស៌វរ្ម័នទី២ (គ.ស. ៩៤១-៩៤៤), ព្រះបាទ រាជេន្ទ្រវរ្ម័នទី១ (គ.ស. ៩៤៤-៩៦៨), ព្រះបាទ ជ័យវរ្ម័នទី៥ (គ.ស. ៩៦៨-១០០១), ព្រះបាទ ឧទយាទិត្យវរ្ម័នទី១ (១០០១-១០០២) និង រាជ្យព្រះបាទ សូរ្យវរ្ម័នទី១ (១០០២-១០៥០)។

តាមសិលាចារឹកប្រាសាទចក ខេត្តសៀមរាប (K. 521) គេដឹងថា ក្នុងឆ្នាំ៨៥០ ព្រះបាទ ជ័យវរ្ម័នទី៣ (ឬ ព្រះនាមតាមសិលាចារឹកគឺ ស្រីជយវម៌ទេវៈ) ក្នុងព្រះជន្ម១៦ព្រះវស្សា បានយាងទៅចាប់ដំរីដែលរត់ចូលព្រៃត្រង់ទីមួយឈ្មោះ ព្រៃស្លា។ គួរបញ្ជាក់ថា ព្រះនាមរបស់ព្រះអង្គពេលមិនទាន់ឡើងគ្រងរាជ្យគឺ ជយវធ៌ន។

នាពេលរាត្រីទ្រង់បានសុបិនឃើញព្រះវិស្ណុ។ ព្រះវិស្ណុបានមានបន្ទូលថា ព្រះអង្គនឹងប្រគល់ដំរីដល់ព្រះបាទ ជ័យវរ្ម័នទី៣ វិញ ប្រសិនបើព្រះបាទ ជ័យវរ្ម័នទី៣ ស្ថាបនាព្រះរូបព្រះវិស្ណុព្រមទាំងមានការគោរពបូជាផង។ គ្រាន់តែចូលដល់ឧទយវេលាកាលណា ដំរីដែលបាត់នោះឃើញក្នុងព្រៃនោះត្រូវបានរកឃើញវិញ។ ព្រះមហាក្សត្របានបញ្ជា ឲ្យគេកាប់ឆ្ការព្រៃទីនោះដើម្បីស្ថាបនាបដិមាព្រះវិស្ណុដែលមានព្រះនាមថា «សកព្រាហ្មណៈ» និង បានប្រទានឈ្មោះកន្លែងនោះថា «វិស្ណុគ្រាម»។ មិនតែប៉ុណ្ណោះ ព្រះរាជាបានថ្វាយដីមួយកន្លែងឈ្មោះ «ផ្ទងប្រាំង» និង អ្នកបម្រើផ្ទាល់របស់ទ្រង់ចំនួន២នាក់ជាស្វាមីភរិយានឹងគ្នាដែលមានជាប់ជាសាច់ថ្លៃខាងទ្រង់ ដល់ប្រាសាទ «សកព្រាហ្មណៈ» ទៀតផង។ អ្នកបម្រើទាំងពីរនេះជាបុព្វបុរសរបស់អ្នកចារសិលាចារឹក។ គូស្វាមីភរិយាទាំងពីរបានសុំឲ្យព្រះរាជាប្រទានភូមិមួយ។ ព្រះអង្គបានព្រះរាជទានភូមិមួយនៅអមោឃបុរៈឲ្យ។

លុះចូលមកដល់រាជ្យព្រះបាទ សូរ្យវរ្ម័នទី១ (១០០២-១០៥០) ភូមិដែលជាព្រះរាជទ្រព្យខាងលើត្រូវបានប្រទានទៅព្រះនាង ស្រីវីរលក្ស្មី, ព្រះមហេសីព្រះបាទ សូរ្យវរ្ម័នទី១។ ជីតាខាងមាតារបស់អ្នកចារសិលាចារឹកឈ្មោះ ជុន ជាមន្ត្រីរបស់ព្រះនាង ស្រីវីរលក្ស្មី បានតំណាលប្រវត្តិដ៏វែងអន្លាយនៃដីនេះថ្វាយដល់ព្រះនាង ជាពិសេសនោះ លោកបានប្រាប់ពីការដែលដីនេះធ្លាប់មានគោលជាចំណាំរហូតដល់ភូមិ ផ្ទងប្រាំង។

ព្រះមហេសី ស្រីវីរលក្ស្មី បានយកបញ្ហាដីនេះទៅបង្គំទូលព្រះរាជាសូមព្រះអង្គទ្រង់ជ្រាបនិងសូមព្រះសភា, ឬ តុលាការនាពេលនោះ, ឲ្យចុះទៅបោះបង្គោលកំណត់ព្រំដី។ រាជសភាបានចាត់ សភាបតីចំនួន៤រូប, មន្ត្រីសភាចំនួន៤រូប និង មន្ត្រីកិច្ចការទូទៅចំនួន៤រូប។ គួរបញ្ជាក់បន្ថែមថា ព្រះនាង ស្រីវីរលក្ស្មី មិនមែនជាអគ្គមហេសីនោះទេ, ព្រះនាងជាមហេសីបន្ទាប់។ តាមសិលាចារឹកប្រាសាទស្រឡៅ (K. 449B) មហេសីច្បងឬអគ្គមហេសីព្រះបាទ សូរ្យវរ្ម័នទី១ គឺព្រះនាង ស្រីនរបតីន្ទ្រលក្ស្មី។

សិលាចារឹកខាងលើនាំឲ្យយើងដឹងថា គិតចាប់ពីរាជ្យព្រះបាទជ័យវរ្ម័នទី៣ មកត្រឹមរាជ្យព្រះបាទសូរ្យវរ្ម័នទី១ ដីមួយកន្លែងនៅសម័យអង្គរខាងលើឆ្លងកាត់រដ្ឋកាលធំៗចំនួន១១និងមានរយៈពេលប្រហែល២០០ឆ្នាំ។

## *ករណីសិក្សាទី៨៖ ការចាប់យកដីដោយខុសច្បាប់*

សិលាចារឹកទួលប្រាសាទ (K. 158), ស្ថិតក្នុង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលទីតាំងនេះពីដើម តាមសិលាចារឹក មានឈ្មោះ ទេវីគ្រាម, បញ្ជាក់ពីព្រះរាជារបស់ព្រះបាទ ជយវីរវរ្ម័ន, សោយរាជ្យនៅអង្គរ, តាមរយៈបណ្ដឹងរបស់ វាប សះ (ឈ្មោះជាភាសាខ្មែរ) ឬ សហទេវៈ (ឈ្មោះជាភាសាសំស្ក្រឹត) ក្នុងឆ្នាំ១០០៣នៃគ.ស.។ វាប សះ ជាត្រួតព្រះបញ្ជី (ឆ្មាំវ្រះបញ្ជី) និយាយរៀបរាប់ពីប្រវត្តិដីរបស់ខ្លួន។ ម្ដាយរបស់ វាប សះ ជាចៅរបស់សេនាបតីមួយរូបឈ្មោះ វីរេន្ទ្រវីរៈ, ក្នុងរាជ្យព្រះបាទ ហស៌វរ្ម័នទី២ ដែលសោយរាជ្យនៅកោះកេរ, និង ជាចៅទួតរបស់បុរសម្នាក់ឈ្មោះ គវ្យៈ។ គវ្យៈ, តាមរយៈដីជូនដីតារបស់ខ្លួន, បានទទួលដីមួយកន្លែងដែលខ្លួនបានសុំពីព្រះបាទ រាជេន្ទ្រវរ្ម័ន។ ព្រះរាជាបានចេញព្រះរាជបញ្ជាឱ្យបោះបង្គោលព្រំដីឱ្យ គវ្យៈ។

ក្រោយពី គវ្យៈ ស្លាប់ទៅ មានមនុស្ស៣នាក់គឺឈ្មោះ ហី, ឈ្មោះ បូ និង ឈ្មោះ កេ ចេញមកអះអាងថា ដីនេះជាកម្មសិទ្ធិរបស់ខ្លួន។ តាមរយៈការញុះញង់ពីឈ្មោះ ហេម, ឈ្មោះ បូ បានទៅដកបង្គោលព្រំដី។ វាប សះ បានប្ដឹងដល់ព្រះបាទ ជ័យវរ្ម័នទី៥។ ព្រះរាជាបានចេញបញ្ជាឱ្យគេកាត់ដៃនិងបបូរមាត់ពិរុទ្ធិកជនទាំង២ (ហី និង បូ) ចំណែកឯឈ្មោះ កេ ត្រូវរួចខ្លួនរស់នៅជាមួយគ្រួសារវិញដោយសារជាពូរបស់ វាប សះ។

ក្រោយមក មានមនុស្សអាក្រក់៥នាក់ទៀតបានយកដីកេររបស់ វាប សះ នេះ។ វាប សះ បានប្ដឹងជាថ្មីដល់ព្រះករុណាព្រះបាទ ជយវីរវរ្ម័ន។ ព្រះរាជាបានចេញបញ្ជាឱ្យគេគាបក្បាលជនល្មើសទាំងនោះ។ ក្រោយមកទៀត វាប សះ បានធ្វើអំណោយដីនេះព្រមទាំងវត្ថុជាតង្វាយផ្សេងៗ ដល់ព្រះវិហារលិង្គេត្វរៈ, ដល់ព្រះពុទ្ធ និង ដល់ព្រះពោធិសត្វលោកេត្វរៈ។

តាមការរៀបរាប់ប្រវត្តិដីរបស់ វាប សះ គេដឹងថា ដីទំនាស់ខាងលើមានប្រវត្តិប្រមាណ៣០០ឆ្នាំមកហើយ ពោលគឺ តាំងពីរាជ្យរបស់ព្រះបាទ ជយវរ្ម័នទី២ មកម្ល៉េះ។

## *ករណីសិក្សាទី៩៖ ការទទួលស្គាល់ដោយច្បាប់លើកម្មសិទ្ធិដីធ្លី*

សិលាចារឹកចារឹកអូរស្មាច់ខេត្តឧត្តរមានជ័យ(Ka 17, Ka 18[20]) បានបញ្ជាក់ពីវត្តមានរបស់ព្រះមហាក្សត្រក្នុងការបញ្ជាក់កម្មសិទ្ធិកាន់កាប់ដីធ្លី។ តាមការសង្ខេបន័យរបស់លោកបណ្ឌិត ឡុង សៀម

[20] សូមមើល ឡុង សៀម «សិក្សាកថាសិលាចារឹករកឃើញថ្មីរបស់ព្រះបាទសុរ្យវរ្ម័នទីមួយ (នៅសារមន្ទីរអភិរក្សអង្គរ)», *ទស្សនាវដ្ដីភាសា និង សិលាចារឹកវិទ្យា,* វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា, ឆ្នាំទី១, លេខ១, ខែកញ្ញាព.ស.២៥៤៤ គ.ស.២០០០, ទំ. 19-43។ ក្នុងការសិក្សារបស់លោកសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម សិលាចារឹកនេះមានលេខសម្គាល់ Ka 17 ហើយ លោកសិក្សាដោយធ្វើសេចក្ដីសង្ខេបខ្លឹមសារនិងប្រែចំហៀងជាភាសាខ្មែរប៉ុណ្ណោះ (៥៧បន្ទាត់សិលាចារឹក), មួយចំហៀងទៀតជាភាសាខ្មែរលាយភាសាសំស្ក្រឹត លោកមិនទាន់សិក្សានៅឡើយទេ។ សិលាចារឹកដដែលត្រូវបានសិក្សាដោយលោកស្រីសាស្ត្រាចារ្យបណ្ឌិត ពៅ សាវរស ទាំងផ្នែកភាសាខ្មែរសុទ្ធទាំងផ្នែកភាសាខ្មែរលាយភាសាសំស្ក្រឹត (៣០បន្ទាត់សិលាចារឹកជាភាសាខ្មែរនិង២៩ទៀតជាភាសាសំស្ក្រឹត)។ ក្នុងការសិក្សារបស់លោកស្រី សិលា-ចារឹកនេះមានលេខសម្គាល់ Ka. 18។ ដូច្នេះ, ដោយគិតថា ការដាក់លេខសម្គាល់ជាបញ្ហាបច្ចេកទេស, បញ្ហារបស់យើងនៅទីនេះ គឺផ្ដោតលើខ្លឹមសិលាចារឹកប៉ុណ្ណោះ។ Cf. "Stèle de O Smach (Oudor Mean Chey) Ka. 18,

សិលាចារឹករៀបរាប់ពីព្រះបញ្ជារបស់ព្រះបាទ សូរ្យវរ្ម័នទី១ ឱ្យចារនៅព្រះវិហារសិវលិង្គនៅមធ្យទេសពីព្រះប្រទល់ដីជាកម្មសិទ្ធិរបស់មន្ត្រីជាន់ខ្ពស់មួយរូបឈ្មោះ វ្រះកំស្តេងអញ លក្ស្មីបតិវម៌។ នៅព្រះវិហារសិវលិង្គ គេបានរៀបចំពិធីសាសនាមួយចំនួន ដូចជា ពិធីបូជាយញ្ញដល់ព្រាហ្មណ៍, ពិធីបូជាយញ្ញដល់ព្រះមាតា និង ពិធីអភិសេកសិវលិង្គ។ ពិធីទាំងនេះធ្វើឡើងដើម្បីផ្តល់ភាពស្របច្បាប់ក្នុងការកាន់កាប់ដីធ្លីរបស់មហាមន្ត្រី លក្ស្មីបតិវម៌។ លើសពីនេះ អាយុកាលនៃការកាប់ដីធ្លីនេះមានប្រសិទ្ធភាពតកូនតចៅផៅសន្តាន។ តាមសិលចារឹក មានត្រកូលគ្រួសារមួយឈ្មោះ វៅ ប្រទូស្តនឹងរាជ្យព្រះបាទ សូរ្យ-វរ្ម័នទី១។ ដីធ្លីនិងព្រះវិហារ សុខាវាស ជាអារាមព្រះពុទ្ធសាសនា ដែលគ្រប់គ្រងដោយគ្រួសារនេះត្រូវបានរឹបអូសហើយប្រគល់ដល់មហាមន្ត្រី លក្ស្មីបតិវម៌។ ព្រះរាជាបានបញ្ជាឱ្យលោកមហាមន្ត្រីរូបនេះស្ថាបនាសិវលិង្គជាជំនួសព្រះពុទ្ធរូបនៅព្រះវិហារសុខាវាសវិញ។

### *ករណីសិក្សាទី១០៖ ការបែងចែកទ្រព្យសម្បត្តិដីធ្លីសម្រាប់គ្រួសារនិងអាទិទេព*

ប្រាសាទកន្ទប់ស្ថិតក្នុងខេត្តព្រះវិហារ ស្ថិតនៅខាងត្បូងប្រាសាទតារស់ មានចម្ងាយ១៥០០ម៉ែត្រខាងជើងប្រាសាទថ្នល់ស្វាយ និង មានចម្ងាយ១៥០០ម៉ែត្រដូចគ្នាខាងលិចឆៀងទៅពាយព្យនៃប្រាសាទថ្នល់ឈូក។

នៅសតវត្សរ៍ទី១០ ប្រាសាទកន្ទប់, ប្រាសាទតារស់, ប្រាសាទថ្នល់ស្វាយ និង ប្រាសាទថ្នល់ឈូក ស្ថិតក្រោមការឧបត្ថម្ភពីប្រាសាទអ្នកបួស។ ដើមឡើយ ប្រាសាទកន្ទប់ស្ថិតក្នុងតំបន់ជាំក្សាន្ត។ តាមគេហទំព័រ CISARK របស់សាលាបារាំងចុងបូព៌ា បច្ចុប្បន្ន ប្រាសាទនេះស្ថិតក្នុងស្រុកសង្គមថ្មីខេត្តព្រះវិហារ។

សិលាចារឹកន្ទប់(K.352)ចារក្នុងរាជ្យព្រះបាទ រាជេន្ទ្រវរ្ម័ន នាសតវត្សរ៍ទី១០ បានប្រាប់យើងឲ្យដឹងពីស្ត្រីម្នាក់ឈ្មោះ មហេន្ទ្រណី បានក្រាបបង្គំទូលដល់ព្រះបាទ រាជេន្ទ្រវរ្ម័ន ទាក់ទងនឹងការកសាងសមិទ្ធផលរបស់ខ្លួនគឺ ការស្ថាបនាព្រះសិវលិង្គរុទ្រាបាទ (ប្រាសាទកន្ទប់) ក្នុងស្រុក រុទ្រាបាទ ។

លោកស្រី មហេន្ទ្រណី មានបំណងឲ្យប្រាសាទកន្ទប់ស្ថិតក្រោមការឧបត្ថម្ភរបស់ប្រាសាទសិវបាទ (ប្រាសាទអ្នកបួស)។ គាត់ធ្វើបុញ្ញកម្មនេះរួមគ្នាជាមួយនឹងកូនប្រុសរបស់គាត់ឈ្មោះ ប្រភាព ជាសាស្រ្តាចារ្យ។ គាត់និងកូនប្រុស ផ្គត់ផ្គង់អង្ករប្រាំល្អីជារៀងរាល់ថ្ងៃ និង ផ្តល់អ្នកដណ្តាំស្លម្នាក់ ដល់ប្រាសាទ ដើម្បីធ្វើម្ហូបសម្រាប់ពិធីបូជាយញ្ញ។ សាស្រ្តាចារ្យ ប្រភាព ទទួលសិទ្ធិផ្តាច់មុខក្នុងការធ្វើពិធីបូជាយញ្ញចំពោះព្រះសិវលិង្គនៃប្រាសាទកន្ទប់។

មហេន្ទ្រណីនិងកូនប្រុសបានថ្វាយដល់ព្រះអាទិទេពនូវ រតនៈ, មាស, ប្រាក់, គោ, ក្របី, ខ្ញុំបម្រើប្រុសស្រី។ ពួកគេបានទិញដីស្រែនិងដីភូមិពីមនុស្សជាច្រើន។

ព្រះករុណាព្រះបាទ រាជេន្ទ្រវរ្ម័ន មានព្រះរាជបញ្ជាឲ្យអ្នកគ្រប់គ្រងប្រាសាទអ្នកបួស វាស់ដីភូមិនិងពិនិត្យទ្រព្យសម្បត្តិដែលត្រូវថ្វាយទៅព្រះអាទិទេព (ព្រះសិវៈ, ព្រះវិស្ណុ និង ព្រះនាងសរស្វតី) និង

---

*Nouvelles inscriptions du Cambodge,* II & III, Traduites et éditées par Saveros Pou, (Paris : École française d'Etrême-Orient), 2001, pp. 240-259។

បោះបង្គោលព្រំដី។ ព្រះរាជាបញ្ញត្តិមិនឲ្យមន្ត្រីមូលដ្ឋានណាយក មនុស្ស, ទ្រព្យធន, ភូមិអាករ ដែលជាតង្វាយរបស់ លោកស្រី មហេន្ទ្រណី និង កូនប្រុស ឡើយ។ លោកស្រី មហេន្ទ្រណី បានទូលថ្វាយព្រះរាជាថា ភូមិអាករនិងទ្រព្យដែលគាត់មាន ១ភាគសម្រាប់ថ្វាយព្រះអាទិទេព ១ភាគទៀតសម្រាប់កូនចៅគាត់ ដែលបម្រើព្រះរាជការ ដើម្បីចិញ្ចឹមជីវិត។ គាត់បញ្ជាក់បញ្ហានេះចំនួន២ដងក្នុងសិលាចារឹក។ បន្ទាប់មកគាត់បន្ថែមទៀតថា របស់ទ្រព្យដែលមិនត្រូវបានសរសេររៀបរាប់ក្នុងសិលាចារឹក គឺសម្រាប់កូនចៅគាត់ រីឯរបស់ទ្រព្យដែលបានសរសេររៀបរាប់ក្នុងសិលាចារឹក គឺសម្រាប់អាទិទេព ។

នៅចុងក្រោយ គឺបណ្តាសា។ គាត់សូមឲ្យអ្នកដែលធ្វើឲ្យចម្រើនដល់ការបូជាទាំងឡាយចំពោះព្រះអាទិទេព ទទួលបានផលបុណ្យពាក់កណ្តាល មានសេចក្តីសុខតាមបំណងប្រាថ្នា តាំងពីលោកនេះរហូតដល់បរលោក ដរាបណាព្រះអាទិត្យនិងព្រះចន្ទ្រនៅតែមាន គឺសោយសេចក្តីសុខជានិច្ច។ ចំពោះអ្នក លួចធក់ ឬ ប៉ះពាល់អ្នកបម្រើ, មាស, ប្រាក់, របស់របរ ដែលបូជាដល់ព្រះអាទិទេព សូមឲ្យអ្នកនោះសោយសេចក្តីទុក្ខ ដរាបណាព្រះអាទិត្យនិងព្រះចន្ទ្រនៅតែមាន គឺសោយសេចក្តីទុក្ខជានិច្ច។

### *ករណីសិក្សាទី១១៖ ការច្រូតស្រូវនិងការដកបង្គោលព្រំដីស្រែអ្នកដទៃ*

រឿងក្តីមួយនេះទាក់ទងនឹងការនាំមនុស្សទៅច្រូតស្រូវលើដីអ្នកដទៃនិងការដកបង្គោលសម្គាល់ព្រំដីស្រែរបស់ម្ចាស់ស្រែថែមទៀត។ យើងបានស្រង់ដំណើររឿងនេះ ដោយបានប្រែសម្រួលពីសិលាចារឹក អ្នកតាចារឹក K.181 ខេត្តព្រះវិហារ។ សិលាចារឹកនេះមានកាលបរិច្ឆេទស្ថិតក្នុងសតវត្សរ៍ទី១០ នៅក្នុងរាជ្យព្រះបាទ រាជេន្ទ្រវរ្ម័ន (៩៤៤-៩៦៨ គ.ស.)។

ព្រះបាទ រាជេន្ទ្រវរ្ម័ន មានព្រះរាជបញ្ជាឲ្យតុលាកាត់ក្តីរឿងខាងលើដោយសារបុរសម្នាក់ឈ្មោះ វីរកក្តិគរជ្ជិត។ លោក ជាអភិបាលស្រុក វីរបុរៈ។ លោកបានប្រើមនុស្សឲ្យទៅច្រូតស្រូវនិងដកបង្គោលដីមួយកន្លែងដែលបានបោះបង្គោលតាមព្រះរាជបញ្ជា។

ប្រវត្តិនៃដីនេះ គឺ ដំបូងឡើយ មានមន្ត្រី២នាក់ឈ្មោះ ស្រី វីរេន្ទ្រវម្ម៌ះ និង ស្រី ន្ទបេន្ទ្រាវិមថនៈ បានទិញជាទ្រព្យពីបុរសម្នាក់ឈ្មោះ ងាច ដើម្បីជូនដីនេះដល់គ្រូភ្លេងម្នាក់ឈ្មោះ ចូ និង ក្រុមគ្រួសារ ហើយ ព្រម ទាំងបានសុំព្រះរាជបញ្ជាបោះព្រំដីផង។ គឺភូមិខាងលើនេះហើយដែលលោកអភិបាលស្រុកបានបំពាន។ តុលាការបានសាកសួរ។ លោក អភិបាលស្រុកបានទទួលកំហុសថា គាត់បានប្រព្រឹត្តដូចការចោទមែន តែ មានសាក្សីម្នាក់ឈ្មោះ អម្រឹត បានប្រាប់តុលាការថា ដីដែលលោកអភិបាលស្រុកខាងលើប្រើគេឲ្យទៅដកបង្គោលនោះ គឺជាដីស្ថិតនៅកន្លែងផ្សេងទេ។

ជាចុងក្រោយ តុលាការបានពិន័យលោកអភិបាល ស្រុករូបនេះជា មាស១០តម្លឹង ហើយ ប្អូនរបស់គាត់ដែលបញ្ជាឲ្យគេទៅច្រូតស្រូវ នៅដីនោះត្រូវវាយខ្នងចំនួន១០២ផ្តៅ ចំណែកសាក្សី ដែលផ្តល់ចម្លើយខុសការពិត ត្រូវទទួលទោសដោយត្រូវវាយខ្នងចំនួន១០២ផ្តៅដែរ។ ចំពោះបុរសម្នាក់ទៀតឈ្មោះ បិត ដែលនាំគ្នីគ្នាទៅច្រូតស្រូវនោះក៏ត្រូវពិន័យផងដែរ។ ព្រះរាជានិងតុលាការបានផ្តល់យុត្តិធម៌ និងសម្រេចប្រគល់ដីជូនម្ចាស់ដើមវិញ។

យើងសូមស្រង់ដំណើររឿងក្ដីដីធ្លីមួយទៀតតាមរយៈការប្រែសម្រួលពីសិលាចារឹកអូរស្មាច់ ខេត្តឧត្ដរមានជ័យ Ka.18។ សិលាចារឹកនេះមានកាលបរិច្ឆេទស្ថិតក្នុងសតវត្សរ៍ទី១២ នៅក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២ (១១១៣-១១៥០គ.ស.)។

ដំណើររឿងមានដូចតទៅ នាគ្រិស្តសករាជ១១១២ មន្ត្រីជាន់ខ្ពស់ម្នាក់ឈ្មោះ ព្រះកំស្ដែង ស្រីលក្ស្មិបតិវរ្ម័ន បានទិញភូមិមាត់ចង្វាពីបុរសម្នាក់ឈ្មោះ ជូ នៅប្រឡាយ ម្រឹតកធន ដោយដោះដូរគ្នាជាមួយនឹងរបស់មួយចំនួន។ សិលាចារឹកមានបញ្ជាក់ច្បាស់ពីព្រំប្រទល់ដីភូមិនេះថាជាប់នឹងភូមិណាៗ។ គួរកត់សម្គាល់ថា នៅខាងជើងភូមិមាត់ចង្វានេះ មានភូមិមួយជាកម្មសិទ្ធិរបស់កំស្ដែង ជលវន្ទ។

មកដល់គ្រិស្តសករាជ១១១៣ ទំនាស់បានកើតឡើងដោយសារមន្ត្រីម្នាក់ឈ្មោះ កំស្ដែង មលួយ, ដោយអាងអំណាច, បានប្រើមនុស្សឲ្យទៅច្រូតស្រូវនៅភូមិព្រះពួក។ ភូមិនេះក៏ជារបស់ព្រះកំស្ដែង ស្រីលក្ស្មិបតិវរ្ម័ន ដែរ។ កំស្ដែង មលួយ បានឲ្យភូមិព្រះពួកទៅបុរសឈ្មោះ ជូ។ ព្រះកំស្ដែង ស្រីលក្ស្មិបតិវរ្ម័ន បានទូលព្រះរាជាគ្រប់ដំណើរដើមទងនៃប្រវត្តិរបស់ភូមិព្រះពួកនេះ។ ក្រោយពីព្រះបាទ សូរ្យវរ្ម័នទី២ទ្រង់ជ្រាបហើយ ទ្រង់ពិរោធយ៉ាងខ្លាំង ហើយ ទ្រង់បង្គាប់តុលាការ, ដែលសម័យនោះ គេហៅថា «ព្រះសភា» (ឬ «វ្រះសភា» តាមសិលាចារឹក), វិនិច្ឆ័យរឿងក្ដីនេះ។ សមាសភាពនៃអង្គជំនុំជម្រះមាន ព្រះកំស្ដែង សិវបាទ ជាប្រធានតុលាការកម្រិត៣, ព្រះកំស្ដែងអញ គិរិបាទ ជាប្រធានតុលាការកម្រិត២ និង កំស្ដែង កុតិ រុង ជាមន្ត្រីផ្នែកគុណទោសកម្រិត២។

តុលាការបានសម្រេចឲ្យ បុរសឈ្មោះ ជូ ចាញ់ក្ដីព្រះកំស្ដែង ស្រីលក្ស្មិបតិវរ្ម័ន និង បង្គាប់ឲ្យគេដាក់ច្រវាក់ឈ្មោះ ជូ នេះ។ បុរសឈ្មោះ ជូ បានថ្វាយទ្រព្យដើម្បីសុំរស់ជីវិត ហើយ ប្រគល់កម្មសិទ្ធិភូមិព្រះពួកទៅព្រះកំស្ដែង ស្រីលក្ស្មិបតិវរ្ម័នវិញ។

ក្រោយមក ព្រះរាជាបានថ្វាយភូមិព្រះពួកចំពោះព្រះអាទិទេពសិវលិង្គដែលមានកម្ពស់១២ហត្ថ នៅមាទ្យា-ទេស។ ព្រះអង្គបានត្រាស់បង្គាប់ ស្ដេងអញ ភវនាទិត្យ ជាមន្ត្រីតុលាការ និង មន្ត្រីស៊ើបអង្កេតកម្រិតបី១រូប ឲ្យទៅនាំចាស់ទុំនិងអ្នកគ្រប់គ្រងមនុស្សប្រុសក្នុងភូមិព្រះពួកចំនួន៤នាក់មកធ្វើជាសាក្សីក្នុងការបោះបង្គោលព្រំដីភូមិនេះ។ លើសពីនេះ ព្រះបរមរាជាបាន«សូម»កំស្ដែង ជលវន្ទ ដែលមានភូមិជាប់នឹងភូមិព្រះពួកនេះឲ្យចូលរួមការបោះបង្គោលព្រំដីនោះផង។

### *ករណីសិក្សាទី១២៖ ការសុំទទួលស្គាល់ភាពជាម្ចាស់កម្មសិទ្ធិតាមរយៈតុលាការ*

សិលាចារឹកគោកពោធិ៍នៃក្រុមប្រាសាទគោកពោធិ៍ ស្ថិតនៅខាងជើងបារាយណ៍ខាងលិច ខេត្តសៀមរាប គ.ស.៩៧៩ រៀបរាប់ពីបណ្ដឹងរបស់មន្ត្រីម្នាក់មានជា ខ្លោញពល ឈ្មោះ ត្រវាង៌វ្រាហ្មណ (ត្រពាំងព្រាហ្មណ៍) ទៅតុលាការ(នៅសម័យនោះ គេហៅថា រាជសភា) សុំឱ្យវាស់វែងដីនិងទទួលស្គាល់កម្មសិទ្ធិដីធ្លីដែលខ្លួនមាន។ មានសេចក្ដីសម្រេចរបស់តុលាការ (វ្រះអាជ្ញា) ដល់មន្ត្រីតុលាការនិងអ្នកពាក់ព័ន្ធមួយចំនួនអនុវត្ត។ មន្ត្រីនិងអ្នកពាក់ព័ន្ធទាំងនោះមាន ម្រតាញ គ្រី ឫទ្ធិវីរេន្ទ្របណ្ឌិត ជាគុណទោមទរគី (អ្នកកាត់សេចក្ដីខុសត្រូវ), អ្នកលក់ គឺ វាបិ មៅ និង វាបិ វិសិ ជាធម្មាធិការណបាល (អ្នកទទួលបន្ទុករឿងបណ្ដឹង), វាបិ បិតិ ជាតម្រួតអម្វតកធន (អ្នកកាប់ទ្រព្យសម្បត្តិអាទិ

ទេព), វាប៊ិ ធម៌ាចារ្យ ជាតម្រួតរង្វាង់កម្រិត៣។ អ្នកទាំងអស់ត្រូវបំពេញកាតព្វកិច្ច កំណត់ព្រះដីឈ្មោះ អារាម និង ហៅអ្នកដឹងឮ(សាក្សី)ដែលមាន បុរុមប្រធាន, គ្រាមវ្រួធ និង ចាស់ទុំក្នុងទិសទាំងបួននៅភូមិនោះឱ្យមកចូលរួមកិច្ចការកំណត់ព្រំដីជូនលោកមន្ត្រី ត្រពាំងព្រាហ្មណ៍។ លោក មៅ និង លោក វិស ជាអ្នកបង្ហាញទីតាំងដីដើម្បីបោះបង្គោលនៅទិសទាំងបួន (ជើង, ត្បូង, លិច, កើត) ហើយ ម្ចាស់កម្មសិទ្ធគឺលោក ត្រពាំងព្រាហ្មណ៍ ទូងស្គរជុំវិញដីនោះ។ សកម្មភាពវាស់វែងនិងបោះបង្គោលនេះត្រូវធ្វើនៅចំពោះមុខអ្នកពាក់ព័ន្ធ។

នៅគ.ស.១០០៤ លោក ត្រពាំងព្រាហ្មណ៍ បានទិញដីស្រែពីមនុស្សមួយចំនួន។ ប្រហាក់ប្រហាក់ហែលនឹងករណីខាងលើដែរ អ្នកពាក់ព័ន្ធនិងអ្នកចូលរួមមាន ម្ចាស់ដីនិងអ្នកលក់ និង មន្ត្រីមួយចំនួន៖ ស្តេញអញ វិទ្យាគ្រម ជាប្រធាននៃអាចារ្យទាំងឡាយនិងជាប្រធានតុលាការ, ម្រតាញ ជយេន្ទ្របណ្ឌិត ជាអ្នកកាត់សេចក្តីខុសត្រូវ, ម្រតាញ ឫទ្ធិវិន្ទ្របណ្ឌិត ជាអ្នកសូត្រគម្ពីរធម្មសាស្ត្រ, ម្រតាញ ន្ទបតីន្ទ្រាទិត្យា ជាអ្នកត្រួតក្មេងបម្រើនៅស្រុក ច្បូង រមាំង និង វាប៊ិ ធម៌ាចារ្យ ជាតម្រួតរង្វាង់កម្រិត៣។[21]

## ២.១- គោលនយោបាយរដ្ឋបាលដីធ្លីនៅសម័យមុនអង្គរ

ប្រវត្តិវិទូ ម៉ៃឃើល វីកឃើរី បានសន្និដ្ឋានទាក់ទងនឹងកម្មសិទ្ធិដីធ្លីនៅសម័យមុនអង្គរថា ព្រះរាជាមិនមានភាពជាម្ចាស់កម្មសិទ្ធិដាក់លាក់លើដីធ្លីនោះទេ។ ដោយផ្អែកលើសិលាចារឹក លោកកត់សម្គាល់ថា ដីធ្លីដែលថ្វាយព្រះអាទិទេពឬព្រះវិហារ ឬ ដីធ្លីដែលដោះដូរគ្នា ដោយ ប៉ោញ, ម្រតាញ និង មន្ត្រីដទៃទៀតនោះ មិនមែនជារបស់ផ្ទាល់ខ្លួននោះទេ ប៉ុន្តែ ជារបស់សហគមន៍ឬអ្នកដែលស្ថិតក្រោមអំណាចរបស់ ប៉ោញ, ម្រតាញ, កុរាក ជាដើម។[22]

## ២.២- គោលនយោបាយរដ្ឋបាលដីធ្លីនៅសម័យអង្គរ

កម្មសិទ្ធិដីធ្លីមានលក្ខណៈច្បាស់លាស់នៅសម័យអង្គរ។ ក្នុងការកាន់កាប់នេះ គេសង្កេតឃើញមានមានមូលដ្ឋានបីដែលបញ្ជាក់ភាពជាម្ចាស់លើដីធ្លី។ មូលដ្ឋានទីមួយ គឺ ការទិញដូរឬលក់រវាងភាគីអ្នកលក់អ្នកដូរនិងអ្នកទិញ, មូលដ្ឋានទីពីរ គឺ ការវាស់ចារលើថ្មចារឹកពី ឈ្មោះមនុស្សដែលទាក់ទង វត្ថុដែលត្រូវបានយកមកធ្វើមធ្យោបាយនៃការដោះដូរឬទិញ និង ទីតាំងឬព្រំប្រទល់បញ្ជាក់ទីតាំង, មូលដ្ឋានបី គឺ ការទទួលស្គាល់របស់តុលាការដែនដីលើការដោះដូរឬទិញលក់នោះ។ ក្នុងករណីពិសេសម្ចាស់កម្មសិទ្ធិនឹងទទួលការបញ្ជាក់នូវសិទ្ធិពីព្រះរាជាក្នុងការកាន់កាប់ដីធ្លីនោះអស់មួយពូជអម្បូររបស់ខ្លួន ដែលតាមសិលាចារឹក មានន័យម្ចាស់ដីនោះអាចនឹងកាន់កាប់ដីរបស់ខ្លួនរហូត«ដរាបណាព្រះអាទិត្យព្រះចន្ទនៅតែមាន»។

---

[21] Coedès Georges, Dupont Pierre. Les inscriptions du Pràsàt Kôk Pô. In: Bulletin de l'Ecole française d'Extrême-Orient. Tome 37, 1937. pp. 379-413; R. C. Majumdar, *Inscriptions of Kambuja,* (Calcutta: The Asiatic Society, 1953), pp. 311-319.

[22] Michael Vickery, *Society, Economics, and Politics in Pre-Angkor Cambodia: The 7th-8th Centuries,* (Tokyo: The Centre for East Asian Cultural Studies for Unesco, The Toyo Bunko, 1998), p.299.

ដើម្បីយល់ស្ថានភាពនៃការគ្រប់គ្រងដីនៅសម័យអង្គរ គេគប្បីយល់បច្ចេកសព្ទខ្លះនៅសម័យនោះដែលគេប្រើសម្គាល់ឬសម្រាប់ចែករដ្ឋបាលដែនដី, ពាក្យទាំងនោះគឺ *គ្រាម, ប្រមាណ, ស្រុក, វិមយ*។ អ្នកស្រាវជ្រាវបានកត់សម្គាល់ឃើញថា ប្រមាណអាចមានធំនិងគ្របដណ្ដប់លើស្រុក។ ពេលខ្លះ គ្រាមត្រូវបានគេប្រើដោយមានន័យប្រហាក់ប្រហែលនឹងស្រុក ដូចជា *គ្រាមវិភេទ* ឬ *ស្រុកវិភេទ*។ ពេលខ្លះគ្រាមច្រើនផ្គុំគ្នាបង្កើតជាស្រុក ដូចជាឈ្មោះថា *ស្រុកតត្រៃវិង្សតិ*។ យើងសង្កេតឃើញថា ប្រមាណនេះមានលក្ខណៈជាការបែងចែកតំបន់ដីធំៗគ្របដណ្ដប់លើ បុរៈ ទៀត ដូចជា *ស្រុកផ្ទៃអាយវ្យែក ប្រមាណគ្រឹឥន្ទ្របុរ* (K. 105)។ បុរៈមួយចំនួនអាចជាប្រមាណឬវិស័យ។ នៅសម័យអង្គរ មានបុរៈជាច្រើនជាប្រមាណដូចជា *គម្ពុបុរ, វ្យែក, ឥន្ទ្របុរ* (និងក៏ជា *វិមយ*), *មល្យង៑* (ក្រោយមកក្លាយជា *វិមយ*), *ឧគ្របុរ, អមោឃបុរ, ភីមបុរ, បុន្ទរបុរ, ជេងវ្នំ, ប្រគានវ្រៃម្សេត៑, ជេងតរាញ៑, បូរ៌ទិគ, លវោ*។ ស្ថាននាមខ្លះជាវិស័យដូចជា *វ្យាធបុរ, សន្ទុក, ធន្យបុរ, សង្វះ* ជាដើម។[23]

## ២.៣- គោលនយោបាយរដ្ឋបាលដីធ្លីនៅសម័យមុនអង្គរនិងសម័យអង្គរ

តាមទិន្នន័យសិលាចារឹក យើងបានដឹងពីការប្រកបកសិកម្មនៅសម័យមុនអង្គរនិងសម័យអង្គរ។ ការសិក្សាបញ្ហាមួយក្នុងសង្គម បញ្ហាដទៃទៀតដែលពាក់ព័ន្ធបានលេចឡើង។ ការសិក្សាទិដ្ឋភាពសង្គមនយោបាយទាក់ទងនឹងដីធ្លីជាការសិក្សាមានលក្ខណៈបរិយាបន្ន ពីព្រោះ វិស័យផ្សេងៗក្នុងទម្រង់សង្គម, ទោះបច្ចុប្បន្នក្ដី ទៅអតីតកាលក្ដី, សុទ្ធតែមានគោលដៅបម្រើមនុស្សក្នុងសង្គមនោះ។ វាជាការចាំបាច់ដែលយើងត្រូវយល់ដឹងផ្នែកច្បាប់ផ្នែកសាសនានៅសម័យកាលនោះថាមានលក្ខណៈដូចម្ដេចទើបយើងអាចទាញសេចក្ដីសន្និដ្ឋានមួយមានរឹងមាំ។

### ២.៣.១- ច្បាប់, មនុស្ស និង ស្ថាប័ន

សម័យបុរាណមានច្បាប់ទម្លាប់ដោយឡែកពីសម័យបច្ចុប្បន្ន ហើយ ការប្រតិបត្តិពីប្រទេសមួយទៅប្រទេសមួយក៏មានលក្ខណៈដោយឡែកដែរ។ តាមសិលាចារឹក គេដឹងអ្នកដឹកនាំខ្មែរទាំងផ្នែកអាណាចក្រនិងធម្មចក្រមានចំណេះដឹងផ្នែកគម្ពីរ *វេទ, វេទាង្គ,*[24] *បុរាណៈ, សិទ្ធាន, តន្ត្រៈ* និង គម្ពីរឥណ្ឌាជាច្រើនទៀត។ ក្នុងការគ្រប់គ្រងផ្នែកសាសនា គម្ពីរវេទជាមូលដ្ឋាន ហើយ ក្នុងការគ្រប់គ្រងរដ្ឋគម្ពីរអាថ៌សាស្ត្រនិងធម៌សាស្ត្រជាមូលដ្ឋាន។

---

[23] Sachchidanand SAHAI, *Les institutions politiques et l'organisation administrative du Cambodge ancient ( VIe-XIIIe siècle ),* ( Paris : EFEO, 1970 ), pp. 71-79.

[24] សិលាចារឹកតាំងក្រង ស្រុកជើងព្រៃ ខេត្តកំពង់ចាម បញ្ជាក់ពីព្រាហ្មណ៍ម្នាក់ឈ្មោះ ធម៌ស្វាមី, ក្នុងរាជ្យព្រះបាទ ជ័យវរ្ម័នទី១, សតវត្សរ៍ទី៧, ជាអ្នកមានចំណេះដឹងផ្នែកគម្ពីរវេទនិងវេទាង្គ។ សិលាចារឹកប្រាសាទ គោកពោធិ៍, ប្រាង្គB ( K. 256 ), ខាងជើងបារាយណ៍ខាងលិច, ខេត្តសៀមរាប, និយាយពីព្រាហ្មណ៍ម្នាក់នៅសតវត្សរ៍ទី៩ឈ្មោះ គ្រី និវាសកវិទី១ ឬ ប្ញថិវីន្ទ្របណ្ឌិត ជាព្រះរាជគ្រូព្រះបាទជ័យវរ្ម័នទី៣។ ព្រាហ្មណ៍នេះ មានចំណេះដឹងផ្នែកគម្ពីរ វេទ, វេយ្យាករណៈ, ចាក់ធ្លុះក្នុងប្រព័ន្ធទស្សនវិជ្ជា។ សិលាចារឹកប្រាសាទបន្ទាយស្រី, សតវត្សរ៍ទី១០, និយាយពីកាតព្វកិច្ចរបស់អ្នកគ្រប់គ្រងប្រាសាទដែលត្រូវទទួលភ្ញៀវនិងការសូត្រគម្ពីរវេទមិនឈប់ដោយសាស្ត្រាចារ្យ។ សិលា-ចារឹកប្រាសាទមង្គលាថ៌នៅអង្គរធំ( K. 488 )និយាយពីព្រាហ្មណ៍ម្នាក់ ជាភារទ្វាជគោត្រ មានកំណើតនៅនរបតិទេគ, ដែលអ្នកប្រាជ្ញខ្លះយល់ថាត្រូវនឹងប្រទេសភូមាបច្ចុប្បន្ន, បានធ្វើដំណើរមកកាន់ប្រទេសកម្ពុជានៅសតវត្សរ៍ទី១២ក្រោយពីដឹងប្រទេសនេះមានអ្នកប្រាជ្ញផ្នែកគម្ពីរវេទច្រើន។ គាត់បានបង្កើតក្រុមគ្រួសារដ៏ធំមួយនៅប្រទេសកម្ពុជានៅសម័យអង្គរ។ គាត់មានរស់នៅរហូតដល់អាយុ១០៤ឆ្នាំ។

អាថ៌សាស្ត្រទាក់ទងនឹងនយោបាយគ្រប់គ្រងប្រទេស។ គម្ពីរនេះនិយាយពីតួនាទីរបស់ ព្រះរាជា, មន្ត្រីសេនាបតី, រាជវង្សានុវង្ស និង បព្វជិត; ការពារពាណិជ្ជករសិប្បករ, ការដាក់ទោសទណ្ឌផ្សេងៗ; ការចងសម្ព័ន្ធមេត្រីជាមួយនានាប្រទេស, សង្គ្រាម, សន្តិភាព, ការប្រកាន់ជំហរនយោបាយ; ...។[25] ធម៌សាស្ត្រជាគម្ពីរច្បាប់ដែលនិយាយពីការគ្រប់គ្រងរដ្ឋដែរ ប៉ុន្តែ វាមានលក្ខណៈល្អិតល្អន់ជាងពិស្តារជាងបរិយាបន្នជាងនិងមានបុរាណភាពជាង។[26]

តាមសិលាចារឹកខ្មែរ ក្នុងការកាត់ក្តី «រាជសភា»ជាតុលាការ។ តុលាការសម្រេចក្តីដោយអនុវត្តតាមគម្ពីរធម្មសាស្ត្រដែលយើងអាចនិយាយបានមានមន្ត្រីច្បាប់ដែលមានចំណេះដឹងលើគម្ពីរនេះចូលរួមតាមតម្រូវការរបស់តុលាការ។ គួរកត់សម្គាល់ត្រង់ចំណុចនេះថា តាមសិលាចារឹក ចំណេះដឹងរបស់បុព្វជនខ្មែរសម័យបុរាណមានគម្ពីរភាពលើគម្ពីរធម្មសាស្ត្រ។ យើងសង្កេតឃើញថា ក្នុងវិស័យច្បាប់ឬតុលាការសម័យនោះ គេទាមទារចាំបាច់មានអ្នកជំនាញខាងផ្នែកធម្មសាស្ត្រ ពីព្រោះ វាជាច្បាប់គោលក្នុងការកាត់សេចក្តី។[27]

---

[25] Cf. *Kaultiya's Arthashastra,* Trans. R. Shamasastry. Bangalore: Government Press, 1915.

[26] Cf. Pandurang Vaman Kane, *History of Dhamrmaśastra (Ancient and Mediaeval Religious and Civil Law in India),* Vol. I, Poona: Bhandarkar Oriental Research Institute, 1930, p. 9. គេពិបាកនឹងកំណត់ឱ្យបានច្បាស់លាស់ពីកាលបរិច្ឆេទរបស់គម្ពីរធម៌សាស្ត្រនិងអថ៌សាស្ត្រ ហើយ វាក៏ដូចគ្នានឹងគម្ពីរបុរាណមួយចំនួនដែរ ពីព្រោះ ជាទីទៅ គេដឹងតាមរយៈសំណេររបស់អ្នកនិពន្ធណាម្នាក់។ ទោះយ៉ាងណាក្តី ដើម្បីជាគោលក្នុងការសិក្សា យើងផ្អែកលើការស្រាវស្រាវរបស់លោកបណ្ឌិត Pandurang Vaman Kane ដែលបានធ្វើជាកាលប្បវត្តិសម្រាប់តាមដានប្រវត្តិនៃគម្ពីរឥណ្ឌាមួយចំនួន (Cf. pp. xvii-xxiii)៖

សហស្សវត្សរ៍ទី៥–សហស្សវត្សរ៍ទី២មុនគ.ស.ជា **វេទ**; ស.វ.ទី៩–ស.វ.ទី៦មុនគ.ស. **និរុក្ត**, ស.វ.ទី៩មុនគ.ស.–ស.វ.ទី៥មុនគ.ស. **ស្រៅតសូត្រ**; ស.វ.ទី៧ដល់ស.វ.ទី៤មុនគ.ស. **ធម៌សូត្រ**របស់ គៅតម, អាបស្តម្ព, បៅធ្យាយនៈ, វសិស្ថ និង **គ្ឫហ្យសូត្រ**របស់ បារស្ករៈ និង អ្នកនិពន្ធដទៃទៀត; ស.វ.ទី៦មុនគ.ស. –ស.វ.ទី៣មុនគ.ស. បាណិនិ; ស.វ.ទី៦មុនគ.ស. –ស.វ.ទី៣មុនគ.ស. **បូវ៌មិ-មំសសូត្រ**របស់ ដៃមិនិ; ស.វ.ទី៤មុនគ.ស. –ស.វ.ទី២នៃគ.ស. **អាថ៌សាស្ត្រ**របស់ កៅតិល្យ; ឆ្នាំ១៥០មុនគ.ស. **មហាភាឞ្យ**របស់ បតញ្ជលិ; ស.វ.ទី៣មុនគ.ស. –ស.វ.ទី២នៃគ.ស. **មនុស្មតិ**; ស.វ.ទី២នៃគ.ស. –ស.វ.ទី៤មុនគ.ស. **យាជ្ញវល្ក្យស្មតិ**; ស.វ.ទី២នៃ គ.ស. –ស.វ.ទី៤នៃគ.ស. **វិស្ណុធម៌សូត្រ**; ស.វ.ទី២នៃគ.ស. –ស.វ.ទី៥នៃគ.ស. **នារទស្មតិ**; ស.វ.ទី៣នៃគ.ស. –ស.វ.ទី៦នៃគ.ស. **គពរ**របស់ដៃមិនិ; ស.វ.ទី៤នៃគ.ស.–ស.វ.ទី៦នៃគ.ស. **ព្ឫហស្បតិស្មតិ** ស្តីពី វ្យវហារ; ស.វ.ទី៤នៃគ.ស. –ស.វ.ទី៧នៃគ.ស. មានគម្ពីរបុរាណៈមួយចំនួនដូចជា **វាយុ**, **វិស្ណុ**, **មាក៌នទេយៈ**, **មត្ស្យ**, **កូម៌**; ស.វ.ទី៥នៃគ.ស. –ស.វ.ទី៧មុនគ.ស. **កាត្យាយនស្មតិ** ស្តីពី វ្យវហារ; ស.វ.ទី៥នៃគ.ស. –ស.វ.ទី៧នៃគ.ស. **កាមន្ទ កីយនីតិសារ**; ស.វ.ទី៦នៃគ.ស. **ព្ឫហតសំសិតា**, **ព្ឫហជជាតក**, **បញ្ចសិទ្ធាន** និង ស្នាដៃដទៃទៀតរបស់ វរាហមិហិរៈ; ស.វ.ទី៧នៃគ.ស. **កាទ្ពរី** និង **ហរសចរិត** របស់ ពានៈ; ស.វ.ទី៧នៃគ.ស. –ស.វ.ទី៨នៃគ.ស. **ឝ្លោកវារតិកៈ**, **តន្ត្រវារតិកៈ** និង **ដុបទីកា** របស់ កុមារិលភត្ត; ស.វ.ទី៧នៃគ.ស., ស.វ.ទី១០នៃគ.ស. **ស្មតិ**ស្ទើរតែទាំងអស់និង **បុរាណៈ**មួយចំនួន; ស.វ.ទី៨នៃគ.ស. –ស.វ.ទី៩នៃគ.ស. គង្ករាចារ្យ; ស.វ.ទី៩នៃគ.ស. **យាជ្ញវល្ក្យស្មតិ**របស់ វិស្វរូប; ស.វ.ទី១០នៃគ.ស. –ស.វ.ទី១២នៃគ.ស. **គាស្ត្រទីបិកា**, **តន្ត្ររត្នៈ** និង **ន្យាយរត្នាករៈ** របស់ បារថសារថិមិស្រៈ; ស.វ.ទី១០នៃគ.ស. **ព្ឫហតសំហិតា** និង **ព្ឫហជជាតកៈ** របស់ ឧតបលៈ; ស.វ.ទី១១នៃគ.ស. **ធារេស្វរៈ** (ភោជៈ); ស.វ.ទី១១នៃគ.ស. –ស.វ.ទី១២នៃគ.ស. **មិតាក្សរា**-របស់ វិជ្ញានេគ្វរៈ; ស.វ.ទី១១នៃគ.ស. –ស.វ.ទី១២នៃគ.ស. **មនុស្មតិ** របស់ គោវិទរាជ; ស.វ.ទី១២នៃគ.ស. **ក្ឫត្យកល្បតរុ** ឬ **កល្បតរុ**របស់ លក្ឞ្មីធរៈ; ស.វ.ទី១២នៃគ.ស. **ទាយភាគៈ**, **កាលវិវេកៈ** និង **វ្យវហារមាត្រកា** របស់ ជិមូតវាហនៈ; ស.វ.ទី១២នៃគ.ស. **សិ-ទ្ធាន្តសិរោមានី**របស់ ភាស្ករាចារ្យ ដែល លីលាវតី បានចូលរួមចំណែដែរ។ យើងសូមស្រង់ឆ្នាំស្នាដៃនិងអ្នកនិពន្ធត្រឹមនេះ ពីព្រោះ យើងយល់ថា គំនិតដែលកើតចេញពីគម្ពីរខាងលើអាចជាជំនួយដល់ការពិចារណាទាក់ទងនឹងនឹងប្រព័ន្ធគំនិតឬប្រព័ន្ធច្បាប់សម័យមុនអង្គរនិងសម័យអង្គរ។

[27] សិលាចារឹកមួយចំនួនបានបញ្ជាក់ពីបញ្ហានេះដូចជា វ្រះកម្រតេង៑អញ៑វិទ្យាគ្រមស្វតិវ្រះធម៌គាស្ត្រ (សិលាចារឹកបាសែតឆ្នាំ៩៦៤គកៈ, គ្រិស្តសករាជ១០៤២, ផ្តែរខាងត្បូងនៃទ្វារខាងលិច, ប.៦១); សិលាចារឹកនិយាយសរសើរពីព្រះបាទ សូរ្យវរ្ម័នទី១ ដែលមានចំណេះដឹងផ្នែក មហាភាឞ្យៈ, កាព្យ, ទស៌នៈទាំង៦ និង គម្ពីរវេយ្យាករណ៍ដទៃទៀត (សិលាចារឹកព្រះខាន់, ប.៦); សិលាចារឹកស្តុកកក់ក្នុងរាជ្យព្រះបាទ ឧទយាទិត្យវរ្ម័នទី២ សរសើរពីព្រះរាជគ្រូរបស់ទ្រង់នាម វ្រះក្រម្រតេង៑អញ៑ គ្រីជយេន្ទ្រវរ្ម័ន។ ព្រះរាជាបានសិក្សាពីព្រះរាជគ្រូនេះគ្រប់វិជ្ជាទាំងអស់មានដូចជា សិទ្ធាន, វ្យាករណៈ, ធម៌សាស្ត្រ និង សាស្ត្រៈ ដទៃទៀត (សិលាចារឹកស្តុកកក់ធំ, ស.វ.

ក្នុងលទ្ធិព្រាហ្មណ៍ មុនក្លាយជាព្រះមហាក្សត្រ គេត្រូវឆ្លងកាត់ការសិក្សាគម្ពីរវេទនិងគម្ពីរដទៃទៀតតាមកម្មវិធីសិក្សាដូចជា ត្រយី, អាវីក្សិកី; វាត៌្តា និង ទណ្ឌនីតិ ដែលមុខវិជ្ជាទាំងនេះបង្រៀនដោយអ្នកប្រាជ្ញល្បី, ចៅក្រសួង និង អ្នកជំនាញផ្នែកទ្រឹស្ដីគ្រប់គ្រងរដ្ឋ។ ក្រៅពីនេះ ទ្រង់ត្រូវស្ដាប់បាឋកថាពីសាស្ត្រាចារ្យនានានូវគម្ពីរមួយចំនួន ដូចជា បុរាណៈ, ឥតិវុត្ត, អាខ្យាយិកា, ឧទាហរណៈ, ធម៌គាស្ត្រ និង អាថ៌គាស្ត្រ។ ក្រៅពីនេះ ទ្រង់ត្រូវសិក្សាមុខវិជ្ជាផ្នែកកងទ័ព ដូចជា ហស្តិវិទ្យា (វិជ្ជាទាក់ទងនឹងដំរី), អឞ្វវិទ្យា វិជ្ជាទាក់ទងនឹងសេះ), រថវិទ្យា (វិជ្ជាទាក់ទងនឹងរថ) និង ប្រហរណវិទ្យា (វិជ្ជាទាក់ទងនឹងអាវុធ)។ យុវក្សត្រត្រូវរៀងរហូតអាយុ១៦ឆ្នាំ។[28]

យើងតែងសង្កេតឃើញថា ក្នុងការទិញលក់ដីធ្លីឬរឿងក្ដីក្ដាំ ក្រោយពីម្ចាស់ដីប្ដឹងទៅតុលាការឱ្យដឹងឮ។ ចុងក្រោយប្រភពចេញសេចក្ដីសម្រេចគឺព្រះរាជា។ សេចក្ដីសម្រេចនេះជាការបន្ថែមភាពស្របច្បាប់ផ្លូវការ។ ព្រះរាជាមានសិទ្ធិចាត់ចែងលើដីទាំងអស់ ទាំងផ្លូវលោក ទាំងផ្លូវធម៌។ ក្នុងផ្នែកសាសនាទ្រង់មានភារកិច្ចប្រទានដីធ្លីដីព្រៃឈើ[29]សម្រាប់វត្តអារាមនិងការពារភ័យន្តរាយទាំងឡាយដែលប៉ះពាល់ដល់ព្រះរាជប្រទាន។ ក្នុងផ្នែកសង្គម ព្រះរាជាជាតំណាងគុណធម៌និងយុត្តិធម៌ដែលផ្ដល់ភាពសុខសាន្តនិងភាពសម្បូរសប្បាយដល់ប្រជារាស្ត្រនិងមន្ត្រីក្នុងដែនដី។

ក្រៅពីរឿងក្ដីព្រហ្មទណ្ឌ គេសង្កេតមានក្ដីរដ្ឋប្បវេណីមួយចំនួនដែរដែលគេបានប្ដឹងទៅតុលាការដើម្បីដោះស្រាយ និយាយមួយបែបទៀត តុលាការដោះស្រាយទាំងរឿងក្ដីព្រហ្មទណ្ឌទាំងរឿងក្ដីរដ្ឋប្បវេណី ដូចករណីសិក្សាមួយចំនួនដែលយើងបានបង្ហាញខាងលើ។

តាមសិលាចារឹក បន្ទាប់ពីមានការផ្ដល់ហើយ អាជ្ញាសាលា(រង្វាង)ត្រូវចុះតាមដាន ហើយ នៅពេលសម្រេច ត្រូវមានមន្ត្រីជំនាញផ្នែកគម្ពីរធម៌សាស្ត្រដើម្បីពិភាក្សា។ ក្នុងករណីទិញលក់ដីធ្លី គេត្រូវប្ដឹងទៅរាជសភាដើម្បីចេញសេចក្ដីសម្រេច ក្រោយពីដើមបណ្ដឹងបានទិញដូររួចស្រេចបាច់ (វត្ថុដែលត្រូវទិញដូរនឹងគ្នា)។ ព្រះរាជាប្រទានសិទ្ធិដល់តុលាការជាអ្នកចាត់ចែងលើកិច្ចការវាស់វែងដីធ្លីជូនដើមបណ្ដឹងដែលមានការចូលរួមពីចាស់ទុំក្នុងស្រុកភូមិជាសាក្សី។ សាក្សីត្រូវធ្វើសម្បថបញ្ជាក់ពីការសម្ដីរបស់ខ្លួន។

ជាទូទៅ មន្ត្រីនិងអភិជនសម័យនោះចូលរួមក្នុងសកម្មភាពទិញលក់ដោះដូរដីធ្លី។ ប៉ុន្តែ ចំណុចគួរកត់សម្គាល់នោះគឺ ករណីភាគច្រើនដែលអ្នកទាំងនោះទិញដីស្រែចម្ការច្បារដំណាំព្រមទាំងអ្នកប្រើ

ទី១១, ប.៦៤-៧០); ក្នុងសិលាចារឹកគុកត្រពាំងស្រុក មាននិយាយពីមន្ត្រីធំមួយរូបជាអ្នកចេះដឹងមាននាម វ្រះកម្រតេងអញ គ្រីកណ្ឌបណ្ឌិត ជាអ្នកចេះគម្ពីរធម៌សាស្ត្រ (K. 91, ស្រុកជើងព្រៃ, ខេត្តកំពង់ចាម, ស.វ.ទី១១, ២២-២៥)។

[28] Cf. Narendra Nath Law, *Aspects of Ancient Indian Polity,* (Oxford: The Clarendon Press, 1921), pp. 72-73.

[29] សិលាចារឹកតាំងក្រង (*IC*, Vol. I :7-12) និយាយពីព្រាហ្មណ៍ម្នាក់ឈ្មោះ ធម៌ស្វាមិន ក្នុងរាជ្យព្រះបាទ ជ័យវរ្ម័នទី១ ដែលជាចៅហ្វាយក្រុងធម៌បុរៈ។ គាត់មានកូនបងដែលបានតែងតាំងជា ចៅហ្វាយក្រុង ស្រេម្ឋបុរៈ និង ចៅហ្វាយក្រុង ធ្រុវបុរៈ ហើយ កូនពៅឈ្មោះ ប្រចណ្ឌសិង្ហ ទទួលខុសត្រូវជ្រើសរើសកងការពាររាជវាំងនិងទទួលខុសត្រូវស្ថាប័នមួយចំនួនទៀត។ គួរបញ្ជាក់ថា ធ្រុវបុរៈជាទឹកដីគ្របដណ្ដប់ដោយព្រៃឈើនិងមានមនុស្សព្រៃរស់នៅ។ តាមសិលាចារឹក កូនរបស់ព្រាហ្មណ៍ ធម៌ស្វាមិន គ្រប់គ្រងក្រុងធ្រុវបុរៈដើម្បីការពារភ័យន្តរាយទាំងឡាយ។

(ខ្ញុំ)ថ្វាយវត្តអារាម។ ភោគផលកសិកម្មពីស្រែចម្ការនេះ ម្ចាស់ទានមានសិទ្ធិចាត់ចែងថាឱ្យវត្តអារាមណាប្រើប្រាស់ឬអាចទាញយកផលមួយចំណែកសម្រាប់ខ្លួនផង។

ទាក់ទងនឹងឋានន្តរនាមតាមសិលាចារឹកសម័យមុននេះ លោកសាស្ត្រាចារ្យ **ឡុង សៀម** បានចែកឋានន្តរនាមជាពីរក្រុមធំៗ។ ក្រុមទី១មាន រាជវង្សានុវង្ស, ព្រាហ្មណ៍បុរោហិត ព្រះរាជគ្រូ មន្ត្រីសង្ឃជាន់ខ្ពស់, ពួកអភិជន, ពួកកុដុម្ពីក៍, អ្នកបម្រើរាជការ ជាដើម; ក្រុមទី២មាន អ្នកបម្រើតាមប្រាសាទវត្តអារាម អ្នកធ្វើស្រែចម្ការច្បារដំណាំឧទ្យាន, គង្វាលសត្វពាហនៈ, ផ្ទាំវិហារ ផ្ទាំច្បារ ផ្ទាំសាលា ផ្ទាំមាសប្រាក់, សិប្បករ, សិល្បករ, អ្នកដាំស្ល, អ្នកធ្វើអង្ករ, អ្នកផលិតគ្រឿងក្រអូប ជាដើម។

ក្រុមពី១មានឋានន្តរនាមសម្គាល់ដូចជា *បុ/បោ; បោញ; ចសិ/ចះ, អចសិ/អចះ, អំចសិ; លោញ; ក្លោញ, បន្លោញ; ហេង, កន្ទេង; វុង, កុរុង; កុរាក; តាង, តាងអញ, ម្រតាង/ម្រតាញ, ម្រតាងក្លោញ, ម្រតាងកុរុង, កំម្រតាង/កំម្រតាញ, វ្រះកំម្រតាង, វ្រះកំម្រតាងអញ; យង/យាង* ។ ក្រុមទី២មានឋានន្តរនាមសម្គាល់ដូចជា កុ, វ/វា។

តាមលោកសាស្ត្រចារ្យ **ឡុង សៀម** ឧត្តមភាពឋានៈកើនឡើងអាស្រ័យពាក្យកម្លាយនិងសមាស មានន័យថា ឋានន្តរនាមដែលជាពាក្យមានផ្នត់ពីរជាន់មានឧត្តមភាពជាងពាក្យដែលមានផ្នត់មួយជាន់ ហើយ ឋានន្តរនាមដែលជាពាក្យសមាសមានឧត្តមភាពជាងពាក្យទោល។[30]

នៅសម័យអង្គរ ឋានន្តរនាមដែលយើងអាចបន្ថែមក្នុងក្រុមទី១នេះមានដូចជា *កំម្រតេង, កំម្រតេងអញ, កម្រតេងកំត្វនអញ, កម្រតេងជគត, ស្តេង/ស្តេញ, ស្តេងអញ, កំស្តេង, វ្រះកំស្តេង* ។[31]

---

[30] ឡុង សៀម, *វចនានុក្រមខ្មែរ (តាមសិលាចារឹកបុរេអង្គរ សតវត្សទី ៦-៨)/Dictionnaire du khmèr ancient (D'après les inscriptions du Cambodge du VIe. – VIIIe. siècles*, ភ្នំពេញ, វិទ្យាស្ថានភាសាជាតិ,២០០០, ទំ.1G-8G.

[31] - **កំស្តេង** ឋានន្តរនាមសម្គាល់មន្ត្រីជាន់ខ្ពស់ឬព្រះអាទិទេព។ ឧ. *កំស្តេងស្រវេង* (K. 313, ស.វ.ទី៩, ប.៣៦), *កំស្តេងជគតលិង្គបុរ* (K. 780, ស.វ.ទី១០, ប.១៣), *កំស្តេងអញរាជកុល្លមហាមន្ត្រី* (K. 231, ស.វ.ទី១០, ប.៣០), *ជូនិតវ្រះកំស្តេងអញគិរលិង្គ* (K. 741, ស.វ.ទី១១, ប.១៦...), *កំស្តេងចាំវ្រះបញ្ជីយ* (K. 374, ស.វ.ទី១១, ប.១៨)។; **ស្តេង/ស្តេញ** ឋានន្តរនាមសម្គាល់មន្ត្រីជាន់ខ្ពស់សម័យអង្គរ។ ឧ. *ស្តេញមហេន្ទ្របតិ* (K. 352, ស.វ.ទី10, ប.២៧...), *ស្តេញកុលបតិ* (K. 262, ស.វ.ទី១០, ប.៣), *ស្តេញវ្រទាចាវ្យបូរោហិត* (K. 231, ស.វ.ទី១០, ប.៥៣), *ស្តេងភគវនិកន្លោងវ្រះកម្រតេងអញរាជគុហា* (K. 221, ស.វ.ទី១១, ប.៩), *សិស្តេង* (K. 366, ស.វ.ទី១២, ប.១៧)។;**ស្តេងអញ** ឋានន្តរនាមសម្គាល់បុរសអ្នកមានចំណេះដឹងសម័យអង្គរ។ ឧ. *អំនោយបោញដានិយជមាន* (K. 709, មុនអង្គរ, ប.៤), *គុបោញវ្រះអញ* (K. 137, មុនអង្គរ, ប.១៣), *ស្តេងអញវ្រះគុរុ* (K. 262, ស.វ.ទី១០, ប.៨...), *ស្តេងអញអាចាវ្យប្រធាននាត្រីណិ* (K. 693, ស.វ.ទី១១, ប.៦), *ស្តេញអញគិរកែវល្បេតអ្និប្រាជ្ញ* (K. 235, ស.វ.ទី១១, ប.៦១)។; **បោញ** ឋានន្តរនាមសម្គាល់មន្ត្រីឬបព្វជិត។ ឧ. *បោញឧយឱយកំព្វតក្លោញកម្រតាងអញ* (K. 600, ស.វ.ទី៧, ប.១), *ស្រេតេលបោញគិរទត្តឱយព្វតអញ* (K. 54, ស.វ.ទី៧, ប.៨), *បោញក្លោញក្រាំតអាចាវ្យយជមាន* (K. 423, ស.វ.ទី៧, ប.១), *បោញកាត្លេម្ម* (K. 493, ស.វ.ទី៧, ប.២៤), *បោញវាសេន*(K.44, ស.វ.ទី៧,ប.៩), *បោញតោតិលតាងអាជ្ញាវ្រះកម្រតាងអញ* (K. 44, ស.វ.ទី៧, ប.១៣), *គេតក្លោញស្រុកគិតទំនេប្របោញគិរក្សេ* (K. 41, ស.វ.ទី៧, ប.៤-៥), *បោញសុវ្ទទត្តកោនម្រតាញ* (K. 113, ស.វ.ទី៧, ប.៤), *បុណ្យបោញក្ទ្លូទត្ត* (K. 8, ស.វ.ទី៧-៨, ប.១), *កុំអំនោយបោញ* (K. 129, ស.វ.ទី៧-៨, ប.១), *បោញប្រជ្ញាចន្ទ្រ* (K. 163, ស.វ.ទី៧-៨, ប.១), *ប្រវេងបោញគិលទេវ* (K. 1, ស.វ.ទី៧-៨, ប.២៣), *បោញវ្រះអញ* (K. 557, ស.វ.ទី៧, ប.៨), *បោញក្លោញបញ្ចស* (K. 9, ស.វ.ទី៧, ប.២៦), *បុណ្យអ្និបោញតាង* (K. 38, ស.វ.ទី៧, ប.៥)។; **ម្រតាង /ម្រតាញ/ម្រតេញ** *កុំវ្រះកម្រតាងអញ ... មនម្រតាងអន្តារឱយសំបរិភោគព្វតវ្រះកម្រតាងអញកម្រតាងតំក្រាំ* (K. 600E, ស.វ.ទី៧, ប.១), ក្លោញម្រតាង (K. 600, ស.វ.ទី៧, ប.៩), *ក្លោញម្រតាងកោនក្លោញម្រតាង ...* (K. 748, ស.វ.ទី៧, ប.១៤), *អំនោយម្រតាងយជមានអាយតវ្រះ* (K. 78, ស.វ.ទី៧, ប.២២), *វ្រះម្រតាងអតា* (K. 137, ស.វ.ទី៧, ប.១១), *បន្លសម្រតាញយជមាន* (K. 46B, ស.វ.ទី៧, ប.១១), *បុណ្យម្រតាញក្លោញ* (K. 818, ស.វ.ទី៧-៨, ប.១០), *អំនោយម្រតាញអនន្តស្វាមិតវ្រះកំម្រតាងអញ* (K. 910, ស.វ.ទី៧, ប.៣), *ម្រតាញមេធាវិន្ទុ* (K. 493, ស.វ.ទី៧, ប.៣០), *ម្រតាញទុគ៌្គស្វាមិ* (K. 438, ស.វ.ទី៧, ប.១១), *ម្រតាញកំម្រតាង* (K. 137, ស.វ.ទី៧, ប.២), *ម្រតាញគក្រស្វាមិអគ្រាសន* (K. 904A, ស.វ.ទី៨, ប.១៦, ២៧), *ម្រតាញកុរុងវិក្រមបុរ* (K. 68, មុនអង្គរ, ប.១១; K. 904A, ស.វ.ទី៨, ប.១៦, ២៧), *ម្រតាញយជមានឱយ ...* (K. 115, មុនអង្គរ, ប.១៨), *ម្រតេញគិរសោមស្វាប-នាវ្រះកម្រតេងអញ* (K. 809, ស.វ.ទី៩, ប.១), *ម្រតេញវ្រទាចត្វាចាវ្យតអ្វាស* (K. 831, ស.វ.ទី១០, ប.១១), *ម្រតាញគ្រីវណកេសាវិខ្លោញត្លាងនាទោ* (K. 158, ស.វ.ទី១១, ប.១៨)។; **កុរា**

បណ្ដាពាក្យជាឋានន្តរនាមខាងលើ ពាក្យខ្លះមិនមានប្រើទៀតក្នុងសម័យបច្ចុប្បន្ន ពាក្យខ្លះបានវិវត្តរូបឬន័យជាពាក្យមួយប្រភេទទៀត។[32]

## ២.៣.២- ប្រភេទខ្លះៗនៃដីធ្លី

តាមការពិនិត្យ យើងសូមចែកបច្ចេកសព្ទទាក់ទងនឹងដីធ្លីជា៤ប្រភេទៈ ដីរដ្ឋត្រូវបានសម្គាល់ដែនរដ្ឋបាល, ដីភូមិ, ដីកសិកម្ម និង ដីពិសិដ្ឋ។ ដីដែលជាដែនរដ្ឋបាលត្រូវបានសម្គាល់ដោយពាក្យ *ប្រមាណ* ឬ *ប្រមាន,* វិមយ និង ស្រុក។ ដីភូមិសម្គាល់ដោយពាក្យ *គ្នាង* (លំនៅ), *ច្បរ៑/ច្បារ* (សួន, ច្បារដំណាំ), *ភូមិ, ចំនត* និង *អន្រាយ* ។ ដីកសិកម្មត្រូវបានសម្គាល់ដោយពាក្យ *ស្រេ, ចំការ* ។

តាមលោកបណ្ឌិត ឡុង សៀម *ប្រមាណ* ជាដែនដីរដ្ឋមានទំហំធំ។ ពាក្យនេះមានវត្តមានទាំងក្នុងសម័យមុនអង្គរទាំងក្នុងសម័យអង្គរ។ *វិសយ* ជាតំបន់ឬខេត្ត។ នៅមុនសម័យអង្គរ *ស្រុក* សម្គាល់ភូមិតូចតាច លុះចូលដល់សង្គមអង្គរ ពាក្យនេះបានពង្រីកនិយមន័យរបស់ខ្លួន តាមរយៈនយោបាយពង្រីកទឹកដី។ *ចំនត* ជាភូមិទើបបង្កើតថ្មី។ ភូមិថ្មីនេះជាកម្មសិទ្ធិរបស់អភិជន។ *អន្រាយ* ជាភូមិដែលមានភារៈបំពេញការងារសម្រាប់ប្រយោជន៍វត្ត។ *ភូមិ* ជាដីហ៊ុមព័ទ្ធដោយរបងឬដោយព្រំប្រទល់។ នៅសម័យអង្គរ ភូមិជាកម្មសិទ្ធិរបស់ កុដុម្ពីក៍ វត្ត សេដ្ឋី ឬ អភិជន។[33]

ដីភូមិកើតពីគោលនយោបាយរបស់ព្រះមហាក្សត្រនៅសម័យនោះក្នុងការអភិវឌ្ឍដីថ្មីឬជាថ្មីក្នុងរាជ្យរបស់ទ្រង់។ នាពេលនោះ ប្រជារាស្ត្រនិងមន្ត្រីមានសិទ្ធិសុំព្រះរាជទានជាដីធ្លី ក្រៅពីវត្ថុប្រើប្រាស់និងរតនវត្ថុ។

ការស្រាវជ្រាវរបស់លោកស្រី Judith Jacob លើសិលាចារឹកមុនអង្គរចំនួន១២៥ បង្ហាញពីដែនដីដែលសិលចារឹកស្ថិតនៅនាសម័យបុរាណ។ ភាគពាយព្យ ដីលាតសន្ធឹងដល់ដំបន់ខ្ពង់រាប

**ក៏** ឋានន្តរនាមសម្គាល់ចៅហ្វាយខេត្តឬចៅហ្វាយក្រុង។ ឧ. *ក្ញុំអំនោយ៑កុរាក៑ហ្វារិតវ្រះ* (K. 54, ស.វ.ទី៧, ប.១២), *ត្បល៑អំនោយ៑កុរាក៑អញ្ចាន៑* (K. 9, ស.វ.ទី៧, ប.១២), *អំនោយ៑កុរាក៑ក្លោញ៑វ្យាធបុរអោយ៑តវ្រះកម្រ- តាង៑អញ៑គ្រឹរុទ្រមហាលយ* (K. 109, ស.វ.ទី៧, ប.២០), *កុរាក៑ទន្លេក្រៅ* (K. 22, ស.វ.ទី៧, ប.១៧), *កុរាក៑ក្លោញ៑ស្រុក៑ក្រៅ* (K. 648, ស.វ.ទី៧, ប.២; K. 38, ស.វ.ទី៧, ប.៤))។; **កុ** ឋានន្តរនាមសម្គាល់ស្ត្រីវណ្ណៈដាន់ទាបនៅសម័យមុនអង្គរ។ ស្ត្រីទាំងនេះ ក្នុងសិលាចារឹក ត្រូវបានថ្វាយជាអំណោយដល់ព្រះអាទិទេពឬព្រះវិហារជាមួយនឹងវត្ថុនានាព្រមទាំងគោក្របីដីស្រែចម្ការ។ ឧ. *កុក្ដាយ៑១កោន៑៣* (K. 127, មុនអង្គរ, ប.១៨), *កុក្រហ្វាញ៑* (K. 561, មុនអង្គរ, ប.៣៩), *កុតន្នារុវលវោ* (K. 557, ស.វ.ទី៧, ប.៣), *កុស្រេកោន៑កុក្ដួរ* (K. 926, ស.វ.ទី៧, ប.៩), *កុនិម្ដធុរកោន៑កុ៣* (K. 926, ស.វ.ទី៧, ប.៩), *កុនយនីកោន៑កុ៤ចៅកុ២* (K. ៦៦៤, ស.វ.ទី៧-៨, ប.6)។; **តាង៑/តាញ៑** តាង៑ សម្គាល់ឋានន្តរនាមអភិជននៅសម័យមុនអង្គរ, តាញ៑ សម្គាល់ឋានន្តរនាមសម្គាល់អភិជននៅសម័យអង្គរ។ ឧ. *តាង៑កន្ទេង៑ម្រសិរ* (K. 9, សម័យមុនអង្គរ, ប.១៤), *តាង៑វិទ្យាទេវ* (K. 80, សម័យមុនអង្គរ, ប.8), *តាង៑ប្រជ្ញាសេន៑* (K. 54, ស.វ.ទី៧, ប.១៥-៦), *តាង៑ស្បូន៑តាង៑ភោ* (K. 1, ស.វ.ទី៧-៨, ប.៧), *តាញ៑កម្រតេង៑អញ៑មហេន្ទ្រទេវី* (K. 165, ស.វ.ទី១០, ប.២), *តាញ៑ធម្ម៑* (K. 349, សម័យទី១០, ប.២៥)។; **វា** ឋានន្តរនាមសម្គាល់បុរសវណ្ណៈដាន់ទាបតាំងពីសម័យមុនអង្គរ។ ស្ត្រីទាំងនេះ ក្នុងសិលាចារឹក ត្រូវបានថ្វាយជាអំណោយដល់ព្រះអាទិទេពឬព្រះវិហារជាមួយនឹងវត្ថុនានាព្រមទាំងគោក្របីដីស្រែចម្ការ។

[32] តាមនិរុត្តិសាស្ត្រ ពាក្យ *តេង៑* ជាពាក្យដើមដែលជាសមាសភាគសំខាន់ក្នុងការបង្កើតពាក្យ *កំស្ដេង៑, កម្រតេង៑, កម្រតែង, គម្ដែង, (អា) ដែង,* ...។ *តាង៑* ជាពាក្យដើមសំខាន់សម្រាប់បង្កើតពាក្យ *តាង៑អញ៑, កម្រតាង៑, កម្រតាង៑អញ៑,* ...។ នៅពេលគេបន្ថែម *វ្រះ* ពីបណ្ដាពាក្យទាំងនេះតាមភាពជាក់ស្ដែងនៃវណ្ណៈនៅសង្គមនោះ ពាក្យដែលកើតនេះរឹតតែបញ្ជាក់ពីឋានៈខ្ពង់ខ្ពស់របស់មនុស្សឬបុគ្គលនោះ។ *វា* បានក្លាយជានាមសព្ទសម្គាល់មនុស្សវ័យក្មេង ដែលគេហៅ *អាវ៉ា* និង បានក្លាយជា *វា* ក្នុងប្រភេទពាក្យជាបុរិសសព្វនាម។ *កុរាក៑* ត្រូវបានប្រើជាពិសេសសម្គាល់មនុស្សប្រុសដែលមានឋានៈរដ្ឋបាលខ្ពស់ក្នុងសម័យមុនអង្គរ។ នៅសម័យអង្គរ ពាក្យនេះវិវត្តជា *កុរេក៑* ។ សម័យក្រោយមក ពាក្យដដែលនេះវិវត្តជាពាក្យឯកព្យាង្គ *ក្រែក* ដែលគេឃើញក្នុងសមាសភាគនៃពាក្យដូចជា *ពញាក្រែក* ជាដើម។

[33] ឡុង សៀម, *ស្ថាននាមវិទ្យាខ្មែរ (Toponymie khmère),* ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៩៧, ទំ. ១៨-២៩។

នគររាជប្រទេសថៃបច្ចុប្បន្ន, ភាគឥសាន ដល់ដំបន់ប៉ាកសេប្រទេសឡាវបច្ចុប្បន្ន និង ភាគនីរតី ដល់ខេត្តភូវិញប្រទេសវៀតណាមបច្ចុប្បន្ន។[34]

ក្រោយពីសិក្សាពីច្បាប់ទម្លាប់ទាក់ទងនឹងការកាន់កាប់ឬគ្រប់គ្រងដីធ្លីនៅសម័យអង្គរសតវត្សរ៍ទី១០ លោក M. C. Ricklefs បានកត់សម្គាល់ថា នៅសម័យនោះ ក្រៅពីរាជធានី ប្រជារាស្ត្រធម្មតាមានសិទ្ធិកាន់កាប់ដីធ្លី។ ព្រះរាជានៅតែជាម្ចាស់ផ្នែកព្រលឹងវិញ្ញាណលើទឹកដីទាំងអស់ក្នុងប្រទេស។ កិត្យានុភាពនេះជាការជំរុញឱ្យមានប្រសិទ្ធ-ភាពផ្នែកប្រព័ន្ធយុត្តិធម៌ ពីព្រោះ ប្រសិនបើគ្មានទ្រង់ទេ នោះអ្នកកាន់កាប់ដីធ្លីទាំងអស់មិនមានភាពកក់ក្ដៅឡើយ។ ជាការគាំទ្រផ្នែកផ្លូវច្បាប់នាពេលនោះជាការបញ្ជាក់ពីទំនុកចំពោះសមត្ថភាពស្ថាប័នរាជការក្នុងការរក្សានូវសណ្ដាប់និងស្ថិរភាពសង្គម។[35]

ការអភិវឌ្ឍថ្មីបានបញ្ជាក់តាមរយៈបច្ច្ចេកសព្ទមួយចំនួន ដូចជា *ចំនតិ* និង *ត្នី* ដែលផ្សំបង្កើតជាកន្សោមពាក្យចំនួនដូចជា *ចាតិភូមិ, ស្រុកត្នី* ជាដើម។

បច្ចេកពាក្យជលនាមជាជំនួយសំខាន់ដើម្បីយល់បញ្ហាទាំងនេះ។ បច្ចេកសព្ទទាំងនោះមាន *ទន្លេ, ថ្និង ឬ ធ្និង (ស្ទឹង), ចន្ទោរ ឬ ចន្ទូរ (ចង្កូរ, ចង្អូរ), ប្រលាយ៑ (ប្រឡាយ), បិង៑ (បឹង), ត្រវ៉េង៑ ឬ ត្រវាង៑ (ត្រពាំង), ស្តុក៑ (ព្រៃស្តុក), លង្ហង៑ (អន្លង់)* និង *ទំនប់*។

ក្នុងការសិក្សាស្ថាននាមតាមសិលាចារឹកសម័យមុនអង្គរនិងសម័យអង្គរ លោកបណ្ឌិត ឡុង សៀម បានកត់សម្គាល់ថា «ស្ថាននាមដែលមានពាក្យ វាល, ស្រែ, ចំការ, សួន, ច្បារ, ទំនប់, បឹងបួរ ដែលយើងបានពណ៌នារួចមកហើយ គឺជាភស្តុតាងបញ្ជាក់អោយដឹងថា មុខរបរសំខាន់របស់ប្រជាជន គឺ (ធ្វើស្រែ, ចំការ)។»[36] «ចំណែកស្ថាននាមដែលមានបច្ចេកពាក្យសត្តវិទ្យា (ដូចជាគោ, ក្របី, សេះ, ដំរី) អាចបញ្ជាក់អោយយើងដឹងអំពីសត្វពាហនៈ ដែលគេប្រើសំរាប់អូសទាញក្នុងការភ្ជួររាស់ និង ដឹកនាំ ។[37]» លើសពីនេះ ក្នុងការវាយតម្លៃលើលទ្ធភាពនៃការផលិតក្នុងវិស័យកសិកម្មនៅសម័យនោះ លោកបណ្ឌិតបានគូសបង្ហាញថា «ដោយសារប្រព័ន្ធទឹកពីធម្មជាតិ និងប្រព័ន្ធស្រោចស្រពខ្វែងខ្វាត់មានដូចជាព្រែកជីក ស្រះតូចធំ ទំនប់ជាដើម ធ្វើអោយកម្ពុជទេស ក្លាយជាផលិតករដ៏ខ្លាំងផ្នែកដំណាំស្រូវ និងមានប្រភពទឹកដ៏ធំធេង ។[38]»

## ២.៣.៣- វង្វាស់វង្វាល់មួយចំនួនប្រើក្នុងការទិញលក់ដីធ្លីនិងទំនិញ

បណ្ដាឈ្មោះវង្វាស់វង្វាល់ដែលយើងបានយកបង្ហាញនេះមិនមាន ឈ្មោះវង្វាស់វង្វាល់ខ្លះនៅប្រើចូលមកដល់សម័យកណ្ដាល ហើយ ឈ្មោះខ្លះទៀតបានវិវត្តន័យទៅជាឈ្មោះវង្វាស់វង្វាល់ផ្សេងទៀត។

---

34 Judith Jacob, *op.cit.,* p. 305។

35 M. C. Ricklefs,"Land and the Law in the Epigraphy of Tenth-Century Cambodia", The Journal of Asian Studies, Vol. 26, No. 3. (May, 1967), pp. 411-420.

36 ឡុង សៀម, *ស្ថាននាមវិទ្យាខ្មែរ,* ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៩៧, ទំ.៩៥។

37 -ដ-, ទំ.៩៥។

38 -ដ-, ទំ.៩៧។

### ២.៣.៣.១- រង្វាស់

ក្នុងសិលាចារឹក យើងសង្កេតឃើញមានប្រើរង្វាស់ប្រវែងមួយចំនួនដូចជា *ធ្នាញ់, ថ្លាស, បាទ, មាស, វ្យាម(ព្យាម), ហត្ថ, សន្រេ/សររេ, ស្លឹក,* ជាដើម។[39] គួរកត់សម្គាល់ ភាគច្រើនរង្វាស់ប្រវែងស្រែចម្ការ គេឃើញសិលាចារឹកប្រើពាក្យ *សន្រេ/សររេ* ច្រើន។ ពាក្យមួយចំនួនដូចជា *ព្យាម, ហត្ថ* ត្រូវបានប្រើជារង្វាស់ប្រវែងបែបបុរាណសម្រាប់ជនជាតិខ្មែរបច្ចុប្បន្ន ឯ *ស្លឹក* ត្រូវបានប្រើជាពាក្យរនាប់សម្រាប់ចំនួនដែលបរិមាណ៤០០។

### ២.៣.៣.២- រង្វាល់

តាមរាជទូតចិន លោក ជីវ តាក្វាន់ ដែលមកធ្វើទស្សនកិច្ចនៅសម័យអង្គរនាចុងសតវត្សរ៍ទី ១៣ និង តាមការសង្កេត យើងដឹងថា ក្នុងជំនួញជួញដូរ គេប្រើរៀប៣បែបៈ មួយបែប គឺ ការយកទំនិញដូរជាមួយនឹងទំនិញ, មួយទៀត គឺ ការបង់ជាកាសស្ពាន់, មួយបែបទៀត គឺ ការបង់ជាមាសប្រាក់។

ការយកទំនិញដូរនឹងទំនិញនិងការបង់ជាមាសប្រាក់នោះ យើងបានឃើញជាឧទាហរណ៍ស្រាប់តាមការបង្ហាញរបស់សិលាចារឹកនានា។ ចំណែកប្រើបង់កាស, ទោះជាកាសអ្វីក៏ដោយ, យើងខ្វះឧទាហរណ៍ច្បាស់លាស់ជាឯកសារសំណេរ។ ទោះយ៉ាងណាក្តី ការបញ្ជាក់របស់ ជីវ តាក្វាន់ នេះជាពន្លឺសំខាន់មួយ។

លោក Groslier បានបញ្ជាក់ថា ព្រះសត្ថាទី១ បានផលិតប្រាក់កាសជាលើកដំបូងក្នុងឆ្នាំ ១៥៩៥ ហើយ ប្រើរៀងរហូតមកដល់នឹងសម័យអាណាព្យាបាលបារាំង។ លោកបានយោងលើសិលាចារឹកនគរវត្តមួយដែលបញ្ជាក់ពីអំណោយជាប្រាក់«១តម្លឹង៣ស្លឹង១ពៃ»[40]។ លោក Groslier បញ្ជាក់ពីការរកឃើញដងជញ្ជីងថ្លឹងមួយនៅតំបន់អង្គរធ្វើពីទង់ដែងខាងចុងលម្អជាក្បាលនាគ[41]។

---

[39] - **ធ្នាញ់** ឧ. *តិឧត្តរទៅវបិតគោលតិឧត្តរវ្នំវ្រេង៑ប្រសបិនុភូមិស្រុកិឈេលោស្រុកិត្វង៑ម្វយ៑តែំចំងាយ៑ធ្នាញ៑១ស្លិក៥១៨០ថ្លាស៑៦* (សិលាចារឹកស្តុកកក់ធំ, ស.វ.ទី១១, ចំហៀងD, ប.១១១-១១២)។; **ថ្លាស** ឧ. *តិឧត្តរទៅវបិតគោលតិឧត្តរវ្នំវ្រេង៑ប្រសបិនុភូមិស្រុកិឈេលោស្រុកិត្វង៑ម្វយ៑តែំចំងាយ៑ធ្នាញ៑១ស្លិក៥១៨០ថ្លាស៑៦* (សិលាចារឹកស្តុកកក់ធំ, ស.វ.ទី១១, ចំហៀងD, ប.១១១-១១២)។; **មាស** ឧ. *ព្វតេល៑អំរោល៑២មាស៑១* (K. 910, ស.វ.ទី៧, ប.១១), *អំរុង៑គ៑មាស៑៣* (K. 22, ស.វ.ទី៧, ប.៣២), *ស្រេមាស៑៧* (K. 728, ស.វ.ទី៨, ប.២), *ស្បេព្យះ អន្រេាំមាស៑ជេងមាស៑១* (K. 713, ស.វ.ទី៩, ប.២), *ស្បេព្យះអនវ៉ាំជេង៑មាស៑១* (K. 188, ស.វ.ទី១០, ប.៤); *ក្សីរមាស៑៤* (K. 689, ស.វ. ទី៧-៨, ប.៦), *មាធុអន្លោង៑៤មាស៑១០* (K. 421, ស.វ.ទី៧, ប.៨)។; **វ្យាម** ឧ. *គក៌រៅយោបលក្ខតប្រាការណាំ សមន្តតៈ វ្យាមាសិ សហស្រេ ទ្វេ សប្ត គតានិ ទ្វៅ ច សំខ្យយា* (សិលាចារឹកតាព្រហ្ម, ស.វ.ទី១២, ល្បះទី៨០, ប.១៥-១៦)។; **ស្លិក** ឧ. *តិឧត្តរទៅវបិតគោលតិឧត្តរវ្នំវ្រេង៑ប្រសបិនុភូមិស្រុកឈេស្រុកិត្វង៑ម្វាយ៑តែំចំងាយ៑ធ្នាញ៑១ស្លិក៥១៨០ថ្លាស៑៦* (សិលាចារឹកស្តុកកក់ធំ, ស.វ.ទី១១, ផ្ទាំងD, ប. ១១១-១១២)។; **ហស្ត** ឧ. *ស្ថាបនាវ្រះលិង្គទ្វិហស្ត* (សិលាចារឹកស្តុកកក់ធំ, ស.វ.ទី១១, ផ្ទាំងD, ប.៧៥)។

[40] យើងបានផ្ទៀងផ្ទាត់នឹងសៀវភៅរបស់លោក Groslier។ សៀវភៅនេះជាប្រភពខុសដែលធ្វើឱ្យមានភន្តច្រឡំដល់លោក Le May ដែលសិក្សាពីប្រវត្តិរូបិយវត្ថុសៀម។ ចំណែកលោក Groslier វិញ លោកក៏មិនបានផ្ទៀងផ្ទាត់ពត៌មានហើយជឿតាមលោក Aymonier។ ក្នុងទំព័រ៣១នៃសៀវភៅរបស់ខ្លួន លោក Groslier សរសេរដូចនេះ "Au xv^e s. une inscription d'Angkor Vat dont Aymonier a donné une traduction nous met Presque sur la voie et du moins signale en 1444 une relation pondérale et des noms qui devaient devenir dans la suite des noms de monnaie."។ លោក Le May យល់ច្រឡំថា 1444 ជាឆ្នាំគ្រិស្តសករាជ។ យើងបានផ្ទៀងផ្ទាត់នឹងអត្ថបទសិលាចារឹកដើម។ សិលាចារឹកនោះជាសិលាចារឹក លេខ១០ n⁰ 23 មានកាលបរិច្ឆេទ១៥៥៤ ពោលគឺ វាជាឆ្នាំមហាសករាជដែលមនុស្សខ្មែរប្រើតាំងពីសម័យមុនអង្គរម្ល៉េះ។ ដូច្នេះ ផ្អែកតាមកាលបរិច្ឆេទនេះ សិលាចារឹកត្រូវនឹងគ.ស. ១៦៣២។ ដោយសារការសិក្សារបស់ផ្តោតត្រឹមសម័យមុនអង្គរនិងសម័យអង្គរ យើងមិនចូលជ្រៅពិភាក្សាបញ្ហាសម័យក្រោយមកទៀតទេ។ Cf. R. S. Le May, "The Coinage of Siam: The Coins of the Bangkok Dynasty, 1782-1924", *JSS,* Vol. 18.3, 1924, p.160; G. Groslier, *Recherches sur les Cambodgiens d'après les textes et les monuments depuis les premiers siècles de notre ère*, (Paris : A.Challamel, 1921), p.31; ក្រសេម, *សិលាចារឹកនគរវត្ត,* Paris, Cedoreck, 1984, ទំ.៣៩៖ «តួនបុសឲ្យប្រ៉កនាងមលលិង១បាទ៣ស្លិង១ពៃ១»។

[41] Goslier, *op.cit.,* p. 27.

គេអាចយល់ជាទូទៅបានថា ប្រជារាស្ត្រមានសិទ្ធិក្នុងការរកស៊ីទទួលទាន។ ការទិញដូរឬលក់ជាការបង្ហាញពីការពង្រីកទ្រព្យសម្បត្តិឬការដោះបំណុលនានា។ ការដោះដូរដីស្រែចម្ការឲ្យរដំណាំនិងទ្រព្យមានវិញ្ញាណឬឥតវិញ្ញាណជាការផ្តល់លទ្ធភាពជម្រើសក្នុងការប្រើមធ្យោបាយពាណិជ្ជកម្ម។ ក្នុងករណីខ្លះ នៅពេលដែលប្រជារាស្ត្រទិញសម្រាប់ប្រយោជន៍សាសនានោះ ព្រះរាជា, ដោយសេចក្តីអនុគ្រោះ, បានបន្ធូរបន្ថយបញ្ចុះភាគរយ។

នៅសម័យអង្គរឬមុនអង្គរការលក់ដូរប្រព្រឹត្តទៅដោយការប្រើវត្ថុជាអចលនៈនិងអចលនៈ។ វត្ថុជាចលនៈមាន ដីធ្លី, សម្លៀកបំពាក់, ទឹកឃ្មុំ, ទឹកដោះ, ប្រេង ជាដើម, វត្ថុជាចលនៈមាន គោ ក្របី ដំរី ជាដើម ហើយ វត្ថុប្រើប្រាស់ និង លោហៈមានតម្លៃមាន ប្រាក់, ស្ពាន់, សំរឹទ្ធិ, សំណ ជាដើម។

វត្ថុនិងលោហៈធម្មតា(ដែក, ស្ពាន់, សំណ និង សង្កសី ជាដើម)និងលោហៈមានតម្លៃត្រូវបានវាស់ថ្លឹងដោយឧបករណ៍ដែលមានឈ្មោះផ្សេងៗទៅតាមបរិមាណដូចជា *យជិកៈ, ទ្រោណៈ, ប្រស្ថ, អាឍកៈ, កុទុវៈ, ភារៈ, តុលៈ, ថ្លោង, ជេ, ជ្យង/ជឹង, លិង, កដ្តី, បណៈ, បាទ, មាស, ពិម្ពកៈ* ជាដើម។

សម្លៀកបំពាក់ស្បៃស្បង់ជាដើម គេប្រើ *យៅ*[42] ជារណប។

ឈ្មោះនៃរង្វាស់រង្វាស់ខ្មែរបុរាណបង្ហាញពីសមានយោគនៃប្រភពវប្បធម៌៣៖ ខ្មែរ, ឥណ្ឌា, ចិន។[43]

ឈ្មោះរង្វាស់រង្វាល់ខ្លះត្រូវបានប្រើសម្រាប់រង្វាស់ផងសម្រាប់រង្វាល់ផង ដូចជា *មាស* ។ ឈ្មោះខ្លះមានវត្តមានរហូតមកដល់បច្ចុប្បន្ន។ ថ្វីត្បិតយើងអាចតាមដានការវិវត្តរូបពាក្យនេះក្តី ក៏ពាក្យមួយ

---

[42] ពាក្យនេះ គេមិនឃើញមានប្រើតមកសម័យក្រោយទេ។

[43] - **កដ្តិកៈ** ឧ. *ត្រិទ្រោណៅសិ ចាជិកាះ បញ្ចវិំគតិរ យជិកា យ្ចុតមិ* (សិលាចារឹកតាព្រហ្ម, ល្បះ៤៨, ប.២៤)។; **កុទុវៈ** ឧ. *តិលា ឯកាទគ ប្រស្ថា ត្ងៅ កុទុវាវ៑ អពិ* (សិលាចារឹកតាព្រហ្ម, ល្បះ៤៨, ប.២៤)។; **ខារិកៈ** រង្វាល់ទម្ងន់មួយប្រភេទ។ ឧ. *ទ្រោណៅ បាក្យាមតាះ ប្រាស្ថៅ ត្រយយាសសប្តតិខារិកាះ* (សិលាចារឹកតាព្រហ្ម, ល្បះ៣៨, ប.៤), *បញ្ច ប្រស្ថាសិ ត្រយោ ទ្រោណា មរិចានាំ ទ្វិខារិកេ* (សិលាចារឹកតាព្រហ្ម, ល្បះ៩០, ប.៣)។; **យជី** ឧ. *យជី ប្រស្ថៅ ទ្វិកុទុវៅ តៃលាំ ប្រស្ថត្រយាំសិ តថា* (សិលាចារឹកតាព្រហ្ម, ល្បះ៩១, ប.៩)។; **យជិកា** ឧ. *ឯកាត្រឹំគទិ ទធិក្សីរេ ប្រត្យេកាំ យជិកា មធុ* (សិលាចារឹកតាព្រហ្ម, ល្បះ៤៩, ប.២៥)។; **ជ្យង៑/ជ្យេង៑** ឧ. *មធុច្ចិការ២ ជ្យង៑១០-៥លិង៑១០* (K. 421, ស.វ.ទី៨-១១?, ប.២-៣), *ក្របាសិតុលិ៤ជ្យេង៑១០* (K. 124, ស.វ.ទី៩, ប.១០-១១), *កន្តិកាប្រាមតុលម្វយ៑ជ្យង៑ម្វយ៑លិង៑តបិវ្យរ៑* (K. 258, ស.វ.ទី១២, ប.៤៣...)។; **ទ្រោណៈ** ឧ. *គ្រេតតន្ទុលទ្រោណម្វយ៑* (K. 570, ស.វ.ទី១០, ប.២៥); *ទ្រោណៅ បាក្យាមតាះ ប្រាស្ថៅ ត្រយយាសសប្តតិខារិកាះ* (សិលាចារឹកតាព្រហ្ម, ល្បះ៣៨, ប.៤)។; **តុល** ឧ. *ក្របាសិតុលិ៤ជ្យេង៑១០* (K. 124, ស.វ.ទី៩, ប.១០-១១), *កន្តិកាប្រាមតុលម្វយ៑ជ្យង៑ម្វយ៑លិង៑តបិវ្យរ៑* (K. 258, ស.វ.ទី១២, ប.៤៣...)។; **ពិម្ពៈ** ឧ. *បាទសិ ត្រិមាចាះ កប៉ូរសិ តថា វិម្វចតុម្តយមិ* (សិលាចារឹកប្រាសាទតាព្រហ្ម, ល្បះ៩៩, ប.៥៤)។; **ភារៈ** ឧ. *មធុច្ចិការ២ជ្យង៑១០-៥លិង៑១០* (K. 421, ស.វ.ទី៨-១១?, ប.២-៣), *មធុច្ចិម្តការ២តុល១០* (K. 421, ស.វ.ទី៨-១១?, ប.១៤)។; **លិង៑** ឧ. បុរក៑សោលិង៑១ (K. 79, មុនអង្គរ, ប.១៧), កដ្តិ៣លិង១៧ (K. 877, ស.វ.ទី៧-៨, ប.១២), ចនច្យន៑១លិង៑១ (K. 420, ស.វ.ទី១១, ប.២២), ស្វោក៑១ជ្យង៑លិង៑១០ (K. 33, ស.វ.ទី១១, ប.៨), កន្តិកាប្រាមតុលម្វយ៑ជ្យង៑ម្វយ៑លិង៑តបិវ្យរ៑ (K. 258, ស.វ.ទី១២, ប.៤៣...)។; **ថ្លង៑/ថ្លោង៑/ថលុង៑** ឧ. *រង្គោថ្លោង៑៥* (K. 56, ស.វ.ទី៧, ប.១៤), *ស្រូវត្លោង៑៣ជេ២* (K. 79, ស.វ.ទី៧, ប.១៦), *ល្ងោត្លោង៑១ជេ១ត្ងៅត្លោង៑១ជេ១* (K. 124, ស.វ.ទី៩, ប.១១)។; **ប្រស្ថ** ឧ. *ស្ថាបនានៃវេទ្យប្រស្ថ៥មុគ្តា២* (K. 341S, ស.វ.ទី៨, ប.៦), *តន្ទុលប្រស្ថ២* (K. 187, ស.វ.ទី១០, ប.៩...), *បា្យង៑ប្រស្ថ៤* (K. 232, ស.វ.ទី១១, ប.៨)។; **អន្ទោង៑** ឧ. *បរេង៑អន្ទោង៑៣* (K. 451, ស.វ.ទី៧, ប.៧), *គ្នំអន្ទោង៑៣មាស៑៦* (K. 124, ស.វ.ទី៩, ប.១២៤)។; **យៅ** ឧ. *ចន្លេក៑យុគលយៅ៣អំវលិយៅ១* (K. 79, ស.វ.ទី៧, ប.១៥), *ចន្លេក់យៅហ្វ១* (K. 154 B, ស.វ.ទី៧, ប.៣), *ដ្វីយៅ៧* (K. 505, មុនអង្គរ, ប.២០...), *វ៉ាំបំន្ទោស៑តប្វះយៅ៣* (K. 124, ស.វ.ទី៩, ប.១៤), *ចន្ល្យក៑យៅហ្វម្វយ៑* (K. 370, ស.វ.ទី១១, ប.១០) *ចាថ្មិតបិហត៑យៅ* (K. 258, ស.វ.ទី១២, ប.១១)។; **សន្រែ/សរេ** ឧ. *ស្រែសរេ១* (K. 76, មុនអង្គរ, ប.១៦), *មោឃ៑សន្រែ* (K. 790, មុនអង្គរ, ប.៨...), *កន្លះសន្រែ* (K. 18, មុនអង្គរ, ប.៥), *ស្រែផល(ម)និជាហ្វតកុរាក៑ជ្លេង៑ទោង៑បោញ៑វិទ្យាគត្តិសរេកន្លះ* (K. 493, ស.វ.ទី៧, ប.២០), *សរេ១បាទ១* (K. 719, ស.វ.ទី៧, ប.១២), *ស្រែសរេ៣* (K. 78, ស.វ.ទី៧, ប.២១), *ស្រែធនិវិសេរេ១* (K. 757, ស.វ.ទី៧-៨, ប.១៨)។; **បណៈ** ឧ. *មធូច្ចិម្តស្យ ភារាសិ តុ គណិតា ទគ សប្ត ច អព្ទាទគ តុលាះ បញ្ច កត្តៅ នវ បណាសិ តថា* (សិលាចារឹកតាព្រហ្ម, ស.វ.ទី១២, ល្បះទី៦០, ប.៤៧-៤៨)។; **បាទ** ឧ. *បញ្ច វិំគតិ ភារាគ ច រូប្យាណាំ ទគ បញ្ច ច តុលា ទ្វេ កដ្តិកេ ទ្វៅ ច បាទៅ បណ ចតុម្តយំ* (សិលាចារឹកតាព្រហ្ម, ស.វ.ទី១២, ល្បះទី៦៩, ប.៦៥-៦៦)។

ចំនួនបានប្រែប្រួលន័យឃ្លាតពីន័យដើម ហើយ ត្រូវបានប្រើក្នុងបរិបទផ្សេងដូចជា ស្លឹក (វិវត្តពី *ស្លិក; ស្លឹក* នៅពេលបច្ចុប្បន្ន របាប់ចំនួន៤០០ ដូចជា *សំណាប១ស្លឹក, ផ្លែឈើ១ស្លឹក* ជាដើម), ជញ្ជីង (វិវត្តពី *ជីង* ), តម្លឹង (វិវត្តពី *លិង* ), ជញ្ជើ (វិវត្តពី *ជេ* ), បាទ (នៅប្រើសម័យកណ្ដាលរៀងរហូតមកដល់ពេលដែលប្រទេសជាក់អាណាព្យាបាលនិងប្រើរូបិយវត្ថុដែលគេហៅថា *ព្យ៉ាស(piastre), រៀល* ជំនួស)។ បច្ចុប្បន្ន *បាត* ជាឈ្មោះរូបិយបណ្ណប្រទេសថៃ), ពាក្យ ដុល (វិវត្តពី *តុលៈ* ) ដែលយើងន័យក្នុងកន្សោមពាក្យឬឈ្មោះដូចជា *ដែក១ដុល* សម្គាល់ដែកមួយដុំធំ, *ចម្លងទាំងដុល* គឺចម្លងទាំងស្រុងដោយមិនកែប្រែឬសម្រួល។

ក្រៅពីការកំណត់ដីស្រែចម្ការច្បារដំណាំដោយរង្វាស់ខ្នាតទាំងឡាយ ព្រំប្រទល់នៃដីធ្លីត្រូវបានកំណត់តាម រយៈទិស (ក្រោមខ្យល់, លើខ្យល់, ថ្ងៃលិច, ឧត្តរ, ឦសាន, បូព៌, ...) ហើយ ជាប់នឹងដីរបស់ម្ចាស់ណា, ជាប់គ្រពាំងអ្វី, ថ្នល់ទិសខាងណា ជាដើម។

នៅសម័យមុនអង្គរនិងសម័យអង្គរ ព្រះរាជាមានកាតព្វកិច្ច គោរពសាសនា និង គ្រប់គ្រងចាត់ចែងលើអ្នកដែលស្ថិតក្នុងដែនអំណាច។ ទ្រង់មានកាតព្វកិច្ចធ្វើឱ្យប្រទេសជាតិនិងប្រជារាស្ត្ររស់នៅសម្បូរសប្បាយនិងការពារភេយន្តរាយនានា។ «រាជសភា» នៅពេលនោះ ជាតុលាការដែលមានអំណាចកាត់ក្ដីទាំងផ្នែកព្រហ្មទណ្ឌទាំងផ្នែករដ្ឋប្បវេណី។ ដំណើរការក្ដីមានលំដាប់លំដោយរដ្ឋបាលពីថ្នាក់ខេត្តដល់ថ្នាក់រាជធានី[44]។

មុនចេញសេចក្ដីសម្រេចនានាជាពិសេស ទាក់ទងនឹងរឿងដីធ្លីនេះ ប្រព័ន្ធច្បាប់នៅសម័យនោះមានលក្ខណៈល្អិតល្អន់និងរឹងមាំ ពោលគឺ មិនមែនសម្រេចលើ មតិផ្ទាល់ខ្លួនឬក្រុមមនុស្សថ្នាក់លើ ឬ បណ្ដឹងរបស់ម្ចាស់បណ្ដឹងនោះទេ។ ជាទូទៅ គេតម្រូវឱ្យមានសាក្សីច្រើននាក់ទាំងមន្ត្រីនៅថ្នាក់លើទាំងប្រជារាស្ត្រនៅមូលដ្ឋាន។

ការដាក់ទោសទណ្ឌមានកម្រិតពីស្រាលដល់ធ្ងន់ (ទោសប្រហារជីវិត)។ យើងសង្កេតឃើញច្បាប់មិនមែនដាច់ហេតុទេ ព្រោះ ក្នុងករណីខ្លះ ទោះបីជនណាម្នាក់មានទោសធ្ងន់ធ្ងរក្ដីក៏គេអាចទទួលបានសិទ្ធិបន្ធូរបន្ថយទោសដែរ។

## សេចក្ដីសន្និដ្ឋាន

ក្នុងការអភិវឌ្ឍជាតិក៏ដូចជានយោបាយដីធ្លី គេឃើញមាន ការចាត់តាំងកាប់គាស់រានឆ្ការដី, ដីដែលមិនទាន់មានមនុស្សនៅឱ្យមានមនុស្សនៅ, ដីឬកន្លែងដែលត្រូវអភិវឌ្ឍ គេនឹងកេណ្ឌមនុស្សឱ្យមករស់នៅ និង ការប្រគល់ដីដល់មន្ត្រីឬអ្នកមានលទ្ធភាពអភិវឌ្ឍដីដែលទំនេរ។ មិនតែប៉ុណ្ណោះសោត ការអភិវឌ្ឍដីថ្មីតំបន់ថ្មីត្រូវធ្វើស្របគ្នានឹងការអភិវឌ្ឍផ្នែកសាសនា។

---

[44] យើងសង្កេតថា ប្រព័ន្ធតុលាការពេលនោះមានការបែងចែកជា៤កម្រិត។ ចំណុចនេះមានលក្ខណៈច្បាស់លាស់ជាងការបញ្ជាក់ក្នុងឯកសារទាក់ទងនឹងបំណែងចែកនៃប្រព័ន្ធតុលាការឥណ្ឌាបុរាណ។ ប្រព័ន្ធតុលាការខ្មែរសម័យអង្គរអាចនឹងសិក្សាបានដោយដេញមកកេសម័យកណ្ដាលរហូតមកដល់សម័យអាណានិគមបារាំង។ ទោះយ៉ាងណាក្ដី ការសិក្សារបស់យើងផ្ដោតលើបញ្ហាដីធ្លីក្នុងបរិបទសម័យមុនអង្គរនិងសម័យអង្គរ។

ជាធម្មតា នៅពេលគេថ្វាយដីស្រែចម្ការកន្លែងណាមួយដល់ព្រះវិហារឬព្រះអាទិទេព គេតែងភ្ជាប់មកជាមួយខ្ញុំបម្រើប្រុសស្រី។ អ្នកទាំងនេះជាកម្លាំងពលកម្មដែលចូលទៅកាប់គាស់ធ្វើស្រែចម្ការដំណាំ។ ភោគផលបានពីដីស្រែនេះ ម្ចាស់កម្មសិទ្ធិអាចមានសិទ្ធិប្រើប្រាស់ឬផ្តល់ទៅព្រះវិហារឬព្រះអាទិទេព (នៃប្រាសាទ) ណាមួយផ្សេងៗទៀតប្រើរួមគ្នា (សំបរិភោគ)។ ដូច្នេះ នៅស្រុកណាមួយមានវត្តអារាម, ដីស្រែចម្ការ, អ្នកធ្វើការលើដីស្រែចម្ការនោះ និង ការទទួលផ្លែផ្កានៃភោគផលការងារដែលបានធ្វើ។ នេះជាទម្រង់នៃការបង្កើតសហគមន៍និងការរស់នៅបែបសហគមន៍ក្នុងទម្រង់មីក្រូសង្គម។

បុគ្គលណាម្នាក់ដែលកាន់កាប់ដីធ្លីមានសិទ្ធិលក់ដូរ ដោយប្រើរូបិយវត្ថុជាលោហៈ មានមាសប្រាក់ជាដើម និង ដោយដោះដូរនឹងវត្ថុដទៃជាចលនៈក្តីអចលនៈក្តី មានគោក្របីនិងគ្រឿងឧបភោគបរិភោគជាដើម។ សិទ្ធិនៃការកាន់កាប់ដីធ្លីមានលក្ខណៈពិសេសក្នុងប្រវត្តិសាស្ត្រខ្មែរ។ អ្នកមានដីធ្លីមានសិទ្ធិគ្រប់គ្រងជារៀងរហូត។ ក្នុងផ្នែកសង្គម ព្រះរាជាជាតំណាងគុណធម៌និងយុត្តិធម៌ដែលផ្តល់ភាពសុខសាន្តនិងការភាពសម្បូរសប្បាយដល់ប្រជារាស្ត្រនិងមន្ត្រីក្នុងដែនដី។

តុលាការដោះស្រាយទាំងរឿងក្តីព្រហ្មទណ្ឌទាំងរឿងក្តីរដ្ឋប្បវេណី។ ប្រព័ន្ធតុលាការក៏ដូចជាប្រព័ន្ធរដ្ឋបាលមួយចំនួនទៀតត្រូវបានចែកជាជាន់ថ្នាក់ពីកម្រិត១ដល់កម្រិត៤។ ការបែងចែកមានជាភស្តុតាងច្បាស់លាស់, ដែលត្រង់ចំណុចខ្លះ, ផ្តល់ជាពន្លឺជាងឯកសារដែលគេសិក្សាទាក់ទងនឹងប្រព័ន្ធតុលាការនៅប្រទេសឥណ្ឌាបុរាណ។

លទ្ធភាពនៃការផលិតក្នុងវិស័យកសិកម្មនៅសម័យនោះបានពឹងផ្អែកលើធម្មជាតិនិងប្រព័ន្ធស្រោចស្រពខ្វែងខ្វាត់ដែលជាចលនករធ្វើឱ្យប្រទេសកម្ពុជាសម័យបុរាណមានសក្តានុពលផ្នែកកសិកម្ម៕

## គន្ថនិទ្ទេស


[ឈិម] ក្រសេម, *សិលាចារឹកនគរវត្ត*, Paris, Cedoreck, 1984។

ទីឃាយុ (ប្រែសម្រួល), *រឿងរ៉ាវរបស់ព្រះអង្គម្ចាស់ យុគន្ធរ (L'affaire Yukanthor: Autopsie d'un scandale colonial),* ????។

*ពុទ្ធសាសនា ២៥០០,* ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៥៧។

លី ធាមតេង, បកប្រែ, *កំណត់ហេតុរបស់ ជីវតាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា*, ភ្នំពេញ, បោះពុម្ពលើកទី៣, ១៩៧៣។

ឡុង សៀម, *វចនានុក្រមខ្មែរ (តាមសិលាចារឹកបុរេអង្គរ សតវត្សទី ៦-៨)/Dictionnaire du khmèr ancient (D'après les inscriptions du Cambodge du VIe. – VIIIe. siècles*, ភ្នំពេញ, វិទ្យាស្ថានភាសាជាតិ,២០០០។

_____, *ស្ថាននាមវិទ្យាខ្មែរ*, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ,១៩៩៧។

_____ (ប្រែសម្រួល), *ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា,* ឃ.ឃ. មីហេយេវ (និពន្ធនាយក), មូស្គូ, ការិយាល័យនិពន្ធនាយកផ្នែកអក្សរសិល្ប៍បូព៌ា នៃអង្គការបោះពុម្ពផ្សាយ«ណាអ៊ូកា», ១៩៨១។

អ៊ុក សុឡុង, បេលិងប៉ាវ អ៊ុក, *ជីវតាគ្មាន់ កំណត់ហេតុអំពីទឹកដីនិងប្រពៃណីប្រទេសកម្ពុជា,* ភ្នំពេញ, បោះពុម្ពលើកទី១, ២០១១។

Barth, M. A. *Inscriptions sancrites du Cambodge.* Paris : Imprimerie nationale, 1885.

Chakravarti, Adhir. *Royal Succession in Ancient Cambodia.* Calcutta: The Asiatic Society, 1982.

Dauphin-Meunier, A. *Histoire du Cambodge.* Paris : Presse universitaires de France, 1961.

Cœdès, G. *Inscriptions du Cambodge.* Vol. I, II; Hanoi : 1937, 1942; Vol. I-VIII; Paris : 1951-1966.

Coedès, G., Dupont Pierre. "Les inscriptions du Pràsàt Kôk Pô." In : *BEFEO.* Tome 37, 1937. pp. 379-413.

Coedès, G. Etudes cambodgiennes. XXV, «Deux inscriptions sanskrites du Fou-nan». In : *BEFEO.* Tome 31, 1931, pp.1-9.

_______. *The Indianized States of Southeast Asia,* Walter F. Vella, ed. Sue Brown Cowing, trans. Honolulu: University of Hawaii Press, 1968.

Cribb, Joe. "First Coin of Ancient Khmer Kingdom Discovered", *Revue de la Société de Numismatique Asiatique,* Noméro 6, Juin 2013.

Finot, Louis. "L'inscription de Sdok Kak Thom." In : *BEFEO.* Tome XIV-XX, 1915. pp. 53-106.

Giteau, M. *Histoire du Cambodge,* Paris : Didier, 1957.

Groslier, G. *Recherches sur les Cambodgiens d'après les textes et les monuments depuis les premiers siècles de notre ère*. Paris : A.Challamel, 1921.

Gutman, Pamela. "The Ancient Coinage of Southeast Asia". Paper presented at *the 7th Conference of the International Association of Historians of Asia, at Bangkok, August 1977* ;

Le May, R. S. "The Coinage of Siam: The Coins of the Bangkok Dynasty, 1782-1924", *JSS,* Vol. 18.3, 1924, p.160;

*Kaultiya's Arthashastra,* Trans. R. Shamasastry. Bangalore: Government Press, 1915.

Majumdar, R. C. *Inscriptions of Kambuja.* Calcutta: The Asiatic Society, 1953.

Jacob, Judith. "Pre-Angkor Cambodia: Evidence from Khmer Inscriptions", in *Cambodian Linguistics, Literature and History,* David A. Smyth, ed. London: School of Oriental and African Studies, University of London, 1993.

Law, Narendra Nath. *Aspects of Ancient Indian Polity.* Oxford: The Clarendon Press, 1921.

Lowman, Ian Nathaniel. *The Descendants of Kambu: The Political Imagination of Angkorian Cambodia.* PhD diss. University of California, Berkeley, 2011.

Pandurang Vaman Kane, *History of Dhamrmaśastra (Ancient and Mediaeval Religious and Civil Law in India),* Poona: Bhandarkar Oriental Research Instittue; Vol. I, 1930; Vol. II, Part I, 1941; Vol. II, Part II, 1941; Vol. III, 1973; Vol. IV, 1953; Vol. V, Part I, 1958; Vol. V, Part II, 1962.

SAHAI, Sachchidanand. *Les institutions politiques et l'organisation administrative du Cambodge ancient (VIe-XIIIe siècle).* Paris : EFEO, 1970.

Pou, Saveros, Traduites et éditées. *Nouvelles inscriptions du Cambodge,* II & III. Paris : École française d'Etrême-Orient, 2001.

POU, Saveros. *Dictionnaire vieux khmer-français-anglaise/An Old Khmer-French-English Dictionary/វចនានុក្រមខ្មែរចាស់-បារាំង-អង់គ្លេស.* Paris: មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌/Centre de documentation et de recherche sur la civilization khmère, 1992.

______, Traduites et éditées. *Nouvelles inscriptions du Cambodge*, II & III. Paris : École française d'Etrême-Orient), 2001.

Ricklefs, M. C. "Land and the Law in the Epigraphy of Tenth-Century Cambodia", The Journal of Asian Studies, Vol. 26, No. 3. (May, 1967), pp. 411-420.

Vickery, Michael. *Society, Economics, and Politics in Pre-Angkor Cambodia: The 7th-8th Centuries.* Tokyo: The Centre for East Asian Cultural Studies for Unesco, The Toyo Bunko, 1998.



# លោកគ្រូ នៅ ស៊ុន និងជីវិតសិល្បៈ

លោក ផង់ ភិរុណ
មន្ត្រីវិទ្យាស្ថានភាសាជាតិ

បេះដូងបញ្ញវន្ត ជាវហេស្សនាមមួយដែលហាក់ដូចជាសង្ខំខ្លួនយ៉ាងអាថ៌កំបាំងហើយក៏មានមនុស្សម្នា ជាច្រើននាក់ ច្រើនវ័យ ច្រើនសម័យកាលស្ទើរតែមិនចាប់អារម្មណ៍ឬមិនបានយល់ថាយ៉ាងម៉េចដែរទៅលើអត្ថន័យ នៃពាក្យ«បេះដូងបញ្ញវន្ត »នេះយ៉ាងណានោះឡើយ។ **បេះដូងបញ្ញវន្ត**ក្នុងទីនេះ សំដៅលើស្មារតី មនោសញ្ចេតនា ទឹកចិត្តនិងការផ្ដល់តម្លៃខ្ពស់ទៅលើបុគ្គលណាដែលបានបួសរៀនឬសិក្សាអក្សរសាស្ត្រ លេខនព្វន្តនានាពី សំណាក់ចាស់ៗឬ ព្រឹទ្ធាចារ្យ។ មួយវិញទៀត **បេះដូងបញ្ញវន្ត** មួយឃ្លានេះ បានចាក់ស្រេះ នៅក្នុងបេះដូងអ្នកខេត្ត តាកែវកាលពីអតីតកាល។ គ្រាប់ពូជនៃទឹកដីបេះដូងបញ្ញវ័ន្តបានបន្តតំណែលនៅឡើយ។ ក្នុងនោះ ក៏មានលោកគ្រូ នៅ ស៊ុន មួយរូបដែរដែលបានក្លាយ ជាគ្រាប់ពេជ្រនៅលើទឹកដីបេះដូងបញ្ញវន្តផងដែរ។

ក្រៅពីតួនាទីទាក់ទងនឹងកិច្ចការងារប្រចាំថ្ងៃ ពេលសម្រាកកាយឬក្នុងពិធីបុណ្យនានាម្ដងៗ លោកគ្រូ តែង តែជ្រើសរើសយកបទចម្រៀងខ្មែរតិចឬច្រើនមកច្រៀងក្នុងពិធីនោះដើម្បីបំពេរអារម្មណ៍ ឬមួយសប្បាយរីករាយ សើចកំប្លែងជូនអ្នកចូលរួមស្ដាប់តាមប្រភេទបទដែលចម្រៀងទាំងនោះ។ ការច្រៀងចម្រៀងរបស់លោកគ្រូ មិនមែនជាការងារមួយច្រៀងនៅទីសាធារណៈដូចតារាចម្រៀងអាជីពដែលប្រកបមុខរបរនោះឡើយ។ លោកច្រៀងតែនៅក្នុងស្រុកកំណើតរបស់លោក( គេហដ្ឋានរបស់លោក ភូមិវាលប្រីយ៍ ឃុំចំបក់ ស្រុកបាទី ) ក្នុងពិធីបុណ្យដារភូមិ បុណ្យចូល ឆ្នាំជាមួយកូនក្មួយនិងញាតិមិត្តក្នុងភូមិដើម្បីជាការកំសាន្ត សាមគ្គីភាព សប្បាយរីករាយប៉ុណ្ណោះ។

តាមការពិនិត្យនិងធ្លាប់ចូលរួមក្នុងកម្មវិធីជាមួយលោកគ្រូ ជាញឹកញាប់នៅភូមិកំណើតរបស់លោកគ្រូ កាលពីរូបលោកនៅមានជីវិតនោះ ខ្ញុំ ផង់ ភិរុណ ជាកូនសិស្ស មួយរូបក្នុងចំណោមសិស្សគណជាច្រើនរបស់ លោកគ្រូគឺលោកបានទទួលយកខ្ញុំជានិស្សិតសរសេរសារណាថ្នាក់អនុបណ្ឌិតផ្នែកភាសាវិទ្យារហូតទទួលបានជាជ័យលាភីនៅឆ្នាំ២០០២ហើយរហូតមកដល់ដើមឆ្នាំ២០០៩ មកទល់នឹងបច្ចុប្បន្ន លោកគ្រូនៅតែជាគ្រូដឹកនាំខ្ញុំក្នុងកម្រិតថ្នាក់បណ្ឌិតបន្តទៀត។ តែជាអកុសលលោកគ្រូបានលាចាកពីខ្ញុំ ទៅបាត់ដែលខ្ញុំមិនទាន់បានការពារចប់សព្វគ្រប់នៅឡើយ។ ចំណែកបទចម្រៀងដែលលោកគ្រូចូលចិត្តយកមកច្រៀងក្នុងកម្មវិធីនានា ជាពិសេស នៅ ភូមិកំណើតរបស់គាត់ហើយក៏ជា

បទដែលលោកគ្រូបានអោយខ្ញុំស្វែងរកស្រាវជ្រាវនិងយកទៅប្រគុំជាតន្ត្រីអ័កកាដង់ចំនួនបីលើក។ បទទាំងនោះជារួមមានចំនួន ៣៤ ចំណងជើង ដូចខាងក្រោម ៖

| លរ | ចំណងជើងបទចម្រៀង | ចង្វាក់ | អត្ថន័យ | ផ្សេងៗ |
|---|---|---|---|---|
| ១ | នឹកគ្រារួមរ័ក្ស | Bosston *=( ចង្វាក់៣ ) | អនុស្សាវរីយស្នេហា | |
| ២ | បញ្ចពិតកល្យាណី | Bosston *=( ចង្វាក់៣ ) | សម្រស់ | |
| ៣ | បញ្ជីខ្មោច | Pop Walth | មរណភាពតួអង្គ | |
| ៤ | បានជួបគ្នាហើយ | Slow | រំលឹកពីការជួបគ្នា | |
| ៥ | បុប្ផាកំពង់ហាវ | Slow | សម្រស់ ការលួចស្រឡាញ់ | |
| ៦ | ប្រវត្តិស្នេហា | Cha Cha Cha | សាវតានៃការសាងស្នេហ៍ | |
| ៧ | ព្រះចន្ទប្រចាំជាតិ | Cha Cha Cha | បារមីរបស់ព្រះមហាក្សត្រ | |
| ៨ | ម៉េរ៉ាស្នេហាបង | SlowRock | សុំស្នេហា | |
| ៩ | ប៉េបពីតូល | Cha Cha Cha | សុំស្នេហា | |
| ១០ | កម្រងស្នេហា | Pop Walth | ចំណងអនុស្សាវរីយ៍ | |
| ១១ | ចំពោះវរលក្ខណ៍ | Bolerotwise | អង្វរសុំស្នេហ៍ | |
| ១២ | ឈឺស្នាមក្តិច | Bolerolente | អង្វរករ លួមលោម | |
| ១៣ | ញញឹមទៀតទៅ | Slow Rock | សរសើរសម្រស់និងសុំស្នេហ៍ | |
| ១៤ | ទិព្វនារី | Bolerolente | សរសើរសម្រស់ | |
| ១៥ | ទីក្រុងកែប | Bolerolente | សម្ផស្ស | |
| ១៦ | ទឹកភ្នែកខ្ញុំ | Bosston | ទុក្ខសោក | |
| ១៧ | និស្ស័យអប្សរា | Bolerotwise | សរសើរសម្រស់ | |
| ១៨ | ភរិយាពីរ | Slow Rock | ចំណងស្នេហ៍ចាក់ស្រែះ | |
| ១៩ | ភ្លៀងជោគដំ | Tongo | បណ្តាំស្នេហ៍ | |
| ២០ | មុខក្រញូវ | Cha Cha Cha | លេបខាយ | |
| ២១ | ញញឹមមក | Slow Rock | ស្តាយស្នេហ៍ | |
| ២២ | រាត្រីចុងក្រោយ | Bolerolente | ថ្នមស្នេហ៍ | |
| ២៣ | វាយោកំពូលភ្នំ | Bolerolente | អនុស្សាវរីយ៍ | |
| ២៤ | បុប្ផាក្នុងសុបិន | Bolerolente | ស្នេហ៍ឥតន័យ | |
| ២៥ | នេះគឺវាសនា | Bosston | ជំពាក់ចិត្ត | |
| ២៦ | វាសនាខ្សែទឹកឈូ | Bolerolente | អង្វរចិត្ត | |
| ២៧ | សាយ្ណណាប៉ា | Cha Cha Cha | លាគ្នាពេលចប់កម្មវិធី | |

| | | | | |
|---|---|---|---|---|
| ២៨ | ស្ដាយក្លិនកូលាបរោយ | Bolerotwise | សោកស្ដាយ | |
| ២៩ | ស្ពានឃោល | Bolerotwise | ស្ដាយអនុស្សាវរីយ៍ | |
| ៣០ | សំបូរទឹកហូរគគ្រាំ | Bolerotwise | ស្ដាយស្រណោះ | |
| ៣១ | ជំរំវត្តស្លែង | Bolerotwise | អនុស្សាវរីយ៍កងទ័ព | |
| ៣២ | អោយតែស្ម័គ្រ | Bolerotwise | រំលឹកអនុស្សាវរីយ៍ | |
| ៣៣ | ទីកែប | Bolerotwise | សម្រស់ទេសភាព | |
| ៣៤ | យុវជនខូចចិត្ត | Jerk Twise | ឈឺចិត្ត | |

ក្នុងចំណោមបទចម្រៀងទាំងប៉ុន្មានខាងលើ តាមការកត់សំគាល់និងធ្លាប់ទៅប្រគុំជាមួយលោកគ្រូគឺលោកចូលចិត្តច្រៀងបទ«យុវជនខូចចិត្ត » បទ« សំបូរទឹកហូរគគ្រាំ» និង បទ«ជំរំវត្តស្លែង» ជាងបទ ណាៗទាំងអស់។ ខាងក្រោម ជាអត្ថន័យទាំងស្រុងតាមរយៈបទចម្រៀងក្រោមចំណងជើងថា«ជំរំវត្តស្លែង»

បទចម្រៀង ជំរំវត្តស្លែង (ចង្វាក់បុលឡេរ៉ូ)

I- ជំរំវត្តស្លែង ព្រៃវែងពងទឹក ខ្ញុំនឹកមិនភ្លេច អនុស្សាវរីយ៍
ស្រមៃឃើញអូនគ្រប់តែនាទី សុបិនញុំញី យល់តែគគ្រាថ្លៃ។

II- ជំរំវត្តស្លែង ខ្ញុំវែងស្រណោះ បងស្រឡាញ់ស្មោះ ចំពោះរូបស្រី
បងគេងសុបិន មមើលស្រមៃ ឱ្យបងដោះស្រាយរបៀបយ៉ាងណា?

R ក្នុងនាមយុទ្ធជន ការពារទឹកដី កំពុងជាប់ដៃតាមវាយប្រហារ
បើសង្គ្រាមចប់ ក្រែងមានវាសនា បានជួបជីវា ព្រលឹងស្រីពៅ។

III-ជំរំវត្តស្លែង កន្លែងយុទ្ធជន បងខំបែរបន់ឱ្យឈ្នះសត្រូវ
ឱ្យទ័ពខ្មែរឈ្នះ រហ័សឆាប់ទៅ វាសនាបើកផ្លូវ ជួបពៅជាគូ។

ម្ចាស់សំនៀងដើម លោក ថេត សម្បត្តិ

តាមចំណាប់ចំណូលចិត្តនៃប្រភេទបទចម្រៀងខាងលើដែលលោកគ្រូធ្លាប់បាន យកមក ច្រៀង យើងអាចសន្និដ្ឋានបានថា លោក គ្រូជាកុលបុត្រដ៏ល្អម្នាក់ទទួលបានការគោរពកោតសរ សើរពីសិស្សនិស្សិតក៏ដូចជាប្រជាពលរដ្ឋទូទៅផងដែរ។ លោកគ្រូជាបុគ្គលម្នាក់ដែលបង្កប់ មនោសញ្ចេតនាជ្រាលជ្រៅក្នុងដួងចិត្ត ដូចជា *មានភាពរួសរាយ ស្វាហាប់ លើកលែង អនុគ្រោះ ទន់ភ្លន់ មេត្តា ករុណា ឧបេក្ខា*

*អធ្យាស្រ័យ ចែករំលែក មានគតិយុត្តិធម៌ ក្នុងការវិនិច្ឆ័យ* អ្វីមួយបានសមស្រប។ ក្រៅពី លក្ខណៈចិត្តផ្នែកខាងក្នុង លោកគ្រូក៏ជាអ្នកដែលពូកែចោទសួរ ដេញដោល ឆ្លឹះកកាយបញ្ហានានា និងមានភាពរឹងមាំទទួលខុសនិងត្រូវលើការងារដែលលោក បានទទួលយក។

វាំងននជីវិតនៃសកម្មភាពល្អៗទាំងប៉ុន្មានរបស់លោកគ្រូដែលធ្លាប់តែបង្ហើរសំនៀងបំពេរអារម្មណ៍ បង្កើនភាពសប្បាយរីករាយដល់ញាតិមិត្តក្នុងវិថីសិល្បៈចម្រៀងសម័យក៏បានលាក់ខ្លួនបំពួនប្រាណស្ងប់ស្ងៀមពីយើងទាំងអស់គ្នាដូច្នេះដែរ។ ទោះជាយ៉ាងនេះក្តី ស្នាមអនុស្សាវរីយ៍ទាំងឡាយរបស់លោកគ្រូក្នុងពិភពសិល្បៈចម្រៀងសម័យហាក់ដូចជានៅតែរស់រវើកជានិច្ច ក្នុងពិភពអារម្មណ៍ញាតិមិត្តទាំងឡាយណាដែលធ្លាប់បានចូលរួមកម្មវិធីជាមួយគាត់។កាយវិការនិងសំនៀងតាមប្រភេទនៃបទចម្រៀងទាំងនោះធ្វើឱ្យយើងនឹកឃើញ ស្រណោះគាត់ គោរពស្រឡាញ់គាត់និងស្រមៃឃើញគាត់ហាក់មិនទៅណាឆ្ងាយពីយើងទេ។

បទចម្រៀងទាំងប៉ុន្មានខាងលើដែលជាមរតកអនុស្សាវរីយ៍ក្នុងខ្សែជីវិតរបស់លោកគ្រូគឺជាអង្គចងចាំចាក់ស្រែះវេញជាប់ក្នុងប្រអប់បេះដូងនិងផ្លូវចិត្តរបស់ខ្ញុំនិងមនុស្សដទៃទៀតគ្មានថ្ងៃណាបំភ្លេចបានឡើយ។ សូមឧទ្ទិសកុសលនៃបទចម្រៀងទាំងនេះព្រមជាមួយនិងទឹកចិត្តដ៏បរិសុទ្ធពីសំណាក់រូបខ្ញុំ សិស្សគណក៏ដូចជាញាតិមិត្ត កូនចៅនៅភូមិស្រុកជូនដល់ដួងវិញ្ញាណក្ខន្ធលោកគ្រូកុំបីឃ្លៀងឃ្លាតឡើយ។/

សិល្បៈចម្រៀងជាបង្អែមជីវិតសម្រាប់មនុស្ស
ស្តាប់កំសាន្ត រីករាយ ជំពាក់ចិត្ត និងប្រែប្រួលឥរិយាបថគ្រប់យ៉ាង
ដើម្បីរស់នៅក្នុងសង្គម ។

ថ្ងៃពុធ ទី១៣ ខែធ្នូ ឆ្នាំ២០១៧

# សួនកំណាព្យ

## ស្ពាយបញ្ញាវន្តខេត្តយើង

(បទពាក្យ៧)

លោក សេស សារ៉ាត់
សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ នៅវិទ្យាល័យព្រៃសណ្ដែក
ស្រុកទ្រាំង ខេត្តតាកែវ

១- ខេត្តខណ្ឌចំណាស់ភាគខាងត្បូង ទឹកដីដំបូងជាប់ព្រំដែន
មានប្រជាជនរាប់ម៉ឺនសែន រស់ក្នុងភពផែនឈាមតែមួយ។
២- ដីចាស់ស្រស់ឆើតគេហៅថា តាកែវដូនតា[1]ប្រឹងលើកស្ទួយ
ភ្នំដារចារឹកដី[2]ទីមួយ ខ្មែរអើយកុំព្រួយសាមគ្គីគ្នា។
៣- កសិចំការពេញហូរហែ ជាស្នាដៃខ្មែរល្អសោភា
គុណភាពខ្ពស់ជាងជាតិនានា ឈូធរម្នីម្នាទិញរួសរាន់។
៤- រីឯមនុស្សក្នុងសង្គម ច្រើនប្រមូលផ្ដុំដោយបញ្ញវន្ត
មន្ត្រីតូចធំគ្រប់ថ្នាក់ជាន់ អ្នកចេះរយពាន់នៅខេត្តយើង។
៥- ម៉ាស្ទ័របណ្ឌិតនិងបរិញ្ញា លោហិតអ្នកជា[3]ជួយតំកើង
ស្មោះសប្រឹងប្រែងជួយជាតិថ្កើង រុងរឿងឈានឡើងល្បីខ្ចរខ្ចារ។
៦- ពលរដ្ឋតាកែវជាអ្នកចេះ ស្រឡាញ់ចំណេះគ្រប់អង្គា
បញ្ញាភ្លឺថ្លាចិត្តពុះពារ[4] មាននាមមួយថាដោយសោភ័ណ។
៧- ធនធានពុទ្ធិ[5]មានប្រាងច្រូង[6] ទឹកដីបេះដូងនៃបញ្ញវន្ត

[1] ខេត្តមួយដែលបានកកើតមុនគេ ចាស់ជាងគេ ហើយត្រូវបានចារក្នុងសិលាចារឹក ភ្នំដា K . 600 នៃពង្សាវតារខ្មែរ។
[2] ទីឋានឬទឹកដីដែលមានកត់ត្រាតាមសិលាចារឹក។
[3] អ្នកឬមនុស្សនៃប្រជាជាតិដែលមានសន្ដានចិត្តល្អ ស្មោះសនឹងមាតុភូមិខ្លួន។
[4] តាមការសង្កេតនិងតាមស្នាដៃនានា ឃើញថា អ្នកតាកែវជាមនុស្សមានចិត្តមោះមុត ក្លាហាន តែថាគឺធ្វើ។ ដូចជា *តាម៉ុក ឧបនាយករដ្ឋមន្ត្រី សុខ អាន លោកគ្រូ នៅ ស៊ុន* និង អ្នកផ្សេងទៀត ជាឧទាហរណ៍។
[5] ប្ដូរ ថ្មីដើម្បីកុំអោយច្រំដែល អ្នកចេះ មានច្រើនដង គឺយើង ដូរមកជា(ធនធានពុទ្ធិ) ជំនួសវិញម្ដង។ មានន័យថា *អ្នកដែលបានសិក្សារៀនសូត្របានក្លាយទៅជាធនធានឬ សម្បត្តិខាងប្រាជ្ញា ខាងគំនិតដ៏មានតម្លៃសម្រាប់ទឹកដីកំណើតរបស់ខ្លួននិងមាតុភូមិ។*
[6] ប្រាងច្រូងឬពាក្យដើមគឺច្រូងប្រាងតែយើងត្រឡប់ទៅជា ( ប្រាងច្រូង) ដើម្បីអោយចួននឹង (បេះដូង) វិញប្រសើរជាង។ មានន័យថា ដែលឈរកើងដូចជាចម្រូងឬបង្ហាញពីភាពរឹងមាំនៃចំណេះដឹងដែលយកទៅប្រើជាតិមាតុភូមិបាន។

ដួងចិត្តអ្នកប្រាជ្ញវិសេសគន្ធ[7] ចិត្តមិនទុរន់ជន[8]ខេមរា។

៨- បណ្ឌិតអ្នកប្រាជ្ញតាកែវយើង មិនចេះរើសអើងមនុស្សផងគ្នា
ស្គាល់គុណបុណ្យទោសករុណា អ្នកខ្លះមរណាគួរសោកស្តាយ។

៩- ដួងចិត្តចងចាំពិព៌ណនា ខាងកិច្ចចចារប៉ិនបកស្រាយ
បញ្ញាវិបុលគិតវែងឆ្ងាយ កេរ្តិ៍ឈ្មោះសុសសាយគ្រប់ទិសទី។

១០- បណ្ឌិត្យសភាចារ្យ សុខ អាន វែឈ្លាសរកគ្មានល្បីគ្មានពីរ
វិហារប្រាសាទចូលបញ្ជី ចិត្តលោកសំភីខ្មែរត្រេកអរ។

១១- វិជ្ជាជ្រៅជ្រះឈ្មោះបណ្ឌិត ជាអ្នកចេះពិតចិត្តក៏ល្អ
ស្នាដៃជាច្រើនសែនបវរ ជាតិខ្មែរសាទរកត់ចងចាំ។

១២- កសាងសាលាច្រើនអគារ ទុកជូនខេមរារៀនចំណាំ
តម្លៃវិជ្ជាដែលលោកផ្តាំ មិនចង់វេងកម្មត្រូវខំរៀន។

១៣- រូបកាយឃ្លាតទៅនៅគំនិត ទុកជានិមិត្តកម្រមាន
វិញ្ញាណក្ខន្ធលោកទៅនិព្វាន សុខគតិភពឋានទីសុខា។

១៤- អ្នកប្រាជ្ញមួយទៀតនៅបាទី ស្វះស្វែងម្នាម្នីរកវិជ្ជា
ជួយជនរួមជាតិគ្រប់អង្គា ផុតក្តីវេទនាពីល្ងង់ខ្លៅ។

១៥- រៀនក្នុងប្រទេសមិនទាន់ស្កប់ ចេះចាំពុំចប់ទៅរៀនក្រៅ
ប្រទេសនានាឆ្ងាយម៉ែឪ ទោះត្រជាក់ក្តៅដោយតាំងចិត្ត។

១៦- រៀននៅអ៊ុយក្រែននិងរុស្ស៊ី មនុស្សម្នាមូលមីរចោមស្នេហ៍ស្និទ្ធ
ប្រមូលចំណេះថែមរាប់មិត្ត រស់នៅនែបនិត្យចិត្តមូលផ្តុំ។

១៧- ឆ្នាំកៅសិបពីរលោករៀនចប់ លាចាកត្រឡប់មកស្រុកភូមិ
ជួយកិច្ចការជាតិក្នុងសង្គម កសាងទ្រទំស្ងួយជីវិត។

១៨- ពីរពាន់ដប់មួយខែកញ្ញា តែងតាំងមុខងារតាមច្បាប់ក្រឹត្យ[9]
ស្រាវជ្រាវដោះស្រាយផ្តល់គំនិត ពាក្យខ្មែរល្អន់ល្អិតរកខុសត្រូវ។

១៩- ឆ្នាំដប់ប្រាំមួយលោកឡើងជា អនុប្រធានការតាមតម្រូវ

[7] ចំណេះប្រសើរថ្លៃថ្លា ចោរលួចក៏មិនបាន និងចេះយកចំណេះរបស់ខ្លួនទៅប្រើប្រាស់ជាប្រយោជន៍ដល់មនុស្សជាតិជាងក្លិនបុប្ផាដែលក្រអូបតែមួយគ្រា។ ចំណែកចំណេះវិជ្ជា ក្រអូបមួយជីវិត។

[8] ចិត្តមិនចុះញ៉មនឹងឧបសគ្គ មិនគ្រាំគ្រា ត្រជាបត្រដួសគឺរឹងមាំ មិនពឹងលើព្រេងវាសនាគឺពឹងលើសមត្ថភាពផ្ទាល់របស់ខ្លួន ( មនុស្សនិយម )។

[9] តែងតាំងដោយព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ តាមផ្លូវច្បាប់ត្រឹមត្រូវ ជាដើម។

ប្រឹងគិតខំគូសត្រង់តាមផ្លូវ[10] ទុកជូនកូនចៅជារូបមន្ត។
២០- បណ្ឌិតខាងសូរមាននាមថា ចំណោះប្រាជ្ញាគ្រូ នៅ ស៊ុន
កើតនៅវាលប្រើយ៍ដីមានគុណ[11] ចំបក់ចិត្តបុណ្យស្រុកបាទី។
២១- លោកគ្រូចេះចាំបួនភាសា អក្ខរៈខេមរានិងរុស្ស៊ី
អង់គ្លេសភាសានៅទីពីរ បារាំងសំភីប្រើប្រាស់បាន។
២២- ដប់ប្រាំបួនថ្ងៃចៃដន្យអ្វី តុលាប្រល័យឃ្លាតសន្តាន
ជនរួមលោហិតស្តាយរកគ្មាន លោកគ្រូចែកឋានចោលយើងហើយ។
២៣- មរណភាពលោកសែនសោកស្តាយ ញាតិមិត្តជិតឆ្ងាយទុក្ខមិនស្បើយ
ស្តាយកេរស្តាយឈ្មោះស្តាយចម្លើយ ជួយជាតិដល់ត្រើយសុខក្សេមក្សាន្ត។
២៤- ទួញសោកយំយែកដង្ហោយហៅ ចង់អោយលោកនៅបើវិលថ្កាន
ទ្រូងស្ទើរបែកប្រេះរលេះប្រាណ ដូចទីស្មសានគ្មានវាចា។
២៥- ប្រណម្យបួងសួងអង្គសក្តិសិទ្ធ មានមហិទ្ធឫទ្ធិក្នុងលោកា
តាមជួយការពារថែរក្សា វិញ្ញាណរូបាដល់ឋានសុខ។
២៦- កំណាព្យកាព្យឃ្លោងខ្ញុំសូមធ្វើ សាទរសរសើរនិងរួមទុក្ខ
បុណ្យ១០០ថ្ងៃជាទំនុក ចិត្តចាំចារទុកនិងសោកស្តាយ។

[10] ការអនុម័តពាក្យដែលខុស ឬន័យសេចក្តីពុំគ្រប់គ្រាន់អោយត្រូវតាមក្បួនខ្នាតនៃភាសានិងអក្សរសាស្ត្រជាតិ។
[11] ទីដែលផ្តល់នូវកំណើត គុណធ៌ម និង សិរីសួស្តីគ្រប់យ៉ាង។

# បាត់ដំបងបណ្តូលចិត្ត

(បទកាកគតិ)

លោក អ៊ឹម គួយ
សាស្ត្រាចារ្យ អក្សរសាស្ត្រខ្មែរ
សាកលវិទ្យាល័យបាត់ដំបង
០១៧ ៣៤៣ ៤៤៧

១ មមែសប្តស័ក កក្កដាលើកដាក់ ដាច់ដល់សីហា
ពីរពាន់ដប់ប្រាំ ឆ្នាំជោគជតា ចង់ថ្លែងអក្ខរា
សារសព្ទសេចក្តី។

២ ខ្ញុំសូមបង្គុំ លើកករប្រណម្យ ដាក់លើសិរសី
គុណព្រះត្រ័យរតន៍ គុណកែវទាំងបី សូមមានសិរី
ឈ្នះអស់ឥតហ្មង។

៣ ខ្ញុំសូមរៀបរាប់ ទុកជាសណ្តាប់ ដល់អស់អ្នកផង
ត្បិតស្រុកឥឡូវ សប្បាយកន្លង ប្រជាប្អូនបង
មានសិទ្ធិសេរី។

៤ ខេត្តបាត់ដំបង នាពេលកន្លង កេរ្តិ៍ឈ្មោះល្បាញល្បី
ពានទីក្រុងស្អាត ផ្ការំដួលបី ប្រជាប្រុសស្រី
អបអរបេតី។

៥ មើលតាមសួនច្បារ ល្អស្រស់ពេកណា មានផ្សាររាត្រី
តូបតាំងលក់នំ លក់សព្វអ្វីៗ ម្ហូបខ្មែរល្បាញល្បី
អត្តជាតិខ្មែរ។

៦ មានឈ្មោះគ្រប់មុខ កកូរអាម៉ុក សម្លម្ជូរស្រែ
ទឹកគ្រឿងអន្លក់ ស្ងោរជ្រក់ដាក់ក្បែរ យើងខិតខំថែ
កេរខ្មែរអង្គរ។

៧ មើលត្រើយខាងលិច ទង់បក់រវិច បង្ហាញជំហរ
មានគ្រប់ជាតិសាសន៍ ទូទាំងនគរ សម័យតេជោ
រុងរឿងឧត្តម។

៨ រីត្រើយខាងកើត បុប្ផាល្អធើត ទទួលស្វាគមន៍
សួនក្រឡាហោម ប្រជាជួបជុំ ទាំងតូចទាំងធំ
មានច្រើនហូរហែ។

៩ មើលប្រាំងទាបទេរ ល្អឥតគ្នាន់គ្នេរ ដងស្ទឹងសង្កែ
បុប្ផារីកស្រស់ សម្រស់មានស្នេហ៍ វស្សាដើមខែ
ភ្លៀងធ្លាក់សន្ទឹក។

១០ មានស្ពានស្រួលឆ្លង ប្រជាប្អូនបង យប់ថ្ងៃល្ងាចព្រឹក
ដឹកភោគផល្លា លាន់ឮគគ្រឹក ដួងចិត្តគួចនឹក
គុណដ៏ថ្លៃថ្លា។

១១ សង្កាត់ខណ្ឌខេត្ត ផ្លូវលំផ្លូវបែក ចេញជាផ្លែផ្កា
មានគ្រប់កន្លែង ល្អល្អះអស្ចារ្យ អភិវឌ្ឍក្រៃណា
ល្អគាប់ភ្នែកញាតិ។

១២ មានសាលារៀន មានផ្លូវមានស្ពាន អគារខ្ពស់ទៀត
ផ្ទះថ្មក៏ច្រើន លូតកើនព្រោងព្រាត ទេសចរមិនឃ្លាត
គ្រប់ជាតិស្វាគមន៍។

១៣ បរិស្ថានល្អ ប្រជាសាទរ មូលមីរជួបប្រជុំ
មានសួនកម្សាន កុមារតូចធំ លេងលោតរងំ
ជុំជិតស្និទ្ធស្នាល។

១៤ រីផលដំណាំ ប្រជាបានដាំ គ្រប់រដូវកាល
មានទាំងក្រូចថ្លុង ពោធិ៍សាត់វិសាល ចេកម្នាស់ត្រកាល
បានផលចំណេញ។

១៥ ទំពាំងបាយជូរ ធ្វើស្រាយឺនយូរ ឱជារសឆ្ងាញ់
គុណភាពល្អគាប់ ល្អជាប់មិនចាញ់ បរទេសត្រេកត្រអាល
មូលមីរជួបជុំ។

១៦ បាណន់ខ្ញុំអើយ នៅកៀកបង្កើយ ទាក់ទាញរូបខ្ញុំ
មានប្រាង្គប្រាសាទ ល្អស្អាតហើយធំ លើកំពូលភ្នំ
ខ្ពង់ខ្ពស់បំផុត។

១៧ គឺទីនេះហើយ វាលធំល្វឹងល្វើយ អាកាសបរិសុទ្ធ
អារម្មណ៍សប្បាយ ប្រែក្លាយឆ្លងផុត ពីចិត្តស្រយុត
មកស្រស់កាយា។

១៨ យើងរក្សាបាន ផ្ទះខ្មែរបុរាណ កេរពីដូនតា
មានក្បូរក្បាច់ល្អ ឈរអ្រួតសង្ហារ ក្នុងភូមិនោះណា
ឈ្មោះថាវត្តគរ។

១៩ អាងកំពីងពួយ សេកសកលើកស្ទួយ វិស័យទេសចរណ៍
ជ្រលងបុព្វតា សេវាកម្មល្អ ផ្អែមឆ្ងាញ់បវរ
ទុរេនសំឡូត។

២០ កំរៀងភ្នំព្រឹក សំពៅលូនរឭក នឹកឃើញរហូត
ទឹកដីជាយដែន មិនឱ្យរបូត អភិវឌ្ឍស្រួត
ដីខ្មែរដើរកេរ។

២១ កិច្ចការទាំងនេះ គឺជាតម្រេះ ដែលខំរិះរេ
ពីថ្នាក់ដឹកនាំ ខ្លាំងពីបុព្វេ គ្មានស្គាល់ទំនេរ
គ្រប់ៗអាត្មា។

២២ បាត់ដំបងសុះសាយ ទោះខេត្តជិតឆ្ងាយ តែងយល់ច្បាស់ការ
ថ្នាក់ដឹកនាំល្អ ទឹកចិត្តថ្លៃថ្លា បម្រើខេមរា
បានសុខកាយា។

២៣ យើងសូមចងចាំ ទុកជាបណ្តាំ កុំគិតសង្កា
ស្ទួយសមិទ្ធផល តម្កល់ខេមរា ទើបជាតិថ្លៃថ្លា
រុងរឿងបានឆាប់៕

ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ
Journal of Institute of National Language